គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

# ក្រមវិធាន
# គ្រប់គ្រងវិជ្ជាជីវៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

រួមគ្នាដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី

អាសយដ្ឋាន៖ អគារកាច់ជ្រុងផ្លូវ១១២៩ និងផ្លូវ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ០២៣ ៦២២ ៧០ ៧០

អ៊ីមែល info@bakc.org.kh

# កម្រងវិធាន
# គ្រប់គ្រងវិជ្ជាជីវៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

វិជ្ជាជីវៈមេធាវី បានបង្ហាញវត្តមាននៅក្នុងសង្គមកម្ពុជា តាំងពីសម័យអាណានិគមនិយមបារាំង តាមរយៈព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃ៣ ខែម៉ាវ្ស ឆ្នាំ១៩៣២ ស្តីពី«**ចំណាយកែសេចក្តីក្នុងតុលាការខ្មែរ**» ព្រះរាជប្រកាសលេខ១៤ ចុះថ្ងៃ១ ខែហ្វេវ្រីយេរ ឆ្នាំ១៩៣៣ ស្តីពី «**អ្នកចំណាយក្តីត្រូវឱ្យមានសំលៀកបំពាក់**» និងបានកែសម្រួលដោយព្រះរាជក្រមលេខ៦៤៨ ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៥១ ស្តីពី «**វិជ្ជាជីវៈស្មាក្តី**»។

វិជ្ជាជីវៈមេធាវីបានអវត្តមានមួយរយៈ ដោយសារប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអូសបន្លាយជាច្រើនទសវត្សរ៍។ វិជ្ជាជីវៈនេះមានវត្តមានជាថ្មី នៅអំឡុងឆ្នាំ១៩៩២ ដោយក្នុងសម័យនោះ មានបញ្ញត្តិច្បាប់មួយចំនួនដែលកំណត់អំពីសិទ្ធិរបស់មេធាវី ដូចជាមាត្រា ៨៥ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬមាត្រា ៧ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់ការអនុវត្តនៅក្នុងកម្ពុជាក្នុងសម័យអន្តរកាល ប៉ុន្តែមិនមានច្បាប់គ្រប់គ្រងវិជ្ជាជីវៈមេធាវីនោះទេ ហើយជាក់ស្តែងក៏ពុំទាន់មានវត្តមានមេធាវីផងដែរ។ នៅក្រោយការបង្កើតព្រះរាជាណាចក្រកម្ពុជាទី២ ពោលគឺនៅឆ្នាំ១៩៩៥ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតជាផ្លូវការ ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។ ច្បាប់នេះបានទុកសិទ្ធិឱ្យក្រុមប្រឹក្សាគណៈមេធាវី ធ្វើការបំពេញបន្ថែមនូវអត្ថបទក្រោមច្បាប់ សម្រាប់គ្រប់គ្រងការអនុវត្តវិជ្ជាជីវៈនេះ។ កិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាគណៈមេធាវីបានអនុម័តបទបញ្ជាផ្ទៃក្នុងគណៈមេធាវី និងក្រមសីលធម៌មេធាវី ហើយសេចក្តីសម្រេចនានាដែលមានលក្ខណៈជាបទបញ្ជា ក៏ត្រូវបានចេញជាបន្តបន្ទាប់ ដែលមានលក្ខណៈវឌ្ឍនភាពទៅតាមសម័យកាល សម្រាប់ជាវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវី ដោយចូលរួមចំណែកធ្វើយ៉ាងណាឱ្យវិជ្ជាជីវៈមួយនេះ មានភាពល្អប្រសើរ គ្រប់ជ្រុងជ្រោយ និងមានតម្លៃក្នុងសង្គម ក្រោមមូលបទ «**វិជ្ជាជីវៈមេធាវី និងយុត្តិធម៌សង្គម**» ប្រកបដោយអន្តរានិស្សរភាព និងកាលានុវត្តភាព។

មេធាវីទាំងអស់ចាំបាច់ត្រូវយល់ដឹង ប្រតិបត្តិឱ្យបានម៉ឺងម៉ាត់ និងគោរពច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងគណៈមេធាវី ក្រមសីលធម៌មេធាវីនិងសេចក្តីសម្រេចនានាដែលមានលក្ខណៈជាបទបញ្ជារបស់ក្រុមប្រឹក្សាគណៈមេធាវីដែលនៅជាធរមាន។ យ៉ាងណាមិញ ដើម្បីមានភាពងាយស្រួល

ចំពោះការសិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពនូវច្បាប់និងលិខិតបទដ្ឋានទាក់ទងនឹងការគ្រប់គ្រងវិជ្ជាជីវៈមេធាវី **ឯកឧត្តម លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី១៣ និងទី១៤ បានផ្តួចផ្តើមគំនិតក្នុងការរៀបចំនិងចងក្រងសៀវភៅស្តីពី «**កម្រងវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**» ដោយធ្វើការបែងចែកច្បាប់និងលិខិតបទដ្ឋានដែលនៅជាធរមាន និងច្បាប់និងលិខិតបទដ្ឋានដែលត្រូវបានកែតម្រូវ ដោយរាប់បញ្ចូលនូវច្បាប់និងលិខិតបទដ្ឋានដែលត្រូវបាននិរាករណ៍ សម្រាប់ជាប្រទីបធ្វើឱ្យមានភាពងាយស្រួល ក្នុងការស្វែងយល់ សិក្សា ស្រាវជ្រាវ និងចែករំលែកបន្ត ដែលមានលក្ខណៈជាបរិយាបន្ននិងជវភាព។ ក្រុមការងារបានស្រាវជ្រាវវិធានវិជ្ជាជីវៈមេធាវីដែលមាននៅឆ្នាំ១៩៣២ ឆ្នាំ១៩៣៣ និងឆ្នាំ១៩៥១ ហើយបានធ្វើការវាយជាអត្ថបទថ្មីឡើងវិញ ដោយសារឯកសារទាំងនោះ មានសភាពចាស់ និងផ្នែកមួយចំនួនបានបាត់រលុបខ្លះៗ។

ជាទីបញ្ចប់ គណៈមេធាវីសង្ឃឹមថា សហភាតាមេធាវី អ្នកវិជ្ជាជីវៈច្បាប់ដទៃផ្សេងទៀត ក៏ដូចជាសាធារណជន ដែលមានបំណងស្វែងយល់ស៊ីជម្រៅអំពីវិជ្ជាជីវៈមេធាវី នឹងទទួលបានភាពពេញលេញច្បាស់លាស់ និងផ្លូវការ អំពី «**កម្រងវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**» តាំងពីពេលកកើតនូវវិជ្ជាជីវៈមេធាវី រហូតដល់បច្ចុប្បន្ន តាមរយៈសៀវភៅនេះ។

**«រួមគ្នាដើម្បីឧត្តមភាព និងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី»**

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣



**លី ច័ន្ទតុលា**
ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា


## ក. បទដ្ឋានគតិយុត្តដែលមានអានុភាពអនុវត្តជាធរមាន

១. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ........................................................................ ១

២. បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា.......... ២៦

៣. ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២........................................................................................ ៤២

## ខ. សេចក្តីសម្រេចស្តីពីការកែសម្រួលបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី

១. សេចក្តីសម្រេចលេខ ៨០៧/សសគម/២០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា .......................................................... ៧១

២. សេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃ បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា........... ៧៤

## គ. បទដ្ឋានគតិយុត្តដែលលែងមានអានុភាពអនុវត្ត

១. ព្រះរាជប្រកាសលេខ៣២អំពីថណាយកែសេចក្តីក្នុងតុលាការខ្មែរ.. ៧៩

២. ព្រះរាជប្រកាសលេខ១៤អំពីអ្នកថណាយក្តីត្រូវឱ្យមានសំលៀកបំពាក់.. ១១៣

៣. ព្រះរាជក្រមលេខ ៦៤៨ ន.ស ស្តីពីវិជ្ជាជីវៈស្មាក្តី ........................... ១១៤

៤. បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៥...១៤៣

៥. ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៥.................................................................................. ១៦០

៦. ប្រការមួយចំនួននៃបទបញ្ជាផ្ទៃក្នុងគណៈមេធាវីឆ្នាំ២០១៦ដែលត្រូវបាន កែសម្រួល ............................................................................... ១៧៤

៧. សេចក្តីសម្រេចលេខ៣៩៣/សសគម/២០ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ......................................................... ១៧៨

# កំណត់សម្គាល់

ឯកសារបោះពុម្ពនេះ មានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងច្បាប់ដើម៖

១. ខ្លឹមសារនៃអត្ថបទច្បាប់ ត្រូវបានរក្សានៅដដែល។

២. អក្ខរាវិរុទ្ធ ត្រូវបានរក្សាទុកតាមច្បាប់ដើមដដែល។

៣. ដោយឡែក បទបញ្ញាផ្ទៃក្នុង (ឆ្នាំ២០១៦) ដែលមានអានុភាពអនុវត្ត ត្រូវបានបញ្ចូលនូវខ្លឹមសារនៃប្រការមួយចំនួនដែលត្រូវបានកែសម្រួលដោយសេចក្តីសម្រេចដែលមានលក្ខណៈបទបញ្ញារបស់ក្រុមប្រឹក្សាគណៈមេធាវី។ ប្រការដែលបានកែសម្រួល និងសេចក្តីយោង មានបញ្ជាក់នៅក្នុងអត្ថបទបទបញ្ញាផ្ទៃក្នុងនោះ។

# ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី

ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៨៩៥/០៦

# ព្រះរាជក្រម
# យើង
# ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
# រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
# ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
# ព្រះចៅក្រុងកម្ពុជាធិបតី

******

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

-យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

-យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈមេធាវី ដែលមានសេចក្តីទាំងស្រុងដូចតទៅះ

# ច្បាប់ស្តីពី
# លក្ខន្តិកៈមេធាវី
## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.**

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌។

វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមធាវី។

**មាត្រា ២.**

មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់ សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច។

ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ។

**មាត្រា ៣.**

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត។

មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឱ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបាន លុះត្រាតែមានច្បាប់អនុញ្ញាត។

**មាត្រា ៤.**

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត។

មាត្រា ៥.

មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរហើយ អមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។ មេធាវីទាំងនោះពុំអាចតំណាងកូនក្ដីបានឡើយ។

មាត្រា ៦.

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្ដល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ។ ការយល់ព្រមអាចត្រូវដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្ដីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សាគណៈមេធាវី មិនឱ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ ថ្ងៃ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន។ សេចក្ដីសម្រេចនេះអាចប្ដឹងឧទ្ធរណ៍បាន ក្នុងរយៈពេល ២ ខែ ក្រោយពីបានទទួលដំណឹង។

មាត្រា ៧.

មេធាវីបរទេសដែលត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈនេះ ពុំអាចធ្វើសកម្មភាពទាក់ទាញកូនក្ដី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ។

## ជំពូកទី ២
## ការរៀបចំវិជ្ជាជីវៈមេធាវី
### ផ្នែកទី ១
### គណៈមេធាវី

មាត្រា ៨.

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្ដុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មេធាវីម្នាក់ៗត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវីក្រោយពីចុះឈ្មោះក្នុងបញ្ជី គណៈមេធាវី។

មាត្រា ៩.

គណៈមេធាវីត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី។ ប្រធានគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ២ ឆ្នាំ។ អាណត្តិនេះអាចត្រូវបានបន្តតែមួយអាណត្តិទៀតដោយវិធីបោះឆ្នោត។

មាត្រា ១០.

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីមានៈ

-ចំនួន ៥ នាក់ ក្នុងករណីគណៈមេធាវី មានសមាជិកមិនលើសពី ៣០ នាក់

-ចំនួន ៩ នាក់ បើមានសមាជិកពី ៣១ នាក់ ទៅ ៥០ នាក់

-ចំនួន ១៣ នាក់ បើមានសមាជិកពី ៥១ នាក់ទៅ ២០០ នាក់

-ចំនួន ១៩ នាក់ បើមាន សមាជិកពី ២០១ នាក់ ទៅដល់ ៥០០ នាក់

-ចំនួន ២៧ នាក់ បើមានសមាជិកពី ៥០១ នាក់ទៅ ១.០០០ នាក់

-ចំនួន ៣៣ នាក់ បើមានសមាជិកលើសពី ១០០១ នាក់។

មាត្រា ១១.

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៣ ឆ្នាំ។ អាណត្តិនេះអាចបន្តម្តងទៀតបាន ប៉ុន្តែមិនអាចបន្តភ្ជាប់ពីចប់អាណត្តិភ្លាមនោះទេ។ ផុតរយៈពេល ៣ ឆ្នាំ ក្រោយពីចប់អាណត្តិ ទើបអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន។ ប្រធានគណៈមេធាវី អាចត្រូវបានបោះឆ្នោតជ្រើសតាំងឱ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីបានក្រោយបានចប់អាណត្តិរបស់ខ្លួន ដោយមិនបាច់រង់ចាំផុតរយៈពេល ៣ ឆ្នាំទេ។

មាត្រា ១២.

បើប្រធានគណៈមេធាវី ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាគណៈមេធាវីទទួលមរណភាពឬឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន នោះត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងអ្នកជំនួស ដើម្បីបញ្ចប់អាណត្តិនោះ។

មាត្រា ១៣.

គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការសាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ។

ការសម្តែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់។

គណៈមេធាវីមានថវិកាស្វយ័ត ប៉ុន្តែមិនអាចធ្វើសកម្មភាពយកផលចំណេញបានឡើយ។

## ផ្នែកទី ២

## ការបោះឆ្នោត

មាត្រា ១៤.

ប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ក្នុងមហាសន្និបាតនៃគណៈមេធាវី។ អ្នកដែលមានសិទ្ធិបោះឆ្នោត គឺមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្ម វិន័យណាមយឡើយ ។

មាត្រា ១៥.

អ្នកដែលអាចឈរឈ្មោះឱ្យគេបោះឆ្នោត ជ្រើសតាំងជាប្រធានគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ៣ ឆ្នាំ យ៉ាងតិច ហើយដែលឥត បានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ។

អ្នកដែលអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមធាវីបានរយៈពេល ២ ឆ្នាំយ៉ាងតិចហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតទាំងនោះ។

មាត្រា ១៦.

ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយមហាសន្និបាតនៃគណៈមេធាវី ២ ឆ្នាំម្តង ចំពោះប្រធានគណៈមេធាវី និង ៣ ឆ្នាំម្តង ចំពោះសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី។

ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តជាសម្ងាត់ និងជាឯកនាមហើយអាចធ្វើជាពីរលើកបាន។ ការបោះឆ្នោតលើកទី១ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើនដាច់ខាតនៃសមាជិកគណៈមេធាវី

ទាំងមូល និងលើកទី ២ ដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសម្លេងស្មើគ្នា មេធាវីដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង។

មាត្រា ១៧.

បែបបទនៃការបោះឆ្នោត ការកោះអញ្ជើញមករួមប្រជុំ និងកូរ៉ុមត្រូវបានកំណត់ ដោយបទបញ្ជាផ្ទៃក្នុង។ មេធាវីដែលមានសិទ្ធិបោះឆ្នោត ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្ដឹងតវ៉ាអំពីការបោះឆ្នោតនេះ ទៅសាលាឧទ្ធរណ៍បាន។

ពាក្យបណ្ដឹងនេះ ត្រូវធ្វើឡើងដោយមេធាវីក្នុងរយៈពេល ១៥ ថ្ងៃក្រោយការបោះឆ្នោត ឬដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈរយៈពេល ១៥ ថ្ងៃគិតពីថ្ងៃទទួល ដំណឹងស្ដីពីលទ្ធផលនៃការបោះឆ្នោតនោះ។

## ផ្នែកទី ៣
## មហាសន្និបាត

មាត្រា ១៨.

មហាសន្និបាតសាមញ្ញនៃគណៈមេធាវីប្រព្រឹត្តទៅមួយឆ្នាំម្ដង ដែលផ្ដើមធ្វើឡើងដោយប្រធានគណៈមេធាវីតាមរបៀបវារៈដែល ត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

មហាសន្និបាតអាចធ្វើសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ ខែ។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន បើមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីចំនួន៣០% បានស្នើសុំដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។

## ផ្នែកទី ៤
## ក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ១៩.

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តន៍វិជ្ជាជីវៈមេធាវី។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ចនិងការពារសិទ្ធិរបស់មេធាវី។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចជាអាទិ៍ ដូចតទៅ៖

-ធ្វើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌

-សំរេចឱ្យចុះឈ្មោះធ្វើកម្មសិក្សា និងចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី

-សំរេចលើការស្នើសុំអនុញ្ញាតទាំងឡាយដែលធ្វើឡើងដោយមេធាវី

-ពិនិត្យកិច្ចព្រមព្រៀងនិងឯកសារទាំងឡាយដែលមេធាវីមានកាតព្វកិច្ចត្រូវដាក់ឱ្យពិនិត្យ ហើយបញ្ចេញមតិណែនាំលើកិច្ចព្រមព្រៀង និងឯកសារ ទាំងនោះ

-ត្រួតពិនិត្យការកាន់កាប់ទៀងទាត់នៃបញ្ជីគណៈនេយ្យរបស់មេធាវី

-ធានាការគោរពវិន័យ និងការដាក់វិន័យ

-ធានារ៉ាប់រងការរៀបចំ និងការគ្រប់គ្រងសេវាទូទៅរបស់គណៈមេធាវី

-គ្រប់គ្រងទ្រព្យសម្បត្តិ និងថវិការបស់គណៈមេធាវី កំណត់ចំនួនទឹកប្រាក់ភាគទានរបស់មេធាវីម្នាក់ៗ និងបង់ប្រាក់ធានារ៉ាប់រងសំរាប់វិជ្ជាជីវៈមេធាវី

-គ្រប់គ្រងបេឡានៃមូលនីធិរបស់គណៈមេធាវី

-បញ្ចេញមតិលើបញ្ហាទាំងឡាយដែលទាក់ទងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវីក្នុងវិស័យការពារ ជាអាទិ៍នៅពេលដែលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ។

មាត្រា ២០.

ក្រុមប្រឹក្សាគណៈមេធាវីអាចរួមប្រជុំបាន លុះត្រាតែមានសមាជិករបស់ខ្លួនចូលរួមលើសពីពាក់កណ្តាល។ ក្រុមប្រឹក្សាគណៈមេធាវីសំរេចសេចក្តីតាមមតិភាគច្រើន។

មាត្រា ២១.

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមានលក្ខណៈជាបទបញ្ជា ត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានចុះសេចក្តីថាបានទទួល។ ចំពោះសេចក្តីសំរេចដាក់វិន័យក៏ដូចជាសេចក្តីសំរេចលើការចុះឈ្មោះ ឬការសុំឱ្យនៅក្រៅបញ្ជីរបស់មេធាវី ក៏ត្រូវធ្វើដូច្នេះដែរ។ សេចក្តីសំរេចចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវផ្តល់ជាពត៌មានដល់សមាជិកនៃគណៈមេធាវី តាមមធ្យោបាយសមស្រប។

មាត្រា ២២.

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីលើមេធាវីណាម្នាក់ ត្រូវជូនដំណឹងទៅមេធាវីនោះតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល។

មាត្រា ២៣.

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមិនមែនជាមុខនាទីរបស់ខ្លួនឬផ្ទុយនឹងបទបញ្ញត្តិច្បាប់ជាធរមានឬបទបញ្ជាអាចត្រូវបដិសេធចោល ដោយសាលាឧទ្ធរណ៍ក្រោយពីមានការប្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

មាត្រា ២៤.

មេធាវីអាចប្តឹងអំពីសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលធ្វើឱ្យខាតប្រយោជន៍ដល់វិជ្ជាជីវៈរបស់ខ្លួនបាន។ បើសេចក្តីសំរេចឥតត្រូវបានឱ្យដំណឹងដល់មេធាវី មេធាវីនោះត្រូវសុំឱ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យសេចក្តីសំរេចនោះសាជាថ្មីម្តងទៀតមុននឹងប្តឹង។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវសំរេចលើសេចក្តីស្នើសុំនោះក្នុងរយៈពេល ២ ខែ ក្រោយពីបានអញ្ជើញមេធាវីនោះឱ្យបញ្ចេញយោបល់របស់ខ្លួន។ សេចក្តីសំរេចថ្មីត្រូវបានជូនដំណឹងទៅសាមីខ្លួន។ បើគ្មានការសំរេចសាជាថ្មីក្នុងរយៈពេលដូចកំណត់ខាងលើនេះទេ ត្រូវចាត់ទុកសេចក្តីសំរេចមុននោះជាអសាបង់។

មាត្រា ២៥.

ពាក្យបណ្តឹងទាំងឡាយមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍។ គេអាចដាក់ពាក្យបណ្តឹងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល។ រយៈពេលប្តឹងឧទ្ធរណ៍គឺ ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង។

មាត្រា ២៦.

ក្រុមប្រឹក្សាគណៈមេធាវី ត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យនិងផ្សព្វផ្សាយជាសាធារណៈជារៀងរាល់ឆ្នាំ នូវរបាយការណ៍លំអិតស្តីពីសកម្មភាពការងាររបស់គណៈមេធាវី។ ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបង្ហាញស្ថានភាពហិរញ្ញវត្ថុនិងផ្តល់ព័ត៌មានផ្សេងៗជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បើមានសំណូមពរពីក្រសួងនេះ។

## ជំពូកទី ៥
## ប្រធានគណៈមេធាវី

មាត្រា ២៧.

ប្រធានគណៈមេធាវីមានតួនាទី៖

-ជាអ្នកដឹកនាំគណៈមេធាវី

-ជាអធិបតីនៃមហាសន្និបាតគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី

-ជាអ្នកធានាផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិកទាំងអស់

-ជាអ្នកផ្សះផ្សា ហើយបើមានការចាំបាច់និងតាមសំណើរបស់គូក្តី ធ្វើអាជ្ញាកណ្តាលក្នុងវិវាទដែលកើតឡើងរវាងមេធាវីនិងមេធាវី រវាងមេធាវីនិងអតិថិជន

-ជាតំណាងវិជ្ជាជីវៈមេធាវីចំពោះមុខតតិយជននិងអាជ្ញាធរសាធារណៈ

-ជាតំណាងគណៈមេធាវីក្នុងរឿងក្តីដែលទាក់ទងគណៈមេធាវី ក្រោយពីមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី។

ក្នុងការបោះឆ្នោត សំឡេងរបស់ប្រធានគណៈមេធាវីឥតមានឧត្តមានុភាពទេ។

មាត្រា ២៨.

ប្រធានគណៈមេធាវីអាចផ្ទេរអំណាចណាមួយ ឬអំណាចទាំងអស់ទៅឱ្យសមាជិកណាម្នាក់ ឬច្រើននាក់នៃក្រុមប្រឹក្សាគណៈមេធាវីបាន ក្នុងរយៈពេលមានកំណត់។

ក្នុងករណីមានធុរៈ ប្រធានគណៈមេធាវីត្រូវជំនួសដោយសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីដែលមានវ័យចាស់ជាងគេ។

## ជំពូកទី ៦
## មូលនីធិនៃគណៈមេធាវី

មាត្រា ២៩.

មូលនីធិនៃគណៈមេធាវីបានមកពីការបង់ភាគទាននៃសមាជិកទាំងអស់ និងវិភាគទានផ្សេងៗ។ នៅក្នុងមូលនីធិនេះត្រូវបង្កើតឱ្យមានបេឡាពិសេសមួយសំរាប់ផ្តល់ប្រាក់កំរៃ ដល់មេធាវីដែលការពារជនក្រីក្រ ។

បេឡាពិសេសនេះអាចទទួលអំណោយ ឬប្រាក់ជំនួយដែលឯកជន អង្គការអន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឱ្យដើម្បីការពារជនក្រីក្រ។

មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារជនក្រីក្រ តាមបែបបទនៃបទបញ្ជាផ្ទៃក្នុងហើយឱ្យដូចជាជួយការពារអតិថិជនរបស់ខ្លួន។

មាត្រា ៣០.

ដែលហៅថាជនក្រីក្រ គឺជនដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូលឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព។

ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន។

## ជំពូកទី ៣
## ការឧទ្ទលឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី បញ្ជីគណៈមេធាវី
## ផ្នែកទី ១
## ល័ក្ខខ័ណ្ឌ

មាត្រា ៣១.

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ៖

១.ត្រូវមានសញ្ជាតិជាខ្មែរ

២.ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល

៣.ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឱ្យដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

៤.មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ

ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

មាត្រា ៣២.

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់៖

-ចៅក្រម ដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ។

មិនចាំបាច់មានវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈមេធាវី៖

-អ្នកមានបរិញ្ញាប័ត្រច្បាប់ ហើយដែលបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ ឆ្នាំ

-មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ

-អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់។

## ផ្នែកទី ២
## ការឧទ្ទលឱ្យប្រកបវិជ្ជាជីវៈមេធាវី

មាត្រា ៣៣.

ការយល់ព្រមឱ្យប្រកបវិជ្ជាជីវៈមេធាវី ត្រូវសំរេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីបានត្រួតពិនិត្យលើការបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ដែលមានកំណត់ក្នុងច្បាប់នេះនិងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

សេចក្តីសំរេចត្រូវឱ្យដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រម ដោយគ្មានការកោះអញ្ជើញសាមីខ្លួនឱ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច ១០ ថ្ងៃ បានឡើយ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានសេចក្តីបញ្ជាក់ថាបានទទួល។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ។

មាត្រា ៣៤.

មេធាវីដែលត្រូវបានទទួលឱ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយដែលមានសេចក្តីដូចតទៅ៖

«ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា» ។

## ផ្នែកទី ៣

## កម្មសិក្សា

មាត្រា ៣៥.

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ តាមបែបបទដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី លើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឱ្យរួចផុតពីកម្មសិក្សា។ បែបបទនៃកម្មសិក្សាមានជាអាទិ៍ដូចតទៅ៖

-ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី

-ត្រូវចូលរួមបំរើការងារឱ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ។

មាត្រា ៣៦.

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ។

មាត្រា ៣៧.

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីដោយផ្អែកលើរបាយការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា។ ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចឱ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឱ្យលើសពី ១ ឆ្នាំ ឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមធាវី ចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជី ឬការ បន្តកម្មសិក្សា ពុំអាចធ្វើទៅបានឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួនឱ្យមកបញ្ចេញយោបល់ តាមល័ក្ខខ័ណ្ឌដែលមាន

ចែងក្នុងមាត្រា ៣៣ សេចក្ដីសំរេចនេះអាចនឹងប្ដឹងតវ៉ាបានតាមល័ក្ខខ័ណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រា ២៤ និង ២៥។

មាត្រា ៣៨.

រៀលរាល់ឆ្នាំ ក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសិក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្ដីទាំងអស់។

បញ្ជីនោះមានដូចតទៅ ៖

-ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី និងអាស័យដ្ឋានរបស់មេធាវីនោះ

-ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា

មាត្រា ៣៩.

លេខរៀងនៃការចុះឈ្មោះរបស់មេធាវីត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធាន ហើយត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាគណៈមេធាវី ដែលបានសំរេចឱ្យចុះឈ្មោះ។

## ផ្នែកទី ៤
## ការដាក់នៅក្រៅបញ្ជី

មាត្រា ៤០.

ដោយមានមូលហេតុសមស្រប មេធាវីអាចសុំនៅក្រៅបញ្ជីនៃគណៈមេធាវីបាន សំរាប់រយៈពេលពីរឆ្នាំម្ដងៗជាអតិបរមា។

មាត្រា ៤១.

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជី បើមេធាវីនោះ ស្ថិតនៅក្នុងស្ថានភាពវិសមិតភាព ឬបើមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈ របស់ខ្លួនបាន ។

ក្នុងករណីមានបណ្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចខាងលើនោះ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣។

មាត្រា ៤២.

មេធាវីដែលត្រូវបានដាក់ឱ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ចទាំងឡាយដែលទាក់ទងទៅនឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី។

ការដាក់ឱ្យនៅក្រោមបញ្ញើពុំអាចរារាំងការចោទប្រកាន់ខាងវិន័យឡើយ។

## ផ្នែកទី ៤
## ងារជាមេធាវីកិត្តិយស

មាត្រា ៤៣.

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្ដល់ងារជាមេធាវីកិត្តិយសជូនមេធាវីដែលឈប់ប្រកបវិជ្ជាជីវៈមេធាវី ក្រោយពីបានប្រកបវិជ្ជាជីវៈរយៈពេល ១៥ ឆ្នាំយ៉ាងតិច។

មាត្រា ៤៤.

មេធាវីកិត្តិយសនៅតែជាសមាជិកនៃគណៈមេធាវីដដែល ហើយអាចចូលរួមក្នុងមហាសន្និបាតមេធាវី មានសិទ្ធិផ្ដល់យោបល់ ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗ។

ដោយឡែក មេធាវីកិត្តិយសអាចផ្ដល់យោបល់ដល់អតិថិជន ហើយអាចត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ជាអ្នកសម្រុះសម្រួល ឬជាអ្នកអាជ្ញាកណ្ដាល។

មាត្រា ៤៥.

ក្រុមប្រឹក្សាគណៈមេធាវី អាចដកហូតងារជាមេធាវីកិត្តិយសនេះបាន បើមានហេតុដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្ដីថ្លៃថ្នូររបស់មេធាវីនោះ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុងមាត្រា ៣៣។

## ជំពូកទី ៤
## បែបបទនៃការប្រកបវិជ្ជាជីវៈ
## ផ្នែកទី ១
## ការប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តជន ឬជាសមូហភាព

មាត្រា ៤៦.

មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន ឬនៅក្នុងក្របខ័ណ្ឌជាក្រុម ឬក្រុមហ៊ុនមេធាវីណាមួយដែលបង្កើតឡើងត្រឹមត្រូវតាមច្បាប់។

ក្រុមហ៊ុននេះត្រូវមានលក្ខណៈជាក្រុមហ៊ុនស៊ីវិល ហើយមានសុទ្ធតែមេធាវីជាសមាជិក។ មេធាវីកិត្តិយសអាចនៅជាសមាជិកនៃក្រុមហ៊ុនដើមរបស់ខ្លួនបាន។

សិទ្ធិវន្ត គឺអ្នកដែលមានសិទ្ធិទទួលមរតកពីមេធាវី ដែលបានទទួលមរណភាពអាចបន្តកាន់កាប់ភាគហ៊ុននោះបានក្នុងរយៈពេល ៣ ឆ្នាំជាអតិបរមា។ ផុតរយៈពេល ៣ ឆ្នាំ នោះត្រូវលក់ភាគហ៊ុននោះទៅឱ្យមេធាវីណាម្នាក់ឬទៅឱ្យក្រុមហ៊ុននោះវិញ។

មាត្រា ៤៧.

ក្រុម និងក្រុមហ៊ុនមេធាវីទាំងឡាយ ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រប់គ្រងក្រុមនិងក្រុមហ៊ុន លើកលែងតែបទបញ្ញត្តិនៃបទបញ្ជានោះប៉ះពាល់ដល់គោលការណ៍គ្រប់គ្រងវិជ្ជាជីវៈមេធាវី។

មាត្រា ៤៨.

មេធាវីទាំងឡាយ ត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងជាមួយសមាជិកនៃវិជ្ជាជីវៈសេរីដទៃទៀត ដើម្បីប្រមូលផ្ដុំមធ្យោបាយជាមួយគ្នា។ ការធ្វើកិច្ចព្រមព្រៀងនេះមិនត្រូវឱ្យប៉ះពាល់ដល់វិធាននៃវិជ្ជាជីវៈមេធាវី ជាអាទិ៍ប៉ះពាល់ដល់ការគោរពការសម្ងាត់នៃវិជ្ជាជីវៈនេះ។

មាត្រា ៤៩.

រាល់កិច្ចព្រមព្រៀងដែលមេធាវីខ្មែរណាម្នាក់បានចុះជាមួយមេធាវីខ្មែរណាម្នាក់ទៀត ឬជាមួយមេធាវីបរទេស ឬក៏ជាមួយសមាជិកនៃវិជ្ជាជីវៈសេរីណាមួយ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ហើយជូនពត៌មានដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្នុងករណីនេះត្រូវអនុវត្ត នីតិវិធីដែលមានចែងក្នុងមាត្រា ៣៣។

## ផ្នែកទី ២
## កិច្ចសហការ

មាត្រា ៥០.

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងលក្ខណៈជាសហការីរបស់មេធាវីម្នាក់ទៀត។

មាត្រា ៥១.

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាគា។ គេពុំអាចបំពេញកិច្ចការបានទេ បើគ្មានការយល់ព្រមពីសហភាគា ប៉ុន្តែគេមានសិទ្ធិពេញទីក្នុងការជ្រើសរើសមធ្យោបាយធ្វើការងាររបស់គេ។ គេអាចសុំមិនទទួលបំពេញ បេសកកម្មណាមួយ ដែលគេយល់ថាផ្ទុយ នឹងសម្បជញ្ញៈរបស់គេ។

មាត្រា ៤២.

ក្នុងករណីណាក៏ដោយ កិច្ចសហការមិនអាចរារាំងមិនឱ្យសហការីមេធាវីបង្កើតការិយាល័យផ្ទាល់របស់គេ ឬរារាំងមិនឱ្យគោរពកាតព្វកិច្ចនិងវិធាននៃវិជ្ជាជីវៈមេធាវីបានឡើយ។ គេធ្វើការក្នុងនាមគេផ្ទាល់ កាលណាគេការពារកូនក្តីគេផ្ទាល់ខ្លួន។

កិច្ចសន្យានៃកិច្ចសហការត្រូវរៀបចំឡើង ហើយផ្ញើជូនក្រុមប្រឹក្សាគណៈមេធាវី។

## ជំពូកទី ៤
## វិធាននៃវិជ្ជាជីវៈ បទវិន័យ
## ផ្នែកទី ១
## វិសមិតភាព

មាត្រា ៤៣.

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរពាណិជ្ជកម្ម ទោះការប្រកបនោះដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី។

មាត្រា ៤៤.

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិ ជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ។

មាត្រា ៤៥.

មេធាវីដែលជាអតីតមន្ត្រីរាជការ អាចធ្វើបទអន្តរាគមន៍ការពារកូនក្តីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន។

## ផ្នែកទី ២
## បទវិន័យ

មាត្រា ៤៦.

វិធាននៃវិជ្ជាជីវៈមេធាវី ត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី។ វិធាននេះជានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន។

មាត្រា ៤៧.

គ្រប់អំពើទាក់ទាញ ប្រកាសផ្សាយជាឯកត្តជន ឬទទូចសុំការពាររបស់មេធាវី ចំពោះអតិថិជនត្រូវហាមឃាត់។

មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឱ្យធ្វើបាន។ ការប្រកាសផ្សាយនេះ ត្រូវធ្វើឱ្យបានត្រឹមត្រូវ ហើយមិនត្រូវឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មេធាវីឡើយ។

មាត្រា ៤៨.

មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត។ មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក។

មេធាវីពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាច ត្រូវបានបង្ខំឱ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួន ទោះបីនៅមុខតុលាការក៏ដោយ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជន ផ្ញើទាក់ទងគ្នា។

## ផ្នែកទី ៣
## ទណ្ឌកម្មជាបទវិន័យ

មាត្រា ៤៩.

ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ។

មាត្រា ៦០.

ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្រុមប្រឹក្សាគណៈមេធាវីចាត់មេធាវីម្នាក់ឱ្យធ្វើជាអ្នករាយការណ៍។ ការប្តឹងត្រូវជូនដំណឹងជាមុនទៅសាមីខ្លួនដែលត្រូវដឹងពីសំណុំរឿងនៃការប្តឹងនោះ និងអាចបញ្ចេញយោបល់ការពារខ្លួនបាន។ បើមានការស៊ើបអង្កេត ក៏ត្រូវផ្តល់ពត៌មាននោះទៅសាមីខ្លួនដែរ។ របាយការណ៍ត្រូវផ្ញើជូនសាមីខ្លួន

ជាមួយនឹងលិខិតកោះអញ្ជើញ ហើយសំណុំរឿងក៏ត្រូវដាក់ឱ្យសាមីខ្លួនពិនិត្យដែរ។ លិខិតកោះអញ្ជើញត្រូវតែផ្ញើតាមលិខិតអនុសិដ្ឋដោយមានចុះសេចក្តីថា បានទទួល ឬជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងតិចមុនថ្ងៃប្រជុំ ។ សាមីខ្លួនអាចជ្រើសរើសយកមេធាវីម្នាក់ឱ្យការពារខ្លួនបាន។ ប៉ុន្តែសាមីខ្លួនពុំអាចអវត្តមានដោយឱ្យជនណាម្នាក់ធ្វើជាតំណាងជួសខ្លួនបានឡើយ បើគ្មានការអនុគ្រោះយល់ព្រមជាពិសេស ជាមុន ដោយមានមូលហេតុសមស្របទេ។

បើគ្មានការឆ្លើយតបទៅនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ឬរបស់តតិយជនក្នុងរយៈពេល ២ ខែទេ ការមិនឆ្លើយតបពីក្រុមប្រឹក្សាគណៈមេធាវីត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ខែ ចាប់ពីថ្ងៃផុតរយៈពេល ២ ខែខាងលើ។

មាត្រា ៦១.

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានមូលហេតុច្បាស់លាស់ ត្រូវបានជូនដំណឹងទៅសាមីខ្លួន និងអគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេចតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានចុះសេចក្តីថាបានទទួល។

មាត្រា ៦២.

ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយសាមីខ្លួន ឬដោយអគ្គព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ក្នុងចិរៈវេលា និងតាមទម្រង់ដែលមានចែងក្នុងមាត្រា ២៥។ បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជំរះជាសម្ងាត់ លើកលែងតែមានសេចក្តីសំរេចផ្ទុយពីនេះរបស់សាលាឧទ្ធរណ៍ តាមការស្នើសុំច្បាស់លាស់ពីមេធាវីដែលត្រូវចោទ។ គណៈមេធាវីមិនមែនជាភាគីក្នុងរឿងក្តីនេះទេ ប៉ុន្តែប្រធានគណៈមេធាវីត្រូវតែបញ្ចេញយោបល់កត់សំគាល់របស់ខ្លួន ហើយអគ្គព្រះរាជអាជ្ញាត្រូវធ្វើការសន្និដ្ឋាននៅពេលនោះ។

មាត្រា ៦៣.

ទណ្ឌកម្មជាបទវិន័យ មានដូចតទៅ ៖

-ការព្រមាន

-ការស្តីបន្ទោស

-ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ២ ឆ្នាំ

-ការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការហូតងារកិត្តិយស។

មាត្រា ៦៤.

ទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលអាចព្យួរបាន។ ប៉ុន្តែបើក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីបានប្រកាសទោសព្យួរនេះ មេធាវីនោះត្រូវបានផ្តន្ទាទោសវិន័យថ្មីមួយទៀត ក្នុងករណីនេះ ត្រូវអនុវត្តទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈដោយយកទោសថ្មីទៅបូកជាមួយទោសចាស់ដែលបានព្យួរ។

មាត្រា ៦៥.

គ្រប់ទណ្ឌកម្ម អាចត្រូវបានបន្ថែមទណ្ឌកម្មហាមឃាត់មិនឱ្យបំពេញជាប្រធានគណៈមេធាវី ឬជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ។ សេចក្តីសំរេចដាក់ទណ្ឌកម្មនេះត្រូវកំណត់ផងដែរ អំពីការផ្សាយជាសាធារណៈ បើជាការចាំបាច់ត្រូវផ្សាយ។

មាត្រា ៦៦.

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្អាកពីមុខងារជាបណ្តោះអាសន្ន ចំពោះមេធាវីណា ដែលបានត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬបទវិន័យណាមួយដោយបញ្ញត្តិ ឬតាមបណ្តឹងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បើគ្មានសេចក្តីសំរេចពីក្រុមប្រឹក្សាគណៈមេធាវីឆ្លើយតបទៅនឹងការការប្តឹងរបស់អគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ២០ ថ្ងៃ នោះនឹងត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។

មាត្រា ៦៧.

ការផ្អាកពីមុខងារជាបណ្តោះអាសន្នពុំអាចសំរេចបានឡើយ បើគ្មានការកោះអញ្ជើញសាមីខ្លួនឱ្យចូលមកបញ្ចេញយោបល់របស់ខ្លួន។ ការកោះអញ្ជើញត្រូវធ្វើឡើងតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថា បានទទួល ហើយដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៥ ថ្ងៃ មុនថ្ងៃប្រជុំ។ ការផ្អាកពីមុខងារជាបណ្តោះអាសន្ន អាចត្រូវប្តឹងឧទ្ធរណ៍បានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦២។ ការប្តឹងឧទ្ធរណ៍ពុំអាចផ្អាកការអនុវត្តន៍សេចក្តីសំរេចខាងលើបានឡើយ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធានា និងឃ្លាំមើលការអនុវត្តន៍ទណ្ឌកម្មខាងវិន័យ និងការផ្អាកពីមុខងារជាបណ្តោះអាសន្ន។

## ផ្នែកទី ៤
## កំរៃ

### មាត្រា ៦៨.

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារ តាមទំហំសមត្ថភាពដែលបានបញ្ចេញក្នុងការងារនោះ តាមការលំបាកនៃការងារ តាមលទ្ធផលដែលសំរេចបាន ឬតាមតារាងប្រាក់ម៉ោងកំណត់ដោយគណៈមេធាវីរៀងរាល់ឆ្នាំ។ មេធាវីត្រូវចេញបង្កាន់ដៃ ឱ្យអតិថិជននៅពេលបានប្រាក់កំរៃ។

### មាត្រា ៦៩.

ការតវ៉ាអំពីកំរៃ ក្រៅពីប្តឹងទៅតាមនីតិវិធីរដ្ឋប្បវេណី អាចប្តឹងទៅប្រធានគណៈមេធាវីជាអាជ្ញាកណ្តាលសំរេចបាន បើមានការយល់ព្រមពីភាគីទំនាស់។ សេចក្តីសំរេចត្រូវឱ្យដំណឹងទៅសាមីខ្លួន តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល។ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ២ ខែ ក្រោយថ្ងៃទទួលបណ្តឹង។ ពាក្យបណ្តឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬផ្ញើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានចុះសេចក្តីថាបានទទួល។ បណ្តឹងឧទ្ធរណ៍នេះត្រូវជំនុំជំរះដោយប្រធានសាលាឧទ្ធរណ៍ ឬដោយអ្នកទទួលសិទ្ធិពីប្រធានសាលាឧទ្ធរណ៍។

## ជំពូកទី ៦
## គណនេយ្យ-ការប្រើប្រាស់មូលនិធិ
## ការធានា–ធ្វាក់ធានារ៉ាប់រង

### មាត្រា ៧០.

មេធាវីដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវី មិនអាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់មូលនីធិរបស់អតិថិជន ឬមូលនីធិទុកសំរាប់អតិថិជនក្នុងពេលដែលខ្លួនបំពេញបេសកកម្មឱ្យអតិថិជនទេ។ មូលនីធិនេះបានមកពីប្រាក់ធានាក្តី និងបានមកពីប្រាក់សំណងដែលឈ្នះក្តី។ មេធាវីត្រូវដាក់មូលនីធិនេះក្នុងគណនីពិសេសមួយដែលបើកឡើងដោយគណៈមេធាវី ហើយមានឈ្មោះថា «បេឡាទូទាត់របស់គណៈមេធាវី»។

មេធាវីពុំអាចរក្សាទុកមូលនីធិនេះនៅក្នុងបេឡានោះឱ្យលើសពីថិរៈវេលាចាំបាច់ ដើម្បីសំរេចកិច្ចការដែលអតិថិជនប្រគល់ឱ្យនោះទេ។ គេពុំអាចកាត់យកកំរៃដែលគេត្រូវទទួល ក្នុងការសំរេចលទ្ធផលការងារពីមូលនីធិខាងលើនេះឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន។

មេធាវីអាចយកមូលនីធិដែលអតិថិជនបានតម្កល់ទុកសំរាប់បង់ប្រដាប់ក្តី និងកំរៃអ្នកជំនួយការយុត្តិធម៌ទៅបង់ជំនួសអតិថិជនបាន។

មាត្រា ៧១.

មេធាវីអាចត្រូវបានតែងតាំងជាអ្នកទទួលទុកបញ្ញើ តាមការព្រមព្រៀងពីភាគី ឬពីចៅក្រម។ កិច្ចព្រមព្រៀង ឬសេចក្តីសំរេចអំពីការទទួលទុកបញ្ញើត្រូវកំណត់បែបបទ ជាពិសេស បែបបទនៃការប្រាក់ ព្រមទាំងបែបបទបញ្ចប់ទទួលទុកបញ្ញើ។ មូលនីធិ ឬវត្ថុទាំងឡាយ ត្រូវរក្សាទុកក្នុងបេឡាទូទាត់របស់គណៈមេធាវី ។

មាត្រា ៧២.

មេធាវីត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុង។ ការទូទាត់ប្រើមូលនីធិ ឬវត្ថុបញ្ញើត្រូវធ្វើឡើងក្នុងគណនយ្យ មួយដោយឡែក។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួនប្រសិនបើមាន ដល់អ្នកត្រួតពិនិត្យ ចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៧៣.

មេធាវី ត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវី សំរាប់ ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនីធិ និងរបស់មានតម្លៃទាំងឡាយដែលខ្លួនបានទទួលទុក។ ប្រាក់ធានានោះត្រូវគិតបញ្ចូលក្នុងប្រាក់បង់វិភាគទាន ដែលកំណត់ដោយគណៈមេធាវី។

## ជំពូកទី ៧
## ការជំនួស ការដោះរដ្ឋបាល

មាត្រា ៧៤.

មេធាវីដែលអាក់ខានប្រកបវិជ្ជាជីវៈរបស់ខ្លួនជាបណ្តោះអាសន្ន អាចចាត់តាំង អ្នកជំនួសម្នាក់ដោយមានការយល់ព្រមពីប្រធានគណៈមេធាវី។ បើគ្មានការចាត់តាំងជំនួសទេនោះ ប្រធាន

គណៈមេធាវីចាត់តាំងអ្នកជំនួសដោយបញ្ញត្តិ។

មាត្រា ៧៥.

សេចក្តីសំរេចហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈកាល ឬផ្អាកការប្រកបវិជ្ជាជីវៈជាបណ្តោះអាសន្ន ឬដាក់នៅក្រៅបញ្ជីគណៈមេធាវី ត្រូវចាត់តាំងមេធាវីម្នាក់ឱ្យគ្រប់គ្រងការិយាល័យមេធាវីជំនួស។ បើអ្នកគ្រប់គ្រងការិយាល័យនោះមានធុរៈ ប្រធានគណៈមេធាវីត្រូវចេញសេចក្តីសំរេចចាត់តាំងអ្នកជំនួស។

មាត្រា ៧៦.

បើមេធាវីម្នាក់ទទួលមរណភាព ឬឈប់ប្រកបវិជ្ជាជីវៈរបស់ខ្លួន ប្រធានគណៈមេធាវីចាត់តាំងមេធាវីម្នាក់ឱ្យទទួលបន្ទុកចាត់ការលើសំណុំរឿង ដែលនៅសល់ និងជម្រះបញ្ជីគណនេយ្យ រួចបិទការិយាល័យ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

មាត្រា ៧៧.

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១ ២ ៣ ៤ ៥ ៦ ៧ ១៣ និង ៥៧ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀលទៅដល់ ៥.០០០.០០០ រៀល។ បើបទល្មើសនោះ ប្រព្រឹត្តឡើងដោយជនបរទេស ជននោះអាចត្រូវបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាថែមទៀត។

ក្នុងករណីមិនរាងចាល ត្រូវពិន័យទ្វេមួយជាពីរ និងអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ដល់ ៦ ខែ។

បើមានបទល្មើសខាងលើនេះ ក្រុមប្រឹក្សាគណៈមេធាវីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។

មាត្រា ៧៨.

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ។

# ជំពូកទី ៩
# អន្តរប្បញ្ញត្តិ

មាត្រា ៧៩.

តួនាទីការពារកូនក្ដីរបស់មេធាវីក្នុងរឿងព្រហ្មទណ្ឌអាចត្រូវបំពេញបានដោយអ្នកការពារក្ដី ដែលមិនមែនជាមេធាវី តាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

មាត្រា ៨០.

អាចត្រូវបានជ្រើសរើសឱ្យប្រឡងចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលមេធាវី ៖

-អ្នកការពារកូនក្ដីដែលមានលទ្ធភាពបំពេញមុខងារនេះ ហើយដែលបំពេញមុខងារនេះពិតប្រាកដ និងជាប់រហូត ២ ឆ្នាំមក នៅតាមតុលាការខេត្ត ក្រុង។

អ្នកការពារកូនក្ដីទាំងនេះ ត្រូវមានកម្រិតចេះដឹងឧត្ដមសិក្សាពី ២ ឆ្នាំឡើងទៅ។

-មន្ត្រីរាជការដែលបានបម្រើការងាររដ្ឋ ២ ឆ្នាំ យ៉ាងតិច ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សានីតិសាស្ត្រ។

អ្នកដែលមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូលមិនចាំបាច់ប្រឡងទេ។

មាត្រា ៨១.

អាចទទួលឱ្យចុះឈ្មោះ ក្នុងបញ្ជីសំរាប់ឱ្យប្រឡងចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលមេធាវីបាន ស្របតាមមាត្រាខាងលើ អ្នកដែលមិនដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ។

មាត្រា ៨២.

វគ្គបណ្ដុះបណ្ដាលមានរយៈពេលយ៉ាងតិច ៨ ខែ។ កម្មវិធី និងបែបបទនៃវគ្គបណ្ដុះបណ្ដាលព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡង ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបណ្ដុះបណ្ដាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាគណៈមេធាវី។

អ្នកដែលប្រឡងជាប់ នឹងត្រូវទទួលវិញ្ញាបនប័ត្រសម្បទា សំរាប់ប្រកបវិជ្ជាជីវៈមេធាវី។

មាត្រា ៨៣.

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់ធ្វើកម្មសិក្សាចំពោះ៖

-អ្នកមានបរិញ្ញាប័ត្រច្បាប់ ឬអ្នកមានសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល ហើយបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការរយៈពេល ២ ឆ្នាំ យ៉ាងតិច

-អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់

-ចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរយៈពេលយ៉ាងតិច ២ឆ្នាំ។

មាត្រា ៨៤.

មុនពេលបង្កើតបានគណៈមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានភារកិច្ចទទួល និងពិនិត្យពាក្យសុំប្រកបវិជ្ជាជីវៈមេធាវី ហើយកោះអញ្ជើញអ្នកដែលបានបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ឱ្យមកធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ដើម្បីបំពេញឋានៈជាមេធាវី និងចូលរួមមហា-សន្និបាតបង្កើតគណៈមេធាវី។

មាត្រា ៨៥.

មហាសន្និបាតត្រូវរៀបចំបោះឆ្នោត ក្រោមការទទួលខុសត្រូវរបស់មេធាវី ដែលមានវ័យចាស់ជាងគេ ដើម្បីជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៨៦.

មួយឆ្នាំក្រោយមកទៀត ត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មីម្នាក់ និងក្រុមប្រឹក្សាគណៈមេធាវីថ្មីមួយ ដោយមេធាវីទាំងអស់ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី។

មាត្រា ៨៧.

ក្នុងករណីចាំបាច់ អាណត្តិនៃក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវី ដែលជាប់ឆ្នោតលើកដំបូង ត្រូវបន្តរហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មី និងក្រុមប្រឹក្សាគណៈមេធាវីថ្មី។

មាត្រា ៨៨.

ដោយមិនទាន់គិតដល់មាត្រា ១៤ និងមាត្រា ១៥ អ្នកដែលមានសិទ្ធិ បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតដូចមានចែងក្នុងមាត្រា ៨៤ គឺមេធាវីទាំងឡាយដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី និងក្នុងបញ្ជីកម្មសិក្សា ដោយមិនគិតពីអតីតភាព។

មាត្រា ៨៩.

អន្តរប្បញ្ញត្តិនេះ មានអានុភាពអនុវត្តរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

មាត្រា ៩០.

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខា
ចែម ស្គួន

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា
ហ៊ុន សែន

លេខ ៤៣ ច.ល.
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌីតាន់

# បទបញ្ជាផ្ទៃក្នុង
# នៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី១
# វិជ្ជាជីវៈមេធាវី

## ប្រការ ១. វិធានត្រឹះ

មេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវី ត្រូវប្រតិបត្តិ និងគោរពគ្រប់វិធានវិជ្ជាជីវៈដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី និងសេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ២. ច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត

មេធាវីដែលចុះបញ្ជីនៅគណៈមេធាវីត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ប្រការ ៣. ការមិនគោរពវិធានវិជ្ជាជីវៈ

ការមិនគោរពវិធានវិជ្ជាជីវៈណាមួយ នឹងនាំឱ្យមានកំហុស ដែលអាចទទួលទណ្ឌកម្មជាបទវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# បញ្ជីគណៈមេធាវី និងការតព្វកិច្ចភាគទាន

## ប្រការ ៤. ប្រភេទនៃបញ្ជីគណៈមេធាវី

បញ្ជីគណៈមេធាវី រួមមាន បញ្ជីមេធាវីពេញសិទ្ធិ បញ្ជីមេធាវីកម្មសិក្សា និងបញ្ជីមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅកម្ពុជា។

- បញ្ជីមេធាវីពេញសិទ្ធិ រួមមាន៖
    - មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ
    - មេធាវីដែលត្រូវបានហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈ
    - មេធាវីមិនប្រកបវិជ្ជាជីវៈ
    - មេធាវីនៅក្រៅបញ្ជីគណៈមេធាវី។
- បញ្ជីមេធាវីកម្មសិក្សា៖ បញ្ជីដែលចុះឈ្មោះតែមេធាវីកម្មសិក្សា។
- បញ្ជីមេធាវីបរទេស៖ បញ្ជីដែលចុះឈ្មោះមេធាវីបរទេសទាំងឡាយ ដែលត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាគណៈមេធាវីឱ្យប្រកបវិជ្ជាជីវៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៥. ភាគទានភាគទាន

មេធាវីពេញសិទ្ធិ មេធាវីបរទេស មានកាតព្វកិច្ចបង់ប្រាក់ភាគទានជូនគណៈមេធាវី ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

# ជំពូកទី ៣
# មហាសន្និបាតគណៈមេធាវី

## ប្រការ ៦. មហាសន្និបាតគណៈមេធាវី

មហាសន្និបាតគណៈមេធាវី ប្រមូលផ្តុំមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ និងចុះឈ្មោះក្នុងបញ្ជីមេធាវីកម្មសិក្សា។

មានតែមេធាវីពេញសិទ្ធិដែលមានសិទ្ធិបោះឆ្នោតតែប៉ុណ្ណោះ ទើបអាចចូលរួមក្នុងការពិភាក្សារបស់មហាសន្និបាត។

មហាសន្និបាតមាន ២ (ពីរ) ប្រភេទ៖

- មហាសន្និបាតសាមញ្ញត្រូវកោះប្រជុំមួយឆ្នាំម្តង នៅរៀងរាល់ថ្ងៃទី ១៦ ខែតុលា លើកលែងតែក្រុមប្រឹក្សាគណៈមេធាវីសម្រេចកំណត់យកកាលបរិច្ឆេទផ្សេងពីនេះ។

- មហាសន្និបាតវិសាមញ្ញ អាចកោះប្រជុំបានលុះត្រាតែមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិចំនួន ៣០ (សាមសិប) % បានស្នើដោយមានភ្ជាប់របៀបវារៈជាមួយផងយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ។ មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសម្រេចពីក្រុមប្រឹក្សាគណៈមេធាវី។

## ប្រការ ៧. គោលបំណងនៃមហាសន្និបាតគណៈមេធាវី

មហាសន្និបាតគណៈមេធាវី មានគោលបំណង៖

- ជូនរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុរបស់គណៈមេធាវីក្នុងរយៈពេលមួយឆ្នាំកន្លងមក
- ពិគ្រោះយោបល់ជាមួយសមាជិក-សមាជិកាគណៈមេធាវី
- លើកសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ (បី) ខែ
- បោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី
- បោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីន

### ប្រការ ៨. របៀបវារៈមហាសន្និបាត

មហាសន្និបាតសាមញ្ញគណៈមេធាវី ប្រព្រឹត្តទៅមួយឆ្នាំម្តង ដែលផ្តើមធ្វើឡើងដោយប្រធានគណៈមេធាវី តាមរបៀបវារៈដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

លើកលែងតែមានកិច្ចការប្រញាប់ របៀបវារៈនេះត្រូវឱ្យសហភាគាបានដឹង ១ (មួយ) ខែ មុនយ៉ាងតិចតាមគ្រប់មធ្យោបាយសមស្រប។

មេធាវីដែលមានសិទ្ធិបោះឆ្នោតមួយរូបៗ អាចសុំចុះបញ្ហារបស់ខ្លួនក្នុងរបៀបវារៈបានដោយធ្វើពាក្យសុំផ្ញើទៅក្រុមប្រឹក្សាគណៈមេធាវី ១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំ តាមរយៈលិខិតអនុសិដ្ឋដែលមានចុះថា បានទទួល ឬ តាមលិខិតដាក់ជូនអគ្គលេខាធិការដ្ឋាន ដោយមានបង្កាន់ដៃទទួល។

### ប្រការ ៩. ការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី

មហាសន្និបាតប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានគណៈមេធាវី។

ប្រសិនបើត្រូវធ្វើការបោះឆ្នោត គឺត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងករណីធ្វើការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី។

ការបោះឆ្នោតតាមព្រឹត្តបត្រសម្ងាត់ អាចសម្រេចដោយប្រធានគណៈមេធាវី ឬដោយសំណើរបស់សមាជិកដែលមានចំនួន១/៤ (មួយភាគបួន) នៃសមាជិកវត្តមាន។

## ជំពូកទី ៤
## ការបោះឆ្នោតជ្រើសតាំងប្រធាន និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

### ប្រការ ១០. ការរៀបចំការបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ត្រូវធ្វើឡើង ២ (ពីរ) ឆ្នាំម្តង។

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើឡើង ៣ (បី) ឆ្នាំម្តង។

ការបោះឆ្នោតប្រព្រឹត្តទៅនៅក្នុងមហាសន្និបាតគណៈមេធាវី នៅពេលវេលាដែលត្រូវបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ឬសមាជិកក្រុមប្រឹក្សាគណៈមេធាវី។

មេធាវីដែលមានសិទ្ធិបោះឆ្នោត មាន៖

- មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមេធាវី។

- មេធាវីពេញសិទ្ធិដែលស្នើសុំមិនប្រកបវិជ្ជាជីវៈមេធាវី។
- មេធាវីពេញសិទ្ធិដែលត្រូវបានហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមេធាវី តែមិនត្រូវបានទទួលទណ្ឌកម្ម ដកសិទ្ធិបោះឆ្នោត។

## ប្រការ ១១. ការកោះអញ្ជើញចូលរួមបោះឆ្នោត

មេធាវីដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ត្រូវកោះអញ្ជើញ ១ (មួយ) ខែមុនថ្ងៃបោះឆ្នោត តាមគ្រប់មធ្យោបាយសមស្រប។

## ប្រការ ១២. បេក្ខភាពឈរឈ្មោះ

បេក្ខភាពឈរឈ្មោះបោះឆ្នោត ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយដាក់ជូនទៅប្រធានគណៈមេធាវី តាមការកំណត់របស់គណៈមេធាវី បើមិនដូច្នោះនឹងមិនត្រូវបានទទួលឡើយ។ ឈ្មោះនៃបេក្ខជនទាំងអស់ត្រូវផ្សព្វផ្សាយតាមគ្រប់មធ្យោបាយសមស្រប ហើយត្រូវបិទនៅការិយាល័យបោះឆ្នោត។

បេក្ខភាពក្រុមប្រឹក្សាគណៈមេធាវី ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មេធាវីពេញសិទ្ធិ យ៉ាងតិច ២ (ពីរ) ឆ្នាំ។
- មេធាវីមានសិទ្ធិបោះឆ្នោត។
- ឥតបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយ។

បេក្ខភាពប្រធានគណៈមេធាវី ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មេធាវីពេញសិទ្ធិ យ៉ាងតិច ៣ (បី) ឆ្នាំ។
- មេធាវីមានសិទ្ធិបោះឆ្នោត។
- ឥតបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយ។

## ប្រការ១៣ថ្មី(២). ដំណើរការនៃការបោះឆ្នោត[1]

ការបោះឆ្នោតនឹងអាចប្រព្រឹត្តទៅបានលុះត្រាតែវត្តមានមេធាវីពេញសិទ្ធិចំនួនលើសពីពាក់កណ្តាល។

[1] ប្រការ១៣ ត្រូវបានកែសម្រួលចំនួន ២ លើក ដោយលើកទី១ ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៣៩៣/សសគម/២០ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣ នៃបទបញ្ញាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលើកទី២ ដោយសេចក្តីសម្រេចលេខ ៨០៧/សសគម/២០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣ នៃបទបញ្ញាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលត្រូវបានសម្រេចជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមួយត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមានតួនាទីរៀបចំដំណើរការបោះឆ្នោតប្រធាន និងបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

សមាជិកគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី ក្នុងចំណោមមេធាវីពេញសិទ្ធិ មេធាវីកម្មសិក្សា សិស្សមេធាវី និងបុគ្គលិកគណៈមេធាវី ដែលស្ម័គ្រចិត្តដាក់ពាក្យសុំចូលរួមជួយបំពេញកិច្ចការនេះ។

គណៈកម្មការបោះឆ្នោតជាគណៈកម្មការចំពោះកិច្ច ដែលត្រូវចប់ភារកិច្ច និងរំលាយដោយស្វ័យប្រវត្តិក្រោយពីការរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោតចប់សព្វគ្រប់។

ប្រធានគណៈមេធាវី ឬតំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត មេធាវីមានសិទ្ធិបោះឆ្នោតត្រូវពាក់អាវវិជ្ជាជីវៈមេធាវី និងបង្ហាញបណ្ណសម្គាល់មេធាវី ឬលិខិតបញ្ជាក់ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។ ចំពោះប្រធានគណៈមេធាវី អាចពាក់អាវសម្រាប់ប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះអតីតប្រធានគណៈមេធាវី អាចពាក់អាវសម្រាប់អតីតប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចពាក់អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យទនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចពាក់អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យទាននានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ អាចពាក់អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។

និងបង្ហាញបណ្ណសម្គាល់មេធាវី ឬលិខិតបញ្ជាក់ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

ការបោះឆ្នោតលើកទី ១ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) (រាប់ទាំងសំឡេងផ្ទេរសិទ្ធិ) នៃមេធាវីពេញសិទ្ធិទាំងអស់។ ការបោះឆ្នោតលើកទី ១ នេះ ការប្រគល់សិទ្ធិ អាចទទួលយកបាន។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

ការបោះឆ្នោតលើកទី ២ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើននៃមេធាវីពេញសិទ្ធិដែលមានវត្តមានក្នុងពេលបោះឆ្នោតលើកទី២នេះ លើកលែងតែសំឡេងផ្ទេរសិទ្ធិ និងមេធាវីដែលបានផ្ទេរសិទ្ធិឱ្យគេបោះឆ្នោតនៅការបោះឆ្នោតលើកទី១ មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតទេ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាសសលាត ឬមោឃៈត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកសម្លេងភាគច្រើនឡើយ។

## ប្រការ១៤ថ្មី. ការរាប់សន្លឹកឆ្នោត[2]

បន្ទាប់ពីការបោះឆ្នោតចប់ភ្លាម គណៈកម្មការបោះឆ្នោតត្រូវរៀបចំរាប់សន្លឹកឆ្នោត។ ការរាប់សន្លឹកឆ្នោត ត្រូវរាប់តាមការិយាល័យនីមួយៗនៃការបោះឆ្នោតនៅចំពោះមុខសមាជិក-សមាជិកាគណៈមេធាវី ដែលមានវត្តមានជាក់ស្តែងនៅក្នុងមហាសន្និបាត។

## ប្រការ១៥ថ្មី. លទ្ធផលនៃការបោះឆ្នោត[3]

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោតចប់ភ្លាម។ លទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់។

[2] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

[3] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីបំពេញបន្ថែមលើបទបញ្ជាផ្ទៃក្នុងនេះ រាល់ពេលបោះឆ្នោតម្តងៗ ក្រុមប្រឹក្សាគណៈមេធាវី អាចកំណត់នូវបទបញ្ជានិងនីតិវិធីនៃការបោះឆ្នោតមួយដោយឡែកបន្ថែមទៀត។

## ជំពូកទី ៤
## ក្រុមប្រឹក្សាគណៈមេធាវី

### ប្រការ ១៦. ការប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី

កិច្ចប្រជុំនៃក្រុមប្រឹក្សាគណៈមេធាវីត្រូវធ្វើនៅទីស្នាក់ការនៃគណៈមេធាវី ឬទីកន្លែងផ្សេងទៀតតាមការកំណត់របស់ប្រធានគណៈមេធាវីក្នុងករណីចាំបាច់។

### ប្រការ១៦(ស្ទួន). ការកោះប្រជុំ និងរបៀបវារៈ[4]

ក្រុមប្រឹក្សាគណៈមេធាវីរួមប្រជុំតាមការផ្តួចផ្តើមគំនិតរបស់ប្រធានគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ។ សមាជិកក្រុមប្រឹក្សាគណៈមេធាវីចំនួន ១/៣ (មួយភាគបី) អាចស្នើសុំមកប្រធានគណៈមេធាវីដើម្បីពិនិត្យនិងសម្រេចកោះប្រជុំ។

លើកលែងតែមានកិច្ចការប្រញាប់ ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញសមាជិកក្រុមប្រឹក្សាគណៈមេធាវីឱ្យបានយ៉ាងតិច៣(បី)ថ្ងៃមុនថ្ងៃកំណត់ប្រជុំ ដោយភ្ជាប់ជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំតាមគ្រប់មធ្យោបាយសមស្រប។

### ប្រការ១៧ថ្មី. ការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី[5]

កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវីត្រូវដឹកនាំដោយប្រធានគណៈមេធាវី។ ប្រធានគណៈមេធាវីត្រូវចូលរួមពិភាក្សា និងបោះឆ្នោតសម្រេចជាមួយសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ សំឡេងរបស់ប្រធានគណៈមេធាវី ពុំមានឧត្តមានុភាពឡើយ។

---

[4] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

[5] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីប្រធានគណៈមេធាវីមានធុរៈ ប្រធានគណៈមេធាវីអាចចាត់តាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានវ័យចាស់ជាងគេឱ្យដឹកនាំអង្គប្រជុំក្រុមប្រឹក្សាគណៈមេធាវីបាន។

## ប្រការ ១៨. កូរ៉ុម

កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវីអាចដំណើរការទៅបាន លុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាគណៈមេធាវី លើសពីពាក់កណ្ដាលនៃចំនួនសមាជិកទាំងអស់។

## ប្រការ ១៩. សមត្ថកិច្ចរបស់ក្រុមប្រឹក្សាគណៈមេធាវី

ក្រុមប្រឹក្សាគណៈមេធាវី មានសមត្ថកិច្ចពិនិត្យសម្រេចនូវរាល់បញ្ហាទាំងអស់ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ក្រៅពីនេះក្រុមប្រឹក្សាគណៈមេធាវីមានសមត្ថកិច្ចពិនិត្យ និងសម្រេចរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី និងគណៈមេធាវី។

## ប្រការ២០ថ្មី. វិន័យការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី[6]

សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវចូលរួមកិច្ចប្រជុំឱ្យបានទៀងទាត់និងទាន់ពេលវេលា។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវជូនដំណឹងអំពីអវត្តមានរបស់ខ្លួនមកប្រធានគណៈមេធាវី ក្នុងរយៈពេលសមស្រប តាមគ្រប់មធ្យោបាយសមស្រប។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនសមាជិកណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនក្នុងការបោះឆ្នោតសម្រេចលើបញ្ហានានានៅក្នុងកិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីម្នាក់អាចទទួលការផ្ទេរសិទ្ធិបានតែមួយប៉ុណ្ណោះ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវគោរពនិងប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវីដែលសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

## ប្រការ ២១. ការសម្រេច

ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីអាចធ្វើឡើងតាមវិធីបោះឆ្នោតជាសម្ងាត់ ឬដោយលើកដៃ។

[6] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ការជ្រើសរើសយកវិធីណាមួយក្នុងការសម្រេច ត្រូវមានការសម្រេចពីកិច្ចប្រជុំជាមុនដោយលើកដៃ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីមួយរូប មានសិទ្ធិបោះឆ្នោតសម្រេចចំនួនមួយសម្លេង។ ក្នុងករណីទទួលការផ្ទេរសិទ្ធិពីសមាជិកក្រុមប្រឹក្សាដែលអវត្តមាន សមាជិកក្រុមប្រឹក្សាដែលទទួលសិទ្ធិ មានសិទ្ធិសម្រេចបានមួយសម្លេងបន្ថែមលើសម្លេងរបស់ខ្លួនផ្ទាល់។

ក្រុមប្រឹក្សាគណៈមេធាវីសម្រេចសេចក្តីតាមមតិភាគច្រើននៃសមាជិកវត្តមាន និងផ្ទេរសិទ្ធិ។

## ប្រការ ២២. ដំណើរការនៃកិច្ចប្រជុំ និងកិច្ចពិភាក្សា

មុននឹងចាប់ផ្តើមកិច្ចប្រជុំ ក្រុមប្រឹក្សាត្រូវសម្រេចអនុម័តលើរបៀបវារៈនៃកិច្ចប្រជុំជាមុនសិន។

ប្រធានគណៈមេធាវី ត្រូវលើកយករបៀបវារៈម្តងមួយមកធ្វើការពិនិត្យ ពិភាក្សា និងសម្រេច។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីអាចបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរី លើចំណុចនីមួយៗនៃរបៀបវារៈ ប៉ុន្តែមិនត្រូវនិយាយចាកប្រធានបទ វាយប្រហារបុគ្គល ឬធ្វើឱ្យខាតបង់ពេលវេលារបស់កិច្ចប្រជុំនោះទេ។

មុននឹងបញ្ចេញមតិយោបល់ សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវសុំការអនុញ្ញាតពីប្រធានជាមុនសិន។

ប្រធានមានសិទ្ធិព្រមានដោយផ្ទាល់មាត់ ឬហាមឃាត់ការបញ្ចេញមតិយោបល់របស់សមាជិកណាដែលនិយាយចាកប្រធានបទ ឬនិយាយវាយប្រហារបុគ្គល ឬនិយាយធ្វើឱ្យខាតបង់ពេលវេលា។

រាល់មតិយោបល់ និងការពិភាក្សារបស់កិច្ចប្រជុំ ត្រូវរក្សាជាការសម្ងាត់។

រាល់ការទម្លាយការសម្ងាត់នៃព័ត៌មានទាំងអស់នេះ ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

## ប្រការ ២៣. កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី

នៅរាល់កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើកំណត់ហេតុដែលត្រូវធ្វើឡើងដោយលេខាធិការអង្គប្រជុំ។

លេខាធិការដ្ឋានអង្គប្រជុំក្រុមប្រឹក្សាគណៈមេធាវី ត្រូវកំណត់ចាត់តាំងដោយក្រុមប្រឹក្សាគណៈមេធាវី។

កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី ត្រូវមានចុះហត្ថលេខាដោយប្រធានគណៈមេធាវី និងមានការយល់ព្រមដោយសមាជិកក្រុមប្រឹក្សាគណៈមេធាវី។

# ជំពូកទី ៦
# ជំនួយសង្គ្រោះតាមផ្លូវតុលាការ

## ប្រការ ២៤. ការចាត់តាំងមេធាវីស្ម័គ្រចិត្ត ដោយប្រធានគណៈមេធាវី

ស្របតាមមាត្រា ២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បេឡាពិសេសមួយបានត្រូវបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការផ្តល់សេវាកម្មច្បាប់ជូនជនក្រីក្រ ដោយឥតគិតថ្លៃ។

មេធាវី ដែលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី។

មេធាវីគ្រប់រូបអាចស្ម័គ្រចិត្តជួយការពារក្តីជូនជនក្រីក្របានគ្រប់ពេលវេលា។ មេធាវីស្ម័គ្រចិត្តត្រូវដាក់ពាក្យសុំមកគណៈមេធាវី ដើម្បីគណៈមេធាវីសម្រេចចាត់តាំង។

មេធាវីកម្មសិក្សាទាំងអស់ត្រូវមានកាតព្វកិច្ចការពារក្តីជូនជនក្រីក្រ តាមការចាត់តាំងរបស់ប្រធានគណៈមេធាវី យ៉ាងតិច ៣ (បី) សំណុំរឿងក្តីក្នុង ១ (មួយ) ឆ្នាំ។

ជំនួយសង្គ្រោះតាមផ្លូវតុលាការដល់ជនក្រីក្រ អាចធ្វើឡើងតាម ២ (ពីរ) របៀបៈ

- ការស្នើសុំទៅប្រធានគណៈមេធាវី តាមរយៈនាយកដ្ឋានការពារក្តីជូនជនក្រីក្រ។
- ការស្នើសុំតាមរយៈសាលាជម្រះក្តី និងអយ្យការ។

ជនដែលត្រូវបានទទួលនូវជំនួយសង្គ្រោះតាមផ្លូវតុលាការ ត្រូវធ្វើពាក្យសុំជំនួយជូនទៅប្រធានគណៈមេធាវី *(គំរូលេខ ១)* ដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ដែលជននោះរស់នៅថា «ជាជនដែលមានជីវភាពក្រីក្រ គ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង» ឬមានឯកសារបញ្ជាក់ថាជាជនក្រីក្រ។

ក្នុងករណីមានការស្នើសុំតាមរយៈសាលាជម្រះក្តី ឬស្ថាប័នអយ្យការ ចៅក្រម ឬព្រះរាជអាជ្ញាដែលទទួលបន្ទុកដោះស្រាយសំណុំរឿងត្រូវធ្វើលិខិតស្នើសុំចាត់តាំងមេធាវីស្ម័គ្រចិត្តមកប្រធានគណៈមេធាវី។

ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ យ៉ាងយូរបំផុត ប្រធានគណៈមេធាវី ត្រូវចាត់តាំងសហភាតារបស់ខ្លួនម្នាក់ដែលត្រូវបំពេញបេសកកម្មដោយស្ម័គ្រចិត្តនូវជំនួយសង្គ្រោះតាមផ្លូវតុលាការនេះ។

មេធាវីស្ម័គ្រចិត្ត ត្រូវបំពេញកាតព្វកិច្ចការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់ប្រធានគណៈមេធាវីដោយយកចិត្តទុកដាក់ ឱ្យអស់ពីសមត្ថភាព និងឱ្យដូចជាការជួយការពារឱ្យអតិថិជនរបស់ខ្លួនដែរ។

ក្រុមប្រឹក្សាគណៈមេធាវី ត្រូវកំណត់ឱ្យបានច្បាស់ អំពីចំនួនមេធាវីចាំបាច់ សម្រាប់ធានានូវការប្រព្រឹត្តទៅឱ្យបានល្អនៃជំនួយសង្គ្រោះតាមផ្លូវតុលាការនេះ។

### ប្រការ ២៥. ប្រាក់ឧបត្ថម្ភ

មេធាវីស្ម័គ្រចិត្តដែលមកធ្វើការក្នុងរឿងជំនួយសង្គ្រោះតាមផ្លូវតុលាការ អាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់ឧបត្ថម្ភចំពោះការពិគ្រោះយោបល់ច្បាប់ ឬប្រាក់សោហ៊ុយសម្រាប់ចំណាយលើរឿងក្តីនីមួយៗ (សោហ៊ុយធ្វើដំណើរ សោហ៊ុយហូបចុក ស្នាក់នៅ និងសោហ៊ុយថតចម្លងសំណុំរឿង...។ល។) តាមចំនួនដែលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី។

មេធាវីចាត់តាំង ត្រូវទទួលបន្ទុកលើសំណុំរឿង ដែលខ្លួនត្រូវបានគេចាត់តាំងឱ្យបំពេញ។

ដើម្បីបើកប្រាក់ឧបត្ថម្ភដែលខ្លួនត្រូវបាន មេធាវីសាមីត្រូវប្រគល់របាយការណ៍ការងារនៅរៀងរាល់ថ្ងៃទី១៥ នៃខែនីមួយៗ *(គំរូលេខ ២)* ដែលបញ្ជាក់អំពីស្ថានភាពជឿនលឿន នៃសំណុំរឿងដែលបានដាក់ចុះឱ្យបំពេញ។

ប្រសិនបើមេធាវីស្ម័គ្រចិត្តពុំបានបំពេញកិច្ចការចាំបាច់ តាមដំណើរការនីតិវិធីដែលត្រូវប្រព្រឹត្តទៅទេ ប្រធានគណៈមេធាវីអាចនឹងដកឈ្មោះចេញពីបញ្ជីមេធាវីស្ម័គ្រចិត្ត ហើយអាចនឹងចោទប្រកាន់ខាងបទវិន័យដល់មេធាវីនោះផង។

ក្នុងករណីនេះមេធាវី សងប្រាក់ដែលខ្លួនបានបើកហើយ ដោយមិនត្រឹមត្រូវនោះមកវិញ។

## ជំពូកទី ៧

## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

### ប្រការ ២៦. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ព្រមទាំងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី ត្រូវធ្វើឡើងស្របតាមអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

### ប្រការ ២៧. បទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបំពេញការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងបទបញ្ជាផ្ទៃក្នុងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី។

## ជំពូកទី ៨
## ការរៀបចំកម្មសិក្សា

### ប្រការ២៨ថ្មី. ការរៀបចំកម្មសិក្សា[7]

កម្មសិក្សាមានថិរវេលា១(មួយ)ឆ្នាំហើយអាចពន្យារពេលបានតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

កម្មសិក្សាត្រូវរួមបញ្ចូលទាំងសកម្មភាពបណ្តុះបណ្តាលបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវីនិងការសហការពិតប្រាកដក្នុងការិយាល័យរបស់មេធាវីណាមួយផង។

កម្មសិក្សាការី អាចធ្វើផ្នែកខ្លះនៅក្នុងការិយាល័យមេធាវីនៅឯបរទេសនៃប្រទេសណាមួយក៏បាន។

### ប្រការ ២៩. គ្រូកម្មសិក្សា និងកម្មសិក្សាការី

គ្រូកម្មសិក្សា និងកម្មសិក្សាការីចុះហត្ថលេខាលើកិច្ចសន្យាសហការ *(គំរូលេខ៣)* ដែលត្រូវបានដាក់ជូនទៅក្រុមប្រឹក្សាគណៈមេធាវី ស្របតាមមាត្រា ៥២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

គ្រូកម្មសិក្សា មានកាតព្វកិច្ចចូលរួមដោយសកម្មចំពោះការអប់រំការអនុវត្តវិជ្ជាជីវៈ និងអប់រំក្រមសីលធម៌ ដល់កម្មសិក្សាការី។

បែបបទនៃកម្មសិក្សានៅក្នុងការិយាល័យមេធាវីនីមួយៗ អាចកំណត់បានដោយសេរីរវាងគ្រូកម្មសិក្សានិងកម្មសិក្សាការី។

---

[7] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាគណៈមេធាវី អាចសម្រេចដកសិទ្ធិក្នុងការធ្វើជាគ្រូកម្មសិក្សាចំពោះកម្មសិក្សាការីណាម្នាក់បាន ប្រសិនបើការចាំបាច់នៃការបណ្តុះបណ្តាល មិនត្រូវបានបំពេញដោយប្រក្រតី។

ក្រុមប្រឹក្សាគណៈមេធាវីអាចចេញសេចក្តីសម្រេចកំណត់ពីបែបបទនៃការធ្វើកម្មសិក្សា និងទម្រង់បែបបទនៃការធ្វើរបាយការណ៍បញ្ចប់កម្មសិក្សា។

## ប្រការ ៣០. លក្ខណៈសម្បត្តិរបស់គ្រូកម្មសិក្សា

ដើម្បីអាចធ្វើជាគ្រូកម្មសិក្សាបាន ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- ជាមេធាវីពេញសិទ្ធិដែលប្រកបវិជ្ជាជីវៈមេធាវី យ៉ាងតិច ៣ (បី) ឆ្នាំ។
- មិនធ្លាប់ទទួលទណ្ឌកម្មវិន័យពីគណៈមេធាវី ឬដកសិទ្ធិមិនឱ្យធ្វើគ្រូកម្មសិក្សា។
- ត្រូវមានការិយាល័យប្រកបវិជ្ជាជីវៈត្រឹមត្រូវដែលបានចុះបញ្ជីនៅគណៈមេធាវី។

គ្រូកម្មសិក្សាមិនត្រូវជាញាតិលោហិតថ្នាក់ទីពីរ ឬជាសហព័ទ្ធ របស់កម្មសិក្សាការីឡើយ។

គ្រូកម្មសិក្សាម្នាក់អាចទទួលកម្មសិក្សាការីបានច្រើនបំផុត ៥ (ប្រាំ) រូប។

## ប្រការ ៣១. ការផ្លាស់ប្តូរគ្រូកម្មសិក្សា

ដើម្បីដកស្រង់បទពិសោធន៍ និងទទួលបានចំណេះដឹងអំពីវិជ្ជាជីវៈមេធាវីបន្ថែមកម្មសិក្សាការីអាចស្នើសុំផ្លាស់ប្តូរគ្រូកម្មសិក្សាបាន ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី និងបន្ទាប់ពីបានបំពេញកម្មសិក្សាជាមួយគ្រូកម្មសិក្សាចាស់ បានយ៉ាងតិច ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចាប់ផ្តើមកម្មសិក្សា។

## ប្រការ ៣២ថ្មី. ការព្យួរ និងការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា[8]

ការព្យួរកម្មសិក្សាត្រូវសម្រេចអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី។

ការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា ក៏អាចសម្រេចបានដែរ ចំពោះមេធាវីដែលមិនគោរពកិច្ចសន្យាកម្មសិក្សា ហើយដែលមិនអាចបញ្ជាក់បានត្រឹមត្រូវនូវកិច្ចសន្យាសហការពិតប្រាកដ។

[8] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រការ ៣៣ថ្មី. ការបញ្ចប់កម្មសិក្សា[9]

នៅពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការីត្រូវធ្វើរបាយការណ៍ពីកម្មសិក្សារបស់ខ្លួន ដោយមានមូលវិចារពីគ្រូកម្មសិក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេចចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ។

កម្មសិក្សាការីត្រូវដាក់របាយការណ៍បញ្ចប់កម្មសិក្សាមកគណៈមេធាវី ក្នុងរយៈពេល២ (ពីរ)ខែ គិតចាប់ពីថ្ងៃបញ្ចប់រយៈពេលកម្មសិក្សា។ ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចដាក់ទណ្ឌកម្មវិន័យ។

ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចឱ្យធ្វើកម្មសិក្សាបន្តទៀត តែមិនឱ្យលើសពី១(មួយ) ឆ្នាំឡើយ ចំពោះកម្មសិក្សាការីណា ដែលមិនមានសមត្ថភាពគ្រប់គ្រាន់។ ការសម្រេចមិនចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ ចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល។

# ជំពូកទី ៩
# ការគ្រប់គ្រងមូលនិធិ និងប្រាក់តម្កល់ទុក

## ប្រការ ៣៤. បេឡាទូទាត់របស់គណៈមេធាវី

អនុលោមតាមមាត្រា ៧០ និង ៧១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មូលនិធិដែលបានមកពីការតម្កល់ទុកធានា បានមកពីប្រាក់ធានាសម្រាប់សងគូភាគីឈ្នះក្តី ឬបានមកពីប្រាក់តម្កល់ទុកត្រូវមេធាវីបង់ចូលទៅគណនីពិសេសដែល បើកឡើងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលមានឈ្មោះថា «**បេឡាទូទាត់គណៈមេធាវី**»។

## ប្រការ ៣៥. ការប្រតិបត្តិនៃបេឡា

មេធាវីត្រូវតម្កល់មូលនិធិដែលបានទទួលដូចខាងលើ *(ជាមូលប្បទានប័ត្រ ការបង្វែរប្រាក់ ឬជាក្រដាសប្រាក់)* នៅក្នុងបេឡាទូទាត់គណៈមេធាវី។

ក្រៅពីឈ្មោះផ្ទាល់របស់ខ្លួនចេញ មេធាវីត្រូវដាក់ឈ្មោះអតិថិជន និងរឿងក្តីដែលពាក់ព័ន្ធ *(គំរូលេខ៤)*។

---

[9] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

បង្កាន់ដៃមួយដែលមានព័ត៌មានដូចគ្នានេះ ត្រូវចេញឱ្យមេធាវីនោះ ដោយប្រធានគណៈមេធាវី *(គំរូលេខ២៥)*។

តាមការសុំជាលាយលក្ខណ៍អក្សរ *(គំរូលេខ២៦)* របស់មេធាវី បេឡាត្រូវបើកមូលនិធិដែលបានរក្សាទុកក្នុងក្របខ័ណ្ឌនៃរឿងក្តី ឱ្យទៅជនជាអត្ថគាហក។

សម្រង់បញ្ជីទឹកប្រាក់នៃមូលនិធិដែលនៅសល់ក្នុងរឿងក្តី ត្រូវប្រគល់ទៅឱ្យមេធាវី។

សមតុល្យនៃប្រាក់ក្នុងរឿងក្តីនីមួយៗ មិនត្រូវអាចជាសមតុល្យឥណាយិកទេ។

### ប្រការ ៣៦. ការកាត់យកទ្រាក់កម្រៃមេធាវី

មេធាវីនឹងអាចកាត់យកមុនបាន នូវប្រាក់កម្រៃពីមូលនិធិតម្កល់ទុកដោយអតិថិជន តែក្នុងលក្ខខណ្ឌដែលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជននោះ ដោយបញ្ជាក់ច្បាស់អំពីឈ្មោះនៃរឿងក្តី និងចំនួនទឹកប្រាក់ដែលត្រូវកាត់យកមុន។

សេចក្តីអនុញ្ញាតនេះ មេធាវីត្រូវបញ្ជូនដោយខានមិនបាន ទៅបេឡាទូទាត់របស់គណៈមេធាវី នៅពេលដែលធ្វើពាក្យសុំបើកប្រាក់ពីមូលនិធិ។

### ប្រការ ៣៧. ការត្រួតពិនិត្យរបស់ប្រធានគណៈមេធាវី

ប្រធានគណៈមេធាវី អាចសុំឱ្យមេធាវីបញ្ជាក់ហេតុផលទាំងឡាយ ដែលទាក់ទងនឹងប្រភពដើម និងអត្ថគាហកនៃមូលនិធិតម្កល់ទុក។

ប្រធានគណៈមេធាវីអាចចោទប្រកាន់មេធាវីពីបទវិន័យ បើសិនជាពុំមានអ្វីសំអាងហេតុផលឱ្យបានត្រឹមត្រូវ។

## ជំពូកទី ១០
## គណនេយ្យកិច្ចគណនេយ្យ និងការត្រួតពិនិត្យ

### ប្រការ ៣៨ថ្មី. គណនេយ្យកិច្ចគណនេយ្យ[10]

មេធាវីត្រូវកាន់គណនេយ្យនៃកិច្ចប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន ដោយញែកឱ្យបានច្បាស់រវាងកិច្ចប្រតិបត្តិទាក់ទងនឹងការគ្រប់គ្រងការិយាល័យរបស់ខ្លួន និងកិច្ចប្រតិបត្តិធ្វើឡើងសម្រាប់ផលប្រយោជន៍អតិថិជន។

[10] ត្រូវបានកែសម្រួលដោយសេចក្តីសម្រេចលេខ ៨២៤/សសគម/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួល ប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណនេយ្យនៃកិច្ចប្រតិបត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការិយាល័យមេធាវី ត្រូវធ្វើឡើងឱ្យសមស្របនឹងវិធានច្បាប់ ឬបើគ្មានវិធាននោះទេ ក៏ត្រូវធ្វើតាមបែបបទចំណូល/ចំណាយដែរ។

មេធាវីត្រូវបំពេញកាតព្វកិច្ចជាបុគ្គលរាយការណ៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយនៃអាវុធមហាប្រល័យ។

កិច្ចប្រតិបត្តិការដែលទាក់ទងនឹងការបង់ប្រាក់ប្រដាប់ក្តី ប្រាក់ពន្ធអាករ និងប្រាក់ចេញជូសឱ្យមុន ដែលធ្វើឡើងក្នុងផលប្រយោជន៍អតិថិជន ត្រូវកត់ចូលក្នុងគណនេយ្យមួយដោយឡែក។

## ប្រការ ៣៩. ការត្រួតពិនិត្យ និងការពិនិត្យបញ្ជាក់

ប្រធានគណៈមេធាវី ចាត់ចែងឱ្យត្រួតពិនិត្យការប្រើប្រាស់មូលនិធិ ប្រាក់តម្កល់ និងឱ្យពិនិត្យផ្ទៀងផ្ទាត់លើឯកសារគណនេយ្យនានា តាមរយៈមេធាវីទាំងឡាយដែលខ្លួនចាត់តាំងអមជាយថាហេតុ ដោយជនមានសមត្ថភាព ឬដោយអ្នកជំនាញការងារគណនេយ្យ។

មេធាវីដែលត្រួតពិនិត្យត្រូវចង្អុលឈ្មោះ ដោយប្រធានគណៈមេធាវី។

មេធាវី ត្រូវបង្ហាញគណនេយ្យរបស់ខ្លួនដល់ជនដែលត្រូវបានចាត់តាំងដោយប្រធានគណៈមេធាវី។

ការត្រួតពិនិត្យ ត្រូវធ្វើឡើងក្នុងការិយាល័យមេធាវីដែលត្រូវត្រួតពិនិត្យ។

អ្នកត្រួតពិនិត្យ អាចឱ្យមេធាវីដែលត្រូវប្រគល់ឯកសារគណនេយ្យនានា សំណុំរឿង ហើយប្រសិនបើមានតម្រូវការសុំឱ្យប្រគល់ឯកសារនៃគណនីផ្ទាល់ខ្លួនមេធាវី និងសុំឱ្យធ្វើការពន្យល់សព្វសារពើផង។

ការត្រួតពិនិត្យនីមួយៗ តម្រូវឱ្យមានរបាយការណ៍លំអិតដែលត្រូវជូនទៅប្រធានគណៈមេធាវី។

# ជំពូកទី ១១

# អវសានប្បញ្ញត្តិ

## ប្រការ ៤០. និរាករណ៍

បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ក្រោមអធិបតីភាពរបស់លោកមេធាវី **សាយ បូរី** ប្រធានគណៈមេធាវី អាណត្តិទី១ និងទី២ ត្រូវចាត់ទុកជានិរាករណ៍។

បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៨ នាសម័យប្រជុំថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ក្រោមអធិបតីភាពរបស់លោកមេធាវី **ប៊ុន ហុន** ប្រធានគណៈមេធាវី អាណត្តិទី៩ និងទី១០។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

ប្រធានគណៈមេធាវី

នៃព្រះរាជាណាចក្រកម្ពុជា

# គំរូលេខ ១ (ព្រហ្មទណ្ឌ)

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំមេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..........................................អាយុ..........ឆ្នាំ មុខរបរ................ មានទីលំនៅ.......................................................................................................... លេខទូរស័ព្ទទំនាក់ទំនង.......................................... ត្រូវជា........................................ ..........................................................................................................................។

## សូមគោរពចូលមក

## លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ៖** សំណើសុំចាត់តាំងមេធាវី ដើម្បីការពារក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ........ចុះថ្ងៃទី.... របស់.......................................................។

**យោង៖** លិខិតបញ្ជាក់លេខ.................ចុះថ្ងៃទី................របស់...................................។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថាខ្ញុំបាទ/នាងខ្ញុំ ត្រូវបានតុលាការ.......................កោះហៅឱ្យចូលនៅថ្ងៃទី..................។ ខ្ញុំបាទ/នាងខ្ញុំ ជាប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពពឹងពាក់មេធាវី និងមិនអាចការពារខ្លួននៅចំពោះមុខតុលាការបាន ទើបខ្ញុំបាទ/នាងខ្ញុំ ស្នើសុំការចាត់តាំងមេធាវីពីគណៈមេធាវី។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាអនុញ្ញាតចាត់តាំងមេធាវី ដើម្បីការពារឱ្យខ្ញុំបាទ/នាងខ្ញុំនៅតុលាការ...........................ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ........... ឆ្នាំ...........

**ស្នាមមេដៃស្តាំ និង ឈ្មោះ**

គំរូលេខ ១ (រដ្ឋប្បវេណី)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំមេធាវី

ខ្ញុំខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................អាយុ..........ឆ្នាំ មុខរបរ................ មានទីលំនៅ.......................................................................................................... លេខទូរស័ព្ទទំនាក់ទំនង.......................................... ត្រូវជា.......................................... ..........................................................................................................................។

## សូមគោរពចូលមក

## លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ៖** សំណើសុំចាត់តាំងមេធាវី ដើម្បីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ..............ចុះថ្ងៃទី.............. របស់...........................................................។

**យោង៖** លិខិតបញ្ជាក់លេខ.................ចុះថ្ងៃទី................របស់...................................។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថាខ្ញុំបាទ/នាងខ្ញុំ ត្រូវបានតុលាការ.......................កោះហៅឱ្យចូលនៅថ្ងៃទី..................។ ខ្ញុំបាទ/នាងខ្ញុំ ជាប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពពឹងពាក់មេធាវី និងមិនអាចការពារខ្លួននៅចំពោះមុខតុលាការបាន ទើបខ្ញុំបាទ/នាងខ្ញុំ ស្នើសុំការចាត់តាំងមេធាវីពីគណៈមេធាវី។

អាស្រ័យហេតុនេះ សូម លោកប្រធាន មេត្តាអនុញ្ញាតចាត់តាំងមេធាវី ដើម្បីជាតំណាងឱ្យខ្ញុំបាទ/នាងខ្ញុំនៅតុលាការ...........................ដោយក្ដីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ........... ឆ្នាំ...........

ស្នាមមេដៃស្ដាំ និង ឈ្មោះ

# គំរូលេខ ២

# របាយការណ៍នៃការជួយសង្គ្រោះតាមផ្លូវតុលាការ

ធ្វើដោយលោកមេធាវី..................................................................

ថ្ងៃ.......................................................................................

| ឈ្មោះអតិថិជន | ឈ្មោះរឿងក្តី | នីតិវិធី | ភាពជឿនលឿនសំណុំរឿង |
|---|---|---|---|
| ១. ម៉ៅ សុក | ម៉ៅ សុក/សម សៅ | ការបណ្តេញចេញពីការងារដោយរំលោភ | -បានជួបប្រាស្រ័យ ២ដង/ម្តង១ម៉ោង<br>-បានចេញដីកាកោះរួចហើយ |
| | | | |

ហត្ថលេខាមេធាវី

# គំរូលេខ ៣
# កិច្ចសន្យាសហការ

<u>រវាង៖</u>

លោកមេធាវី..........................................អត្តលេខ.................... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទីលំនៅនៅផ្ទះលេខ..................................................ជាភាគីម្ខាង

និង

លោកមេធាវី..........................................អត្តលេខ....................ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទីលំនៅនៅផ្ទះលេខ..............................................ជាភាគីម្ខាងទៀត

បានកំណត់ និងព្រមព្រៀងគ្នា ដូចខាងក្រោម៖

<u>ប្រការ១</u>

លោកមេធាវី....................................និងលោកមេធាវី.................................. បានយល់ព្រមជាមួយគ្នា ធ្វើកិច្ចសន្យាសហការគិតពីថ្ងៃទី.............................................. តទៅ។

<u>ប្រការ២</u>

លោកមេធាវី...........................នឹងប្រគល់ទៅលោកមេធាវី............................ នូវការរៀបចំសំណុំរឿង សេវាគ្រប់បែបសម្រាប់សវនាការ សេចក្តីសន្និដ្ឋានដោះសារ និងការអនុវត្តន៍គ្រប់ការងារដែលសមស្របនឹងវិជ្ជាជីវៈ។

លោកមេធាវី........................... មានលទ្ធភាពបរិបូរណ៍ ក្នុងការបំពេញកិច្ចការនៃវិជ្ជាជីវៈមេធាវី ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន និងពង្រីកអតិថិជនផ្ទាល់ខ្លួន។

<u>ប្រការ៣</u>

លោកមេធាវី...........................នឹងប្រគល់ទៅលោកមេធាវី.........................ប្រើប្រាស់ទីកន្លែងបណ្ណាល័យ សម្ភារ និងលេខាធិការដ្ឋាន ដែលមានការចាំបាច់សម្រាប់កិច្ចសហការផង។

<u>ប្រការ៤</u>

លោកមេធាវី........................... ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវការងារដែលបានប្រគល់ឱ្យធ្វើឱ្យបានសម្រេចដូចជាការងាររបស់ខ្លួនផ្ទាល់។

ប៉ុន្តែលោកមេធាវី............................អាចសុំមិនទទួលនូវបេសកកម្ម ដែលខ្លួនយល់ថាផ្ទុយពីសម្បជញ្ញៈរបស់ខ្លួន។ លោកមេធាវី ..................................ត្រូវរៀសវៀវធ្វើពាក្យសុំមិនទទួលធ្វើនេះឱ្យបានទាន់ក្នុងចិរវេលា ដែលអាចឱ្យរកមេធាវីផ្សេងដទៃមកជំនួសបាន ដោយមិនបណ្តាលឱ្យមានការខូចខាតដល់ការិយាល័យមេធាវី ដែលប្រគល់ការងារឱ្យធ្វើផង ឬដល់អតិជនផង។

មេធាវី ត្រូវរៀបចំសកម្មភាពរបស់ខ្លួន ទៅតាមផ្ទៃរឿងដែលការិយាល័យបានប្រគល់ឱ្យផង ដែលអតិថិជនផ្ទាល់របស់ខ្លួនបានប្រគល់ឱ្យផង និងទៅតាមសកម្មភាពកម្មសិក្សាផង។

<u>ប្រការ៥</u>

មេធាវី...................................... ផ្ទេរឱ្យមេធាវី .............................................វិញ ជាបដិភាគ នៃសហការនូវប្រាក់កម្រៃក្រោមលក្ខខណ្ឌដូចតទៅនេះ៖

មេធាវីក្រោយនេះជាអ្នកទទួលខុសត្រូវខ្លួនឯង ក្នុងការបង់ប្រាក់បន្ទុកសង្គម និងពន្ធដារដែលទាក់ទិននឹងសកម្មភាពការងារនេះ។

សោហ៊ុយធ្វើដំណើរ បានចាយក្នុងក្របខ័ណ្ឌសហការ នឹងត្រូវទូទាត់ដាច់ដោយឡែកតាមបែបបទដូចតទៅ៖

..................................................................................................................................

..................................................................................................................................

<u>ប្រការ៦</u>

មេធាវី............................. ត្រូវជូនដំណឹងទៅមេធាវី ...................................... អំពីអវត្តមានរបស់ខ្លួន។ កាលបរិច្ឆេទក្នុងករណីអវត្តមានដែលអាចព្រាងទុកបាន និងត្រូវកំណត់តាមការព្រមព្រៀងទៅវិញទៅមកឱ្យបានឆាប់ ដើម្បីជៀសវាងការរំខានដល់ភាគីទាំងសងខាង។

<u>ប្រការ៧</u>

កិច្ចសន្យាសហការនេះ ពុំមានកំណត់ពេលវេលាឡើយ។

គូភាគីអាចបញ្ចប់កិច្ចសន្យាបានក្រោមការគោរពការជូនដំណឹង ៣ខែមុន។ ប៉ុន្តែក្នុងរយៈកាល ២ ខែដំបូង គូភាគីអាចបញ្ចប់កិច្ចសន្យាបាន ដោយមិនចាំបាច់គិតរយៈកាលជូនដំណឹងជាមុនឡើយ។

មេធាវី.............................. អាចតាំងទីលំនៅនៅការិយាល័យរបស់មេធាវី................. បានរហូតដល់ពេលខ្លួនបានជូនដំណឹងទៅគណៈមេធាវី អំពីលក្ខខណ្ឌសកម្មភាពថ្មីរបស់ខ្លួនហើយ ការជូនដំណឹងអំពីលក្ខខណ្ឌសកម្មភាពថ្មីនេះ ត្រូវធ្វើឡើងមិនឱ្យលើសពី៣ខែឡើយ។

ប៉ុន្តែក្រោយរយៈពេលនេះ សំបុត្រឆ្លើយឆ្លងទាំងឡាយរបស់មេធាវីនេះ ត្រូវបញ្ជូនឱ្យជាធម្មតា។

## ប្រការ៨ (កម្មសិក្សា)

មេធាវី ....................សន្យាជាបដិភាគក្នុងក្របខ័ណ្ឌសហការជាមួយមេធាវី ................ ថានឹងធានាអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មេធាវី............................................... ដោយមានការឱ្យចូលរួមពេញលេញ ក្នុងសកម្មភាពការិយាល័យ និងឱ្យជួបជាមួយអតិថិជនរបស់ខ្លួនជាដើម។

សកម្មភាពដែលត្រូវធ្វើជាកាតព្វកិច្ចនៃកម្មសិក្សា គឺមានលក្ខណៈជាអាទិភាព។

## ប្រការ៩

គ្រប់ការលំបាកដែលលេចឡើងក្នុងពេលអនុវត្ត ឬមិនបានអនុវត្ត ឬក្នុងពេលផ្តាច់កិច្ចសន្យានេះ ត្រូវដាក់ជូន០១ច្បាប់ទៅប្រធានគណៈមេធាវី ដើម្បីឱ្យជួយសម្រុះសម្រួល។

ធ្វើនៅ..................ថ្ងៃទី............ខែ.............ឆ្នាំ.............

## គំរូលេខ ៤
## លិខិតដាក់ប្រាក់តម្កល់ទុក

លោកមេធាវី................................................ បានដាក់ប្រាក់តម្កល់ទុក នៅថ្ងៃទី.................
ចំនួន...................................................................... ក្នុងគណនីនៃបេឡាទូទាត់របស់
គណៈមេធាវីសម្រាប់រឿងក្តី...................................................................................

ភ្នំពេញ, ថ្ងៃទី...........................................

មេធាវី

(ហត្ថលេខា)

## គំរូលេខ ៨

## បង្កាន់ដៃគណៈមេធាវី

ប្រធានគណៈមេធាវី បញ្ជាក់ថាបានទទួល នៅថ្ងៃទី.............................................................

ប្រាក់តម្កល់ចំនួន .....................................................................................................

ជាក្រដាសប្រាក់-មូលប្បទានប័ត្រ(១)

ពីលោកមេធាវី ..........................................................................................................

សម្រាប់រឿងក្តី ..........................................................................................................

ភ្នំពេញ, ថ្ងៃទី..........................................

ប្រធានគណៈមេធាវី

(ហត្ថលេខា)

(១) លុបចោលពាក្យឥតប្រយោជន៍

# គំរូលេខ ៦
# ពាក្យសុំឱ្យបើកប្រាក់

លោកមេធាវី....................................... សុំឱ្យគណៈមេធាវីបើកប្រាក់ឱ្យលោក ........................

ចំនួន ..........................................................................................................

សម្រាប់រឿងក្តី ...................................................................................................

ភ្នំពេញ, ថ្ងៃទី............................................

មេធាវី

(ហត្ថលេខា)

# ក្រមសីលធម៌មេធាវី
# នៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០១២

# ក្រមសីលធម៌មេធាវី
# នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១
## វិធានទូទៅ

### មាត្រា ១. គោលបំណង

ក្រមសីលធម៌មេធាវីមានគោលបំណងការពារនិងពង្រឹងឯករាជ្យភាព សេរីភាពនៃវិជ្ជាជីវៈមេធាវី និងធានាសេចក្តីថ្លៃថ្នូររបស់មេធាវី ទាំងក្នុងនិងក្រៅការប្រកបវិជ្ជាជីវៈ ដើម្បីបង្កើនជំនឿទុកចិត្តពីសាធារណជន។

### មាត្រា ២. វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះមេធាវីកម្មសិក្សា និងមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ៣. គោលការណ៍គ្រឹះ

នៅគ្រប់កាលៈទេសៈ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរព គោលការណ៍នៃសម្បជញ្ញៈ មនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។

មេធាវីមិនត្រូវចូលរួមសកម្មភាពដែលមានលក្ខណៈផ្ទុយនឹងច្បាប់ វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។

### មាត្រា ៤. បេសកកម្ម

មេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។

### មាត្រា ៥. សេរីភាពនិងឯករាជ្យភាព

មេធាវីមានសេរីភាព និងឯករាជ្យភាពនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

### មាត្រា ៦. សុចរិតភាពនិងភាពស្មោះត្រង់

មេធាវីត្រូវគោរពនិងប្រតិបត្តិ នូវគោលការណ៍សុចរិតភាពនិងភាពស្មោះត្រង់។

### មាត្រា ៧. ការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ។ ការសម្ងាត់នេះមិនត្រូវអាចឱ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ។

ពុំមានកាតព្វកិច្ចលាក់ការសម្ងាត់ទេ ល្គឹកណាមេធាវីត្រូវឆ្លើយតបទៅនឹងបណ្តឹងអតិថិជនរបស់ខ្លួន ប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកម្រិតនៃការចាំបាច់នៃការការពាររបស់ខ្លួនតែប៉ុណ្ណោះ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការផ្តល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួន និងលិខិតស្នាមទាំងឡាយដែលមេធាវីនិងអតិថិជនរបស់ខ្លួនផ្ញើទាក់ទងគ្នា។

### មាត្រា ៨. វិញ្ញាបនបត្រសមាជិកគណៈមេធាវី

មេធាវីបញ្ជាក់ពីភាពត្រឹមត្រូវនៃមុខងាររបស់ខ្លួន តាមរយៈវិញ្ញាបនបត្រដែលចេញដោយគណៈមេធាវី។

វិញ្ញាបនបត្រនេះត្រូវដកហូតមកវិញដោយគណៈមេធាវី ក្នុងករណីដែលមេធាវីបានលាឈប់ ឬត្រូវហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈក្នុងរយៈពេលមួយមានកំណត់ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី។

### មាត្រា ៩. អាវវិជ្ជាជីវៈមេធាវី

មេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវីនៅចំពោះមុខសវនាការ និងយុត្តាធិការគ្រប់ប្រភេទលើកលែងតែមានប្រពៃណីផ្ទុយពីនេះ។

មេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវី នៅពេលចូលរួមពិធីផ្លូវការ ឬបុណ្យរបស់គណៈមេធាវីតាមតម្រូវការរបស់គណៈមេធាវី។

## ជំពូកទី២
## ទីលំនៅវិជ្ជាជីវៈនិងកន្លែងពិគ្រោះយោបល់

### មាត្រា ១០. ការិយាល័យដើម

សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ ត្រូវមានការិយាល័យដើម ឬជាសមាជិកនៃការិយាល័យមេធាវីណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យដើមរបស់មេធាវីត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-នាមករណ៍ ស្លាកសញ្ញា អាសយដ្ឋានការិយាល័យ និងលេខទូរស័ព្ទ

-ទូរសារ ទូរពុម្ព គេហទំព័ររបស់ការិយាល័យនិងរូបភាពរបស់ការិយាល័យ (ប្រសិនមាន)

-បញ្ជីឈ្មោះមេធាវីដែលបានចូលរួមក្នុងការិយាល័យនេះ (ប្រសិនមាន)

-គំនូសបង្ហាញទីតាំងការិយាល័យ និងគំនូសបង្ហាញប្លង់ក្នុងការិយាល័យ

-រូបសញ្ញា (Logo) ប្រសិនបើមាន ត្រូវមានការអនុញ្ញាតពីគណៈមេធាវី

-ឯកសារពាក់ពន្ធ័ផ្សេងទៀត តាមតម្រូវការរបស់គណៈមេធាវី។

ការតាំងការិយាល័យប្រកបវិជ្ជាជីវៈ ត្រូវធ្វើនៅដាច់ដោយឡែកពីការិយាល័យពាណិជ្ជកម្ម រ៉ាប់រងឱ្យបាននូវការគោរពគោលការណ៍នៃសេចក្តីថ្លៃថ្នូរ និងឯករាជ្យភាពព្រមទាំងធានានូវការសម្ងាត់នៃវិជ្ជាជីវៈ។

សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ នៅតាមអង្គភាព ឬស្ថាប័នណាមួយដែលគ្មានការិយាល័យដើម ឬជាសមាជិកនៃការិយាល័យមេធាវីណាមួយត្រូវផ្តល់អាសយដ្ឋានជាក់លាក់ សម្រាប់ទំនាក់ទំនងជាមួយគណៈមេធាវី។

## មាត្រា ១១. ការិយាល័យសាខា

ការិយាល័យសាខា គឺជាការិយាល័យមួយដោយឡែកពីការិយាល័យដើម និងមានទីតាំងស្ថិតនៅក្រៅដែនដី រដ្ឋបាលរាជធានី-ខេត្តដែលការិយាល័យដើមតាំងនៅ។

មេធាវីដែលចង់បើកការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ ខាងលើ និងយ៉ាងតិចត្រូវមានមេធាវីពេញសិទ្ធិម្នាក់ជាអ្នកទទួលខុសត្រូវ។

ការបើកការិយាល័យសាខាត្រូវមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាគណៈមេធាវី។ ការបើកការិយាល័យសាខាធ្វើបានតែមួយគត់ នៅតាមរដ្ឋបាលដែនដីនៃរាជធានី និងខេត្តនីមួយៗ។

មេធាវីដែលមានបំណងបើកការិយាល័យសាខានៅបរទេស ត្រូវជូនដំណឹងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគោរពតាមលក្ខខណ្ឌតម្រូវនានារបស់គណៈមេធាវីបរទេសនោះ។

ដើម្បីធានាការសម្ងាត់និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវី គណៈមេធាវីអាចត្រួតពិនិត្យការិយាល័យដើម និងការិយាល័យសាខាបាននៅរាល់ម៉ោងធ្វើការ ដោយគ្រាន់តែជូនដំណឹងជាមុនក្នុងរយៈពេល៧ថ្ងៃនៃថ្ងៃធ្វើការយ៉ាងតិច ទៅការិយាល័យដែលត្រូវ ត្រួតពិនិត្យនោះ។

### មាត្រា ១២. ការិយាល័យសាខានៃមេធាវីបរទេស

មេធាវីបរទេស អាចបើកការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមេធាវីបរទេសនោះ បានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

មេធាវីបរទេសដែលគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ត្រូវគោរពតាមច្បាប់ និងវិធានវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ១៣. ទីកន្លែងទទួលពិគ្រោះច្បាប់

មេធាវីអាចទទួលពិគ្រោះច្បាប់ជូនអតិថិជននៅការិយាល័យដើម ឬក្នុងការិយាល័យសាខារបស់ខ្លួន។

មេធាវីអាចទទួលពិគ្រោះច្បាប់ នៅទីកន្លែងផ្សេងទៀតដែលមានភាពសមរម្យ និងធានាបាននូវការសម្ងាត់វិជ្ជាជីវៈ។

## ជំពូក៣
## ការផ្សព្វផ្សាយ

### មាត្រា ១៤. ការផ្សព្វផ្សាយពីមុខងារ

គណៈមេធាវី ជានាយ៉ាប់រងផ្សព្វផ្សាយពីមុខងារនៃវិជ្ជាជីវៈមេធាវីជារួម។

### មាត្រា ១៥. ការផ្សព្វផ្សាយវិជ្ជាជីវៈជាឯកជន

មេធាវីមិនត្រូវផ្ដល់នូវព័ត៌មានក្លែង ឬ បន្លំបោកប្រាស់ ឬ អួតអាងពីសេវាកម្មរបស់ខ្លួនដើម្បីផ្សព្វផ្សាយទាក់ទាញអតិថិជនឡើយ។

មេធាវីអាចធ្វើការផ្សព្វផ្សាយអំពីសេវាកម្មនៃការិយាល័យមេធាវីរបស់ខ្លួន តាមរយៈទំនាក់ទំនងជាលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក រួមទាំងប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈ បន្ទាប់ពីមានការអនុញ្ញាតពីក្រុមប្រឹក្សា។

### មាត្រា ១៦. ក្រដាសសរសេររបស់មេធាវី និងនាមប័ណ្ណរបស់មេធាវី

ក្រដាសសរសេររបស់មេធាវីត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូលបកតិនាមមេធាវី ឬ នាមករណ៍នៃក្រុមហ៊ុនមេធាវី
- រូបសញ្ញា Logo ប្រសិនជាមាន

- និទ្ទេស "មេធាវី" ឬ "មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា"
- ទីលំនៅវិជ្ជាជីវៈដើម ហើយបើមានការិយាល័យសាខា ត្រូវចុះអាសយដ្ឋាននៃការិយាល័យសាខា ដែលបានបើកដោយត្រឹមត្រូវតាមច្បាប់
- លេខកូដប្រៃសណីយ៍ ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដទៃទៀត ប្រសិនជាមាន។

មេធាវីទាំងឡាយដែលបំពេញការងារនៅការិយាល័យប្រមូលផ្តុំ ដោយពុំបានធ្វើជាសមាគមក្រោមរូបភាពណាមួយ អាចត្រូវអនុញ្ញាតឱ្យប្រើក្រដាសសរសេររួមបាន ក្រោមលក្ខខណ្ឌដែលមិនបង្កើតឱ្យមានការភ័ន្តច្រឡំជាមួយរចនាសម្ព័ន្ធការងារ។

នាមប័ណ្ណផ្ទាល់របស់មេធាវីត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូល បកតិនាមមេធាវី ឬ នាមករណ៍នៃក្រុមហ៊ុនមេធាវី
- រូបសញ្ញា Logo ប្រសិនជាមាន
- និទ្ទេស "មេធាវី"
- ទីលំនៅវិជ្ជាជីវៈដើម ហើយបើមានការិយាល័យសាខា ត្រូវចុះអាសយដ្ឋាននៃការិយាល័យសាខា ដែលបានបើកដោយត្រឹមត្រូវតាមច្បាប់
- លេខកូដប្រៃសណីយ៍ ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដទៃទៀត ប្រសិនជាមាន។

### មាត្រា ១៧. អន្តរាគមន៍តាមប្រព័ន្ធផ្សាយព័ត៌មានជាសាធារណៈនៃមេធាវី

គ្រប់អន្តរាគមន៍សាធារណៈ ឬតាមប្រព័ន្ធផ្សាយព័ត៌មានជាសាធារណៈរបស់មេធាវីក្នុងឋានៈខ្លួនជាមេធាវី អាចអនុញ្ញាតឱ្យធ្វើបានតែក្នុងក្របខ័ណ្ឌនៃការគោរពដោយម៉ឺងម៉ាត់នូវកាតព្វកិច្ចនៃវិជ្ជាជីវៈ។ អន្តរាគមន៍បែបនេះ ទាមទារឱ្យមានការប្រុងប្រយ័ត្ន។

## ជំពូកទី៤
## មេធាវី និងអតិថិជន

### មាត្រា ១៨. ទំនាក់ទំនងរវាងមេធាវី និងអតិថិជន

ទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងតាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទំលាប់ និងពីការព្រមព្រៀងគ្នាទៅវិញទៅមក។ មេធាវីគឺជាអ្នកកាន់តំណែងការពារ និងតំណាងឱ្យអតិថិជន។

ទំនាក់ទំនងរវាងមេធាវី និងអតិថិជន កើតមាននៅពេលជនណាម្នាក់ បង្ហាញពីបំណងចង់ឱ្យមេធាវី ផ្តល់សេវាកម្មផ្នែកច្បាប់ ហើយមេធាវីនោះយល់ព្រម។

## មាត្រា ១៩. ការសម្ងាត់វិជ្ជាជីវៈ

មេធាវីគ្រប់រូបមានកាតព្វកិច្ចរក្សាការសម្ងាត់ជូនអតិថិជនរបស់ខ្លួនជាដាច់ខាត ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ មេធាវីមិនត្រូវបង្ហាញការសម្ងាត់របស់អតិថិជនខ្លួនឡើយ លើកលែងតែមានការជូនដំណឹង និងយល់ព្រមពីអតិថិជន ឬកាលណាមានការអនុញ្ញាតដោយច្បាប់ ឬតម្រូវដោយច្បាប់។

## មាត្រា ២០. បញ្ហាលើការតាក់តែងលិខិតស្នាមដោយមេធាវី

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមតែម្នាក់ឯង តាមការព្រមព្រៀងពីគូភាគី អាចធ្វើសកម្មភាព ឬការពារលើការអនុវត្តលិខិតនោះបាន នៅពេលដែលការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់លើលិខិតស្នាមនោះលេចជាបញ្ហា តែមិនត្រូវធ្វើសកម្មភាពប្រឆាំងនឹងភាគីណាមួយដែលមាននៅក្នុងលិខិតស្នាមនោះឡើយ។

មេធាវីដែលបានចូលរួមក្នុងការតាក់តែងលិខិតស្នាម ក្នុងឋានៈជាទីប្រឹក្សារបស់ភាគីម្ខាង អាចធ្វើសកម្មភាពឬការពារលើការអនុវត្តន៍លិខិតនោះតទល់នឹងភាគីម្ខាងទៀតបាន។

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមឬដែលជាអ្នកចូលរួមតាក់តែង មិនអាចបំពេញកិច្ចការ ឬ ការពារលើសុពលភាព ឬ លើការបកស្រាយលិខិតស្នាមដែលខ្លួនបានសរសេរនោះទេ កាលបើការអន្តរាគមន៍របស់ខ្លួន នាំខ្លួនឱ្យទៅជាសាក្សី ឬ ឱ្យប៉ះពាល់ដល់ការសម្ងាត់វិជ្ជាជីវៈ។ មេធាវីនេះ ក៏មិនអាចធ្វើអន្តរាគមន៍ទៅកើតដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនត្រូវលេចជាបញ្ហាឡើង។

## មាត្រា ២១. ការតាក់តែងលិខិតដោយមេធាវីរួមគ្នា

មេធាវីម្នាក់ៗ ត្រូវប្រមូលផ្តុំនូវឯកសារព័ត៌មានផ្ទាល់របស់អតិថិជនខ្លួន។ មេធាវីម្នាក់ៗ ត្រូវផ្ទៀងផ្ទាត់ពិនិត្យភាពត្រឹមត្រូវ ឬ ភាពសច្ចៈនៃអត្តសញ្ញាណរបស់បុគ្គលនៃនិទ្ទេសនានា និងឯកសារនានាដែលអតិថិជនខ្លួនបានប្រគល់ឱ្យ និងហត្ថលេខាដែលខ្លួនបានឱ្យចុះ។

លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ មេធាវីដែលរ៉ាប់រងការរៀបចំលិខិតស្នាម ត្រូវចាប់ផ្តើមកិច្ចការភ្លាម និងចាប់ផ្តើមធ្វើទម្រង់ការចាំបាច់នានាសម្រាប់សុពលភាពនិងប្រសិទ្ធភាព។ បន្ទាប់មក មេធាវីនេះត្រូវជូនទៅសហភាគីរបស់ខ្លួននូវលិខិតស្នាមគ្រប់ច្បាប់ដែលត្រូវបញ្ជូនត្រឡប់ទៅឱ្យអតិថិជនរបស់សហភាគីនេះ។

មេធាវីម្នាក់ៗត្រូវទទួលខុសត្រូវចំពោះមុខសហភាគីរបស់ខ្លួន អំពីការខ្វះខែ្វង អំពីបែបបទដែលខ្លួនជាអ្នកទទួលបន្ទុកត្រូវធ្វើក្នុងផលប្រយោជន៍រួម ប៉ុន្តែក្នុងលក្ខខណ្ឌដែលខ្លួនត្រូវបានទទួលមូលនិធិចាំបាច់រួចហើយសិន។

## មាត្រា ២២. ការទទួលរឿងក្តី

មេធាវីមានសិទ្ធិទទួលឬមិនទទួលជួយអតិថិជន លើកលែងតែត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។ មេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីផ្ទាល់ឬតតីយជន។

ប្រសិនបើយល់ព្រមទទួលយកបេសកកម្ម មេធាវីត្រូវបំពេញបេសកកម្មនោះ ដោយយកចិត្តទុកដាក់ រហូតដល់ចប់បេសកកម្ម លើកលែងតែអតិថិជនឈប់ពឹងពាក់។

ប្រសិនបើយល់ព្រមទទួល មេធាវីត្រូវពន្យល់ប្រាប់អតិថិជនរបស់ខ្លួនអំពីលក្ខណៈនៃរឿងក្តី ជម្រើសនៃវិធីដោះស្រាយ កម្រៃសេវាមេធាវី ការចំណាយ និងកម្រៃផ្សេងៗទៀត ដោយផ្អែកលើព័ត៌មានដែលទទួលបានពីអតិថិជន។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន និងក្នុងការគោរពសេរីភាពរបស់អតិថិជន មេធាវីត្រូវស្ថិតនៅជាម្ចាស់នៃមធ្យោបាយការពារ។

មេធាវីមិនត្រូវផ្តល់នូវការធានា ចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ។

## មាត្រា ២៣. លិខិតប្រគល់សិទ្ធិ

ក្នុងគ្រប់រឿងអ្វីក៏ដោយ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិ ឬលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬ ពាក្យពឹងពាក់ពីអតិថិជនរបស់ខ្លួន។

ខ្លឹមសារនៃលិខិតទាំងអស់ខាងលើនេះ ត្រូវសរសេរលំអិតអំពីសិទ្ធិនិងតួនាទីរបស់មេធាវីដែលអតិថិជនប្រគល់ឱ្យស្របតាមច្បាប់ និងគំរូដែលគណៈមេធាវីកំណត់។

## មាត្រា ២៤. ទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន

ការទាក់ទងជាមួយអតិថិជនត្រូវធ្វើដោយចំពោះនិងផ្ទាល់ខ្លួន។ មេធាវីមិនអាចទទួលរឿងក្តីមួយតាមរយៈតតិយជនបានឡើយ បើខ្លួនគ្មានសេរីភាពនឹងចូលទាក់ទងផ្ទាល់ខ្លួនជាមួយអតិថិជនដែលមានរឿងនោះបាន។

វិធាននេះអាចមិនត្រូវប្រតិបត្តិតាមបាន លុំកណាមេធាវីដើរតួជាអ្នកឆ្លើយឆ្លងរបស់មេធាវីម្នាក់ទៀត។

## មាត្រា ២៥. ទំនាស់ផលប្រយោជន៍

មេធាវី មិនត្រូវទទួលរឿងក្តីទាំងឡាយដូចខាងក្រោម ៖

-រឿងក្តីមួយដែលមេធាវីខ្លួនឯង ឬ ក្រុមមេធាវីរបស់ខ្លួន បានជួយបដិភាគីនៅក្នុងការផ្តល់យោបល់ ឬ បានទទួលយល់ព្រមតំណាងឱ្យបដិភាគីរួចហើយ

-នៅពេលដែលផលប្រយោជន៍របស់អតិថិជនម្នាក់ មានទំនាស់ជាមួយផលប្រយោជន៍អតិថិជនម្នាក់ទៀតនៅក្នុងរឿងក្តីដែលមេធាវី ឬ ក្រុមមេធាវីរបស់ខ្លួនកំពុងកាន់

-នៅពេលដែលអតិថិជនទាំងពីរ ជាភាគីវិវាទនៅក្នុងរឿងក្តីតែមួយ

-នៅពេលដែលអតិថិជនម្នាក់ចង់ពឹងពាក់មេធាវី ឬ ក្រុមមេធាវីរបស់ខ្លួន តែមេធាវី ឬ ក្រុមមេធាវីនេះធ្លាប់ បានទទួលជួយបដិភាគីក្នុងរឿងក្តីដទៃ ឬ មេធាវីបានយល់ព្រមផ្តល់យោបល់ផ្នែកច្បាប់បន្តទៀត លើកលែងតែរឿងក្តីចុងក្រោយដែលមេធាវី ឬ ក្រុមមេធាវីដែលធ្លាប់ពាក់ព័ន្ធនោះបានកន្លងផុតទៅ អស់រយៈពេល២(ពីរ)ឆ្នាំ

-រឿងក្តីមួយដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនបានដើរតួជាអាជ្ញាកណ្តាល អ្នកផ្សះផ្សា ឬ អ្នកសម្របសម្រួលក្នុងទម្រង់នីតិវិធីនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។

ករណីដែលមេធាវី ឬ ក្រុមមេធាវី ជាទីប្រឹក្សា ឬ ធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបាន លុះត្រាតែត្រូវជម្រាបទៅភាគីឯទៀត និងបន្ទាប់ពីទទួលបាន ការយល់ព្រមសិន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពថ្លៃថ្នូរ កិត្តិយស និងការសម្ងាត់វិជ្ជាជីវៈ។

## មាត្រា ២៦. អតិថិជនជាប់ឃុំ

មេធាវី មិនត្រូវផ្តល់មធ្យោបាយ ឬវត្ថុផ្សេងៗ ដែលច្បាប់ហាមឃាត់ទៅអតិថិជនដែលកំពុងជាប់ឃុំ។

## មាត្រា ២៧. កម្រៃមេធាវី

កម្រៃសេវាកម្មមេធាវី គឺជាកម្មវត្ថុនៃការព្រមព្រៀងគ្នា រវាងមេធាវីនិងអតិថិជន។

ជាទូទៅ មេធាវីមិនត្រូវបែងចែកកម្រៃសេវាទៅឱ្យមេធាវីផ្សេងទៀតឡើយ លើកលែងតែករណីដូចខាងក្រោម៖

-មេធាវីជាដៃគូនៅក្នុងការិយាល័យ ឬ ក្រុមមេធាវីជាមួយគ្នា

-មេធាវីដទៃទៀតដែលមិននៅក្នុងការិយាល័យ ឬ ក្រុមមេធាវីជាមួយគ្នា តែមានការទទួលខុសត្រូវរួមគ្នាចំពោះរឿងក្តី ការបែងចែកត្រូវធ្វើទៅតាមសមាមាត្រទៅនឹងសេវាដែលបំពេញដោយមេធាវីម្នាក់ចំពោះរឿងនីមួយៗ ឬតាមចំនួនសមាមាត្រផ្សេងទៀត តាមការព្រមព្រៀង ។

## មាត្រា ២៨. វិវាទជាមួយអតិថិជន

មេធាវីត្រូវព្យាយាមរក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងព្យាយាមបញ្ចៀសជម្លោះជាមួយអតិថិជន។ ប្រសិនបើមានទំនាស់ជាមួយអតិថិជន មេធាវីត្រូវព្យាយាមដោះស្រាយទំនាស់នោះដោយសន្តិវិធីតាមរយៈការ សម្រុះសម្រួលដោយស្ថាប័នគណៈមេធាវី។

## មាត្រា ២៩. ការប្រកែក និងការបោះបង់ចោលបេសកកម្ម

មេធាវីត្រូវប្រកែកមិនព្រមទទួលយកបេសកកម្មទាំងឡាយណា ឬអំពើទាំងឡាយណាដែលផ្ទុយពីវិធានវិជ្ជាជីវៈនិងសម្បជញ្ញៈរបស់ខ្លួន។

មេធាវីមិនត្រូវតំណាង ឬ ការពារ ឬ ត្រូវបញ្ឈប់ការតំណាង ឬ ការពារអតិថិជន បើការតំណាង ឬការការពារបានចាប់ផ្តើមរួចហើយ នៅក្នុងករណីដូចខាងក្រោម៖

-ការតំណាង ឬការការពារនោះ នឹងក្លាយជាលទ្ធផលនៃការរំលោភលើវិធានវិជ្ជាជីវៈ ឬច្បាប់ផ្សេងទៀត

-ស្ថានភាពរាងកាយ ឬ ស្មារតីរបស់មេធាវីធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៅក្នុងការតំណាងការពាររឿងក្តី

-មេធាវីដែលត្រូវបានហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈ ឬលុបឈ្មោះចេញពីបញ្ជីគណៈមេធាវីដោយទណ្ឌកម្មវិន័យ។

ដោយសារបុព្វហេតុដែលចេញពីសម្បជញ្ញៈរបស់ខ្លួន មេធាវីអាចសម្រេចបញ្ឈប់បេសកកម្មរបស់ខ្លួន ប្រសិនបើមានមូលហេតុដូចខាងក្រោម៖

-អតិថិជន បន្តប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ អំពើទុច្ចរិត

-អតិថិជន បានប្រើប្រាស់សេវាកម្មរបស់មេធាវី ដើម្បីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឬ អំពើទុច្ចរិត

-គោលបំណងរបស់អតិថិជនមិនអាចទទួលយកបាន ឬ ផ្ទុយពីជំនឿរបស់មេធាវី

-អតិថិជន មិនសហការជាមួយមេធាវី

-អតិថិជន ខកខានមិនបានបំពេញកាតព្វកិច្ចចំពោះមេធាវី ទាក់ទងនឹងសេវាកម្មរបស់មេធាវី និងបន្ទាប់ពីបានជូនដំណឹងដ៏សមស្របថា មេធាវីនឹងបញ្ឈប់បេសកកម្មរបស់ខ្លួនលុះត្រាតែកាតព្វកិច្ចបានបំពេញ

-មានមូលហេតុសមស្របផ្សេងទៀត សម្រាប់ការបញ្ឈប់បេសកកម្ម។

មុនពេលបញ្ឈប់បេសកកម្មរបស់ខ្លួន មេធាវីត្រូវតែជូនដំណឹងទៅអតិថិជនអំពីការបញ្ឈប់ ឬ ការដកខ្លួននេះ ក្នុងពេលវេលាមួយសមស្របដែលផ្តល់លទ្ធភាពឱ្យអតិថិជននេះ អាចបង្ការផលប្រយោជន៍របស់ខ្លួនបាននិងស្វែងរកមេធាវីផ្សេងទៀត។

មេធាវីត្រូវដឹងឱ្យច្បាស់ថា បេសកកម្មនោះ ស្ថិតនៅក្នុងក្របខ័ណ្ឌជានាប់រងពីក្រុមហ៊ុនដែលជានាប់រងចំពោះខ្លួន។

## មាត្រា ៣០. ការបញ្ឈប់បេសកកម្មមេធាវីដោយអតិថិជន

អតិថិជនអាចបញ្ឈប់បេសកកម្មរបស់មេធាវីនៅពេលណាក៏បាន ដោយមានឬគ្មានមូលហេតុ។ ប៉ុន្តែអតិថិជនត្រូវទទួលខុសត្រូវបង់កម្រៃសេវាកម្មមេធាវីដែលបានព្រមព្រៀង។

## មាត្រា ៣១.

ករណីយកិច្ចរបស់មេធាវី ក្រោយការបញ្ឈប់និងការបញ្ចប់បេសកកម្ម លើកលែងតែមានការហាមឃាត់ដោយច្បាប់និងវិធានវិជ្ជាជីវៈ មេធាវីត្រូវ៖

- ប្រគល់ទៅឱ្យអតិថិជនតាមការស្នើសុំរបស់គេ នូវបញ្ជីស្រង់ប្រាក់ដែលមេធាវីបានចេញជំនួស ចំណាយផ្សេងៗ និងប្រាក់កម្រៃមេធាវី។

-ប្រគល់ឱ្យភាគីហត្ថលេខីនីមួយៗនូវលិខិតដើម ព្រមទាំងឯកសារទាំងអស់ ដែលបញ្ជាក់អំពីការបានបំពេញបែបបទគ្រប់សព្វ បើបេសកកម្មនោះជាការតាក់តែងលិខិតស្នាម។

-ប្រគល់ត្រឡប់ទៅឱ្យអតិថិជនវិញ នូវឯកសារទាំងអស់ដែលខ្លួនបានទទួលទុកដោយគ្មានសិទ្ធិរក្សា ទុកអ្វីទាំងអស់។

ការប្រគល់ឯកសារខាងលើនេះ ត្រូវមានបញ្ជីរាយឈ្មោះឯកសារ និងមានហត្ថលេខាឬស្នាមមេដៃប្រគល់-ទទួលត្រឹមត្រូវ។

## ជំពូកទី៩
## ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី

### មាត្រា ៣២. ភាគីដែលមានជំនួយពីមេធាវី

មេធាវីអាចទាក់ទងជាមួយភាគីម្ខាងទៀតដែលខ្លួនដឹងថាមានមេធាវីជួយ លុះត្រាតែការទាក់ទងនោះធ្វើ នៅចំពោះមុខមេធាវីរបស់ភាគីម្ខាងទៀតឬទាល់តែមានការយល់ព្រមពីមេធាវីនោះ។

លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ រាល់ការជួបប្រជុំត្រូវធ្វើនៅចំពោះមុខភាគីទាំងអស់ និងមេធាវីរបស់ពួកគេ។

### មាត្រា ៣៣. ភាគីដែលគ្មានជំនួយពីមេធាវី

មុនធ្វើសកម្មភាពបណ្តឹង មេធាវីដោយមានការយល់ព្រមពីអតិថិជនរបស់ខ្លួនផង អាចទាក់ទងជាមួយភាគីម្ខាងទៀត ដើម្បីរកការដោះស្រាយដោយសម្រុះសម្រួលគ្នា។

ក្នុងឱកាសនោះ មេធាវីមិនត្រូវធ្វើការកៀបសង្កត់ បង្ខិតបង្ខំ ឬបញ្ឆោះបញ្ឆូលឱ្យភាគីម្ខាងទៀតយល់ខុស ដើម្បីសម្រេចនូវគោលដៅរបស់ខ្លួននោះទេ។

មុននឹងពិភាក្សាគ្នា មេធាវីត្រូវរំលឹកទៅភាគីម្ខាងទៀត អំពីសិទ្ធិរបស់គេដែលត្រូវមានជំនួយពីមេធាវី។

### មាត្រា ៣៤. ការទាញយកឬការផ្តល់ផលប្រយោជន៍ដល់ភាគីម្ខាងទៀត

មេធាវីមិនត្រូវទាញយក ឬ ផ្តល់ផលប្រយោជន៍ ឬ ទទួលយកពិធីកំសាន្តពីសំណាក់ភាគីម្ខាងទៀត នៅក្នុងទំនាក់ទំនងនៃរឿងក្តីឡើយ ប្រសិនបើអំពើនេះ ធ្វើឱ្យមានឥទ្ធិពលដល់រឿងក្តីដែលកំពុងដំណើរការ។

### មាត្រា ៣៥. តតិយជននិងសាក្សី

ក្នុងក្របខ័ណ្ឌសាលាជម្រះក្តីណាមួយ និងគ្រប់ករណី ឬ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងវិធាននីតិវិធី មេធាវីអាចចូលទំនាក់ទំនងជាមួយនឹងតតិយជន ដើម្បីសុំឱ្យផ្តល់ដោយស្រុះស្រួលគ្នានូវឯកសារដែលគេមាន។ បើសុំមិនបានទេ មេធាវីអាចឱ្យចៅក្រមទាមទារឱ្យខ្លួនបាន។

មេធាវី ត្រូវហាមឃាត់ប្រើឥទ្ធិពលតាមវិធីណាមួយក៏ដោយ លើសាក្សីនិង/ឬជនដែលអាចជាសាក្សីដែលនាំឱ្យប៉ះពាល់ដល់សក្ខីកម្មរបស់ជននោះជាដាច់ខាត។

### មាត្រា ៣៦. ការល្បួងឱ្យភូតភរតុលាការ

មេធាវី ដាច់ខាតមិនត្រូវល្បួងសាក្សីឱ្យប្រព្រឹត្តអំពើភូតភរ ឬក្លែងសក្ខីកម្ម ព្រមទាំងមិនត្រូវដាក់ភស្តុតាងក្លែងជូនដល់តុលាការឡើយ។

## ជំពូកទី ៦
## ទំនាក់ទំនងជាមួយតុលាការ

### មាត្រា ៣៧. ទំនាក់ទំនងជាមួយចៅក្រម

មេធាវីត្រូវណែនាំខ្លួនជូនចៅក្រម ចំពោះរឿងក្តីដែលខ្លួនការពារឬតំណាងដោយអាណត្តិ។

មេធាវីត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈ នៅចំពោះមុខតុលាការ។

មេធាវីត្រូវគោរពតាមវិធាននីតិវិធីនិងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។ មេធាវីមានសិទ្ធិសំដែងឡើងនូវអ្វីៗដែលខ្លួនយល់ថា មានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។

មេធាវីត្រូវរួចផុតពីការចោទប្រកាន់ក្នុងបទព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណីចំពោះសេចក្តីថ្លែងការណ៍ឬសារណា ទោះធ្វើជាលាយលក្ខណ៍អក្សរក្តី ជាផ្ទាល់មាត់ក្តី ក្នុងបំណងសុចរិតដើម្បីការពារនៅចំពោះមុខតុលាការ សាលាជម្រះក្តី ឬ អាជ្ញាធរផ្សេងៗទៀត។

ក្នុងករណីមានទំនាស់ជាមួយចៅក្រមពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ ឬសារណា មេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានគណៈមេធាវីភ្លាម។

### មាត្រា ៣៨. ការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងគោរពតាមនីតិវិធីដ៏ត្រឹមត្រូវ

មេធាវីត្រូវទាមទារ និងស្វះស្វែងធ្វើឱ្យមានការជំនុំជម្រះក្ដីដោយយុត្តិធម៌ គោរពតាមច្បាប់ និងនីតិវិធីដ៏ត្រឹមត្រូវឱ្យកើតមានយ៉ាងពិតប្រាកដ។

### មាត្រា ៣៩. ការពន្យារពេលក្នុងនីតិវិធីតុលាការ

មេធាវីមិនត្រូវបង្កឱ្យមានការពន្យានីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬ មូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ។

### មាត្រា ៤០. ការទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបុគ្គលសាធារណៈ

មេធាវីមិនត្រូវប្រើប្រាស់ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយចៅក្រម ព្រះរាជអាជ្ញា មន្ត្រីរាជការ ឬ បុគ្គលមានអំណាចផ្សេងទៀត មកពាក់ព័ន្ធនៅក្នុងនីតិវិធីតុលាការក្នុងការដោះស្រាយរឿងក្ដីនោះទេ។

មេធាវីមិនត្រូវជួយដោយផ្ទាល់ ឬដោយប្រយោលដល់ចៅក្រមក្នុងការប្រព្រឹត្តអំពើខុសច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឡើយ។

## ជំពូកទី៧
## ទំនាក់ទំនងជាមួយសហភាតា
## និងសមាជិកនៃវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា

### មាត្រា ៤១. វិធានទូទៅនិងវិធានផ្សេងៗ

គ្រប់ទំនាក់ទំនងរវាងសហភាតា មេធាវីត្រូវប្រព្រឹត្តដោយសេចក្ដីថ្លៃថ្នូរ សម្បជញ្ញៈ សេចក្ដីទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យ ទេពកោសល្យប៉ិនប្រសប់ គួរសមជានិច្ច និងដោយគោរពវិធានវិជ្ជាជីវៈរបស់ខ្លួន។

ក្នុងការគោរពផលប្រយោជន៍អតិថិជនរបស់ខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនឹងនាំឱ្យខូចខាតដល់សហភាតាខ្លួនឡើយ។

មេធាវីត្រូវជូនដំណឹងជាមុនតាមគ្រប់មធ្យោបាយ ដល់សហភាតានៃភាគីម្ខាងទៀត អំពីការសុំពន្យាពេលក្នុងនីតិវិធីណាមួយ ឬ ការធ្វើបណ្ដឹងឧបាស្រ័យ ព្រមទាំងការចាប់ផ្ដើមធ្វើនីតិវិធីថ្មីណាមួយ លើកលែងតែមានការចាំបាច់ក្នុងការការពារផលប្រយោជន៍ចម្បងរបស់អតិថិជន។

មេធាវីត្រូវជូនដំណឹងបង្គលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងនានា ដល់សហភាតាដោយគ្មានការយឺតយ៉ាវ។

ការប្រជុំនិងការណាត់ជួបគ្នា ត្រូវកំណត់ដោយការព្រមព្រៀងជាមួយគ្នាឱ្យសមស្រប និងអធ្យាស្រ័យរៀងៗខ្លួន។ ជាធម្មតា ការប្រជុំនិងការណាត់ជួបគ្នានេះ ត្រូវមកកន្លែងការិយាល័យរបស់មេធាវីដែលមានអតីតភាពច្រើនជាង។

លំដាប់ថ្នាក់ហៅចូលសវនាការ ត្រូវចាត់ឡើងដោយស្មើភាពគ្នាទាំងអស់រវាង សហភាតា លើកលែងតែប្រធានគណៈមេធាវីដែលត្រូវតែហៅមុនគេ។

ទំនាស់សព្វយ៉ាងរវាងសហភាតា ត្រូវដោះស្រាយតាមការចរចារដោយសន្តិវិធីឬដោយប្រធានគណៈមេធាវី។

## មាត្រា ៤២. ការប្ដឹងទៅស្ថាប័នយុត្តាធិការ

មុននឹងមេធាវីណាម្នាក់ ឬ ច្រើននាក់ ចាប់ផ្តើមធ្វើសកម្មភាពបណ្តឹងទៅស្ថាប័នយុត្តាធិការណាមួយពីមេធាវីណាម្នាក់ ឬ ច្រើននាក់ មេធាវីនោះត្រូវតែជូនដំណឹងជាមុនទៅប្រធានគណៈមេធាវី។

វិវាទទាំងឡាយដែលកើតឡើងរវាងសហភាតា ក្រៅតែអំពីការអនុវត្តន៍នៃវិធាននីតិវិធីតុលាការ ត្រូវស្នើសុំឡើងទៅរកការសម្រុះសម្រួលដោយប្រធានគណៈមេធាវី។

មុននឹងមេធាវីណាម្នាក់ ឬ ច្រើននាក់ចាប់ផ្តើមធ្វើសកម្មភាពបណ្តឹង ពីសមាជិកណាម្នាក់ ឬ ច្រើននាក់នៃវិជ្ជាជីវៈគតិយុត្តផ្សេងទៀត ឬ តុលាការណាមួយ មេធាវីនោះត្រូវជូនដំណឹងជាមុនដល់ប្រធានគណៈមេធាវី។

## មាត្រា ៤៣. សំបុត្រឆ្លងឆ្លើយរវាងសហភាតា

ក.ការឆ្លងឆ្លើយតាមលិខិត ឬ តាមសំដីរវាងមេធាវី និងមេធាវីធម្មតាត្រូវជាការសម្ងាត់។

ទោះក្នុងប្រការណាក៏ដោយ ការឆ្លងឆ្លើយនេះមិនអាចរឹបអូស ឬ មិនអាចបង្ហាញជាសក្ខីកម្មក្នុងតុលាការ និងមិនអាចទុកជាកម្មវត្ថុនៃការលើកភាពសម្ងាត់ចេញបានឡើយ។

ខ.មិនមែនជាការសម្ងាត់៖

- សំបុត្រ ឬ សារអេឡិចត្រូនិកដែលជំនួសលិខិតនីតិវិធី
- សំបុត្រ ឬ សារអេឡិចត្រូនិកដែលមានដាក់ថា "ផ្លូវការ" ហើយដែលបញ្ជូនសេចក្តីស្នើណាមួយ ឬឯកសារមិនសម្ងាត់នានាមក

- ការប្តូរសំបុត្រ ឬ ការឆ្លើយឆ្លងគ្នាទៅវិញទៅមក តាមរយៈសារអេឡិចត្រូនិក ដែលមានដាក់ថា «ផ្លូវការ» ដើម្បីបង្ហាញបញ្ជាក់កិច្ចព្រមព្រៀងណាមួយ ឬ ការចុះហត្ថលេខានៃកិច្ចព្រមព្រៀងណាមួយរវាងមេធាវី និងមេធាវី ក្នុងកម្រិតលក្ខខណ្ឌនៃអាណត្តិរបស់ខ្លួន។ សំបុត្រសារអេឡិចត្រូនិក និងឯកសារទាំងនេះ មិនត្រូវមានយោងទៅលើការប្តូរសំបុត្រគ្នាទៅវិញ ទៅមក ឬក៏ការប្រាស្រ័យគ្នាពីលើកមុនដែលមានលក្ខណៈជាសម្ងាត់នោះឡើយ។

គ. ក្នុងករណីដែលមានការបំពានលើវិធានទាំងឡាយដូចមានចែងក្នុងចំណុច (ក)និង (ខ) នៃមាត្រានេះ ប្រធានគណៈមេធាវីត្រូវធានារ៉ាប់រងឱ្យមានការគោរពនូវគោលការណ៍សំខាន់ៗនៃវិជ្ជាជីវៈមេធាវីតាមក្រមសីលធម៌។

ឃ. ក្នុងការទំនាក់ទំនងជាមួយមេធាវីបរទេសណាមួយ មេធាវីមុននឹងប្តូរព័ត៌មានសម្ងាត់គ្នាទៅវិញទៅមក ត្រូវដឹងឱ្យច្បាស់អំពីភាពវិជ្ជមាននៃវិធានក្នុងការរក្សាការសម្ងាត់នៃការឆ្លងឆ្លើយនៅក្នុងប្រទេស ដែលមានមេធាវីបរទេសប្រកបមុខការ។ នៅក្នុងករណីអវិជ្ជមានវិញ មេធាវីត្រូវសួរអតិថិជនរបស់ខ្លួនថាតើ គាត់យល់ព្រមហ៊ានប្រថុយឱ្យការសម្ងាត់នៃការឆ្លងឆ្លើយប្តូរព័ត៌មាននោះ ឬ អត់។

## មាត្រា ៤៤. ជំនាក់ជំនង់ដែលត្រូវហាមឃាត់

មេធាវីត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះការរំលោភបំពានវិធានវិជ្ជាជីវៈនូវអំពើដូចខាងក្រោម៖

- មានចេតនាបំពានវិធានវិជ្ជាជីវៈ

-ជួយសហការ ផ្តល់មធ្យោបាយ ឬ សម្រួលដល់មេធាវីបរទេស ឬ បុគ្គលដទៃទៀត ឱ្យរំលោភបំពាន វិធានវិជ្ជាជីវៈ

-ប្រើប្រាស់ទំនាក់ទំនងជាមួយមេធាវីបរទេស ឬ បុគ្គលដទៃទៀត ដើម្បីរំលោភបំពានវិធានវិជ្ជាជីវៈ

-ចូលរួមបង្កើត និងសហការជាមួយនឹងរូបវន្តបុគ្គល ឬ នីតិបុគ្គល ឬ មេធាវីបរទេសដែលមិនមែនជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី ឬ ប្រកបវិជ្ជាជីវៈមេធាវីយកកម្រៃ។

## មាត្រា ៤៩. ការប្តូរមេធាវីនិងការបន្ថែមមេធាវី

មុននឹងទទួលយកបេសកកម្មពីអតិថិជនណាមួយ មេធាវីត្រូវតែពិនិត្យផ្ទៀងផ្ទាត់ឱ្យឃើញថា គ្មានសហភាតាណាមួយបានទទួលយកបេសកកម្មនោះមុនខ្លួនទេ។

មេធាវីដែលទទួលបេសកកម្មបន្តពីសហភាតាណាម្នាក់ ឬ ទទួលធ្វើអន្តរាគមន៍អមសហភាតាមុនត្រូវជូនដំណឹងដល់សហភាតានោះឱ្យបានដឹងមុន ហើយសួរអំពីប្រាក់សោហ៊ុយ និងប្រាក់កម្រៃដែលគេត្រូវបាន។ ក្នុងករណីមិនទាន់បានទូទាត់ប្រាក់សេវាជាមួយមេធាវីមុនទេ មេធាវីក្រោយមិនអាចទទួលយកបេសកកម្មបន្តនេះបានទេ លើកលែងតែមានការយល់ព្រមពីសហភាតាមុន ឬ មានសេចក្តីសម្រេចផ្សេងពីនេះដោយប្រធានគណៈមេធាវី។

មេធាវីដែលត្រូវគេឱ្យឈប់ធ្វើរឿងក្តីនោះ ត្រូវឆ្លើយតបយ៉ាងរហ័ស និងបញ្ជូនមកនូវអ្វីៗទាំងអស់របស់សំណុំរឿង ទៅឱ្យមេធាវីដែលទទួលបេសកកម្មបន្ត ដែលខ្លួនគ្មានសិទ្ធិអ្វីនឹងឃាយាំងទុកតទៅទៀតឡើយ។

ករណីមានវិវាទលើកម្រៃ ត្រូវប្តឹងទៅប្រធានគណៈមេធាវី ហើយប្រធានគណៈមេធាវីអាចសុំយកប្រាក់កម្រៃនោះតម្កល់ទុកសិន។

មេធាវីដែលបន្ត ត្រូវជូនដំណឹងអំពីអន្តរាគមន៍របស់ខ្លួនទៅមេធាវីនៃភាគីម្ខាងទៀត ឬ ជាយថាហេតុទៅយុត្តាធិការដែលទទួលបណ្តឹង។

បើមេធាវីដែលគេមកពឹងពាក់ មិនទាន់ចង់ឆ្លើយព្រមទទួលរឿងក្តីភ្លាម មេធាវីនោះ ត្រូវសរសេរទៅប្រាប់សហភាតា ដោយសុំឱ្យផ្ញើសំណុំរឿងមកពិនិត្យ ដោយមានការយល់ព្រមពីអតិថិជន។ មេធាវីនោះត្រូវតែឆ្លើយ ប្រាប់អំពីជំហររបស់គាត់ក្នុងអំឡុងពេលយ៉ាងយូរ១ខែ។ ផុតពីនេះ ត្រូវចាត់ទុកថា គាត់មិនយល់ព្រមទទួលឡើយ ហើយត្រូវបង្វិលសំណុំរឿងនោះទៅឱ្យម្ចាស់ដើមវិញ។

រហូតមកដល់ពេលមានការជូនដំណឹងពីការយល់ព្រមទទួលរបស់មេធាវីក្រោយ មេធាវីមុននៅតែពុំទាន់ផុតភារកិច្ចនៅឡើយ។ មេធាវីក្រោយមិនត្រូវទាន់ធ្វើការខ្នះខ្នែងអ្វីទេ ក្រៅអំពីពិនិត្យសំណុំរឿង និងការទទួល ឬ ទៅជួបអតិថិជនប៉ុណ្ណោះ។

ការបំពេញកិច្ចការអ្វីមួយជាផ្លូវវិជ្ជាជីវៈ មានន័យថាសុខចិត្តព្រមទទួលធ្វើ។

## មាត្រា ៤៦. មេធាវីដែលទទួលធ្វើជាអ្នកឆ្លើយឆ្លង

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយរបស់សហភាគីណាមួយ ត្រូវទទួលខុសត្រូវចំពោះសហភាគី និងចំពោះអតិថិជន អំពីការធ្វើឱ្យបានចប់សព្វគ្រប់នូវបេសកកម្មរបស់ខ្លួន តាមការព្រមព្រៀងជាមួយមេធាវីដើម បើសិនជាខ្លួនបានទទួលឯកសារជាចាំបាច់ទាំងអស់នៃសំណុំរឿង។

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយ អាចជួបផ្ទាល់ជាមួយអតិថិជនបាន លុះត្រាតែមានការយល់ព្រមពីមេធាវីដើម ឬ លើកលែងតែមានការចាំបាច់។

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយ ធ្វើពាក្យសុំប្រាក់បម្រុង និងប្រាក់កម្រៃ តាមរយៈសហភាគីរបស់ខ្លួនដែលត្រូវសម្រេចយល់ព្រមផង។

មេធាវីដើមត្រូវទទួលខុសត្រូវចំពោះសហភាគីនេះនូវការចេញសោហ៊ុយ បរិលាភ និងកម្រៃនានាក្នុងលក្ខខណ្ឌដែលមានសំអាងពិតប្រាកដ។

## មាត្រា ៤៧. មេធាវីដែលជាអនុតំណាង

មេធាវីដែលទទួលបេសកកម្មពីអតិថិជនអាចផ្ទេរបេសកកម្មនោះទាំងស្រុង ឬ មួយភាគទៅឱ្យសហភាគីណាមួយធ្វើជាអនុតំណាងបាន លុះត្រាតែការប្រគល់សិទ្ធិរបស់អតិថិជនផ្តល់ឱ្យមេធាវីដើម មានសិទ្ធិជ្រើសតាំងអនុតំណាងរបស់ខ្លួន។ មេធាវីអនុតំណាងត្រូវបំពេញបេសកកម្មឱ្យដូចជាមេធាវីដើមដែរ។

## មាត្រា ៤៨. ក្រុមមេធាវី

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងក្របខ័ណ្ឌជាក្រុមមេធាវីដែលប្រមូលផ្តុំមេធាវីច្រើន។

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាគីដែលជាប្រធានក្រុមតាមកិច្ចសន្យានៃកិច្ចសហការ។

ក្នុងករណីសមាជិកនៃក្រុមមេធាវី ទទួលបេសកកម្មក្នុងនាមខ្លួនផ្ទាល់ក្រៅពីក្រុម មេធាវីនោះត្រូវតែទទួលខុសត្រូវជាមួយអតិថិជនដោយខ្លួនឯង តែបេសកកម្មនោះមិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយក្រុមខ្លួនទេ។

## មាត្រា ៤៩. ការចូលរួមក្នុងកិច្ចប្រជុំ ឬ សន្និបាត

មេធាវីដែលនឹងចូលរួមក្នុងកិច្ចប្រជុំណាមួយ ទោះជារឿងវិវាទ ឬគ្មានវិវាទ ត្រូវឱ្យដំណឹងជាមុនទៅអ្នកចូលរួមដទៃទៀតដោយផ្ទាល់ខ្លួនតែម្តង ឬ តាមរយៈអតិថិជនរបស់ខ្លួន។

# ជំពូកទី៨
# ទំនាក់ទំនងជាមួយគណៈមេធាវី

## មាត្រា ៩០. វិធានទូទៅ

មេធាវីជាសមាជិកនៃគណៈមេធាវី។

គណៈមេធាវីមានសេវាជូនមេធាវី ជួយជ្រោមជ្រែងមេធាវី និងការពារមេធាវី។

គណៈមេធាវីតំណាងឱ្យមេធាវី គ្រប់គ្រងកិច្ចការរួមនៃគណៈមេធាវី ជាពិសេសការការពារក្តី និងការចូលទៅតុលាការ។

ដោយអាកប្បកិរិយារបស់ខ្លួន មេធាវីម្នាក់ៗ ត្រូវមានស្មារតីទទួលខុសត្រូវចំពោះ៖

- កេរ្តិ៍ឈ្មោះរបស់គណៈមេធាវី
- ឫទ្ធិអំណាចរបស់ប្រធានគណៈមេធាវី និង
- ប្រសិទ្ធផលនៃក្រុមប្រឹក្សាគណៈមេធាវី។

## មាត្រា ៩១. ការសង្កេតលើការអនុវត្តបទប្បញ្ញត្តិជាធរមាន

មេធាវីត្រូវចូលរួមសង្កេតអំពីប្រសិទ្ធភាព លើការអនុវត្តន៍បទប្បញ្ញត្តិនានារបស់គណៈមេធាវី មានជាអាទិ៍ វិធានវិជ្ជាជីវៈ រាល់សេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ព្រមទាំងបទប្បញ្ញត្តិដទៃទៀតដែលកំពុងមានជាធរមាន ដើម្បីលើកជាមតិជូនគណៈមេធាវី។

## មាត្រា ៩២. បេសកកម្មប្រគល់ឱ្យដោយគណៈមេធាវី

មេធាវីត្រូវទទួលរ៉ាប់រងដោយរៀសរវៃ និងហ្មត់ចត់នូវបេសកកម្ម និងសេវារួម ព្រមទាំងការការពារក្តី ជូនជនក្រីក្រដែលបានប្រគល់ឱ្យដោយគណៈមេធាវី ដោយមិនយកកម្រៃ។ មេធាវីមិនអាចប្រកែកមិនទទួលការងារទាំងឡាយណាដែលគណៈមេធាវីបានប្រគល់ឱ្យដោយគ្មានមូលហេតុសមស្របឡើយ។

## មាត្រា ៩៣. ការណ៍យកិច្ចត្រូវឆ្លើយតបទៅប្រធានគណៈមេធាវី

មេធាវីត្រូវឆ្លើយតបចំពោះការសុំ ឬ អធិបញ្ញាទាំងឡាយរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីដោយគ្មានបង្អែបង្អង់។

## មាត្រា ៤៤. មេធាវីដែលត្រូវគេប្តឹង

មេធាវីដែលត្រូវគេប្តឹងអំពីកំហុស ឬ បទល្មើសព្រហ្មទណ្ឌណាមួយ ដែលទាក់ទិននឹងការប្រកបវិជ្ជាជីវៈ ឬ ដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈត្រូវជូនដំណឹងភ្លាមទៅ គណៈមេធាវី។

មេធាវីដែលត្រូវគេប្តឹងពីបទល្មើសព្រហ្មទណ្ឌណាមួយ ក្រៅពីការប្រកបវិជ្ជាជីវៈ អាចជូនដំណឹងដល់គណៈមេធាវី។

## មាត្រា ៤៥. ការបង់ភាគទាន

មេធាវីត្រូវបង់ភាគទានប្រចាំត្រីមាសជូនដល់គណៈមេធាវីសម្រាប់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ភាគទានត្រូវតែបង់ឱ្យទាន់ពេលវេលាដែលបានកំណត់។

សមាជិកនៃគណៈមេធាវី ដែលមិនបានបង់ភាគទានត្រូវទទួលទណ្ឌកម្មជាបទវិន័យតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

## មាត្រា ៤៦. និរាករណ៍

ក្រមសីលធម៌មេធាវីដែលក្រុមប្រឹក្សាគណៈមេធាវីបានអនុម័ត នាសម័យប្រជុំថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ត្រូវទុកជានិរាករណ៍។

## មាត្រា ៤៧. ការអនុវត្ត

ក្រមសីលធម៌មេធាវីនេះ ត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃផុតបណ្តឹងឧទ្ធរណ៍។

---

ក្រមសីលធម៌នេះ ត្រូវបានក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុម័ត នាសម័យប្រជុំថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ ក្រោមអធិបតីភាពរបស់លោកមេធាវី **ជីវ សុងហាក់** ប្រធានគណៈមេធាវីអាណត្តិទី ៨។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

**ប្រធានគណៈមេធាវី**

# សេចក្តីសម្រេចលេខ
# ៨០៧/សសកម/២០
# ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០
# ស្តីពីការកែសម្រួលប្រការ១៣
# នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៨០៧/សសគម/២០

ថ្ងៃពុធ ១២រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលប្រការ១៣ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី *សួន វិសាល* ជាប្រធានគណៈមេធាវីអាណត្តិទី ១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៩

-បានឃើញសេចក្តីសម្រេចលេខ៣៩៣/សសគម/២០ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

## សម្រេច

**ប្រការមួយ.** ប្រការ ១៣ សេចក្តីសម្រេចលេខ៣៩៣/សសគម/២០ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រការ១៣ នៃបទបញ្ញាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចខាងក្រោម៖

**ប្រការ១៣ថ្មី(២). ដំណើរការនៃការបោះឆ្នោត**

ការបោះឆ្នោតនឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែវត្តមានមេធាវីពេញសិទ្ធិចំនួនលើសពីពាក់កណ្តាល។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលត្រូវបានសម្រេចជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមួយត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមានតួនាទីរៀបចំដំណើរការបោះឆ្នោតប្រធាន និងបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

សមាជិកគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី ក្នុងចំណោមមេធាវីពេញសិទ្ធិ មេធាវីកម្មសិក្សា សិស្សមេធាវី និងបុគ្គលិកគណៈមេធាវី ដែលស្ម័គ្រចិត្តដាក់ពាក្យសុំចូលរួមជួយបំពេញកិច្ចការនេះ។

គណៈកម្មការបោះឆ្នោតជាគណៈកម្មការចំពោះកិច្ច ដែលត្រូវចប់ភារកិច្ច និងរំលាយដោយស្វ័យប្រវត្តិក្រោយពីការរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោតចប់សព្វគ្រប់។

ប្រធានគណៈមេធាវី ឬតំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត មេធាវីមានសិទ្ធិបោះឆ្នោតត្រូវពាក់អាវវិជ្ជាជីវៈមេធាវី និងបង្ហាញបណ្ណសម្គាល់មេធាវី ឬលិខិតបញ្ជាក់ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។ ចំពោះប្រធានគណៈមេធាវី អាចពាក់អាវសម្រាប់ប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះអតីតប្រធានគណៈមេធាវី អាចពាក់អាវសម្រាប់អតីតប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចពាក់អាវ

សម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យទនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចពាក់អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យទាននានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។ ចំពោះមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ អាចពាក់អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ឬអាវវិជ្ជាជីវៈមេធាវី។

និងបង្ហាញបណ្ណសម្គាល់មេធាវី ឬលិខិតបញ្ជាក់ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

ការបោះឆ្នោតលើកទី ១ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) (រាប់ទាំងសំឡេងផ្ទេរសិទ្ធិ) នៃមេធាវីពេញសិទ្ធិទាំងអស់។ ការបោះឆ្នោតលើកទី ១ នេះ ការប្រគល់សិទ្ធិ អាចទទួលយកបាន។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

ការបោះឆ្នោតលើកទី ២ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើននៃមេធាវីពេញសិទ្ធិដែលមានវត្តមានក្នុងពេលបោះឆ្នោតលើកទី២នេះ លើកលែងតែសំឡេងផ្ទេរសិទ្ធិ និងមេធាវីដែលបានផ្ទេរសិទ្ធិឱ្យគេបោះឆ្នោតនៅការបោះឆ្នោតលើកទី១ មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតទេ។ គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាសសលាត ឬមោឃៈត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកសម្លេងភាគច្រើនឡើយ។

**ប្រការពីរ.** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.** សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខារបស់ប្រធានគណៈមេធាវី។

**ប្រធាន**

ចម្លងជូន៖

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

-ក្រុមប្រឹក្សាគណៈមេធាវី

«ដើម្បីជ្រាប»

-ឯកសារ-កាលប្បវត្តិ

# សេចក្ដីសម្រេចលេខ

# ៨២៤/សសកម/២៣

# ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

# ស្ដីពីការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៨២៤/សសគម/២៣

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២០ ប្រការ២៨ ប្រការ៣២ ប្រការ៣៣ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី លី ច័ន្ទតុលា ជាប្រធានគណៈមេធាវីអាណត្តិទី ១៤

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ១០

-យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី៣១ខែសីហាឆ្នាំ២០២៣

## សម្រេច

**ប្រការមួយ.** ប្រការ១៤(ការរាប់សន្លឹកឆ្នោត) ប្រការ១៥(លទ្ធផលនៃការបោះឆ្នោត) ប្រការ១៦ (ការកោះប្រជុំនិងរបៀបវារៈ) ប្រការ១៧(ការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី) ប្រការ២០ (វិន័យការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី) ប្រការ២៨(ការរៀបចំកម្មសិក្សា) ប្រការ៣២(ការព្យួរ និងការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា) ប្រការ៣៣(ការបញ្ចប់កម្មសិក្សា) និងប្រការ៣៨ (កាតព្វកិច្ចគណនេយ្យ) នៃបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន កែសម្រួលដូចតទៅ៖

**ប្រការ១៤ថ្មី. ការរាប់សន្លឹកឆ្នោត**

បន្ទាប់ពីការបោះឆ្នោតចប់ភ្លាម គណៈកម្មការបោះឆ្នោតត្រូវរៀបចំរាប់សន្លឹកឆ្នោត។ ការរាប់សន្លឹកឆ្នោត ត្រូវរាប់តាមការិយាល័យនីមួយៗនៃការបោះឆ្នោតនៅចំពោះមុខសមាជិក-សមាជិកាគណៈមេធាវី ដែលមានវត្តមានជាក់ស្តែងនៅក្នុងមហាសន្និបាត។

**ប្រការ១៥ថ្មី. លទ្ធផលនៃការបោះឆ្នោត**

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោតចប់ភ្លាម។ លទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់។

ដើម្បីបំពេញបន្ថែមលើបទបញ្ជាផ្ទៃក្នុងនេះ រាល់ពេលបោះឆ្នោតម្តងៗ ក្រុមប្រឹក្សាគណៈមេធាវីអាចកំណត់នូវបទបញ្ជានិងនីតិវិធីនៃការបោះឆ្នោតមួយដោយឡែកបន្ថែមទៀត។

**ប្រការ១៦(ស្ងួន). ការកោះប្រជុំ និងរបៀបវារៈ**

ក្រុមប្រឹក្សាគណៈមេធាវីរួមប្រជុំតាមការផ្តួចផ្តើមគំនិតរបស់ប្រធានគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ។ សមាជិកក្រុមប្រឹក្សាគណៈមេធាវីចំនួន ១/៣ (មួយភាគបី) អាចស្នើសុំមកប្រធានគណៈមេធាវីដើម្បីពិនិត្យនិងសម្រេចកោះប្រជុំ។

លើកលែងតែមានកិច្ចការប្រញាប់ ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញសមាជិកក្រុមប្រឹក្សាគណៈមេធាវីឱ្យបានយ៉ាងតិច៣(បី)ថ្ងៃមុនថ្ងៃកំណត់ប្រជុំ ដោយភ្ជាប់ជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំតាមគ្រប់មធ្យោបាយសមស្រប។

## ប្រការ១៧ថ្មី. ការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី

កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវីត្រូវដឹកនាំដោយប្រធានគណៈមេធាវី។ ប្រធានគណៈមេធាវីត្រូវចូលរួមពិភាក្សា និងបោះឆ្នោតសម្រេចជាមួយសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ សំឡេងរបស់ប្រធានគណៈមេធាវី ពុំមានឧត្តមានុភាពឡើយ។

ក្នុងករណីប្រធានគណៈមេធាវីមានធុរៈ ប្រធានគណៈមេធាវីអាចចាត់តាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានវ័យចាស់ជាងគេឱ្យដឹកនាំអង្គប្រជុំក្រុមប្រឹក្សាគណៈមេធាវីបាន។

## ប្រការ២០ថ្មី. វិន័យការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី

សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវចូលរួមកិច្ចប្រជុំឱ្យបានទៀងទាត់និងទាន់ពេលវេលា។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវជូនដំណឹងអំពីអវត្តមានរបស់ខ្លួនមកប្រធានគណៈមេធាវី ក្នុងរយៈពេលសមស្រប តាមគ្រប់មធ្យោបាយសមស្រប។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនសមាជិកណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនក្នុងការបោះឆ្នោតសម្រេចលើបញ្ហានានានៅក្នុងកិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីម្នាក់អាចទទួលការផ្ទេរសិទ្ធិបានតែមួយប៉ុណ្ណោះ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវគោរពនិងប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវីដែលសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

## ប្រការ២៨ថ្មី. ការរៀបចំកម្មសិក្សា

កម្មសិក្សាមានថិរវេលា១(មួយ)ឆ្នាំហើយអាចពន្យារពេលបានតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

កម្មសិក្សាត្រូវរួមបញ្ចូលទាំងសកម្មភាពបណ្តុះបណ្តាលបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវីនិងការសហការពិតប្រាកដក្នុងការិយាល័យរបស់មេធាវីណាមួយផង។

កម្មសិក្សាការី អាចធ្វើផ្នែកខ្លះនៅក្នុងការិយាល័យមេធាវីនៅឯបរទេសនៃប្រទេសណាមួយក៏បាន។

## ប្រការ ៣២ថ្មី. ការព្យួរ និងការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា

ការព្យួរកម្មសិក្សាត្រូវសម្រេចអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី។

ការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា ក៏អាចសម្រេចបានដែរ ចំពោះមេធាវីដែលមិនគោរពកិច្ចសន្យាកម្មសិក្សា ហើយដែលមិនអាចបញ្ជាក់បានត្រឹមត្រូវនូវកិច្ចសន្យាសហការពិតប្រាកដ។

## ប្រការ ៣៣ថ្មី. ការបញ្ចប់កម្មសិក្សា

នៅពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការីត្រូវធ្វើរបាយការណ៍ពីកម្មសិក្សារបស់ខ្លួន ដោយមានមូលវិចារពីគ្រូកម្មសិក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេចចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ។

កម្មសិក្សាការីត្រូវដាក់របាយការណ៍បញ្ចប់កម្មសិក្សាមកគណៈមេធាវី ក្នុងរយៈពេល២ (ពីរ)ខែ គិតចាប់ពីថ្ងៃបញ្ចប់រយៈពេលកម្មសិក្សា។ ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចដាក់ទណ្ឌកម្មវិន័យ។

ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចឱ្យធ្វើកម្មសិក្សាបន្តទៀត តែមិនឱ្យលើសពី១(មួយ) ឆ្នាំឡើយ ចំពោះកម្មសិក្សាការីណា ដែលមិនមានសមត្ថភាពគ្រប់គ្រាន់។ ការសម្រេចមិនចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ ចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល។

## ប្រការ ៣៤ថ្មី. ការតព្វកិច្ចគណនេយ្យ

មេធាវីត្រូវកាន់គណនេយ្យនៃកិច្ចប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន ដោយញែកឱ្យបានច្បាស់រវាងកិច្ចប្រតិបត្តិទាក់ទងនឹងការគ្រប់គ្រងការិយាល័យរបស់ខ្លួន និងកិច្ចប្រតិបត្តិធ្វើឡើងសម្រាប់ផលប្រយោជន៍អតិថិជន។

គណនេយ្យនៃកិច្ចប្រតិបត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការិយាល័យមេធាវី ត្រូវធ្វើឡើងឱ្យសមស្របនឹងវិធានច្បាប់ ឬបើគ្មានវិធាននោះទេ ក៏ត្រូវធ្វើតាមបែបបទចំណូល/ចំណាយដែរ។

មេធាវីត្រូវបំពេញកាតព្វកិច្ចជាបុគ្គលរាយការណ៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយនៃអាវុធមហាប្រល័យ។

កិច្ចប្រតិបត្តិការដែលទាក់ទងនឹងការបង់ប្រាក់ប្រដាប់ក្តី ប្រាក់ពន្ធអាករ និងប្រាក់ចេញជួសឱ្យមុន ដែលធ្វើឡើងក្នុងផលប្រយោជន៍អតិថិជន ត្រូវកត់ចូលក្នុងគណនេយ្យមួយដោយឡែក។

**ប្រការពីរ.** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.** អគ្គលេខាធិការគណៈមេធាវីនិងសមាជិក-សមាជិកាគណៈមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៤ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

**ប្រធាន**

**ចម្លងជូនៈ**

-ក្រុមប្រឹក្សាគណៈមេធាវី

«ដើម្បីជ្រាប»

-ដូចប្រការបី

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជប្រកាសលេខ ៣២
# អំពីជណាយកែសេចក្ដី
# ក្នុងតុលាការខ្មែរ

ថ្ងៃ១១ រោជ ខែមាឃ ឆ្នាំមមែត្រីស័ក្ស ព.ស.២៤៧៤
ត្រូវនឹងថ្ងៃ ៣ ខែម៉ាឡ្ស៍ ឆ្នាំ១៩៣២

# ព្រះរាជប្រកាស លេខ ៣៤

## ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្សហរិរាជ បរមិន្ទរ ភូវណៃក្រៃកែវហ្វាសុឡាខ្សៃ ព្រះចៅក្រុងកម្ពុជាធិប្តី ជាអំម្ចាស់ជីវិតលើត្បូង

បានទ្រង់យល់ព្រះរាជប្រកាសពីថ្ងៃ ១២ កើត ខែអាសាឍ ឆ្នាំរកានពស័ក្ស ចុលសករាជ ១២៥៩ ត្រូវនឹងថ្ងៃ១១ខែសូយេតឆ្នាំ១៨៩៧ ដែលបញ្ញត្តិអំពីរបៀបរាជ្ការទាំងពួងក្នុងព្រះនគរ។

បានទ្រង់យល់ព្រះរាជប្រកាសលេខ ១១២ ចុះថ្ងៃ ១២ រោជ ខែមិគ្គសិរ ឆ្នាំខាលអដ្ឋស័ក្ស ចុលសករាជ ១២៨៨ ត្រូវនឹងថ្ងៃ ៣១ ខែដេសម ឆ្នាំ១៩២៦ ដែលបញ្ញត្តិពីចែកមុខក្រសួងកុង្សីយសេនាបតី។

បានទ្រង់យល់ច្បាប់រដ្ឋបវេណីត្រង់ជំពូក៤ ភាគទី៥ ក្នុងក្រំទី៤ ដែលបញ្ញត្តិអំពីរបៀបដំណាងក្តី។

បានទ្រង់យល់ព្រះរាជប្រកាសលេខ១១៨ ចុះថ្ងៃ ៨ រោជ ខែភទ្របុទ ឆ្នាំចចត្វាស័ក្ស ចុលសករាជ ១២៨៤ ត្រូវនឹងថ្ងៃ ១៤ សេបតម ឆ្នាំ១៩២២ ដែលបញ្ញត្តិអំពីរៀបចំតុលាការស្រុកអាយក្នុងក្រុងកម្ពុជាឡើងវិញ។

បានទ្រង់យល់ព្រះរាជប្រកាសលេខ៣៨ ចុះថ្ងៃ ១៣ រោជ ខែផល្គុណ ឆ្នាំម្សាញ់ឯកស័ក្ស ព្រះពុទ្ធសករាជ២៤៧២ ត្រូវនឹងថ្ងៃ ២៧ ខែម៉ារ្ស ឆ្នាំ១៩៣០ ដែលបញ្ញត្តិពីឱ្យជួយកែសេចក្តីមនុស្សជាប់ចោទ្យក្នុងសាលាជំនុំមជ្ឈិមនឹងឧក្រិដ្ឋខេមរ។

បានទ្រង់យល់សេចក្តីដែលកុង្សីយសេនាបតីបានជួបជុំជំនុំព្រមនឹងម៉ូនសៀរ ឡឺរេស៊ីដង្ត សុប៉េរីយ៉ើរ ក្នុងក្រុងកម្ពុជាធិប្តី នៅវេលាជួបជុំធំជាគំរប់លេខ ៦២១ នៅថ្ងៃ ៥ កើតខែផល្គុណ ឆ្នាំមមែត្រីស័ក្ស គឺ ១១ ម៉ារ្ស ១៩៣២។

បានទ្រង់យល់សេចក្តីដែលទ្រង់បានជំនុំព្រមនឹងម៉ូនសៀរ ឡឺរេស៊ីដង្ត សុប៉េរីយ៉ើរ។

តាមសេចក្តីដែលកុង្សីយសេនាបតីក្រាបបង្គំទូលសុំ។

# ត្រាស់បង្គាប់ដូចមានខាងក្រោយនេះ

**ប្រការ ១.**

ក្នុងសាលាជំនុំទាំងឡាយ អំពីរឿងអាជ្ញាគតិនាក់ក្តីនឹងឱ្យមាននាក់ជំណាងជួយសង្គ្រោះ ហើយអំពីរឿងរដ្ឋបវេណីគតិ នឹងឱ្យមាននាក់ថណាយជំណាងជួសខ្លួនបាន ឯជនដែលតាំងខ្លួនជាបទរដ្ឋបវេណីក្នុងរឿងក្តីអាជ្ញាគតិ ត្រូវទុកដូចជាដើមចោទក្នុងរឿងរដ្ឋបវេណី នឹងមានអំណាចឱ្យថណាយជួសខ្លួនបាន។

**ប្រការ ២.**

នាក់ថណាយត្រូវឱ្យមានសំបុត្រផ្សេង ឱ្យអំណាចជំណាង លើកតែនាក់ថណាយនោះបានអនុញ្ញាតឱ្យចូលធ្វើមុខងារជានាក់ជំណាងនាក់ក្តីក្នុងងារស្រេចហើយ ទើបមិនឱ្យមានសំបុត្រនោះបាន។

## ភាគទី១
## អំពីបដិភាសានុញ្ញាតដោយសំបុត្រផ្សេងឱ្យអំណាចជំណាង

**ប្រការ ៣.**

ឯនឹងអនុញ្ញាតឱ្យធ្វើជានាក់ថណាយក្តីដោយសំបុត្រឱ្យអំណាចជំណាងបាននោះ បានតែញាតិសាលោហិតឬញាតិពន្ធនឹងពួកដើមចោទ ឬចុងចម្លើយជាមួយគ្នា។

**ប្រការ ៤.**

ញាតិសាលោហិតឬញាតិពន្ធ ត្រូវឱ្យមានបន្ទាល់សំគាល់ថា ខ្លួនជាប់ញាតិនឹងសាមីខ្លួននាក់ឱ្យអំណាចជំណាងនោះដោយសាច់ញាតិដូចមានខាងក្រោយនេះ៖

១. ស្វាមីភរិយាមានខ័ន្តស្លា។

២. មេបា ឬកូនចៅមានខ័ន្តស្លា ឬឥតខ័ន្តស្លា ឬសាច់ចិញ្ចឹម នឹងសាមីខ្លួននាក់ឱ្យអំណាចជំណាង ឬនឹងប្តីប្រពន្ធមានខ័ន្តស្លា នាក់នេះដូចម្តេច។

៣. សាច់សាខាមានខ័ន្តស្លា ឥតខ័ន្តស្លា ឬចិញ្ចឹមសាច់បង្កើត សាច់ខាងអាពុក ឬខាងម្ដាយ រហូតដល់ជាន់ ៨ ថ្នាក់ គិតទាំងជាន់នេះផង ត្រឹមណានឹងសាមីខ្លួននាក់ឱ្យអំណាចដំណាងឬនឹងប្ដីប្រពន្ធមានខ័ន្តស្លានាក់នេះ។

**ប្រការ ៥.**

ចៅក្រំនឹងអនុញ្ញាតឱ្យពួកដើមចោទ្យ ឬចុងចម្លើយថណាយជួសបាននោះ លុះត្រាតែប្រយោជន៍របស់នាក់ថណាយនោះឥតមានទាស់គ្នា នឹងប្រយោជន៍សាមីខ្លួនទើបឱ្យដំណាងបាន ឯទាស់ប្រយោជន៍គ្នានោះ បើសាមីខ្លួនពុំបានតវ៉ាទេ ត្រូវចាងហ្វាងសាលាដែលទទួលពាក្យបន្តឹងពិនិតពិចារណា បើយល់ឃើញជាទាស់មែននឹងសំរេចបដិសេធបដិភាសានុញ្ញាតជាសូន្យតែម្ដងបានឥតប្ដឹងសើរើបានឡើយ។

**ប្រការ ៦.**

បដិភាសានុញ្ញាតទាំងឡាយដែលឱ្យថណាយមានសំបុត្រផ្សេងឱ្យអំណាច ហើយត្រូវមេឃុំនាទីៗលំនៅសាមីខ្លួនពិនិតបញ្ជាក់ផង ប៉ុន្តែប្ដីនឹងដំណាងប្រពន្ធទី១ នឹងទី២ បានពុំអាចមានសំបុត្រឱ្យអំណាចដំណាងឡើយ ឯប្រពន្ធនឹងដំណាងជួសជនណា១ក្រៅពីប្ដីខ្លួនពុំបានឡើយ បើនឹងដំណាងបាន លុះតែមានអនុញ្ញាតពីប្ដីមានមេឃុំនាទីដែលប្ដីនៅពិនិតបញ្ជាក់សេចក្ដីអនុញ្ញាតនោះផងទើបបាន។

**ប្រការ ៧.**

សំបុត្រឱ្យអំណាចថណាយ ត្រូវធ្វើផ្សេងក្នុងរឿងក្ដីនីមួយៗ។

**ប្រការ ៨.**

កិច្ចបដិភាសានុញ្ញាត ដោយមានសំបុត្រឱ្យអំណាចអនុញ្ញាតផ្សេងត្រូវធ្វើទទេឥតឈ្នួល អ្នកដំណាងត្រូវបានដំណាច់ដែលខ្លួនចេញចាយ នឹងសោហ៊ុយថ្លៃដំណើរហើយនឹងដំណាច់ភាគ។

**ប្រការ ៩.**

នាក់ថណាយត្រូវទទួលខុសត្រូវ នឹងសាមីខ្លួនតាមបញ្ញត្តិដែលសំដែងក្នុងភាគទី១ នឹងទី២ នឹងក្នុងជំពូក៤ ភាគទី៥ ក្រំទី៤ ច្បាប់រដ្ឋបវេណី។

# ភាគទី២
# អំពីបដិភាសានុញ្ញាតដោយអ្នកថណាយចានអនុញ្ញាតពីសាលា

**ប្រការ ១០.**

បដិភាសានុញ្ញាតឥតមានសំបុត្រផ្សេងឱ្យថណាយនោះ នឹងឱ្យទៅជនណាដែលមានមុខជាអ្នកថណាយដែលបានអនុញ្ញាតពីសាលាហើយបាន ។

## ជំពូក១
## អំពីលក្ខណដែលនឹងទទួលមុខជាអ្នកថណាយក្តី ដែលមានអនុញ្ញាតពីសាលាចាន

**ប្រការ ១១.**

ជនដែលមានសភាព នឹងធ្វើជាថណាយដែលមានអនុញ្ញាតពីសាលានោះ គឺជនដែលមានឈ្មោះកត់ក្នុងតារ៉ាងសំរាប់កត់ពួកក្រុំនេះ តាមលំដាប់មុនក្រោយដែលមានប្រកាសសេនាបតីក្រសួងយុត្តិធម៌ សំរេចជំនួនបិទក្នុងសាលាជំនុំនីមួយៗ។

**ប្រការ ១២.**

ជនណាដែលមិនប្រកបលក្ខណ ដូចមានរាយខាងក្រោយនេះទេ នឹងទទួលឱ្យធ្វើជានាក់ថណាយដែលមានអនុញ្ញាតព្រមពីតុលាការពុំបានឡើយ។

១. ជាតិខេមរ។

២. អាយុពេញ ២៥ ឆ្នាំ។

៣. មានទីលំនៅៗជានិច្ចក្នុងក្រុងកម្ពុជាជាង ៥ ឆ្នាំ។

៤. ប្រកបកល់កិរិយាអត្តភាព អាចទទួលកិច្ចការបាន។

៥. ពុំមានទោសអ្វីជាបទឧក្រិដ្ឋឬមជ្ឈិម ដែលសាលាបារាំងឬខ្មែរកាត់សេចក្តី។

៦. ប្រកបដោយសីលមាយាតដ៏ល្អ។

៧. មានធនធានផ្ទាល់ខ្លួនគ្រប់គ្រាន់។

៨. មានចំណេះវិជ្ជាច្បាប់សំគាល់ដោយសញ្ញាបត្តជាបានការ សញ្ញាបត្តបាស្សីល្លីយេរ លីស្សង់ស៊ីយេរ ឬដុកទាវ៍ច្បាប់ដែលសាលាធំណា ១ នៅស្រុកបារាំងចេញឱ្យ ១ ដោយសញ្ញាបត្ត ដែលសាលាបរិយត្តិសិក្សាស្រុកអាំងដូស៊ីន សាលាច្បាប់ ស្រុកហាណូយ ឬសាលារដ្ឋបាលខេមរ ចេញឱ្យក្តី ដោយសំបុត្របដិញាណសិក្សារដ្ឋបាលនឹងតុលាការ ដែលចេញឱ្យកូនសិស្សក្រៅដែល រៀនសាលារដ្ឋបាលខេមរ តែត្រូវឱ្យសាម៉ីខ្លួនបានពិន្ទុ មធ្យមបើយ៉ាងតិចឱ្យស្មើនឹងពិន្ទុ ១៥។

៩. ដាក់ប្រាក់ជានាជំនួន ២០០ រៀល ។

## ប្រការ ១៣.

ជនដែលបានធ្វើការបើយ៉ាងតិច១០ឆ្នាំក្នុងក្រសួងរាជ្ការរដ្ឋបាលតុលាការ ឬក្រុំព្រះនគរបាល យុត្តិធម៌ក្នុងដំណែងជាន់ខ្ពស់ នឹងដំណែងជាន់បន្ទាប់ ក្នុងរាជ្ការខ្មែរក្តី ក្នុងដំណែងថៅក្រំក្តី នឹង សមុហប័ញ្ជីរ ក្រឡាប័ញ្ជីរក្តី ក្នុងដំណែងជាន់ខ្ពស់នឹងជាន់បន្ទាប់ក្នុងរាជ្ការប្រូតិកតូ៉ក្តី មិនត្រូវឱ្យ ជូនសញ្ញាបត្តណា១ ដែលមានរាយត្រង់ខ៏ ៨ ក្នុងប្រការខាងលើនេះទេ ឯកំណត់រាជ្ការនឹងកិរិយាការ ដែលបានធ្វើ ត្រូវក្រសួងរាជ្ការដែលមន្ត្រីបានធ្វើការពីមុននោះចាត់ធ្វើជាប័ញ្ជីរជូនមក។

## ប្រការ ១៤.

មន្ត្រីនកនឹងអនុញ្ញាតឱ្យធ្វើជាអ្នកថណាយក្តីពុំបានទេ បើហេតុដែលឈប់ពីរាជ្ការបណ្តាល មកពីមានទោសទណ្ឌកម្មពីរឿងដែលនាំឱ្យសៅហ្មងដល់កិត្តិយស ឬសេចក្តីសុចរិត។

## ប្រការ ១៥.

ឯធ្វើជានាក់ថណាយ ដែលមានអនុញ្ញាតពីសាលានោះមិនប្រកបនឹងមុខក្រសួង ឬរបរ ដូចមានខាងក្រោមនេះទេ។

១. ព្រះសំឃ។

២. អាចារ្យ។

៣. រាជ្ការយុទ្ធនាធិការ។

៤. មុខងារសាធារណ ឬទីកន្លែងក្នុងរាជ្ការសាធារណ ក្នុងរាជ្ការព្រះករុណាក្តី ក្នុងរាជ្ការ ព្រះបរមរាជវាំងក្តី ក្នុងរាជ្ការបារាំង ឬខេមរក្តី។

៥. កិច្ចដំណាងដោយបោះឆ្នោតរើស។

៦. របរជានាក់កាន់កាប់ជានាយក ឬជានាក់តែង។

៧. របរជំនួញ ឬសិប្បីយការ។

៨. នៅបំរើជំពាក់គេ ឬស៊ីឈ្នួល។

៩. រកស៊ីធ្វើរបរអ្វីមួយដែលមានបង់បាត្តង់។

សេចក្តីដែររាយមុខរបរក្នុងប្រការនេះមិនខានផុតតែប៉ុណ្ណេះទេ ហើយបើឃើញមានរបរអ្វីឯទៀត នោះនឹងដាក់ឱ្យមុខក្រសួងពិនិតជានឹងត្រូវទទួលឱ្យធ្វើជានាក់ថណាយដែលមានអនុញ្ញាតពីសាលា ឬនឹងត្រូវលប់ឈ្មោះចេញក៏បាន។

ជនដែលជាប់ញាតិសាលោហិត ឬញាតិពន្ធនឹងចៅក្រំណាមួយ ឬក្រឡាប័ញ្ចីរណាមួយ រហូតដល់ថ្នាក់ទី៤ គិតទាំងថ្នាក់នេះផង នឹងធ្វើជានាក់ថណាយដែលមានអនុញ្ញាតពីសាលាក្នុងនាទីសាលាដំបូង ឬសាលាលហុ ដែលញាតិសាលោហិតឬញាតិពន្ធនៅធ្វើការក្នុងសាលានោះពុំបានឡើយ ហើយក្នុងសាលាវិនិច្ឆ័យ សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ នឹងសាលាក្រុំចោទ្យនឹងទទួលកាន់រឿងក្តីណាដែលញាតិសាលោហិត ឬញាតិពន្ធរបស់ខ្លួនពិនិតនោះក៏ពុំបានដែរ។

## ប្រការ ១៦.

ឯលក្ខណជាតិនឹងអាយុះ ត្រូវសំរេចដោយបានជូនសំបុត្រកំណើត នឹងជូនសេចក្តីចំឡងពីព្រះរាជប្រកាស ដែលអនុញ្ញាតឱ្យចូលជាតិជាខ្មែរតាមត្រូវការ ឯជនកើតមុនតាំងឱ្យមានអត្រានុកូលដ្ឋានក្នុងក្រុងកម្ពុជា ពីថ្ងៃ ១២ កើតខែបុស្ស ឆ្នាំកុរត្រីស័ក្ស ត្រូវនឹងថ្ងៃ ១ ខែយ៉ាំងវីយេរ ឆ្នាំ១៩១២ ត្រូវជូនសំបុត្របដិញាណសំគាល់ដែលធ្វើតាមលក្ខណត្រឹមត្រូវនឹងបញ្ញត្តិជំនួសសំបុត្រកំណើតដែលគ្មាននោះបាន ឯជនដែលកើតក្រោយថ្ងៃខែឆ្នាំនេះ ត្រូវជូនសានក្រំជំនួសសំបុត្រកំណើត។

## ប្រការ ១៧.

អំពីមានទីកន្លែងនឹងទីលំនៅជានិច្ចក្នុងក្រុងកម្ពុជា បើក្នុងកំណត់យ៉ាងតិច ៥ ឆ្នាំ នោះត្រូវមេឃុំចេញបដិញាណបញ្ជាក់ថា ប្រាកដជាមានទីលំនៅៗក្នុងឃុំរបស់ខ្លួនពិតមែន។

**ប្រការ ១៨.**

អំពីកលកិរិយាអត្តភាពអាចធ្វើកិច្ចការបានពេញបរិបូណ៌ នោះត្រូវក្រឡាប័ញ្ជីរសាលាដែលមានទីលំនៅសាមីខ្លួននៅៗនោះចេញបដិញាណ មានចាងហ្វាងសាលានោះចុះសញ្ញានាមអមផង បញ្ជាក់ថាពុំដែលមានសានក្រំកាត់សេចក្ដីទុកជាសាមីខ្លួនមានវិកល្លណឬហាមឃាត់ទេ។

១ ទៀតឯសត្រីមានប្ដីត្រូវជូនសំបុត្រពីប្ដីអនុញ្ញាតឱ្យធ្វើជានាក់ថណាយដែលមានអនុញ្ញាតពីសាលា នាកាលតមកទៀត បើអនុញ្ញាតប្ដីនោះដកឱ្យឈប់ធ្វើជានាក់ថណាយវិញ ឬនាកាលសត្រីណា ១ លីវ ឬមេម៉ាយធ្វើជានាក់ថណាយយកប្ដីមានខ័ន្តស្លា ហើយពុំបានអនុញ្ញាតពីប្ដីត្រិមត្រូវទេ សត្រីនោះនឹងទុកឱ្យដំណាងក្ដី ពីរឿងដែលប្ដឹងមុនដកអនុញ្ញាតប្ដី ឬមុនរៀបការយកប្ដី។

ឯករិយាមន្ត្រីសាធារណដំណែងរដ្ឋបាល ឬដំណែងតុលាការ នឹងធ្វើជានាក់ថណាយមានអនុញ្ញាតពីសាលាពុំបានឡើយ។

**ប្រការ ១៩.**

ឯនឹងសំគាល់ថាគ្មានទោសឧក្រិដ្ឋ ឬមជ្ឈិម ដែលសាលាបារាំង ឬសាលាខ្មែរណា ១ កាត់សេចក្ដីនោះត្រូវបញ្ជាក់នឹងសំបុត្រសៅរដាកិរិយាខ្លួន ដែលក្រសួងរាជ្ការសៅរជាតុលាការក្រុងកម្ពុជាចេញឱ្យមកក្នុងរវាងតិចចុះពី១ខែហើយ។

**ប្រការ ២០.**

ឯលក្ខណកិរិយាមាយាតដែលប្រកបដោយសីលដ៏ល្អ នឹងមានធនធានគ្រប់គ្រាន់នោះនឹងសំគាល់ឱ្យច្បាស់បាន លុះតែបានសួរស័ប្ទយ៉ាងផ្សេងជាផ្លូវរាជ្ការ គឺក្រសួងរាជ្ការសម្ងាត់ក្រុងកម្ពុជាស៊ើបក្ដី ភ្នាក់ងារក្រុំព្រះនគរបាលយុត្តិធម៌មុខក្រសួងស៊ើបសួរក្ដី ក្នុងអំណាចនឹងតាមបង្គាប់ពីចាងហ្វាងសាលាវិនិច្ឆ័យ។

ឯធនធានផ្ទាល់ខ្លួនត្រូវឱ្យមានគ្រប់គ្រាន់សំរាប់លៀងជីវិត ឧបត្ថម្ភខ្លួននាក់ថណាយដែលមានអនុញ្ញាតពីសាលា នឹងមនុស្សដែលនៅក្នុងបន្ទុកនាក់ថណាយនោះ។

**ប្រការ ២១.**

ឯប្រាក់ធានាសំរេចជំនួន ២០០ រៀល ត្រូវយកទៅប្រគល់ឱ្យក្រឡាប័ញ្ជីរសាលាវិនិច្ឆ័យៗចេញបង្កាន់ដៃឱ្យ ឯក្រឡាប័ញ្ជីរសាលាវិនិច្ឆ័យត្រូវយកប្រាក់ធានានោះទៅទុកផ្ញើនឹងផ្ទះចង្ការប្រាក់ណា ១ ដែលរាជ្ការត្រួតនៅក្រុងភ្នំពេញ។

ក្រឡាបញ្ជីសាលាវិនិច្ឆ័យត្រូវបានការប្រាក់ជានា ហើយត្រូវទទួលធ្វើកិច្ចការនាក់ថណាយ ឥតយកថ្លៃអ្វីនឹងឱ្យមានបង្កាន់ដៃត្រឹមត្រូវសាលាដែលទទួលកិច្ចការពីនាក់ថណាយនោះ។

**ប្រការ ២២.**

ឯជាក់ប្រាក់ជានានឹងបង់ពន្ធបាត្តង់ នោះលុះតែបានពិនិតសំបុត្រ ដែលសុំចុះឈ្មោះក្នុងតារាំងនាក់ថណាយដែលមានអនុញ្ញាតពីសាលាស្រេចជាព្រមហើយ ទើបទារប្រាក់ជានានឹងពន្ធបាត្តង់នោះបាន។

**ប្រការ ២៣.**

សំបុត្រដែលសុំចុះនាមក្នុងតារាំងនាក់ថណាយក្ដីដែលមានអនុញ្ញាតពីសាលានោះ ត្រូវប្ដឹងសេនាបតីក្រសួងយុត្តិធម៌ៗចេញបង្កាន់ដៃចុះថ្ងៃខែឆ្នាំឱ្យ។

**ប្រការ ២៤.**

សេនាបតីក្រសួងយុត្តិធម៌បញ្ជូនសំបុត្រនោះជាប្រញាប់ ទៅឱ្យចាងហ្វាងសាលាវិនិច្ឆ័យបង្គាប់ឱ្យស៊ើបសួររៀបចំសំណុំលិខិតរបស់សាមីខ្លួនឱ្យសព្វគ្រប់ ហើយបើយ៉ាងយឺតក្នុងកំណត់ ១ ខែ ត្រូវជូនសេចក្ដីយល់ឃើញជាពិស្ដារ ដែលបានជួបជុំជំនុំពិនិតសំបុត្រដែលសុំនោះ យល់គួរសំរេចឱ្យបានតាមសុំឬដូចម្ដេច ឯសេចក្ដីយល់ត្រូវយកតាមជំនួនចៅក្រំ ក្នុងសាលារួមក្រុំទាំងអស់ដែលឆ្លើយច្រើន ចៅក្រំស្ដីទីជាចៅក្រំប្រិក្សាសាលាវិនិច្ឆ័យ ក៏ត្រូវចូលជំនុំដែរ នាកាលជួបជុំជំនុំរួចត្រូវក្រឡាបញ្ជីរតែងសេចក្ដីកត់ហេតុ ១ រំពេច តាមចាងហ្វាងបង្គាប់ឱ្យសរសេររួចឱ្យចៅក្រំនីមួយៗដែលបានចូលជំនុំចុះសញ្ញនាម។

**ប្រការ ២៥.**

បើជំនុំយល់ទាស់មិនព្រមឱ្យទេ នឹងរំលងសេចក្ដីជំនុំនោះពុំបានឡើយ។

បើជំនុំយល់ព្រមឱ្យនឹងសំរេចតាមបាន លុះតែសេនាបតីក្រសួងយុត្តិធម៌យល់ព្រមផងទើបបាន។

**ប្រការ ២៦.**

សេនាបតីក្រសួងយុត្តិធម៌ ត្រូវឱ្យដំណឹងទៅសាមីខ្លួនបានដឹងសេចក្ដីដែលបានសំរេចពីពាក្យសុំនោះ។

**ប្រការ ២៧.**

សំបុត្រសុំដែលសាលាវិនិច្ឆ័យ ឬសេនាបតីក្រសួងយុត្តិធម៌បដិសេធមិនព្រមឱ្យនោះ នឹងប្ដឹងតវ៉ាទៅទៀតពុំបានឡើយ ឯនឹងប្ដឹងសុំជាថ្មីទៀតមុនកំណត់ ១ ឆ្នាំ ពុំបានគិតតាំងពីថ្ងៃខែឆ្នាំចូលសំបុត្រជាន់មុន ឯឆ្នាំត្រូវរាប់តាមបែបបារាំង។

### ប្រការ ២៨.

បើសេនាបតីអនុញ្ញាតព្រមតាមសុំហើយត្រូវបង្គាប់ឱ្យសាមីខ្លួនដាក់ប្រាក់ធានានឹងបង់ពន្ធបាត្តង់ នាកាលដាក់ប្រាក់ធានា នឹងបង់ពន្ធបាត្តង់មានបង្កាន់ដៃរួចហើយត្រូវចេញសារត្រាសេនាបតី បង្គាប់ទៅចាងហ្វាងគ្រប់សាលាជំនុំឱ្យចុះឈ្មោះនាក់ថណាយនោះ ១ រំពេចក្នុងតារ៉ាងបិទនៅសាលាជំនុំនៃខ្លួន ចាងហ្វាងត្រូវតបនឹងសារត្រាសេនាបតីវិញជាប្រញាប់ ជូនដំណឹងពីបានសំរេចតាមសេចក្តីបង្គាប់សារត្រានោះ។

### ប្រការ ២៩.

តារ៉ាងដែលកត់នាក់ថណាយនោះ ត្រូវចុះនាមត្រកូលអាពុក-ម្តាយ-អាយុ-ទីលំនៅ នឹងថ្ងៃ-ខែ-ឆ្នាំ ដែលទទួលឱ្យម្នាក់ៗចូលនោះ បើអ្នកថណាយខ្លះសុំឱ្យចុះក្នុងតារ៉ាងសញ្ញាបត្តងារជាកិត្តិយស នឹងគ្រឿងឥស្សរិយសដែលបាន ក៏ត្រូវចុះឱ្យផង។

### ប្រការ ៣០.

ឯចុះក្នុងតារ៉ាងត្រូវចុះតាមមុនក្រោយរៀងមកតាមថ្ងៃខែឆ្នាំប្រកាសសេនាបតី ដែលអនុញ្ញាតព្រមទទួលនាក់ថណាយនីមួយៗ បើនាក់ថណាយពីរអ្នកព្រមទទួលថ្ងៃខែឆ្នាំជាមួយគ្នា ត្រូវចុះអ្នកថណាយអាយុច្រើនមុន បើអាយុដំណាលគ្នាត្រូវយកតាមលំដាប់ជួរអក្សរ។

### ប្រការ ៣១.

តាំងពីថ្ងៃដែលបានចុះឈ្មោះក្នុងតារ៉ាងនាក់ថណាយនឹងចាប់ធ្វើការបាន មិនត្រូវមានសំបុត្រពីសាមីខ្លួនឱ្យអំណាចដំណាងថណាយជួសទេ។

## ជំពូក ២

## អំពីតាំងឱ្យមាននាក់ថណាយក្តីជួសខ្លួន

### ប្រការ ៣២.

អំពីតាំងឱ្យនាក់ថណាយដំណាងជួសទោះនឹងតាំងវេលាណាក៏បាន ឱ្យតែមុនកាត់សេចក្តីចេញសានក្រំ សាលាដើម ឬសាលាជាន់ខ្ពស់ដែលជំនុំជំរះដល់អង្គហេតុ។

### ប្រការ ៣៣.

នាក់ថណាយតែម្នាក់ នឹងទទួលការពីសាមីខ្លួនច្រើននាក់បានក្នុងរឿងក្តីតែមួយដដែល ប៉ុន្តែលុះតែឥតមានទាស់ប្រយោជន៍អ្វីដោយសព្វខ្លួននៃសាមីនាក់ក្តីមួយក្នុងរឿងនោះ។

នាក់ថណាយដែលបានទទួលកាន់រឿងក្តីណា ១ ដែលមានពួកសាមីខ្លួនច្រើននាក់ បើឃើញមានសេចក្តីទាស់ប្រយោជន៍គ្នា លេចឡើងក្នុងរឿងនោះត្រូវឈប់លែងទទួលថណាយជាប្រញាប់ ហើយត្រូវប្តឹងចាងហ្វាងសាលាដែលទទួលរឿងក្តីនោះបានដឹងតាមដំណើរ បើពុំបានធ្វើដូច្នោះទេចាងហ្វាងត្រូវបង្គាប់នាក់ថណាយនោះឱ្យប្រតិបត្តិតាមសេចក្តីបញ្ញត្តិនេះ ហើយត្រូវចេញដិកាសំរេចសេចក្តីដែលមានហេតុទាស់នេះ បញ្ជូនទៅឱ្យចាងហ្វាងសាលាវិនិច្ឆ័យយល់ព្រមផង។

ឯបង្វាតរបស់សាមីខ្លួននាក់ក្តី ត្រូវនាក់ថណាយទទួលលើខ្លួន ហើយត្រូវមានទោសទណ្ឌកម្មពីធ្វើមុខការខ្លួនដែលធ្វើខុស បើពុំឈប់លែងកាន់ក្តីរឿង ដែលមាននាក់ក្តីច្រើននាក់នោះទេ ទោះចាងហ្វាងពុំបានបង្គាប់ឱ្យឈប់ក៏ដោយ។

## ប្រការ ៣៤.

នាក់ក្តីតែម្នាក់នឹងពឹងនាក់ដំណាងថណាយច្រើននាក់ជួសខ្លួន ក្នុងរឿងតែមួយដដែលបានពួកនាក់ថណាយដែលគេពឹងដូច្នេះ ត្រូវប្តឹងសាលាដែលទទួលរឿងឱ្យដឹងជានឹងឱ្យនាក់ថណាយណាមួយ ដំណាងជួសខ្លួននាក់ឯទៀតនិយាយការក្តីនោះ សំបុត្រដែលប្តឹងជូនដំណឹងត្រូវដាក់ក្នុងសំណុំរឿងហើយកត់ចុះក្នុងបញ្ជីរាយលិក្ខិតសំណុំរឿង។

## ប្រការ ៣៥.

អំពីតាំងឱ្យមានដំណាងជាត្រឹមត្រូវបានការតាមរបៀបនោះ ដោយមានសំបុត្រដំណឹងចុះថ្ងៃខែឆ្នាំ ចុះសញ្ញានាមនាក់ថណាយជូនទៅចាងហ្វាងសាលា ហើយទុកក្នុងមន្ទីក្រឡាបញ្ជីសាលានោះ។

នាកាលបានទទួលសំបុត្រដំណឹងហើយ ក្រឡាបញ្ជីត្រូវធ្វើជាកំណត់ដែលចាងហ្វាងត្រូវស៊ីញេអមផង ចុះលេខរៀងសំណុំរឿង។

បើតាំងឱ្យមានដំណាងពានទៅលើរឿងដែលកាត់សេចក្តីហើយ ត្រូវឱ្យដំណឹងទៅនាក់ថណាយតាមការ ចុះលេខរៀងសំណុំរឿងនឹងថ្ងៃខែឆ្នាំសាលក្រំដែលកាត់សេចក្តីឱ្យដឹងផង ឯសំបុត្រជូនដំណឹងពីតាំងឱ្យដំណាងថណាយ នឹងសេចក្តីចំឡងពីកំណត់ដែលក្រឡាបញ្ជីតបទៅវិញនោះត្រូវដាក់ក្នុងសំណុំរឿងចុះក្នុងបញ្ជីរលិក្ខិតរឿង។

## ប្រការ ៣៦.

ឯតាំងឱ្យមានថណាយជួសនោះបានការរហូត លុះតែកាត់សេចក្ដីហើយគិតតាំងពីថ្ងៃដែលឱ្យដំណឹងអំពីតាំងឱ្យមានថណាយទោះកាត់សេចក្ដីដាច់ណាត់ហើយរើជំនុំជំរះឡើងវិញក៏នៅនិយាយការបានដែរ។

## ប្រការ ៣៧.

នាកាលរឿងឡើងដល់សាលាជាន់ខ្ពស់ដោយមានពាក្យឧទ្ធរណ៍ ឬពាក្យសាទុកប្ដឹង នោះត្រូវតាំងថណាយជាថ្មីទៀត បើសាលាជាន់ខ្ពស់បញ្ជូនត្រឡប់មកបន្សល់ឱ្យរើជំនុំជំរះឡើងវិញនោះមិនត្រូវតាំងថណាយជាថ្មីទៀតទេ។

## ប្រការ ៣៨.

នឹងឈប់លែងឱ្យមានថណាយជាមុនបាន ទោះរឿងក្ដីជំនុំជំរះបានការដូចម្ដេចក៏ដោយគឺកាលណាសាមីខ្លួនដកលែងឱ្យមានក្ដី នាក់ថណាយឈប់លែងថណាយក្ដី សាមីខ្លួននឹងនាក់ថណាយព្រមព្រៀងគ្នាឈប់ក្ដី ឬចៅក្រំលើកជាអាសាឥតការឯងៗក្ដី។

## ប្រការ ៣៩.

ឯដកលែងឱ្យដំណាង នាក់ថណាយឈប់នឹងឈប់ដោយព្រមព្រៀងគ្នា ត្រូវឱ្យដំណឹងដោយមានពាក្យប្ដឹងក្ដី ដោយប្ដឹងមាត់ទទេ ដែលចៅក្រំនឹងក្រឡាប៉័ញ្ជីរត្រូវកត់ហេតុ ១ រំពេចក្ដី។

ឯលើកជាអាសាឥតការឯងៗ ដោយមានដិកាចុះហេតុពីចាងហ្វាងសាលាសំរេច។

## ប្រការ ៤០.

ក្រឡាប៉័ញ្ជីរទាំងឡាយ ត្រូវឱ្យដំណឹងសាមីខ្លួនជាប្រញាប់ពីកិច្ចដែលបណ្ដាលឱ្យបន់ឈប់ថណាយនោះ។

## ប្រការ ៤១.

សំបុត្រកិច្ចបណ្ដាលឱ្យបន់ឈប់ថណាយ នឹងសេចក្ដីចំឡងសំបុត្រដែលក្រឡាប៉័ញ្ជីរឱ្យដំណឹងទៅ ត្រូវទុកក្នុងសំណុំរឿងហើយចុះក្នុងប៉័ញ្ជីរលិក្ខិតរឿង។

**ប្រការ ៤២.**

នាកាលផុតលែងឱ្យដំណាងជាមុន នាក់ថណាយត្រូវឈប់លែងជួយសង្គ្រោះមនុស្សត្រូវចោទ្យ ឬដំណាងនាក់ក្ដីទៀតបានតាំងពីថ្ងៃដែលបានទទួល ឬបានធ្វើសំបុត្រកិច្ចបន់ឈប់នោះតាមដំណើរ។

**ប្រការ ៤៣.**

សេចក្ដីដែលសាមីខ្លួននាក់ក្ដី នឹងនាក់ថណាយទាស់គ្នា ពីបន់ឈប់លែងឱ្យថណាយមិននាំឱ្យអាក់រឿងដែលប្ដឹងទេ ត្រូវតែជំនុំជំរះដូចជាពុំបានតាំងឱ្យមានថណាយតរទៅ។

## ជំពូក ៣

## អំពីអំណាចនៃនាក់ថណាយ

**ប្រការ ៤៤.**

ឯតាំងឱ្យមានថណាយជួស នោះនាំឱ្យតាំងទីលំនៅសាមីខ្លួននៅទីកន្លែងធ្វើការអ្នកថណាយពេញច្បាប់។

**ប្រការ ៤៥.**

អ្នកថណាយត្រូវមានផ្ទះសំរាប់នៅមន្ទីធ្វើការ នៅនាទីសាលាជំនុំណា ១។

នាក់ថណាយនីមួយៗ មិនត្រូវមានកន្លែងធ្វើការលើសពី១ទេ ប៉ុន្តែដើម្បីនឹងនិយាយក្ដីឱ្យបានងាយឆាប់រហាស់នឹងតាំងទីលំនៅ មន្ទីធ្វើការរបស់នាក់ថណាយណាមួយដែលព្រមផងហើយឱ្យនាក់ថណាយនោះជំនួសខ្លួនបាន តែមន្ទីធ្វើការនាក់ថណាយដែលរើសជំនួសនោះ ត្រូវឱ្យមាននៅទីរួមខែត្រសាលាជំនុំដែលប្ដឹងទើបបាន។

**ប្រការ ៤៦.**

មន្ទីធ្វើការត្រូវឱ្យបិទកំណត់ខាងក្រៅដាក់ឈ្មោះនាក់ថណាយ នឹងដាក់ថាជានាក់ថណាយដែលសាលាអនុញ្ញាតផង ហើយនឹងចុះងារជាកិត្តិយសឬសញ្ញាបត្តនឹងគ្រឿងឥស្សិរិយសដែលមានក៏ពីឈ្មោះទៅទៀតក៏បាន។

**ប្រការ ៤៧.**

តាំងពីថ្ងៃដែលតាំងឱ្យមានថណាយតាមរបៀបបញ្ញត្តិច្បាប់ហើយ សំបុត្រស្នាមកិច្ចការអ្វីទាំងឡាយដែលនៅមន្ទីធ្វើការនាក់ថណាយ ឬនាក់ថណាយជំនួសនោះទុកជាស្រេចបានការបាន។

## ប្រការ ៤៨.

នាក់ថណាយទាំងឡាយ ត្រូវប្រុងប្រៀបវេលាណាខ្លួនមិននៅឬមានធុរៈ បើមានលិក្ខិតពាក្យរឿងក្ដីនឹងសំបុត្រស្នាមអ្វីសំរាប់រឿងក្ដី ដែលខ្លួនដំណាងថណាយនោះត្រូវឱ្យបានទទួលជរាបជានិច្ច ក្នុងមន្ទីធ្វើការរបស់ខ្លួន បើទទួលសំបុត្រលិក្ខិតអ្វីគ្រប់ជំពូក ត្រូវបោះត្រាសម្គាល់សំរាប់មន្ទីធ្វើការនោះទុកជាបានការថាបានទទួលហើយ។

ទោះប្រការយ៉ាងណាក្ដី បើមនុស្សនៅធ្វើការក្នុងមន្ទីនាក់ថណាយមិនឃើញប្រកែកថាសំបុត្រអ្វីដែលយកទៅប្រគល់ដល់មន្ទីឬមិនព្រមទទួលសំបុត្រនោះ នាក់ថណាយទាំងឡាយ នឹងដោះសាថាខ្លួនមិននៅឬមានធុរៈពុំបានឡើយ។

## ប្រការ ៤៩.

សំបុត្រស្នាមអ្វី ត្រូវមន្ទីក្រឡាប័ញ្ជីរសាលាបញ្ជូនទៅមន្ទីធ្វើការនាក់ថណាយតាមសៀវភៅបញ្ជូនផ្ទាល់ រហូតតែម្ដងក្ដី បញ្ជូនទៅនាក់ថណាយដែលជំនួសក្ដី ឬបញ្ជូនទៅមន្ទីក្រឡាប័ញ្ជីរសាលា ដែលមានមន្ទីនាក់ថណាយនៅនោះប្រគល់ឱ្យក្ដី។

បើបោះត្រាសម្គាល់សំរាប់មន្ទីធ្វើការនាក់ថណាយលើសៀវភៅបញ្ជូននោះ ហើយទុកជាបានទទួលសំបុត្រស្នាមដែលរាយក្នុងសៀវភៅបញ្ជូននោះ។

## ប្រការ ៥០.

អំពីរឿងរដ្ឋបវេណីនាក់ថណាយត្រូវជំនួសសាមីខ្លួននាក់ក្ដីពេញច្បាប់ ហើយដំណាងជួសក្នុងកិច្ចការក្ដីគ្រប់ជំពូកនឹងក្នុងខណពិភាក្សាជំនុំជំរះ។

បើពិភាក្សានឹងកាត់សេចក្ដីនៅមុខនាក់ថណាយ ហើយសាមីខ្លួននាក់ក្ដីពុំបានចូលមកនោះមិនមានទម្ងន់អ្វីទៅលើកិរិយាចំពោះមុខគូក្ដីទេ ទុកជាចំពោះមុខបាន។

បើខាងសាមីខ្លួននាក់ក្ដី ឬខាងនាក់ថណាយទទួលសារភាពក្ដី ព្រមតាមក្ដី ទទួលឬមិនទទួលតាមសេចក្ដីគេសុំក្ដីឈប់លែងប្ដឹងក្ដី នោះនាក់ទាំង២ត្រូវតែព្រមព្រៀងគ្នាទៅវិញទៅមកទើបបាន។

ប៉ុន្តែនាក់ថណាយមិនត្រូវជំនួសនឹងដំណាងនាក់ក្ដី ដូចមានខ៏ខាងក្រោមនេះបានទេ៖

១. នាកាលបង្គាប់ឱ្យនាក់ក្ដីចូលមកផ្ទាល់ខ្លួន។

២. នាកាលចៅក្រំឬគូក្ដីម្ខាងឱ្យស្បថ។

បើនាក់ថណាយទទួលសារភាពក្តី និយាយសុំសេចក្តីអ្វីក្តី មិនទទួលក្តី ទទួលក្តី ឈប់ប្តឹងក្តី ឬព្រមតាមក្តី ដោយសាមីខ្លួនពុំបានព្រមជាមួយផង នោះនាក់ថណាយត្រូវទទួលខុសនឹងនាក់ក្តី នឹងត្រូវមានទោសទណ្ឌកម្មឬទោសអាជ្ញាថែមទៀតផង។

**ប្រការ ៩១.**

អំពីរឿងអាជ្ញាគតិ នោះនាក់ថណាយនឹងជំនួសឬជំណាងសាមីខ្លួនពុំបានទេ បើវេលាណា ដែលសាមីខ្លួនចូលទៅឯចៅក្រំ ឬទៅឯភ្នាក់ងារក្រុំព្រះនគរបាលយុត្តិធម៌ ដែលចៅក្រំចាត់ជំនួស ខ្លួនហៅទៅសួរ នោះនាក់ថណាយត្រូវទៅជួយស្តាប់ការ។

ខណដែលសាមីខ្លួនមិនបានទៅនោះ ត្រូវឱ្យនាក់ថណាយទៅស្តាប់សេចក្តីស៊ើបសួរតាម កិច្ចការទាំងឡាយដែលត្រូវធ្វើហើយអំពីសួរយកចំឡើយសាក្សីក្តី ដំណើរទៅទីណាក្តី ទៅពិនិតដល់ ទីកន្លែងក្តី ផែកធេររើនឹងរិបអូសក្តីជាដើម ក៏ត្រូវធ្វើដូចគ្នាដែរ។

**ប្រការ ៩២.**

ឯនាក់ថណាយមិនមែនតែត្រូវទៅស្តាប់ការខានមិនបានក៏ទេ នឹងមិនទៅជួយស្តាប់ការ សាមីខ្លួនខណដែលសួរស័ម្ធ ឬវេលាពិភាក្សាបានដរាប តែត្រូវទទួលខុសត្រូវលើខ្លួន ត្រូវតែប្រាប់ឱ្យ ទៅជួយសេចក្តីសាមីខ្លួននាក់ក្តី ឬគ្រាន់តែប្រាប់ឱ្យទៅស្តាប់ការស៊ើបសួរតែប៉ុណ្ណោះក៏បានហើយ។

**ប្រការ ៩៣.**

ឯនឹងឱ្យដំណឹងនាក់ថណាយទៅជួយសាមីខ្លួន ឬឱ្យទៅស្តាប់ការ វេលាដែលតុលាការ ស៊ើបសួររឿងសាមីខ្លួននោះមន្ទីក្រឡាប៍ញ្ជីរចេញសំបុត្រហៅទុកជាក្សិណ បើចៅក្រំបានឱ្យដំណឹង មាត់ទទេ ប្រាប់នាក់ថណាយដែលបានចូលមកស្តាប់ថាបង្អង់ដល់ថ្ងៃណាវេលាម៉ោងប៉ុន្មានឱ្យមក ស្តាប់សួរយកចំឡើយឬពិភាក្សាតទៅទៀតនោះ មិនត្រូវមានសំបុត្រហៅទេ ប៉ុន្តែក្រឡាប៍ញ្ជីរត្រូវ កត់សេចក្តីដែលចៅក្រំឱ្យដំណឹងនោះក្នុងកំណត់កត់ហេតុក៏បាន ឬក្នុងសៀវភៅសំរាប់ក្រឡាប៍ញ្ជីរ កត់សេចក្តីវេលាជំនុំជំរះមួយលើកៗ ទុកជាចំណាំក៏បានតាមការ។

ឯតាមច្បាប់សំបុត្រហៅត្រូវផ្ញើទៅឱ្យមុន២៤ម៉ោង ប៉ុន្តែបើការប្រញាប់ចៅក្រំនឹងហៅ នាក់ថណាយវេលាម៉ោងណាបានដរាប។

## ប្រការ ៥៤.

កិច្ចការអ្វីដែលចៅក្រុំឬនាក់ដំណាងចៅក្រុំបានធ្វើនោះ ត្រូវចុះសេចក្តីផ្សេងឱ្យដឹងជានាក់ចំណាយដែលគេពឹងបានចូលមកឬពុំបានចូលមកទេ បើបានចូលមកត្រូវចុះស៊ីញ៉េជាមួយនឹងចៅក្រុំឬដំណាងចៅក្រុំហើយនឹងក្រឡាប័ញ្ជីរ បើពុំបានចូលមកទេក្រឡាប័ញ្ជីរត្រូវកត់ក្នុងកំណត់ហៅ ឬក្នុងសេចក្តីប្រាប់មាត់ទទេឱ្យដឹង។

## ប្រការ ៥៥.

ត្រូវឱ្យដំណឹងទៅនាក់ចំណាយដែលគេពឹងសេចក្តីដូចមានរាយខាងក្រោយនេះ៖

១. សានក្រុំសាលាដំបូង នឹងសានក្រុំសាលាឧទ្ធរណ៍ សាលាវិនិច្ឆ័យដែលកាត់សេចក្តីដោយនាក់ចំណាយពុំបានចូលមក។

២. អំពីឈប់សួរស័ម្ពរឿងអាជ្ញា ឬស៊ើបសួររឿងរដ្ឋបវេណីរួចជាស្រេច មុនសំរេចទោសឬមុនជំនុំជំរះ។

៣. ថ្ងៃខែឆ្នាំដែលត្រូវជំនុំជំរះរឿងដែលមានពាវ័ដមានសព្វគ្រប់បញ្ជូនទៅដើម្បីជំនុំជំរះកាត់សេចក្តី។

៤. សានក្រុំសាលាក្រុំចោទ្យកាត់សេចក្តី។

៥. សេចក្តីដែលសំរេចពីឃុំខ្លួននឹងពីដោះបន្លើរសិន។

សេចក្តីឱ្យដំណឹងត្រូវមានដិកាធ្វើជាពីរច្បាប់ ចុះថ្ងៃខែឆ្នាំនឹងសញ្ញានាមក្រឡាប័ញ្ជីរសាលាដែលប្តឹង មានចាងហ្វាងឬចៅក្រុំ ស៊ីញ៉េអមដិកានោះផងតាមការ ធ្វើទៅតាមសៀវភៅបញ្ជូនរួចត្រូវបញ្ជូន ១ ច្បាប់ត្រឡប់មកមន្ទីក្រឡាប័ញ្ជីរវិញមួយរំពេចចុះសេចក្តីថាបានទទួលហើយ ឬបោះត្រាសំរាប់មន្ទីនាក់ចំណាយដើម្បីទុកក្នុងសំណុំរឿង ហើយកត់ក្នុងប័ញ្ជីរសារបានលិក្ខិតរឿង។

## ប្រការ ៥៦.

អំពីរឿងទាំងអស់ នាក់ចំណាយនឹងទៅឯមន្ទីក្រឡាប័ញ្ជីរមើលសំណុំរឿងក្តីដែលគេពឹងខ្លួនបាន នឹងចំឡងសំបុត្រស្នាមដែលគូក្តីប្តឹង សំបុត្រកត់ហេតុពីក្រសួងបារាំងសែសឬខេមរ សំបុត្ររាយការពីសោតស៊ើបសួរ សានក្រុំដែលកាត់សេចក្តីនឹងសំបុត្រលិក្ខិតទាំងអស់ក្នុងរឿង។

ឯសំបុត្រស្នាមឯទៀតមិនត្រូវឱ្យមើលទេ គឺពាវ៌ដមានសំបុត្រស្នាមដែលក្រសួងរាជ្ការផ្សេងៗ នឹងរាជ្ការប្រតិកតូ៉ាផ្ញើមកជាដើម សំបុត្រស្នាមទាំងនោះនឹងឱ្យនាក់ថណាយមើលបាន លុះតែមានពាក្យប្តឹងសុំ ហើយបញ្ជូនសំណុំរឿងទៅឱ្យសាលាវិនិច្ឆ័យពិនិតចេញដិកាចុះហេតុអនុញ្ញាត ហើយឱ្យសេនាបតីក្រសួងយុត្តិធម៌យល់ព្រមផងទើបបាន បើពុំព្រមទេនឹងប្តឹងត៉ាំពុំបានឡើយ។

**ប្រការ ៥៧.**

ឯមើលសំណុំរឿង ត្រូវមើលនៅទីសាលាជំនុំតាមពេលម៉ោងធ្វើការនៅមុខក្រឡាប័ញ្ជីរឬសមុហប័ញ្ជីរណា១ ដែលក្រឡាប័ញ្ជីរចាត់ឱ្យនៅនោះខុសត្រូវលើខ្លួនក្រឡាប័ញ្ជីរស្រាប់។

**ប្រការ ៥៨.**

បានតែនាក់ថណាយផ្ទាល់ខ្លួន ឬនាក់ថណាយណាមួយជំនួស ទើបទៅមើលសំណុំរឿងក្តីដែលខ្លួនទទួលកែសេចក្តីនឹងចម្លងសំបុត្រស្នាមបាន ទោះប្រការយ៉ាងណាក៏ដោយ នឹងឱ្យនាក់ក្រៅដទៃធ្វើជួសខ្លួនពុំបានឡើយ តែមនុស្សដែលធ្វើការនៅមន្ទីខ្លួនជានិច្ចក៏ពុំបានដែរ។

**ប្រការ ៥៩.**

ធម្មតាដែលសុំសំណុំរឿងមើលនោះ ត្រូវធ្វើពាក្យសុំជាមុនប្តឹងថៅក្រំដែលទទួលរឿងនោះទើបចាងហ្វាងឬថៅក្រំក៏បានតាមការព្រមព្រៀងនឹងក្រឡាប័ញ្ជីរសំរេចថ្ងៃនឹងពេលម៉ោងដែលឱ្យមើលសំណុំរឿង ឥតមានទាស់អ្វីនឹងការដែលធ្វើក្នុងសាលាបាន។

**ប្រការ ៦០.**

នាក់ថណាយទៅជួបនឹងសាមីខ្លួននាក់ក្តី បានតាមចិត្ត ប៉ុន្តែអំពីរឿងអាជ្ញាគតិ បើសាមីខ្លួនជាប់ឃុំត្រូវបានអនុញ្ញាតពីថៅក្រំៗ ដោយព្រមព្រៀងនឹងនាក់ថណាយរួច ចេញដិកាយកខ្លួនចុះថ្ងៃនឹងពេលម៉ោង ដែលត្រូវឱ្យនាំខ្លួនមកឯមន្ទីក្រឡាប័ញ្ជីរសាលា។

ឯនិយាយការជាស្ងាត់ ឬលាក់បំបាំងដោយមាត់ទទេ ឬដោយមានសំបុត្រសរសេរទៅវិញទៅមកត្រូវហាមផ្តាច់ ។

**ប្រការ ៦១.**

នាក់ថណាយនឹងអធិប្បាយជូនសេចក្តីយល់របស់ខ្លួនសេចក្តីសុំ សេចក្តីកែដោះសាបន្សល់នឹងសំអាងដោយមាត់ទទេក្តី ដោយលិក្ខិតក្តី បានតាមចិត្ត បើប្តឹងឧទ្ធរណ៍ នឹងសាលាវិនិច្ឆ័យ

ត្រូវតែធ្វើពាក្យរាយសំអាងដែលអាងអមផងខានមិនបាន បើប្ដឹងសាលាក្រុំចោទ្យក៏ត្រូវធ្វើពាក្យជូនសំអាងដែលសាមីខ្លួនអាងកែដោះសាខ្លួនដូចគ្នាដែរ។

ឯសំបុត្រស្នាមពាក្យអ្វីនីមួយៗដែលនាក់ចណាយប្ដឹងនោះ ត្រូវឱ្យចុះថ្ងៃខែឆ្នាំស៊ីញ៉េឈ្មោះនឹងបោះត្រាមន្ទីនាក់ចណាយបើបានទទួលសំបុត្រឬពាក្យគ្រាណា ក្រឡាប័ញ្ជីរត្រូវចេញបង្កាន់ដៃឱ្យចុះស៊ីញ៉េបោះត្រាក្នុងសំបុត្រ ឬពាក្យនោះដាក់ក្នុងសំណុំរឿង ហើយកត់ក្នុងប័ញ្ជីរាយលិក្ខិតរឿង។

## ប្រការ ៦២.

នាកាលនាក់ចណាយសុំឱ្យសួរជាប្រយោជន៍ រកឱ្យឃើញសេចក្ដីពិត ឬជាប្រយោជន៍កូនក្ដីរបស់ខ្លួន នោះត្រូវទទួលធ្វើតាមសុំជាប្រញាប់ បើចៅក្រំយល់ថាសុំដោះគាប្បី បើយល់ថាមិនគាប្បីទេត្រូវឱ្យនាក់ចណាយធ្វើជាពាក្យសុំ រួចចៅក្រំចេញដិកាសំរេចសេចក្ដីចុះហេតុសព្វគ្រប់តាមការ ត្រូវក្រឡាប័ញ្ជីរឱ្យដំណឹងដិកាចៅក្រំ ដែលសំរេចសេចក្ដីជាប្រញាប់ទៅនាក់ចណាយៗបើមិនសុខចិត្តនឹងឧទ្ធរណ៍បានក្នុងរវាង ១០ ថ្ងៃ គិតតាំងពីថ្ងៃដែលឱ្យដំណឹង ឯឧទ្ធរណ៍នោះមិនបន្ទាលឱ្យបង្អង់សេចក្ដីដែលបានសំរេចទេ បើរឿងមជ្ឈិមត្រូវឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ បើរឿងឧក្រិដ្ឋត្រូវឧទ្ធរណ៍ទៅសាលាក្រុំចោទ្យ។

## ប្រការ ៦៣.

នាក់ចណាយដែលនឹងនិយាយ ត្រូវសុំអនុញ្ញាតពីចៅក្រំបានសិនទើបនិយាយបាន មិនត្រូវនិយាយកាត់សេចក្ដីស៊ើបសួរឬពិភាក្សាទេ ទោះប្រការយ៉ាងណាក្ដី។

ឯវេលាកំពុងជំនុំជំរះ ឬខណកំពុងស៊ើបសួរ នោះត្រូវនិយាយផ្ទាល់ទៅចៅក្រំ ឬទៅសាមីខ្លួននាក់ក្ដីដែលខ្លួនកែសេចក្ដី ហាមផ្ដាច់មិនឱ្យនិយាយផ្ទាល់ទៅគូក្ដីម្ខាង ទៅសាក្សីដើមចោទ្យ ឬមនុស្សត្រូវចោទ្យដែលខ្លួនមិនបានទទួលកែសេចក្ដីនោះឡើយ។

## ប្រការ ៦៤.

នាកាលចៅក្រំយល់ថាគួរអនុញ្ញាតឱ្យនាក់ចណាយនិយាយទើបនិយាយបាន។

ខណដែលកំពុងស៊ើបសួរនឹងពិភាក្សាសេចក្ដី កាលណាបានសួរយកចំឡើយនីមួយ សួរសាក្សីម្ដងៗ នឹងសួរតទល់គ្នាមួយគ្រាៗរួច ត្រូវបើកឱ្យនាក់ចណាយនិយាយកុំខាន សេចក្ដីដែល

បើកឱ្យនិយាយនោះ ត្រូវចុះក្នុងកំណត់ហេតុក៏បាន ឬក្នុងសៀវភៅ (ភ្លូមីទីហ្វ) សំរាប់ក្រឡាប៉ញ្ជីរកត់សេចក្តីវេលាជំនុំជំរះក៏បានតាមការ។

**ប្រការ ៦៥.**

វេលាកំពុងស៊ើបសួរនឹងពិភាក្សាសេចក្តីនាក់ថណាយដែលបានអនុញ្ញាតនិយាយ ត្រូវនិយាយប្រយោជន៍បន្សល់ ឬបញ្ជាក់សេចក្តីដែលខ្លួនចង់ឱ្យចៅក្រំសួរប្រកែកទាស់យ៉ាងណា សុំឱ្យតុលាការចាត់ការស៊ើបដូចម្តេច បន្សល់បំភ្លឺសេចក្តីហើយមិនត្រូវដដែកនិយាយដល់អង្គសេចក្តីទេ តែដដែកត្រូវដកអនុញ្ញាតមិនឱ្យនិយាយឡើយ។

**ប្រការ ៦៦.**

នាកាលចាងហ្វាងប្រាប់ថាពិភាក្សាសេចក្តីចប់ហើយ ត្រូវឱ្យនាក់ថណាយមើលកំណត់ដែលខ្លួនយល់ឃើញសុំដូចម្តេច នឹងអធិប្បាយបំពេញសេចក្តីមាត់ទទេទៀតក៏បានរួចត្រូវប្រគល់កំណត់នោះឱ្យក្រឡាប៉ញ្ជីរមួយរំពេច ក្រឡាប៉ញ្ជីរត្រូវស៊ីញេបោះត្រារួចដាក់ក្នុងសំណុំរឿង ហើយចុះក្នុងប៉ញ្ជីរលក្ខិតរឿងកិច្ចដែលបានសំរេចតាមរបៀបទាំងនេះ ត្រូវកត់ក្នុងសៀវភៅ (ភ្លូមីទីហ្វ) សំរាប់ក្រឡាប៉ញ្ជីរកត់។

បើមិនបានជូនកំណត់យល់ឃើញនោះទេ ត្រូវនាក់ថណាយទទួលខុសត្រូវនឹងសាមីខ្លួននាក់ក្តីរបស់ខ្លួន។

ប៉ុន្តែក្នុងសាលាឧក្រិដ្ឋ នាក់ថណាយដែលមនុស្សជាប់ចោទ្យពឹងនឹងសំរេចសេចក្តីសុំមាត់ទទេបាន។

**ប្រការ ៦៧.**

អំពីរឿងរដ្ឋបវេណី ត្រូវឱ្យមើលកំណត់សុំរបស់ដើមចោទ្យមុនរួចមើលកំណត់របស់ចុងចម្លើយក្រោយ។

អំពីរឿងអាជ្ញាគតិ ត្រូវមើលកំណត់សុំរបស់ដើមចោទ្យបទរដ្ឋបវេណីមុន រួចមើលកំណត់របស់មនុស្សជាប់ចោទ្យក្រោយ។

បើមានដើមចោទ្យច្រើន ចុងចម្លើយច្រើន ដើមចោទ្យបទរដ្ឋបវេណី ឬមនុស្សជាប់ចោទ្យច្រើននាក់ ចាងហ្វាងត្រូវរៀបរបៀបឱ្យនាក់ថណាយនិយាយកុំឱ្យតែទាស់នឹងបញ្ញត្តិខាងលើ គឺទុក

ឱ្យចុងចំឡើយឆ្លើយតនឹងដើមចោទនឹងឱ្យអំណាចមនុស្សជាប់ចោទនិយាយចុងក្រោយបង់អស់ជាដរាប។

## ប្រការ ៦៨.

ចៅក្រមមិនត្រូវកាត់សេចក្តីមុននឹងឱ្យនាក់ចណាយមើលហើយជូនកំណត់សុំនោះឡើយ។

កាលណានាក់ចណាយ ដែលមនុស្សជាប់ចោទពឹងជូនសេចក្តីអធិប្បាយយល់ឃើញរួច សាលាឧក្រិដ្ឋត្រូវកាត់សេចក្តី១រំពេច ឯសាលាឯទៀតក្រោយដែលជូនកំណត់យល់ឃើញរួចនឹងកាត់សេចក្តី ១ រំពេចបាន ឬនឹងបង្អង់ទុកជំនុំជំរះលើកក្រោយក៏បាន។

## ប្រការ ៦៩.

អំពីរឿងរដ្ឋបវេណីនឹងរឿងមជ្ឈិម កាលណាឈប់ពិភាក្សា នាក់ចណាយនឹងសុំឱ្យបង្អង់កាត់សេចក្តីទុកដល់លើកក្រោយបាន ដើម្បីនឹងជូនសេចក្តីយល់ឃើញ តែតទៅនឹងសុំឱ្យបង្អង់ទៀតមិនបានទេ។

បើដល់ជំនុំលើកក្រោយមិនបានជូនសេចក្តីយល់ឃើញទេត្រូវកត់ក្នុងសៀវភៅ (ភ្លូមីទីហ្វ) ថាពុំបានជូនកំណត់យល់ឃើញទេ ហើយត្រូវរំលងកាត់តាមសេចក្តីស្ពានដែលសំរេចក្នុងប្រការខាងលើ។

## ប្រការ ៧០.

ប៉ុន្តែបើនាក់ចណាយដែលចុងចម្លើយ ឬមនុស្សជាប់ចោទជាមជ្ឈិមពឹងនោះសុំឱ្យបង្អង់ ៨ ថ្ងៃម្តងទៀតនឹងឱ្យបាន ដើម្បីនឹងបានតសេចក្តីដែលដើមចោទ ឬដើមបន្តឹងបទរដ្ឋបវេណីប្តឹងសុំពីរឿងមជ្ឈិមនោះ។

## ប្រការ ៧១.

នាក់ចណាយនឹងធ្វើពាក្យផ្សេងសំរាប់រឿងនីមួយៗ សុំឱ្យចុះប័ញ្ជីរឬដាក់រឿងដែលខ្លួនកាន់នោះជំនុំជំរះបានបើសាមីខ្លួននាក់ក្តី ដែលខ្លួនដំណាងមិនទាន់ដាក់ប្រាក់ខ្ទាត់នឹងប្រដាប់ក្តីនៅមន្ទីក្រឡាប័ញ្ជីរក៏ដោយ ពាក្យនោះត្រូវក្រឡាប័ញ្ជីរស៊ីញេរួចដាក់ក្នុងសំណុំរឿងនឹងចុះក្នុងប័ញ្ជីរលិក្ខិតរឿង បើទារប្រាក់ខ្ទាត់នឹងប្រដាប់ក្តីមិនបានទេ ត្រូវនាក់ចណាយទទួលលើខ្លួនជួសនាក់ក្តីនឹងក្រឡាប័ញ្ជីរ។

**ប្រការ ៧២.**

នាក់ថណាយណាមួយដែលយល់ថាគេ ធ្វើរំលោភចំទាស់មិនឱ្យខ្លួនជួយកែសេចក្ដីបាន នឹងធ្វើពាក្យឥតយកថ្លៃប្ដឹងចាងហ្វាងសាលាបាន បើចាងហ្វាងមិនសំរេចឱ្យបានសុខចិត្តទេ នឹងចំឡងពាក្យនោះជូនទៅសេនាបតីក្រសួងយុត្តិធម៌ បើយល់ថាត្រូវការឱ្យធ្វើអង្កេត នឹងបង្គាប់ឱ្យចៅក្រំសាលាវិនិច្ឆ័យមួយនាក់ ដែលចាងហ្វាងសាលានេះចាត់ធ្វើអង្កេត រួចសំរេចសេចក្ដីករណីហេតុនោះ តាមសេចក្ដីជំនុំក្រុំជំនុំសាលាវិនិច្ឆ័យដែលយល់ឃើញ។

សេចក្ដីដែលសេនាបតីសំរេចនឹងប្ដឹងតវ៉ាទៀតពុំបានឡើយហើយត្រូវឱ្យដំណឹងទៅនាក់-ថណាយនឹងចៅក្រំនោះ។

**ប្រការ ៧៣.**

នាក់ថណាយនឹងជួយថណាយកែសេចក្ដីទទេឥតយកថ្លៃក៏បាន ឬទាររង្វាន់ក៏បាន។

**ប្រការ ៧៤.**

បើចាត់ជារាជ្ការឱ្យជួយមនុស្សជាប់ចោទដែលពុំបានតាំងថណាយក្នុងសាលាឧក្រិដ្ឋនោះត្រូវនាក់ថណាយជួយកែសេចក្ដីមនុស្សជាប់ចោទនោះទទេឥតយកថ្លៃ។

**ប្រការ ៧៥.**

ឯចាត់ជារាជ្ការនោះ ត្រូវចាងហ្វាងសាលាឧក្រិដ្ឋចេញដិកាចាត់ ហើយត្រូវក្រឡាបញ្ជីរសាលាឧក្រិដ្ឋឱ្យដំណឹងទៅនាក់ថណាយ បើយ៉ាងតិចរវាង ១០ ថ្ងៃមុនបើកវេលាជំនុំជំរះ តាំងពីថ្ងៃដែលបានឱ្យដំណឹងថណាយនឹងមើលសំណុំរឿងនៅមន្ទីរក្រឡាបញ្ជីរសាលាឧក្រិដ្ឋបាន នឹងជួបនិយាយការជាមួយនឹងមនុស្សត្រូវចោទបាន តែត្រូវចេញដិកាឱ្យនាំមនុស្សត្រូវចោទនោះទៅឯសាលាយុត្តិធម៌ តាមថ្ងៃនឹងម៉ោងដែលចាងហ្វាងនឹងនាក់ថណាយដែលចាត់នោះព្រមព្រៀងគ្នាឱ្យនាំមក។

**ប្រការ ៧៦.**

ឯនឹងចាត់ជារាជ្ការនោះ បានខ្លែនាក់ថណាយដែលនៅៗ ទីដែលមានសាលាឧក្រិដ្ឋ ហើយដោយសុចរិតត្រូវចាត់ម្ដងម្នាក់ នាក់ថណាយដែលត្រូវចាត់នោះ នឹងព្រមព្រៀងជាមួយនឹងនាក់ថណាយដូចគ្នាឱ្យជួសខ្លួនបានតាមចិត្ត តែត្រូវឱ្យប្ដឹងចាងហ្វាងសាលាឧក្រិដ្ឋផង ឯចាងហ្វាង

បើឃើញមានសេចក្ដីទាស់ប្រយោជន៍អ្វីរបស់គូក្ដី ដោយនាក់ថណាយតែម្នាក់ដដែលជួយកែសេចក្ដីនោះត្រូវកុំឱ្យជំនួសគ្នា។

**ប្រការ ៧៧.**

ឯរង្វាន់នឹងទារជាមុនទាំងអស់ឬខ្លះបាន ឯនឹងទារទាំងអស់បាននោះ បាន្តែតាំងពីថ្ងៃដែលកាត់សេចក្ដីរឿង ដែលព្រមព្រៀងឱ្យរង្វាន់គ្នានោះជាស្រេចឥតរើទៀតបាន។

**ប្រការ ៧៨.**

អំពីចេញរង្វាន់ឱ្យនោះ ត្រូវតែសាមីខ្លួននាក់ក្ដីដែលពឹងថណាយចេញដរាប ទោះសាលាកាត់សេចក្ដីដូចម្ដេចក៏ដោយ ហើយបើគូក្ដីម្ខាងត្រូវបង់ខ្ទាត់នឹងប្រដាប់ក្ដីក៏ដោយ។

ឯសាមីខ្លួននាក់ក្ដីច្រើននាក់ដែលបានតាំងឱ្យមាននាក់ថណាយតែម្នាក់នោះ ត្រូវរួមគ្នាចេញរង្វាន់ដែលបានព្រមព្រៀងនោះ។

**ប្រការ ៧៩.**

បើទ្វាររង្វាន់ពុំបាន នឹងប្ដឹងដល់តុលាការបាន ឯពាក្យដែលប្ដឹងរឿងនេះ ត្រូវឱ្យរួចខ្ទាត់ទាំងអស់គ្រប់ជាន់សាលាទាំងចោទនឹងចម្លើយ ឯពាក្យដែលប្ដឹងនោះនឹងបន្ទាលឱ្យកាត់សេចក្ដីឱ្យសងសោហ៊ុយជម្ងឺចិត្ត បានតែចុងការប្រាក់ដែលជំពាក់ តាមច្បាប់គិតតាំងពីថ្ងៃដែលត្រូវសងប្រាក់នោះរហូតដល់សងរួចជាស្រេច។

**ប្រការ ៨០.**

ក្នុងជំនួនប្រាក់រង្វាន់នោះ ត្រូវប្រើចាយវាយក្នុងការដែលត្រូវការកែសេចក្ដីរបស់នាក់ក្ដីគ្រប់ជំពូក ដើមឡើយធ្វើពាក្យប្ដឹងសព្វសារពើ ព្រមទាំងពាក្យប្ដឹងអំពីឃុំខ្លួន ឬដោះបន្ទើរសិន អំពីប្ដឹងទាស់នឹងដីកាចៅក្រំចារបុរស អំពីកាត់សេចក្ដីដាច់ណាត់ អំពីជូនពារ៍ដែមានសំបុត្រស្នាមទុកក្នុងសាលា អំពីថ្លៃសំបុត្រលិក្ខិតសរសេរទៅវិញទៅមក សោហ៊ុយដំណើរ សោហ៊ុយដេកនៅទីកន្លែងណា១ សោហ៊ុយប្ដឹងឱ្យរកពារ៍ដមាន សោហ៊ុយពីគ្រោះប្រឹក្សានឹងនាក់ក្រៅ ឬនាក់មានជំរះវិជ្ជា អំពីគិតគូរនឹងធ្វើការអ្វី១ ប្រយោជន៍ធ្វើការជំណាង ឬក្នុងឱកាសជំណាងនោះ។

**ប្រការ ៨១.**

នាក់ថណាយដែលទារ ឬទទួលប្រាក់ លើសពីជំនួនដែលត្រូវបានតាមច្បាប់នោះ ទុកជាមានទោស ខុសដោយយកប្រាក់លើសជំនួន ត្រូវផ្ដន្ទាតាមមាត្រា ២៦៤ ក្រំព្រហ្មទណ្ឌ។

**ប្រការ ៨២.**

ហាមមិនឱ្យនាក់ថណាយព្រមព្រៀងជាមួយនឹងនាក់ក្ដីសន្យាយកប្រាក់ដោយបង្ខំ ឬដោយលក្ខណមិនប្រាកដ គឺព្រមព្រៀងថាបើកូនក្ដីឈ្នះសេចក្ដីនាក់ថណាយត្រូវបានប្រយោជន៍ផ្ទាល់ខ្លួន ឬឱ្យគេយកជួសខ្លួន ឯនាក់ថណាយ ដែលល្មើសនឹងសេចក្ដីបញ្ញត្តិនេះ ទុកជាមានទោសខុសដោយប្រើអំណាចយកប្រយោជន៍ ត្រូវផ្ដន្ទាតាមមាត្រា ៣១១ ក្រំព្រហ្មទណ្ឌ។

**ប្រការ ៨៣.**

អំពីរឿងរដ្ឋបវេណីនឹងជនដែលតាំងខ្លួន ជាដើមចោទ្យបទរដ្ឋបវេណីក្នុងរឿងអាជ្ញាគតិនោះ រង្វាន់ដែលព្រមព្រៀងគ្នា ឬដែលត្រូវបាននោះ មិនត្រូវឱ្យលើសជំនួនដូចមានខាងក្រោមទេ។

១. នៅសាលាលហុ សាលាដំបូង ចៅក្រំចារបុរស នឹងក្រុំចោទ្យ ត្រូវគិតលើសពីប្រាក់បួកែវសាលាដំបូង ៤ ភាគ ត្រូវជា ២០រៀល នឹងគិត ១ រៀលក្នុង ១០០ រៀលលើដម្លៃក្ដីដែលលើសពី ១០០ រៀលថែមទៀត។

២. ទៅសាលាឧទ្ធរណ៍នឹងសាលាឧក្រិដ្ឋ ត្រូវគិតលើសប្រាក់បួកែវសាលាឧទ្ធរណ៍៣ភាគ ត្រូវជា ៣០ រៀល នឹងយក ១ រៀលក្នុង ១០០ រៀលលើដម្លៃក្ដីដែលលើសពី ១០០ រៀលថែមទៀត។

៣. នៅសាលាវិនិច្ឆ័យ ត្រូវគិតលើសប្រាក់បួកែវសាលាវិនិច្ឆ័យ ២ ភាគ ត្រូវជាប្រាក់ ៣០ រៀល នឹងយក ១ រៀល ក្នុង ១០០ រៀលលើដម្លៃក្ដីដែលលើសពី ១០០ រៀល ថែមទៀត។

បើសាមីខ្លួននាក់ក្ដីច្រើននាក់ពឹងនាក់ថណាយម្នាក់ក៏ពុំត្រូវយករង្វាន់ថែមទៀតឡើយ។

**ប្រការ ៨៤.**

អំពីរឿងអាជ្ញាគតិ រង្វាន់ដែលព្រមព្រៀងគ្នា ឬដែលត្រូវបានពុំត្រូវឱ្យលើសជំនួនដូចមានខាងក្រោមទេ។

១. រឿងលហុទោសនៅសាលាលហុ នឹងសាលាដំបូង ១០ រៀល នៅសាលាវិនិច្ឆ័យ ១០ រៀល។

២. រឿងមជ្ឈិមនៅនាទីចៅក្រំចារបុរសនឹងនៅសាលាដំបូង ២០ រៀល សាលាឧទ្ធរណ៍ ២០ រៀល សាលាវិនិច្ឆ័យ ២០ រៀល.

៣. រឿងឧក្រិដ្ឋនៅនាទីចៅក្រំចារបុរស នឹងសាលាក្រុំចោទ្យ ៣០ រៀល សាលាឧក្រិដ្ឋ ៣០ រៀល សាលាវិនិច្ឆ័យ ៣០ រៀល ១ ទៀតនឹងថែមរង្វាន់ជាប្រាក់ ៥ រៀលក្នុងមនុស្សជាប់ចោទ្យម្នាក់ក្នុងសាលានីមួយៗ បើមនុស្សជាប់ចោទ្យច្រើននាក់តាំងឱ្យមាននាក់ថណាយ។

## ប្រការ ៨៥.

ក្នុងរឿងដែលមានដម្លៃលើសពី ១០០ រៀល ត្រូវគិតបែងភាគរង្វាន់តាមជំនួនប្រាក់ដែលដើមចោទ្យចុះជំនួនក្នុងពាក្យដើម ឬក្នុងពាក្យដែលដើមចោទ្យបទរជ្ជបវេណីប្ដឹងសុំជួសជុលបង់ខាត មិនត្រូវគិតតាមជំនួនប្រាក់ដែលគូក្ដីម្ខាងប្ដឹងសាត្រឡប់សុំជំម្ញឺចិត្តនោះទេ ឯនាក់ថណាយដែលទទួលកែសេចក្ដីឱ្យគូក្ដីនីមួយៗ ក៏ត្រូវគិតរង្វាន់តាមលំដាប់នេះដែរ។

## ប្រការ ៨៦.

នាកាលនាក់ថណាយច្រើននាក់ទទួលដំណាងកែសេចក្ដីឱ្យនាក់ក្ដីតែម្នាក់ជាមួយគ្នា នោះរង្វាន់ដែលព្រមព្រៀងគ្នាឬដែលត្រូវបាន មិនត្រូវលើសពីជំនួនរង្វាន់ដែលនាក់ថណាយតែម្នាក់ត្រូវបាននោះទេ ត្រូវនាក់ថណាយគឺតគូរចែករង្វាន់គ្នា បើទាស់ត្រូវប្ដឹងចាងហ្វាងសាលាវិនិច្ឆ័យ ចាងហ្វាងសាលាវិនិច្ឆ័យនឹងចេញដិកាសំរេចសេចក្ដីឱ្យទទេ ឥតខ្វាត់ជាប្រញាប់ហើយនឹងប្ដឹងតវ៉ាទៅទៀតពុំបានឡើយ បើនាក់ក្ដីម្នាក់តាំងឱ្យមាននាក់ថណាយច្រើននាក់តៗគ្នាក្នុងរឿងតែមួយនោះក៏ ត្រូវសំរេចដូចគ្នាដែរ បើឈប់លែងពឹងថណាយមុនមកពឹងថណាយថ្មីជាក្រោយទៀត នោះនាក់ថណាយមុនត្រូវតែបញ្ជូនសំណុំរឿងមកឱ្យនាក់ថណាយក្រោយកុំខាន មុននឹងសំរេចអំពីចែករង្វាន់គ្នានោះ។

## ប្រការ ៨៧.

នាក់ថណាយត្រូវជួយកែសេចក្ដីសាម៉ីខ្លួននាក់ក្ដីខណដែលរឿងនៅក្នុងជំរះ ឥតទាររង្វាន់ថែមទៀតបានឡើយ គឺនៅក្នុងប្ដឹងតវ៉ាក្ដី វេលាដែលសាលាវិនិច្ឆ័យបន្សល់ឱ្យ រើជំនុំជំរះវិញក្ដី ព្រោះនាក់ក្ដីដដែលបានពឹងខ្លួនឱ្យជួយកែសេចក្ដីតាំងពីមុនមកហើយ បើសាលាក្រុំចោទ្យសំរេចប្រែបទល្មើសជាថ្មីវិញ ហើយបញ្ជូនរឿងទៅឱ្យសាលាមជ្ឈិមជំនុំជំរះ នោះក៏ត្រូវនាក់ថណាយជួយតទៅដូចគ្នា។

## ប្រការ ៨៨.

នាក់ថណាយត្រូវកាត់យកក្នុងរង្វាន់ដែលខ្លួនបាននោះ ជំនួនប្រាក់ ១ ភាគក្នុង ១០ ភាគ ពីរង្វាន់ដែលបានតាមច្បាប់ សំរាប់ឱ្យក្រឡាប័ញ្ជីរដែលធ្វើការក្នុងសាលាដែលទទួលជំនុំជំរះរឿង ដែលខ្លួនកាន់នោះ ប្រាក់នោះជារង្វាន់ដែលក្រឡាប័ញ្ជីរបានធ្វើកិច្ចការរបៀបតាមច្បាប់ បណ្តាល មកអំពីរៀបចំតាំងឱ្យមាននាក់ថណាយ ។

## ប្រការ ៨៩.

រង្វាន់ ១ ភាគក្នុង ១០ ភាគនោះនឹងប្រគល់ឱ្យក្រឡាប័ញ្ជីរបាន លុះតែបានសំរេចកាត់ សេចក្តីរឿងដែលនៅក្នុងសាលាជាស្រេច គឺសាលាលហុ សាលាដំបូង សាលាឧទ្ធរណ៍ នឹង សាលាវិនិច្ឆ័យ បានកាត់សេចក្តីជាស្រេចដល់រូបសេចក្តីហើយ។

អំពីរឿងឧក្រិដ្ឋរង្វាន់ ១ ភាគក្នុង ១០ភាគ នោះត្រូវប្រគល់ឱ្យក្រឡាប័ញ្ជីរវេលាកាលណាមាន សានក្រំសំរេចសេចក្តីបញ្ជូនរឿងឬឱ្យរួចខ្លួនជាស្រេចទើបប្រគល់បាន រង្វាន់នោះត្រូវចែកជាមួយនឹង ក្រឡាប័ញ្ជីរសាលា ដែលបានស៊ើបសួរបន្ទប់សេចក្តីនឹងក្រឡាប័ញ្ជីរសាលាក្រុំចោទ្យ តាមប័ញ្ជីរ ដែលចាងហ្វាងសាលានោះបានស៊ីញ៉េសំគាល់ដាក់ជាប់ជាមួយនឹងកំណត់ ឱ្យដំណឹងអំពីសានក្រំ ដែលសំរេចបញ្ជូនរឿងឬដែលឱ្យរួចខ្លួននោះហើយចុះប័ញ្ជីរទុកក្នុងសំណុំរឿង រង្វាន់ ១ ភាគក្នុង ១០ ភាគដែលត្រូវបានក្រឡាប័ញ្ជីរសាលាឧក្រិដ្ឋ តែក្នុងរង្វាន់ដែលជួយកែសេចក្តីមនុស្សជាប់ចោទ្យ ក្នុងសាលានេះ។

## ប្រការ ៩០.

វេលាដែលពិនិតសំណុំរឿងណាមួយហើយចៅក្រំដែលពិនិតឃើញថា មន្ទីក្រឡាប័ញ្ជីរណា ភ្លេចឬធ្វេសប្រហែសពុំបានសំរេចកិច្ចរបៀបតាមច្បាប់ដែលបញ្ញត្តិអំពីការរៀបចំតាក់តែងនាក់ថណាយ ណាមួយនោះ ត្រូវប្តឹងទៅចាងហ្វាងសាលាវិនិច្ឆ័យៗ តែងសេចក្តីជំនុំចុះហេតុបញ្ជូនទៅសេនាបតី ក្រសួងយុត្តិធម៌តាមការ យល់ព្រមផងបង្គាប់ឱ្យកាត់រង្វាន់ ១ ភាគក្នុង ១០ ភាគ ទាំងអស់ឬកុំឱ្យ បានទៅក្រឡាប័ញ្ជីរដែលខុសនោះ ។

បើភ្លេចធ្វើតាមរបៀបប្រការ ៣៤, ៣៥, ៣៩, ៤០, ៤១, ៤៩,៥៣, ៥៤, ៥៥, ៥៧, ៥៩, ៦១, ៦២, ៦៤, ៦៦, ៦៩, ៧១, ៧៥, ៩២, ៩៣, ១២១, ១២២ ក្នុងព្រះរាជប្រកាសនេះ ជាដើម នោះក៏ត្រូវសំរេចដូចគ្នាដែរ ឯជំនួនប្រាក់ដែលកាត់ដូច្នេះ បើក្រឡាប័ញ្ជីរដែលខុសបាន ទទួលរង្វាន់ ១ ភាគក្នុង ១០ ភាគនោះហើយ ក្រឡាប័ញ្ជីរនោះត្រូវប្រគល់ប្រាក់ដែលកាត់នោះ ទៅឱ្យក្រឡាប័ញ្ជីរសាលាវិនិច្ឆ័យ បើរង្វាន់នោះពុំទាន់បានប្រគល់ឱ្យទេ នាក់ថណាយត្រូវប្រគល់ ឱ្យក្រឡាប័ញ្ជីរសាលាវិនិច្ឆ័យ ឯក្រឡាប័ញ្ជីរសាលាវិនិច្ឆ័យត្រូវទុកប្រាក់នោះជាខ្ទាត់ ជំនុំចុះក្នុង ជំពូកប្រាក់ពិនៃសំរាប់មន្ទីក្រឡាប័ញ្ជីរ ។

**ប្រការ ៩១.**

ប្រាក់រង្វាន់ដែលបង់ឱ្យ ត្រូវចេញបង្កាន់ដៃ១រំពេច បង្កាន់ដៃនោះចុះឈ្មោះនាក់ក្តី ចុះរឿង ក្តីដែលចេញរង្វាន់នេះ បង្កាន់ដៃត្រូវនាក់ថណាយចុះលេខថ្ងៃខែឆ្នាំនឹងស៊ីញ៉េឈ្មោះហែកពីគល់ សៀវភៅដែលចាងហ្វាងសាលាវិនិច្ឆ័យ ឬចៅក្រំណាមួយដែលចាងហ្វាងសាលានេះចាត់ ចុះលេខ ទំពាវ៍ស៊ីញ៉េខ្លីៗគ្រប់ទំពាវ៍ នឹងស៊ីញ៉េឈ្មោះវែងខាងដើមនឹងខាងចុងទំពាវ៍។

**ប្រការ ៩២.**

សន្លឹកបង្កាន់ដៃដែលហែកពីគល់សៀវភៅនោះចែកជាពីរកំណាត់ដូចគ្នា ១ ប្រគល់ឱ្យ សាម៉ីខ្លួននាក់ក្តី ១ ទៀតជូនទៅឱ្យក្រឡាប័ញ្ជីរសាលា ក្រឡាប័ញ្ជីរស៊ីញ៉េលើបង្កាន់ដៃនោះទុកក្នុង សំណុំរឿង ហើយចុះប័ញ្ជីរលិក្ខិតរឿង។

**ប្រការ ៩៣.**

សេចក្តីជំនុំអ្វីដលសំរេចរឿងណា ១ សានក្រំដែលបញ្ជូនរឿងឬដែលឱ្យរួចខ្លួន ដែល សាលាក្រុំចោទ្យកាត់សេចក្តីចេញនោះ ត្រូវចុះជំនួនប្រាក់ដូចមានខាងក្រោម តែត្រូវឱ្យសំរេចខ្ទាត់ រួចសិនបើសំរេចបាន។

១. ជំនួនប្រាក់រង្វាន់ដែលត្រូវទារ។

២. ជំនួនប្រាក់រង្វាន់ ១ ភាគក្នុង ១០ ភាគ ។

៣. ជំនួនប្រាក់រង្វាន់ដែលទទួលហើយឬដែលព្រមព្រៀងគ្នា។

# ជំពូក ៤
# អំពីកិច្ចការនៃនាក់ថណាយក្តី

**ប្រការ ៩៤.**

នាក់ថណាយត្រូវនៅក្រោមអំណាចសេនាបតីក្រសួងយុត្តិធម៌ នឹងនៅក្រោមអំណាចចៅក្រំត្រួតត្រាឯសំណុំសៅរ៍ជាខ្លួនត្រូវទុកក្នុងមន្ទីក្រឡាបញ្ជីរសាលាវិនិច្ឆ័យ។

**ប្រការ ៩៥.**

នាក់ថណាយត្រូវធ្វើតាមមុខក្រសួងខ្លួនឱ្យត្រឹមត្រូវស្មោះត្រង់សុចរិត។

**ប្រការ ៩៦.**

តាំងរង្វាន់នឹងតាំងខ្ទាត់ជំនុំប្រដាប់ក្តី ត្រូវបិទជានិច្ចខាងក្រៅនឹងខាងក្នុងមន្ទីធ្វើការរបស់នាក់ថណាយនីមួយៗ ឱ្យជនានុជនឃើញគ្រប់គ្នា តាំងនោះត្រូវបិទនឹងរក្សាឱ្យបានគេមើលឃើញច្បាស់ប្រាកដ។

**ប្រការ ៩៧.**

ក្នុងមន្ទីធ្វើការនាក់ថណាយនីមួយៗ ត្រូវតែឱ្យមានសៀវភៅដូចរាយខាងក្រោមខានពុំបាន។

១. សៀវភៅចុះសំបុត្រដែលផ្ញើទៅឱ្យសាលាជំនុំ។

២. សៀវភៅចុះសំបុត្រដែលទទួលពីសាលាជំនុំ។

៣. សៀវភៅកត់ប្រាក់។

៤. សៀវភៅចុះឈ្មោះសាមីខ្លួននាក់ក្តីនឹងរឿងក្តី។

៥. សៀវភៅបង្កាន់ដៃសំរាប់កត់រង្វាន់។

សៀវភៅនីមួយៗនោះ ត្រូវចាងហ្វាងសាលាវិនិច្ឆ័យ ឬចៅក្រំណា ១ ដែលចាងហ្វាងសាលានោះចាត់ចុះលេខទំព័រស៊ីញេខ្លីគ្រប់សន្លឹក នឹងស៊ីញេឈ្មោះវែងខាងដើមនឹងខាងចុងទំព័រ។

**ប្រការ ៩៨.**

ឯត្រួតពិនិតសៀវភៅនោះ ត្រូវចាងហ្វាងសាលាវិនិច្ឆ័យចាត់ចៅក្រំម្នាក់ឱ្យពិនិតត្រួតតាមបង្គាប់សេនាបតីក្រសួងយុត្តិធម៌។

**ប្រការ ៩៩.**

នាក់ចណាយត្រូវស្លៀកពាក់ត្រឹមត្រូវស្អាតជរាប វេលាដែលចូលទៅក្នុងទីសំរាប់រាជ្ការសាធារណ នឹងចូលទៅរកចៅក្រំក្រឡាប័ញ្ជីរ នឹងភ្នាក់ងារក្រសួងក្រុំព្រះនគរបាលក្រសួងយុត្តិធម៌។

វេលាជំនុំជំរះត្រូវស្លៀកពាក់ដូចមានខាងក្រោម៖

អាវកុតសរក៏ត្រង់ ឬអាវបើកក៏សរមានអាវត្រនាប់ពីក្នុងសរស្រង់ក៏សររឹងត្រង់នឹងក្រវ៉ាត់ខ្មៅ សម្លត់ផាមួងស្រោមជើងវែងខ្មៅឬសរ ស្បែកជើងខ្មៅឬផ្ទាត់ប៉ាក់ខឹនក្រហម។

**ប្រការ ១០០.**

វេលាដែលចូលទៅក្នុងប៉ុយរ៉ូធ្វើការ ត្រូវដោះមួកហើយគំនាប់តាមទម្លាប់ស្រុក វេលាដែលចៅក្រំចូលនឹងចេញនោះ ត្រូវក្រោកឈរគំនាប់ ហើយលុះតែចៅក្រំប្រាប់ឱ្យអង្គុយទើបអង្គុយវិញបាន ហើយបើនឹងនិយាយត្រូវសុំអនុញ្ញាតពីចៅក្រំបាន ទើបនិយាយបាន ហើយត្រូវនិយាយឱ្យស្រួលដោយសំឡូត។

**ប្រការ ១០១.**

ឯនិយាយនោះត្រូវឈរនិយាយ ត្រូវគំនាប់មុននឹងនិយាយ នឹងក្រោយដែលនិយាយរួច។

**ប្រការ ១០២.**

មិនត្រូវមានវាចាអ្វីជាពាក្យជំនៀលជេរ ពោលនឹងពាក្យមើលងាយប្រមាទនាក់ដទៃឡើយទោះមនុស្សដែលក្តីឬក្រៅក្តីដែលខ្លួនកាន់នោះក៏ដោយ ឯសរសេរសំបុត្រស្នាមក៏ត្រូវហាមដូចគ្នាដែរ នាក់ចណាយនឹងប្តឹងពីនាក់ដទៃដែលប្រព្រឹត្តបទល្មើស នឹងប្តឹងពីមន្ត្រីឬភ្នាក់ងារដំណាងក្រសួងរាជ្ការសាធារណ ដែលធ្វើការអ្វីក្រៅពីមុខក្រសួងខ្លួនបានតាមចិត្ត តែត្រូវប្តេជ្ញាទទួលខុសលើខ្លួន។

**ប្រការ ១០៣.**

ហាមមិនឱ្យមានវាចា ឬសរសេរជាលិក្ខិតទិចទៀនត្មាសតិះដៀលក្រុំក្រសួងរាជ្ការរដ្ឋបាលនឹងរាជ្ការសាធារណ មន្ត្រីឬភ្នាក់ងារដំណាងរាជ្ការសាធារណដែលកំពុងធ្វើការ ឬក្នុងឱកាសធ្វើការមុខក្រសួងខ្លួន នាក់ចណាយនឹងប្តឹងពីមន្ត្រី នឹងភ្នាក់ងារដំណាងក្រសួងរាជ្ការសាធារណដែល

កំពុងធ្វើការ ឬក្នុងឱកាសធ្វើការមុខក្រសួងខ្លួន ប្រព្រឹត្តបទល្មើសនឹងធ្វើខុសក្នុងការមុខក្រសួងខ្លួនបានតាមចិត្ត តែត្រូវប្តេជ្ញាទទួលខុសលើខ្លួន។

**ប្រការ ១០៤.**

នាក់ថណាយត្រូវគោរពប្រតិបត្តិព្រះករុណាព្រះរាជវង្សានុវង្ស រាជ្ការបារាំងសែស នឹងរាជ្ការខេមរកុំបីភ្លេច ហើយត្រូវគោរពគួរសមនឹងបន្ទានាក់រាជ្ការតុលាការវេលាដែលកំពុងធ្វើការមុខក្រសួងខ្លួន ហើយដែលត្រូវការប្រារព្ធគ្នាទៅវិញទៅមកជារាជ្ការ។

**ប្រការ ១០៥.**

ហាមនាក់ថណាយ ទោះប្រការយ៉ាងណាក៏ដោយមិនឱ្យប្រកាសផ្សាយ ឬឱ្យគេប្រកាសផ្ទាល់ខ្លួនឬមិនផ្ទាល់ខ្លួនសេចក្តីទិចទៀនដៀលត្មាស ឬទុច្ចរិតពីនាក់ដទៃដែលកើតក្តីក្នុងរឿងដែលខ្លួនកាន់ពីចៅក្រមមន្ត្រី ឬភ្នាក់ងារដំណាងក្រសួងសាធារណដែលត្រូវការនិយាយក្នុងរឿងក្តី។

**ប្រការ ១០៦.**

នាក់ថណាយមិនត្រូវបរិហាផ្សាយ ឬប្រកាសប្រយោជន៍ឱ្យបាននាក់ក្តីចូលមករកខ្លួនឡើយ ដើមឡើយត្រូវហាមមិនឱ្យប្រើនាក់ពុំនឹងស្មាក់ចិត្តឱ្យឈ្នួល ឬឱ្យរង្វាន់រកនាក់ក្តីមកឱ្យ។

**ប្រការ ១០៧.**

ត្រូវហាមមិនឱ្យធ្វើជាអាជ្ញាកន្តាល គូក្តីនាំឱ្យស្រុះស្រួលឬផ្សះផ្សាជានឹងគ្នា ជួយនិយាយនឹងគូក្តីម្ខាងផ្ទាល់ខ្លួន ឬឱ្យគេនិយាយជួស ហៅមនុស្សឱ្យធ្វើជាសាក្សីមកដល់មន្ទីកន្លែងធ្វើការខ្លួន ឬកន្លែងឯទៀត។

**ប្រការ ១០៨.**

បើបានប្រគល់ប្រាក់ឬសន្យានឹងឱ្យប្រយោជន៍អ្វីទៅជនណា ១ ដែលត្រូវយកធ្វើជាសាក្សីនោះចូលជាបទល្មើសត្រូវផ្តន្ទាទោសតាមមាត្រា ៣៣៦ ក្រំព្រហ្មទណ្ឌ។

**ប្រការ ១០៩.**

នាក់ថណាយត្រូវចាត់ការជាសម្ងាត់ដែលមុខក្រសួងខ្លួនត្រូវចាត់ពុំឱ្យនាក់ឯណាដឹង មិនត្រូវឱ្យនាក់សាមីខ្លួននាក់ក្តីព្រមទាំងគូក្តីម្ខាងនោះក៏ពុំត្រូវដឹងដែរ ទោះប្រការដូចម្តេចក្តីមិនត្រូវប្រាប់ឱ្យនាក់ឯណាដឹងរឿងដែលខ្លួនបានដឹងដោយហេតុដែលខ្លួនជានាក់ថណាយក្តី។

**ប្រការ ១១០.**

ឯនឹងឱ្យរួចពីរក្សាការសម្ងាត់សំរាប់មុខក្រសួងខ្លួននោះបាន លុះតែមានសេចក្ដីជំនុំផ្សេង ដែលបានជំនុំជំរះពីរឿងឧក្រិដ្ឋឬមជ្ឈិម នោះទើបនាក់ថណាយត្រូវឆ្លើយក្នុងសម្បថឱ្យការរឿង ដែលខ្លួនបានដឹងខណកំពុងធ្វើការក្រសួងខ្លួន ហើយត្រូវកត់ចម្លើយនាក់ថណាយក្នុងបន្ទប់ស្ងាត់។

**ប្រការ ១១១.**

នាក់ថណាយត្រូវប្រកែកកុំទទួលកាន់ក្ដីណា ១ ដែលមានប្រយោជន៍ទាស់ខុសគ្នា។

**ប្រការ ១១២.**

នាក់ថណាយមិនត្រូវទទួលដេញថ្លៃទិញផ្ទាល់ខ្លួន ឬឱ្យគេទិញជួសជាប្រយោជន៍ខ្លួនវត្ថុ ដែលលក់ក្នុងសាលាជំនុំទាំងអស់ឬខ្លះទេ ហើយនឹងទិញផ្ទាល់ឬឱ្យគេទិញជួស អំណាចទទួល មរដក ឬអំណាចដែលទាស់ក៏មិនបានដែរ។

**ប្រការ ១១៣.**

កិច្ចសញ្ញាអ្វីដោយបង្ខំ កិច្ចសញ្ញាណា ដោយសង្ស័យលក្ខណមិនប្រាកដ ដែលសញ្ញាគ្នាអំពី រឿងក្ដី នោះចូលជាបទល្មើសប្រើអំណាចយកប្រយោជន៍ ត្រូវផ្ដន្ទាតាមមាត្រា ៣១១ ក្រំព្រហ្មទណ្ឌ។

**ប្រការ ១១៤.**

ឯទារប្រាក់រង្វាន់លើសពីជំនួនដែលសំរេចក្នុងតារាំងចូលជាបទមជ្ឈិមយកប្រាក់លើស ជំនួន ត្រូវមានទោសតាមមាត្រា ២៦៣ នឹង ២៦៤ ក្រំព្រហ្មទណ្ឌ។

**ប្រការ ១១៥.**

ហាមមិនឱ្យនាក់ថណាយដែលមានអនុញ្ញាតពីសាលាប្រើមនុស្សជំណាងជួស ឬពុំនឹងឱ្យ ជាឈ្នួល ធ្វើការគ្រប់ជំពូកដែលកិរិយាពុំមែនជារឿងក្ដី នឹងចូលសមាគមគ្នា ឬជាមួយនឹងស្មាក្ដី បារាំងផ្ទាល់ខ្លួនក្ដី នាំឱ្យគេជួសក្ដីប្រការយ៉ាងណាក៏ដោយ។

បើនាក់ថណាយខ្លួនឯង ឬមនុស្សធ្វើការនៅមន្ទីខ្លួនធ្វើពាក្យនោះ មិនត្រូវយកថ្លៃលើសពី ១រៀលក្នុងទំពាវ័ដំបូង នឹង ៥០ សេន ក្នុងទំពាវ័នីមួយៗ ឯទៀតទេ។

**ប្រការ ១១៦.**

នាក់ថណាយដែលប្រព្រឹត្តខុសបទល្មើសអ្វីដែលកំពុងធ្វើការឬក្រៅពីធ្វើការមុខក្រសួងខ្លួន នោះត្រូវសាលាលូកឃុនជំនុំជំរះកាត់សេចក្ដី ហើយត្រូវយកខ្លួនជំនុំជំរះពុំអាចសុំអនុញ្ញាតជាមុនឡើយ។

**ប្រការ ១១៧.**

នាក់ថណាយត្រូវមានទោសទណ្ឌកម្មដូចមានរាយខាងក្រោម៖

១. រំឭក។

២. ដកអំណាចមិនឱ្យនិយាយ។

៣. បង្គាប់ឱ្យដកពាក្យសំដី។

៤. បន្តេញចេញ។

៥. បន្ទោសប្រដៅ។

៦. បន់ឈប់។

៧. លប់ចោល។

**ប្រការ ១១៨.**

ឯរំឭកដកអំណាចមិនឱ្យនិយាយ បង្គាប់ឱ្យដកពាក្យសំដីនឹងបន្តេញត្រូវចៅក្រំត្រួតកន្លែងជំនុំជុំរះឬកន្លែងក្នុងសាលាដែលឃើញសេចក្ដីប្រព្រឹត្តខុស នោះសំរេចធ្វើតាមទោសានុទោសនោះ។

ឯនឹងធ្វើកំណត់កត់ហេតុអំពីរំឭកក្ដី អំពីដកអំណាចមិនឱ្យនិយាយក្ដី អំពីបង្គាប់ឱ្យដកពាក្យសំដីក្ដី លុះតែនាក់ថណាយមិនព្រមទទួលប្រណីបតីតាម ទើបធ្វើជាសេចក្ដីកត់ហេតុឡើង។

បើបន្តេញចេញ ត្រូវធ្វើជាសេចក្ដីកត់ហេតុ ១ រំពេចជាដរាបសេចក្ដីកត់ហេតុនោះ ត្រូវបញ្ជូនទៅក្រុំសេនាបតីក្រសួងយុត្តិធម៌ជាប្រញាប់ដើម្បីនឹងសំរេចទោសតាមការ។

**ប្រការ ១១៩.**

នាក់ថណាយដែលបន្តេញចេញ ត្រូវនៅកាន់កាប់ធ្វើការនៅមន្ទីរបស់ខ្លួន ប៉ុន្តែនឹងចូលផ្ទាល់ខ្លួនមកកន្លែងជំនុំនឹងក្នុងបន់ទប់ចៅក្រំបានទៀត លុះតែមានសេចក្ដីជំនុំសេនាបតីសំរេចពីរឿងខ្លួនរួចសិនទើបចូលបាន។

### ប្រការ ១២០.

ឯបន្ទោសប្រដៅ មានសេចក្ដីជំនុំសេនាបតីសំរេចតាមសេចក្ដីយល់ឃើញពីសាលាវិនិច្ឆ័យដែលបានអនុញ្ញាតបើកឱ្យនាក់ចំណាយ ឆ្លើយកែដោះសារជូនសំអាងការពារខ្លួនរួចប្រជុំចៅក្រំពិនិតនោះ ហើយត្រូវឱ្យដំណឹងពីសេចក្ដីជំនុំសេនាបតីទៅសាមីខ្លួន នឹងចាងហ្វាងសាលាដែលមានហេតុនោះ នឹងឱ្យចំឡងដាក់ក្នុងសំណុំសោវដាខ្លួននាក់ចំណាយផង។

### ប្រការ ១២១.

ទោសបន់ឈប់ក៏សំរេចដូចស្អានដែលសំរេចពីបន្ទោសប្រដៅដែរ។

ឯបន់ឈប់នោះសំរេចកំណត់កុំឱ្យតិចជាង ៣ខែ នឹងកុំឱ្យលើស ១ ឆ្នាំ ( ត្រូវរាប់តាមថ្ងៃខែឆ្នាំបារាំង )។

ឯកំណត់ទោស ត្រូវគិតតាំងពីថ្ងៃដែលមន្ទីក្រឡាប័ញ្ជីរឱ្យដំណឹងសេចក្ដីជំនុំទៅសាមីខ្លួនតាមបង្គាប់សេនាបតីក្នុងរវាងកំណត់ទោស នោះនាក់ចំណាយមិនត្រូវស្ដីមុខការខ្លួនបានទេ ដើមឡើយត្រូវហាមមិនឱ្យទទួលកាន់ក្ដីថ្មីទៀត ឬប្ដឹងឧទ្ធរណ៍ ឬសាទុកសាលាវិនិច្ឆ័យបានទេ នឹងចាត់ជារាជ្ជការក៏ពុំបានដែរ។

### ប្រការ ១២២.

ទោសលប់ចោល ត្រូវសំរេចដូចស្អានទោសបន្ទោសនឹងបន់ឈប់ដែរ។

ទោសលប់ចោល នាំឱ្យដកហូតនាក់ចំណាយស្រឡាស់ចេញនឹងធ្វើការក្រសួងខ្លួនទៀតពុំបាន គិតតាំងពីថ្ងៃដែលមន្ទីក្រឡាប័ញ្ជីរបានឱ្យដំណឹងតាមបង្គាប់សេនាបតី។

### ប្រការ ១២៣.

នាក់ចំណាយដែលត្រូវបន់ឈប់ ឬលប់ឈ្មោះចោលនៅក្នុងរវាង ១០ ថ្ងៃក្រោយ ដែលបានទទួលដំណឹងទោសនោះ ត្រូវប្រគល់សំណុំរឿងទាំងប៉ុន្មានដែលបានទទួលកែសេចក្ដីនោះទៅឱ្យមន្ទីក្រឡាប័ញ្ជីរសាលា ។

រួចត្រូវចាងហ្វាងសាលាវិនិច្ឆ័យចេញដីកាបង្គាប់ ចែកសំណុំរឿង ឱ្យនាក់ចំណាយឯទៀតឯរង្វាន់ក៏ត្រូវចាងហ្វាងសាលាវិនិច្ឆ័យចែកដែរ បើនាក់ចំណាយឯទៀតនឹងនាក់ចំណាយដែលឈប់ឬលប់ឈ្មោះចោលពុំបានព្រមព្រៀងគ្នា។

**ប្រការ ១២៤.**

ទោសលប់ចោលនឹងទោសបន់ឈប់នោះត្រូវចេញសារគ្រាសេនាបតីឱ្យដំណឹងទៅគ្រប់សាលាជំនុំ ចាងហ្វាងត្រូវត្រួតត្រាមើល កុំឱ្យក្រឡាប័ញ្ជីរទទួលចុះសៀវភៅប្ដឹងក្ដីដែលនាក់ថណាយមានទោសនោះកាន់កៃសេចក្ដី នឹងត្រូវត្រួតឱ្យលប់ឈ្មោះនាក់ថណាយ ដែលមានទោសលប់ចោលនោះពីតារាំងពួកនាក់ថណាយចេញ។

**ប្រការ ១២៥.**

បើមានទោសជាឧក្រិដ្ឋឬមជ្ឈិមនោះបន្ទាលឱ្យមានទោសលប់ឈ្មោះចោលឯងៗ ប៉ុន្តែបើមានត្រឹមតែទោសពិនៃហើយបង្អង់ផង នឹងយកទោសបន់ឈប់ជំនួសទោសលប់ចោលបានតាមសេចក្ដីជំនុំសេនាបតីដែលសំរេចតាមសេចក្ដីយល់ពីសាលាវិនិច្ឆ័យ។

**ប្រការ ១២៦.**

សេចក្ដីដែលចោទ្យដល់តុលាការពីនាក់ថណាយអំពីរឿងឧក្រិដ្ឋឬមជ្ឈិម នាំឱ្យបន់ឈប់ឯងៗ។

**ប្រការ ១២៧.**

សេចក្ដីសៅហ្មងដល់កិត្តិយសនឹងសុចរិតត្រង់មិនចូលជាបទល្មើសអាជ្ញាទេ តែនឹងបន្ទាលឱ្យធ្វើទោសជាទណ្ឌកម្មបន្ទោសប្រដៅបន់ឈប់ឬលប់ចោលបាន។

ទោសទាំងនេះនឹងបន្ទាលឱ្យសំរេចធ្វើទោសបានដែរ បើមានពាក្យប្ដឹងពីនាក់ថណាយរឿងបំណុល រិបអូសឬបង្ខំទៅសាលាបារាំងឬសាលាខ្មែរ។

**ប្រការ ១២៨.**

អំពីករណីហេតុដែលកើតឡើងទាស់គ្នា នាក់ថណាយនឹងសាមីខ្លួននាក់ក្ដីនោះ ត្រូវប្ដឹងសាលាដំបូងភ្នំពេញទោះចុងចំម្លើយនៅទីណាក៏ដោយ។

សេចក្ដីទាស់គ្នាអំពីទារប្រាក់រង្វាន់ នឹងអំពីទទួលខុសត្រូវនោះ ត្រូវប្ដឹងសាលាដំបូងភ្នំពេញដែរ។

**ប្រការ ១២៩.**

ទោសសំណងប្រាក់ដែលកាត់ឱ្យនាក់ចំណាយសងនោះ នឹងសំរេចតាមដិកាបង្គាប់ចាងហ្វាងសាលាវិនិច្ឆ័យ កាត់យកក្នុងប្រាក់ធានាសងបាន។

ឯប្រាក់ធានានោះ ធានាសងប្រាក់រង្វាន់ ១ ភាគក្នុង ១០ ភាគដែលត្រូវបានក្រឡាប័ញ្ជីរដែរ។

ព្រះរាជប្រកាសធ្វើក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញនៅថ្ងៃ ១១ រោជខែមាឃ ឆ្នាំមមែត្រីស័ក្ស ត្រូវនឹងថ្ងៃ ៣ ម៉ារ្ស៍ ឆ្នាំ១៩៣២។

ស៊ីសុវត្ថិ មុនីវង្ស

បានក្រាបបង្គំទូលថ្វាយ សូមឡាយព្រះករុណា

ឧកញ៉ាយោមរាជ

ជា

ព្រះរាជប្រកាស លេខ ៩៥ ចុះថ្ងៃ ១៤ រោជខែពិសាខ ឆ្នាំវកចត្វាស័ក្ស ត្រូវនឹងថ្ងៃ២ ខែឧសភា ឆ្នាំ១៩៣២ ពីសេចក្ដីកាន់ច្រឡំ នៅក្នុងព្រះរាជប្រកាសលេខ ៣២ ចុះថ្ងៃ ១១ រោជ ខែមាឃ ឆ្នាំមមែត្រីស័ក្ស ត្រូវនឹងថ្ងៃ ៣ ខែម៉ារ្ស ឆ្នាំ១៩៣២ អំពីរៀបចំនឹងបញ្ញត្តិពីឱ្យជួយកែសេចក្ដីក្នុងសាលាជំនុំខេមរៈ។

ត្រង់កន្លែងដែលថា៖

ព្រះរាជប្រកាសធ្វើក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ នៅថ្ងៃ ១១ រោជខែមាឃ ឆ្នាំមមែត្រីស័ក្ស ព.ស.២៤៧៤ ត្រូវគ្នានឹងថ្ងៃ ៣ ម៉ារ្ស ឆ្នាំ១៩៣២។

ត្រូវមើលថាដូច្នេះវិញ៖

ព្រះរាជប្រកាសធ្វើក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ នៅថ្ងៃ ៩ កើតខែផល្គុណ ឆ្នាំមមែត្រីស័ក្ស ព.ស.២៤៧៤ ត្រូវគ្នានឹងថ្ងៃ ១៥ ម៉ារ្ស ឆ្នាំ១៩៣២។

# ព្រះរាជប្រកាសលេខ ១៤
# អំពីអ្នកថណាយក្តី
# ត្រូវឱ្យមានសំលៀកបំពាក់

ថ្ងៃ៦កើត ខែមាឃ ឆ្នាំវកចត្វាស័ក្ស ព.ស.២៤៧៥

ត្រូវនឹងថ្ងៃ ១ ខែហ្វេវ្រីយេ ឆ្នាំ១៩៣៣

ព្រះរាជប្រកាសលេខ ១៤ ចុះថ្ងៃ៦កើតខែមាឃ ឆ្នាំរកាចត្វាស័ក្ស ព្រះពុទ្ធសករាជ ២៤៧៥ (១ ហ្វេវ្រីយេ ១៩៣៣) ដែរមានប្រកាសអាររេតេលោកឡឺរេស៊ីដងគ្គសុប៉េរីយ៉ើរ លេខ ៣៩៥ ចុះថ្ងៃ៦ ហ្វេវ្រីយេ ១៩៣៣ ប័ញ្ញត្តឱ្យសំរេចតាម។

**ប្រការ ១.**

នៅវេលាជំនុំជាទីបើកឱកាសដល់មហាជននៃសាលាជំនុំខ្មែរ ជាជំណាងព្រះករុណានោះ អ្នកថណាយក្តីត្រូវមានសំលៀកបំពាក់ជាអាវផាយពណ៌ស មានប៉ានតាតមាសដើមដៃចុងដៃនឹងជាយជុំវិញ។

ឯទំហំអាវផាយទទឹងប៉ានដើមដៃចុងដៃនឹងជាយជុំវិញនោះ ដូចទំហំអាវផាយចៅក្រំនឹងក្រឡាបញ្ជីរ ដែរមានព្រះរាជប្រកាសលេខ ៧០ ចុះថ្ងៃ១១ ខែឱកតូប ឆ្នាំ១៩៣២ បញ្ញត្តិទុកឱ្យប្រើតែត្រូវយកតាមទំហំអាវផាយប៉ានសំរាប់ក្រឡាបញ្ជីរថ្នាក់ទី ៣។

ឯអ្នកថណាយក្តីដែរជាមន្ត្រីចាស់ ត្រូវមានអំណាចប្រើបានទំហំស្មើនឹងសក្តិសំរាប់ខ្លួនកាលដែរនៅក្នុងងារនៅឡើយ។

**ប្រការ ២.**

អ្នកថណាយត្រូវហៅនាមជាមេធាវី។

# ព្រះរាជក្រមលេខ ៦៤៨ ន.ស
# ស្ដីពីវិជ្ជាជីវៈស្ពាក្ដី
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៨១

# សេចក្តីថ្លៃងការណ៍

ព្រះរាជប្រកាសលេខ ៣២ ចុះថ្ងៃ១៥ ខែមិនា គ.ស.១៩៣២ ដែលបានបង្កើតឱ្យមានការថណាយជួយកែសេចក្តីក្នុងតុលាការ បើមិនត្រូវលើកចោលទាំងមូល ក៏ត្រូវកែប្រែជាច្រើនអន្លើ ដើម្បីឱ្យបានសមនឹងដំណើរដែលមានប្រែប្រួលក្នុងព្រះរាជអាណាចក្រខ្មែរ។

ព្រោះតាំងពីបាន បង្កើតឱ្យមានថណាយជួយកែសេចក្តីនេះរៀងមក មានផ្លាស់ប្តូររបៀបក្នុងក្រសួងតុលាការជាច្រើនមកហើយ។ ដូច្នេះគប្បីតែរើរៀបចំលក្ខន្តិកៈនៃអ្នកថណាយក្តីឱ្យបានប្រកបនឹងការចំរើនដែលបានកើតរួចមកហើយនោះ តែត្រូវដំកល់ទុកលក្ខណប្បញ្ញត្តិចាស់ខ្លះ ដែលស្មាក្តី (កាលដើមហៅថាអ្នកថណាយក្តី) បានជាធ្លាប់ចិត្តមកហើយៗ បើនឹងផ្លាស់ប្តូរទាំងមូលភ្លាមតែម្តងទៅ ក្រែងបណ្តាលឱ្យមានវិបរិតនាំឱ្យខូចខាតដល់ស្មាក្តីឯង ដែលបានបាក់ផ្នត់ទៅតាមដំណើរការខ្លះទៅហើយនោះក៏មាន ហើយនាំឱ្យខូចខាតដល់អ្នកក្តីក៏មាន ព្រោះមកដល់ឥឡូវនេះអ្នកក្តី បានជាធ្លាប់ឱ្យគេជួយការពារប្រយោជន៍ខ្លួនក្នុងតុលាការដោយមានសេចក្តីទុកចិត្តគ្រប់ប្រការ ហើយមានតែអ្នកកាន់ការធ្វើស្មាក្តីទើបធ្វើការនេះបាន។

ដោយហេតុនេះហើយ បានជាក្នុងសេចក្តីស្នើច្បាប់នេះត្រូវបំបាត់ចោលចេញ នូវសេចក្តីទាំងប៉ុន្មាន ដែលឱ្យឃើញមានកិរិយាខ្លះថាជាការចាស់នឹងទុកប្រើប្រាស់តទៅមុខទៀតពុំបាន។

លក្ខណៈទាំងប៉ុន្មាន ដែលត្រូវឱ្យប្រកបដើម្បីនឹងធ្វើស្មាក្តីបាន នោះត្រូវទុកឱ្យនៅដូចពីដើមជាច្រើនភាគ។ ត្រង់ច្បាប់ចាស់បញ្ញត្តិថាត្រូវឱ្យមានទីលំនៅក្នុងប្រទេសកម្ពុជាជានិច្ច កំណត់ប្រាំឆ្នាំនោះត្រូវបំបាត់ចោល ព្រោះលក្ខណៈនេះអាចនាំតែឱ្យអស់យុវជនដែលរៀសរវៃ ចាកចេញពីស្រុកកំណើតទៅ ស្វះស្វែងសិក្សាចំណេះវិជ្ជានោះក្របានចូលធ្វើស្មាក្តីភ្លាមតាមបំណង។

ប្រាក់ធានាត្រូវដំឡើងចំនួន ដោយប្រាក់សព្វថ្ងៃចុះថ្លៃ។

ឯសេចក្តីទាស់មុខក្រសួង មិនប្រែប្រួលទេ ប៉ុន្តែត្រូវពង្រីកមុខការធ្វើស្មាក្តីឱ្យទូលាយឡើងទៀត តាមការអនុវត្តន៍នូវរដ្ឋធម្មនុញ្ញ ព្រះរាជអាណាចក្រថ្មីៗ នេះ។

អំពីការពឹងរកស្មាក្តី គ្មានកែប្រែអ្វីទេ ព្រោះអ្នកក្តីនឹងស្មាក្តីបានស្រួលចិត្តតាមល័ក្ខខ័ណ្ឌដែលមានមកនោះហើយៗ ល័ក្ខខ័ណ្ឌនោះបានសំគាល់ឃើញថា ពុំបណ្តាលឱ្យមានគេបន្ទោសឬត្អូញត្អែរអ្វីឡើយ។

អំពីសិទ្ធិនឹងករណីយកិច្ចរបស់ស្នាក្ដីក៏ពុំត្រូវកែប្រែកំរិតនៃព្រះរាជក្រមចាស់ដែលត្រូវទុកជាស្រេចតទៅ គ្រាន់តែបន្ថែមបន្ថយសេចក្ដីបន្ដិចបន្តួច។

ឯសេចក្ដី កែប្រែច្បាប់ចាស់ជាធំនោះ គឺកែប្រែត្រង់បង់ប្រាក់រង្វាន់ស្នាក្ដី។ កាលដើមប្រាក់រង្វាន់នេះ មានកំរិតឱ្យទារតាមអត្រាច្បាប់ស្នាក្ដី ត្រូវតែទទួលប្រតិបត្តិតាម។ ដូច្នេះស្នាក្ដីត្រូវកាន់បញ្ជីកត់ប្រាក់ចំណូលចំណាយ ដូចជាពាណិជ្ជការមួយនាក់ បញ្ជីកត់ប្រាក់នេះមន្ត្រីក្រុមតុលាការអាចត្រួតបាន។

អំណើះតទៅប្រាក់រង្វាន់ស្នាក្ដី យកបានដោយសេរីតាមស្មគ្រចិត្តព្រមព្រៀងគ្នាទៅវិញទៅមក ប៉ុន្តែនឹងបំបាត់មិនឱ្យស្នាក្ដីត្រូវចេញបង្កាន់ដៃគ្រប់តែប្រាក់ដែលខ្លួនបានទទួលនោះក៏ទេ ប្រយោជន៍ដើម្បីកុំឱ្យអ្នកពឹងតវ៉ាបាន ឯចំណែកខាងស្នាក្ដីវិញ នឹងប្ដឹងតុលាការទារប្រាក់រង្វាន់ពីអ្នកក្ដីពុំបានទេ។

អំពីទោសានុទោស ក្រៅពីទណ្ឌកម្មតាមក្រិត្យវិន័យ គឺទោសដែលត្រូវដាក់ខ្លួនឱ្យតុលាការជំនុំជំរះកាត់សេចក្ដី នោះមានកែប្រែខ្លះគឺអំណើះតទៅ ពុំមែនសាលាលុយុនទេ គឺត្រូវសាលាឧទ្ធរណ៍ជំនុំជំរះស្នាក្ដី ដែលត្រូវចោទពីបទដែលខ្លួនបានប្រព្រឹត្តខុសក្នុងកិច្ចការមុខក្រសួងខ្លួន ឬក្នុងឱកាសដែលធ្វើការមុខក្រសួងខ្លួន។ បានតុលាការជាន់ខ្ពស់ជំនុំជំរះ ដូច្នេះជាទីតំកើងក្រុមស្នាក្ដីឱ្យបានខ្ពង់ខ្ពស់ហើយ។

ជាទីបំផុត គួររំលឹកថាព្រះរាជក្រមលេខ ៣០២ ន.ស. ចុះថ្ងៃ៨ មិនា គ.ស.១៩៤៧ ដែលបញ្ញត្តិពីស្នាក្ដីបារាំង នោះត្រូវឱ្យនៅអនុវត្តតាមតទៅ តែត្រូវអនុវត្តន៍ទៅតាមសេចក្ដីកែប្រែដូចមានក្នុងសេចក្ដីស្នើច្បាប់នេះផង។

ភ្នំពេញថ្ងៃ១ ខែវិច្ឆិកា គ.ស.១៩៤៨។
ទីប្រឹក្សា **យូ.ខ្វាន់**

មាត្រា ១.

ព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃ១៥ មារ្ស ឆ្នាំ១៩៣២ អំពីការថណាយជួយកែសេចក្ដីក្នុងតុលាការត្រូវលើកចោល ហើយត្រូវយកបទបញ្ញត្តិទាំងឡាយ ដូចមានខាងក្រោមនេះមកជាជំនួសវិញ៖

## ជំពូក ១

## បញ្ញត្តិទូទៅ

មាត្រា ២.

ចំពោះមុខសាលាជំនុំធម្មតា នឹងសាលាជំនុំពិសេសនោះតាមធម្មតា គូក្ដីអាចចូលទៅការពារសេចក្ដីខ្លួនឯងបាន ឬឱ្យស្មាក្ដីពេញច្បាប់ជួយដោះសារជួសក៏បាន ឥតចាំបាច់ឱ្យជូនសំបុត្រថណាយឡើយ។

តាមមាត្រា១៤៥ ក្រមពិភាក្សារដ្ឋប្បវេណី នឹងមាត្រា២៩១ ក្រមពិភាក្សាព្រហ្មទណ្ឌ, ស្មាក្ដីអាចជួយដោះសារសេចក្ដីបាន មិនតែប៉ុណ្ណោះសោត នៅវេលាសាលាជំនុំជំរះ អាចតំណាងអ្នកក្ដីដូចមានសំដែងក្នុងមាត្រាច្បាប់ទាំងនេះក៏បាន វៀរលេងតែ បើសាលាត្រូវការចំពោះលើរូបគូក្ដី។

## ជំពូក២

## កថាភាគ១

## អំពីលក្ខណៈដែលនឹងឧទ្ទួលឱ្យចូលធ្វើស្មាក្ដីបាន

មាត្រា ៣.

នឹងធ្វើវិជ្ជាជីវៈស្មាក្ដីពេញច្បាប់បាន លុះតែជនណាដែលមានឈ្មោះក្នុងតារាងសំរាប់ចុះឈ្មោះពួកក្រុមនេះ ដោយមានប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចហើយបិទនៅសាលាជំនុំនិមួយៗ។

មាត្រា ៤.

ជនណាដែលមិនប្រកបដោយលក្ខណៈ ដូចមានរាយខាងក្រោយនេះនឹងចុះឈ្មោះក្នុងតារាងស្មាក្ដីពុំបានឡើយ។

១. សញ្ជាតិខេមរៈ

២. អាយុពេញ ២៥ ឆ្នាំ

៣. ពុំដែលមានទោសជាបទមជ្ឈិម ឬឧក្រិដ្ឋនាំឱ្យសៅហ្មងដល់កិត្តិយសឬសេចក្ដីសុចរិតរបស់ខ្លួន។

៤. ប្រកបដោយគំនិតមារយាទល្អ។

៥. ប្រកបដោយសិទ្ធិជាជនធម្មតា។

៦. មានចំណេះវិជ្ជាខាងច្បាប់ ដែលសំគាល់ដោយសញ្ញាប័ត្រពីសាលាមហាវិទ្យាល័យប្រទេសបារាំង ឬសាលាជាន់ខ្ពស់នៅក្នុងប្រទេសឥណ្ឌូចិន ឬសាលាបង្រៀនច្បាប់ នឹងបង្រៀនសេដ្ឋកិច្ច ក្នុងប្រទេសខ្មែរ នឹងសាលារដ្ឋបាលខេមរៈ។

មាត្រា ៤.

ជនដែលបានធ្វើការយ៉ាងតិចកំណត់ ១០ ឆ្នាំ ក្នុងក្រសួងរដ្ឋបាលឬតុលាការ ក្នុងតំណែងជាន់ខ្ពស់ នឹងតំណែងជាន់បន្ទាប់នៃរាជការខ្មែរ មិនចាំបាច់ឱ្យជូនសញ្ញាប័ត្រដូចមានរាយត្រង់ខចុងបំផុតនេះទេ។ អ្នកធ្វើការក្នុងរាជការសហរដ្ឋ នឹងណោទែរក្ដី អាជ្ញាសាលាក្ដី ដែលសុំឈុំពីរាជការ នឹងសុំឈប់លែងធ្វើជាណោទែរ នឹងធ្វើជាអាជ្ញាសាលា ក្រោយបានធ្វើទីទាំងនេះកំណត់១០ឆ្នាំក៏ដូចគ្នាដែរ។

ឯកំណត់រាជការ នឹងតំណែងរាជការ ដែលបានធ្វើ ត្រូវសំគាល់ដោយអត្រាមួយពីក្រសួងរាជការ ដែលមន្ត្រីបានធ្វើការ ធ្វើជូន។

មាត្រា ៦.

មន្ត្រីចាស់នឹងអនុញ្ញាតឱ្យធ្វើស្នាក្ដីពុំបានទេ បើហេតុដែលឈប់ពីរាជការបណ្ដាលមកពីទណ្ឌកម្ម ពីរឿងដែលនាំឱ្យសៅហ្មងដល់កិត្តិយស ឬសេចក្ដីសុចរិតរបស់ខ្លួន។

មាត្រា ៧.

ស្ត្រីបើប្រកបនឹងបញ្ញត្តិត្រង់មាត្រា ៤ ក៏អាចធ្វើស្នាក្ដីបាន តែបើមានប្ដីត្រូវឱ្យប្ដីសុខចិត្តព្រមឱ្យធ្វើផង។

មាត្រា ៨.

លក្ខណៈសញ្ជាតិនឹងអាយុត្រូវបញ្ជាក់ដោយមានជូនសំបុត្រកំណើត នឹងជូនសេចក្ដីចំឡងពីព្រះរាជប្រកាស ឬព្រះរាជក្រិត្យដែលអនុញ្ញាតឱ្យចូលជាតិ ជាខ្មែរជាសំអាង បើគ្មានសំបុត្រ

កំណើតជូនទេនោះជនដែលកើតមុនការបង្កើតឱ្យមានអត្រានុកូលដ្ឋានក្នុងប្រទេសកម្ពុជា គឺថ្ងៃ ១២កើត ខែបុស្ស ឆ្នាំកុរត្រីស័ក ១ខែមករា (យ៉ាំងរីយេរ) ឆ្នាំ១៩១២ ត្រូវជូនសំបុត្រសំគាល់ ដែលធ្វើតាមលក្ខណៈត្រឹមត្រូវនឹងបញ្ញត្តិជាជំនួសសំបុត្រកំណើតដែលគ្មាននោះ។ ឯជនដែលកើតក្រោយថ្ងៃខែឆ្នាំដូចខាងលើនេះ ត្រូវជូនសាលក្រមជំនួសសំបុត្រកំណើត។

មាត្រា ៩.

ចាងហ្វាងសាលាវិនិច្ឆ័យ ត្រូវសុំឱ្យចេញសេចក្តីស្រង់ពីបញ្ជីថ្កោលទោសលេខ ២។

មាត្រា ១០.

មួយទៀតចាងហ្វាងសាលាវិនិច្ឆ័យ ត្រូវចាត់ឱ្យក្រុមស៊ើបការសម្ងាត់ ស៊ើបជាក្រៅផ្លូវការអំពីគំនិតមារយាទ នឹងចរិយានៃអ្នកដែលសុំ។

មាត្រា ១១.

ពាក្យសុំចុះឈ្មោះក្នុងតារាងស្មាក្តី ត្រូវធ្វើជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ៗត្រូវចេញបង្កាន់ដៃទទួលពាក្យនេះ។

មាត្រា ១២.

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បញ្ជូនពាក្យសុំព្រមទាំងលិខិតទាំងប៉ុន្មាន ដែលមានជូនជាប់ជាមួយមកផងទៅចាងហ្វាងសាលាវិនិច្ឆ័យៗ ត្រូវបំពេញសំណុំលិខិត ដោយបញ្ចូលសំបុត្រថ្កោលទោសលេខ ២ នឹងសេចក្តីស៊ើបដែលខ្លួនបានបង្គាប់ឱ្យស៊ើបអំពីគំនិតមារយាទ នឹងចរិយានៃអ្នកសុំដូចមានសំដែងក្នុងមាត្រាមុននេះ។

បើត្រូវការចាងហ្វាងសាលាវិនិច្ឆ័យ អាចបំពេញសំណុំលិខិតនេះដោយបញ្ចូលលិខិតផ្សេងៗឯទៀត ដែលយល់ថាជាមានប្រយោជន៍ក៏បាន។

បើសំណុំលិខិតបានប្រមូលសព្វគ្រប់ដោយរួសរាន់រួចហើយ ចាងហ្វាងសាលាវិនិច្ឆ័យត្រូវជូនសំណុំនេះ ទៅសាលាវិនិច្ឆ័យរួមទាំងពីរក្រុមៗ ត្រូវពិភាក្សាបញ្ចេញយោបល់ជាគួរសំរេចឱ្យបានតាមពាក្យសុំឬដូចម្តេច។

ឯសេចក្តីយល់ត្រូវយកតាមមតិភាគច្រើន។ ចៅក្រមស្តីទីនៅសាលាវិនិច្ឆ័យ ក៏ត្រូវចូលជំនុំដែរ។

នាកាលពិភាក្សារួចហើយ ត្រូវក្រឡាបញ្ជីតែងសេចក្តីកត់ហេតុមួយរំពេចតាមចាងហ្វាង បង្គាប់សេចក្តីឱ្យសរសេររួចឱ្យចៅក្រមនិមួយៗ ដែលបានចូលជំនុំចុះហត្ថលេខាក្នុងសេចក្តីកត់ហេតុនេះ។

បើជំនុំយល់ទាស់មិនព្រមឱ្យតាមពាក្យសុំទេ នឹងរំលងសេចក្តីពិភាក្សានោះពុំបានឡើយ។

បើសេចក្តីពិភាក្សាយល់ព្រមតាមពាក្យសុំ នឹងអនុវត្តន៍តាមបានលុះតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សំរេចយល់ព្រមផង។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវឱ្យតំណឹងទៅសាមីខ្លួនបានដឹងសេចក្តីដែលបានសំរេចពីពាក្យសុំនោះ។

ពាក្យសុំដែលសាលាវិនិច្ឆ័យ ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានបដិសេធចោលនោះ នឹងអាចឱ្យប្តឹងតវ៉ាទៅទៀតពុំបានឡើយ ឯនឹងប្តឹងសុំជាថ្មីទៀតមុនកំណត់មួយឆ្នាំក៏ពុំបាន គិតតាំងពីថ្ងៃដែលចូលពាក្យសុំជាន់មុន។

## មាត្រា ១៣.

ស្នាក្តីមុននឹងចូលកាន់មុខក្រសួងខ្លួនត្រូវដាក់ប្រាក់ជានាចំនួន ១០០០រ,០០ នៅមន្ទីរក្រឡាបញ្ជីក្នុងសាលាវិនិច្ឆ័យ។

ក្រឡាបញ្ជីសាលានេះ ត្រូវនាំប្រាក់ជានានោះ ទៅទុកផ្ញើនឹងផ្ទះចងការប្រាក់ណាមួយនៅក្រុងភ្នំពេញ ដែលរាជរដ្ឋាភិបាលត្រួត។

ក្រឡាបញ្ជីសាលាវិនិច្ឆ័យ ត្រូវបើកការប្រាក់ជានាប្រគល់ទៅឱ្យស្នាក្តីឥតយកថ្លៃអ្វី ស្នាក្តីនឹងចេញបង្កាន់ដៃត្រឹមត្រូវទទួលការប្រាក់នេះ។

មាត្រានេះក៏តំរូវទៅលើស្នាក្តី ដែលបានតាំងរួចមកហើយដែរ។

## មាត្រា ១៤.

មុននឹងចាប់ធ្វើការស្នាក្តី ត្រូវស្បថនៅក្រឡាក្រមសាលាឧទ្ធរណ៍ (ប៉ែករដ្ឋប្បវេណី) គឺព្រះរាជបំរើត្រូវប្រកាសសុំឱ្យទទួលឱ្យស្នាក្តីស្បថពីការមុខក្រសួងរបស់ខ្លួន រួចក្រឡាបញ្ជីសូត្រសេចក្តីសម្បថថាដូច្នេះ "ដោយខ្លួនខ្ញុំជាអ្នកជួយការពារ ឬជួយទូន្មាននោះខ្ញុំសច្ចាថាមិននិយាយបរិហារ ឬប្រកាសដោយលិខិតអំពីការអ្វីៗ ដែលទាស់នឹងសេចក្តីគោរពចំពោះព្រះមហាក្សត្រិយ៍

ទាស់នឹងរដ្ឋធម្មនុញ្ញច្បាប់នឹងបញ្ញត្តិទាំងឡាយ ទាស់នឹងសេចក្តីរៀបរយខាងក្នុងនឹងខាងក្រៅប្រទេស ទាស់នឹងសេចក្តីក្សេមក្សាន្តនៃមហាជន ហើយនឹងមិនប្រព្រឹត្តឱ្យឃ្លាតពីសេចក្តីគោរពចំពោះតុលាការនឹងរាជការសាធារណៈ" ស្មាក្តីត្រូវឈរនៅមុខទីជំនុំ ពាក់អាវផាយនឹងកាន់មួកនៅដៃ ហើយទទួលស្បថ តាមសេចក្តីសម្បថ ដូចមានខាងលើ ដោយឆ្លើយថា "ខ្ញុំសូមទទួលសច្ចា តាមសេចក្តីសម្បថនេះ" រួចហើយចាងហ្វាងសាលាឧទ្ធរណ៍បង្គាប់ឱ្យស្មាក្តី ទៅអង្គុយជាមួយនឹងពួកស្មាក្តីដូចគ្នា។

ក្រឡាបញ្ជីត្រូវតែងសេចក្តីកត់ហេតុយ៉ាងសង្ខេបចុះក្នុងសៀវភៅមួយសំរាប់ចុះសម្បថ ដែលទុកនៅទីសមុហបញ្ជីសាលានេះ។

ស្មាក្តីដែលបានតាំងរួចមកហើយក៏ត្រូវបំពេញកិច្ចនេះដែរ។

កាលណាស្មាក្តីស្បថរួចហើយ ចាងហ្វាងសាលាឧទ្ធរណ៍ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ៗ ត្រូវបង្គាប់ទៅចាងហ្វាងសាលាជំនុំក្នុងព្រះរាជអាណាចក្រ ឱ្យបញ្ចូលឈ្មោះស្មាក្តីនេះក្នុងតារាងស្មាក្តីដែលបិទនៅទីសាលាខ្លួន។

កាលណាបានទទួលបង្គាប់នេះហើយ ចាងហ្វាងសាលាជំនុំត្រូវឆ្លើយមួយរំពេចថា បានសំរេចចាត់ការតាមបង្គាប់ហើយ។

## មាត្រា ១៥.

តារាងដែលចុះស្មាក្តីនេះ ត្រូវចុះនាមត្រកូលនាមខ្លួន នឹងនាមឪពុកម្តាយ អាយុ ទីលំនៅ នឹងថ្ងៃ ខែឆ្នាំ ដែលទទួលឱ្យម្នាក់ៗ បានចូលធ្វើស្មាក្តី។ បើមានស្មាក្តីណាសុំឱ្យចុះសញ្ញាប័ត្រ, ងារជាកិតិយស នឹងគ្រឿងឥស្សរិយយសរបស់ខ្លួនក្នុងតារាងនោះផងត្រូវចុះឱ្យតាមសុំ។

## មាត្រា ១៦.

ឯចុះឈ្មោះក្នុងតារាងត្រូវចុះតាមលំដាប់មុនក្រោយរៀងតាមថ្ងៃ-ខែ-ឆ្នាំ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សំរេចព្រមទទួលឱ្យធ្វើជាស្មាក្តី។

បើស្មាក្តីពីរនាក់តាំងថ្ងៃជាមួយគ្នា ត្រូវចុះឈ្មោះណាដែលអាយុច្រើនមុនគេ។ បើអាយុស្មើគ្នាត្រូវយកនាមតាមលំដាប់តួអក្សរខ្មែរ( ក-ឧ )។

ស្មាក្តីណាដែលបានចុះឈ្មោះរួចមកហើយ ត្រូវទុកឱ្យនៅដូចដែល។

## កថាភាគ ២

## អំពីជំនាស់មុខក្រសួង

មាត្រា ១៧.

មនុស្សម្នាក់ធ្វើស្នាក្ដីផង ធ្វើការក្នុងក្រសួងឬធ្វើរបរដូចមានរាយខាងក្រោមផង ពុំបានឡើយ៖

១. ក្រសួងតុលាការ គឺចៅក្រមសាលាជំនុំជម្រះធម្មតា ឬសាលាជំនុំពិសេស ដូចជាក្រុមវិវាទទាំងឡាយ ព្រមទាំងក្រឡាបញ្ជីសមុហបញ្ជី នឹងមុខការដែលជាប់ទាក់ទង នឹងក្រសួងនេះច្រើនក្ដីតិចក្ដី ដូចជាធ្វើណោទែរ, អាជ្ញាសាលា។ល។

២. បព្វជិត ព្រមទាំងអាចារ្យសំរាប់វត្ត។

៣. មុខក្រសួង ឬមុខការសាធារណៈ ទាំងប៉ុន្មានក្នុងព្រះបរមរាជវាំង ឬក្នុងរាជការគ្រប់ក្រសួង។

៤. ចុះសន្យានៅធ្វើការឱ្យគេ នឹងធ្វើជាអ្នកកាន់បញ្ជីប្រាក់ចេញចូល គឺមុខការទាំងប៉ុន្មានដែលបង្កើតឱ្យមាននូវអាការមួយរវាងអ្នកស៊ីឈ្នួល នឹងអ្នកជួល ហើយអាការនោះអាចនាំឱ្យថយឥស្សរភាពនៃអ្នកស៊ីឈ្នួល។

ដូច្នេះស្នាក្ដី នឹងធ្វើជាអ្នកត្រួតការ តែងកាសែតទទួលប្រាក់ឈ្នួល ពីម្ចាស់កាសែតពុំបានឡើយ។

នឹងធ្វើជាបណ្ណាធិការកាសែតក៏ពុំបាន ព្រោះត្រូវមានទទួលខុសត្រូវសងប្រាក់គេក្នុងការនេះៗ តែបើធ្វើជាអ្នកតែងសេចក្ដីក្នុងកាសែតណាមួយ ឬចាត់ការឱ្យបោះកាសែត ដោយស៊ីប្រាក់ឈ្នួលឥតកំណត់បាន។

ដែលហៅថាអ្នកកាន់បញ្ជីប្រាក់ចេញចូលនោះគឺជនទាំងឡាយដែលទទួលមុខការតំណាងគេហើយត្រូវឱ្យដំណឹងគេពីការនោះ។

៥. ពាណិជ្ជកម្ម ឬ សប្បិយកម្ម។

៦. រាជការយុទ្ធនាធិការ ទោះស័ក្តិធំក្តីតូចក្តីដែលនៅក្នុងរាជការ។

៧. អ្នកទទួលជួយការគេ។

សេចក្តីដែលរាយមុខរបរក្នុងមាត្រានេះ មិនមែនជាកំរិតប៉ុណ្ណោះទេ បើនឹងឃើញមានរបរអ្វីឯទៀតក្រៅពីនេះ ត្រូវសាលាវិនិច្ឆ័យរួមក្រុមពិនិត្យផ្សេងតទៅទៀត។

មាត្រា ១៨.

ជនដែលជាប់ញាតិសាលោហិត ឬញាតិពន្ធនឹងចៅក្រមណាមួយ រហូតដល់ថ្នាក់ទី ៤ គិតទាំងថ្នាក់នេះផង នឹងធ្វើជាស្នាក្តីក្នុងនាទីសាលាដំបូង ឬសាលាលហុ ដែលញាតិសាលោហិតឬញាតិពន្ធខ្លួននៅធ្វើការក្នុងសាលានោះពុំបានឡើយ ហើយមួយទៀតក្នុងសាលាវិនិច្ឆ័យ សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ នឹងសាលាក្រុមចោទ នឹងទទួលកាន់ក្តីណា ដែលចៅក្រមត្រូវជាញាតិសាលោហិតឬញាតិពន្ធខ្លួនបានពិនិត្យក៏ពុំបានដែរ។

មាត្រា ១៩.

ប៉ុន្តែមនុស្សមួយនាក់ធ្វើស្នាក្តីផងធ្វើជាប្រធានរដ្ឋសភា ឬប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ធ្វើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការធ្វើអ្នកតំណាងរាស្ត្រ ឬសមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ ធ្វើទីប្រឹក្សាដោយបោះឆ្នោតជ្រើសតាំង ឬដោយបានតាំងធ្វើជាសមាជិកសភាភូមិភាគ ឬសភាក្រុង ធ្វើពេទ្យ ឬធ្វើគ្រូបង្រៀនច្បាប់ផងនោះ ឥតទាស់ទេ តែក្នុងបណ្ណ នាមភាគវិសិទ មិនត្រូវចុះមុខងារទាំងពីរតំរួតជាមួយគ្នាទេ។

## ចំពូក ៣

## អំពីការពឹងស្នាក្តី

## កថាភាគ១

## អំពីបែបបទដែលពឹង

មាត្រា ២០.

ការពឹងស្នាក្តីនោះ អាចពឹងវេលាណាក៏បានឱ្យតែមុនសាលាដើម ឬសាលាជាន់ខ្ពស់មានសានក្រមសំរេចដល់អង្គសេចក្តី។

មាត្រា ២១.

ស្នាក្តីតែម្នាក់អាចទទួលពំនឹងកូនក្តីច្រើននាក់ក្នុងរឿងក្តីតែមួយជាមួយគ្នាបាន លើកតែបើក្នុងរឿងក្តីនោះមានប្រយោជន៍របស់កូនក្តីជំទាស់គ្នា។ ការទទួលពំនឹងកូនក្តីច្រើននាក់ដូច្នេះរួចហើយ

បើឃើញមានប្រយោជន៍របស់កូនក្តីជំទាស់គ្នាកាលណា ស្នាក្តីត្រូវសុំដកខ្លួនលែងទទួលពំនឹងភ្លាម ហើយត្រូវប្តឹងដល់ចាងហ្វាងសាលាដែលជំនុំ-វិនិច្ឆ័យរឿងនោះ បើមិនធ្វើដូច្នេះទេ ចាងហ្វាងសាលាត្រូវបង្គាប់ឱ្យស្នាក្តី ប្រណិប័តន៍តាមបញ្ញត្តិនេះ។ ចាងហ្វាងត្រូវធ្វើដីកាសំរេចមួយពីហេតុដែលទាស់នេះ ជូនទៅចាងហ្វាងសាលាវិនិច្ឆ័យសុំសេចក្តីយល់ព្រមផង។ ស្នាក្តីត្រូវទទួលខុសត្រូវជាបទរដ្ឋប្បវេណីចំពោះកូនក្តី នឹងត្រូវទទួលខុសត្រូវខាងការមុខក្រសួងរបស់ខ្លួន អំពីដាក់ទណ្ឌកម្ម កាលណាបើស្នាក្តីនៅស្ងៀមមិនសុំដកខ្លួនចេញពីទទួលពំនឹងគេ បើទុកជាគេមិនបានបង្ខំឱ្យដកក៏ដោយ។

មាត្រា ២២.

ស្នាក្តីច្រើននាក់អាចទទួលពំនឹងកូនក្តីតែម្នាក់ក្នុងរឿងក្តីតែមួយក៏បាន។

មាត្រា ២៣.

ការពឹងស្នាក្តីទុកជាត្រឹមត្រូវ នឹងទុកជាបានការដោយមានសំបុត្រជូនដំណឹង ចុះថ្ងៃខែឆ្នាំ នឹងចុះហត្ថលេខាស្នាក្តីជូនទៅចាងហ្វាងសាលាដែលទទួលរឿងក្តីនោះជំនុំជំរះ ដើម្បីទុកក្នុងមន្ទីរក្រឡាបញ្ជីសាលានោះ។

នាកាលបានទទួលសំបុត្រជូនតំណឹងនេះហើយ ក្រឡាបញ្ជីត្រូវធ្វើកំណត់ដែលចាងហ្វាងត្រូវចុះហត្ថលេខាអមផង ឆ្លើយបង្ហាញលេខរៀងសំណុំរឿងនោះ។

បើការពឹងស្នាក្តី ពានទៅលើរឿងក្តីដែលបានកាត់សេចក្តីរួចហើយ នោះត្រូវឆ្លើយឱ្យតំណឹងទៅស្នាក្តីវិញ បង្ហាញលេខរៀងសំណុំរឿងនឹង ថ្ងៃខែឆ្នាំ សាលក្រមដែលបានកាត់សេចក្តី។

ឯសំបុត្រជូនតំណឹងពីការពឹងស្នាក្តី នឹងសេចក្តីចំឡងពីកំណត់ដែលក្រឡាបញ្ជីបានផ្ញើតបទៅវិញនោះ ត្រូវដាក់ទុកក្នុងសំណុំរឿងក្តីហើយ ត្រូវចុះក្នុងបញ្ជីកត់លិខិតរឿងក្តីផង។

## កថាភាគ ២

## អំពីផលការពឹងស្នាក្តី

មាត្រា ២៤.

ការពឹងស្នាក្តីនោះមានផលរហូត លុះតែកាត់សេចក្តីគិតតាំងពីថ្ងៃជូនតំណឹង ទោះរឿងក្តីនោះបានកាត់សេចក្តីដោយដាច់ណាត់ហើយរើជំនុំជំរះឡើងវិញក៏ដោយ។

មាត្រា ២៥.

នាកាលបើរឿងក្តីនោះឡើងដល់សាលាជាន់ខ្ពស់ ដោយមានពាក្យបណ្តឹងឧទ្ធរណ៍ ឬប្តឹងសាទុក្ខ ត្រូវពឹងស្មាក្តីថ្មីទៀត។

បើរឿងក្តីនោះ សាលាជាន់ខ្ពស់បានត្រឡប់មកឱ្យរើជំនុំជំរះឡើងវិញ មិនបាច់ពឹងស្មាក្តីជាថ្មីទៀតទេ។

មាត្រា ២៦.

នឹងឈប់លែងទទួលពំនឹងនៅវេលាណាក៏បាន បើកូនក្តីឈប់លែងពឹងវិញក្តី បើស្មាក្តីឈប់ទទួលពំនឹងក្តី បើកូនក្តីនឹងស្មាក្តីព្រមព្រៀងគ្នាឈប់ក្តី ឬដោយចៅក្រមបញ្ឈប់ជាផ្លូវការក្តី។

មាត្រា ២៧.

ឯសេចក្តីឈប់លែងពឹងក្តី ឈប់ទទួលពំនឹងក្តី ឈប់ពឹងដោយព្រមព្រៀងគ្នាក្តី ត្រូវប្តឹងជូនតំណឹងដោយពាក្យឬប្តឹងដោយមាត់ទទេ បើប្តឹងដោយមាត់ទទេ ចៅក្រមនឹងក្រឡាបញ្ជីធ្វើសេចក្តីកត់ហេតុពីបណ្តឹងនោះមួយរំពេច។

មាត្រា ២៨.

ឯការបញ្ឈប់ជាផ្លូវការ ត្រូវចាងហ្វាងសាលាដែលទទួលជំនុំជំរះរឿងក្តី ធ្វើដីកាបញ្ឈប់ដោយមានអាងហេតុផ្សេងៗ។

មាត្រា ២៩.

ក្រឡាបញ្ជីត្រូវឱ្យតំណឹងទៅសាមីខ្លួនជាប្រញាប់ពីកិច្ចការដែលបណ្តាលឱ្យបញ្ឈប់។

មាត្រា ៣០.

កិច្ចការទាំងប៉ុន្មានដែលបណ្តាលឱ្យឈប់ពឹងស្មាក្តី នឹងសេចក្តីចំឡងកំណត់ឱ្យតំណឹងទាំងប៉ុន្មាន ដែលក្រឡាបញ្ជីធ្វើត្រូវដាក់បញ្ចូលក្នុងសំណុំរឿងក្តី ហើយកត់ក្នុងបញ្ជីលិខិតរឿងក្តីផង។

មាត្រា ៣១.

នាកាលបើគេឈប់លែងពឹង នោះស្មាក្តីត្រូវឈប់លែងជួយសង្គ្រោះមនុស្សត្រូវចោទ ឬលែងតំណាងអ្នកក្តីតាំងពីថ្ងៃដែលបានទទួលសំបុត្របញ្ឈប់ ឬតាំងពីថ្ងៃដែលចេញដីកាបញ្ឈប់តាមតំណើរ។

មាត្រា ៣២.

សេចក្ដីដែលកូនក្ដី នឹងស្នាក្ដីទាស់គ្នាអំពីការបញ្ឈប់នេះមិននាំឱ្យអាក់ខានដំណើររឿងក្ដីនោះទេ ត្រូវតែជំនុំជំរះដូចជាក្ដីដែលឥតមានស្នាក្ដី។

## ចំពូក៤
## សិទ្ធិ និងការណីយកិច្ចនៃស្នាក្ដី
## កថាភាគ១
## ពីសិទ្ធិរបស់ស្នាក្ដី

មាត្រា ៣៣.

ស្នាក្ដីដែលត្រូវមានសិទ្ធិស្រដីជួយដោះសាការពារអ្នកក្ដីដោយសេរីនោះ ក្នុងកិច្ចការមុខក្រសួងខ្លួន ត្រូវចាត់ការជាឯកច្ឆន្ទ កុំឱ្យតែកន្លងនូវសេចក្ដីដូចមានក្នុងសម្បថពីការមុខក្រសួងខ្លួន។

មាត្រា ៣៤.

ការពឹងស្នាក្ដីនោះ តាមច្បាប់នាំឱ្យកូនក្ដីទុកមន្ទីររបស់ស្នាក្ដីជាលំនៅរបស់ខ្លួន។

មាត្រា ៣៥.

ស្នាក្ដីត្រូវមានមន្ទីរធ្វើការមួយជារបស់ខ្លួន នៅទីកន្លែងដែលមានសាលាជំនុំជំរះក្ដី។

មាត្រា ៣៦.

ស្នាក្ដីដែលមានចុះឈ្មោះក្នុងតារាងនោះអាចចូលហ៊ុនគ្នាធ្វើការ នៅមន្ទីរធ្វើការតែមួយកន្លែងជាមួយគ្នាបាន។ ឯកិច្ចចូលហ៊ុនត្រូវធ្វើជាលិខិតមួយច្បាប់ប្ដឹងទៅចាងហ្វាងសាលាវិនិច្ឆ័យៗត្រូវចុះលិខិតនោះក្នុងសៀវភៅមួយផ្សេងក្នុងមន្ទីរក្រឡាបញ្ជីសាលានោះ។ លិខិតចុះកិច្ចការទាំងប៉ុន្មាន នឹងថ្យូងសំបុត្រក្រដាសពុម្ពត្រូវចុះឈ្មោះគ្រប់ស្នាក្ដីដែលចូលហ៊ុនគ្នា។ តែលិខិតដែលធ្វើនោះចុះហត្ថលេខាតែស្នាក្ដីមួយនាក់ ទុកជាបានការហើយ មិនបាច់ចាំដាក់សេចក្ដីក្នុងសំបុត្រថាជំនួសឬតំណាងស្នាក្ដីណាៗឡើយ។

ស្នាក្ដីទាំងប៉ុន្មាន ដែលចូលហ៊ុនគ្នាត្រូវទទួលខុសត្រូវលើខ្លួនជាមួយគ្នា ចំពោះអ្នកដទៃពីការគ្រប់គ្រងជាមួយគ្នា។ ប៉ុន្តែស្នាក្ដីកូនហ៊ុននិមួយៗ មានអំណាចប្ដឹងពីស្នាក្ដី កូនហ៊ុនមួយទៀតដែលបានប្រព្រឹត្តខុសក្នុងការផ្ទាល់ខ្លួនឯង។

មាត្រា ៣៧.

ហាមមិនឱ្យស្មាគ្គីដែលចូលហ៊ុនគ្នាក្ដី ឬមិនចូលហ៊ុនគ្នាក្ដី មានមន្ទីរធ្វើការលើសពីមួយក្នុងអាណាខេត្តខ្មែរ។

មាត្រា ៣៨.

នៅមន្ទីរធ្វើការ ត្រូវឱ្យបិទកំណត់ខាងក្រៅដាក់ឈ្មោះស្មាគ្គីដែលជាម្ចាស់មន្ទីរ នឹងដាក់ថាធ្វើជាស្មាគ្គី បើស្មាគ្គីច្រើននាក់ចូលហ៊ុនគ្នាត្រូវឱ្យចុះឈ្មោះគ្រប់គ្នា។ ឯនាមស្មាគ្គីនឹងចុះថែមដាក់ងារជាកិត្តិយសឬសញ្ញាប័ត្រ នឹងគ្រឿងឥស្សរិយយសដែលមានតពីឈ្មោះខ្លួនទៅទៀតក៏បាន។

មាត្រា ៣៩.

គិតតាំងពីថ្ងៃដែលការពឹងស្មាគ្គីបានសំរេចតាមច្បាប់ហើយ នោះកិច្ចការទាំងប៉ុន្មានអំពីរឿងក្ដី ដែលបានធ្វើនៅមន្ទីរធ្វើការរបស់ស្មាគ្គីជាប្រយោជន៍កូនក្ដីអ្នកពឹង ត្រូវទុកជាត្រឹមត្រូវនឹងបានការ។

មាត្រា ៤០.

ទោះដោយប្រការយ៉ាងណាក្ដី ស្មាគ្គីនឹងដោះសាថាខ្លួនមិននៅ ឬថាខ្លួនមានធុរៈពុំបានទេ ដើម្បីប្រកែកថាខ្លួនមិនបានទទួលកំណត់ពាក្យណាមួយ ដែលគេបានយកមកប្រគល់នៅមន្ទីរធ្វើការរបស់ខ្លួន ឬដើម្បីជាសំអាងតំរូវនឹងសេចក្ដីដែលបុគ្គលិកក្នុងមន្ទីរធ្វើការរបស់ខ្លួនបានប្រកែកមិនព្រមទទួលកំណត់ពាក្យនោះ។ បើដូច្នេះស្មាគ្គីត្រូវចាត់ចែងឱ្យបានសព្វគ្រប់ ថាបើខ្លួនមិននៅ ឬបើខ្លួនមានធុរៈខាននោះត្រូវតែមានមនុស្សនៅប្រចាំការក្នុងមន្ទីរធ្វើការរបស់ខ្លួនជានិច្ច ដើម្បីទទួលពាក្យក្ដី នឹងសំបុត្រស្នាមអ្វីអំពីរឿងក្ដី ដែលគេបានពឹងខ្លួនឱ្យជួយ។ បើបានបោះត្រាមន្ទីររបស់ស្មាគ្គីទទួលលិខិតទាំងនោះ ហើយត្រូវទុកជាបានការ។

មាត្រា ៤១.

កំណត់ពាក្យទាំងឡាយ ត្រូវមន្ទីរក្រឡាបញ្ជីផ្ញើផ្ទាល់ទៅមន្ទីរក្រឡាបញ្ជីផ្ញើ ផ្ទាល់ទៅមន្ទីរធ្វើការរបស់ស្មាគ្គីតាមសៀវភៅបញ្ជូន។ បើមានចុះសញ្ញាទទួលដោយបានបោះត្រាមន្ទីររបស់ស្មាគ្គីលើសៀវភៅបញ្ជូនហើយ ត្រូវទុកជាភ័ស្ដុតាង ថាបានប្រគល់កំណត់ពាក្យដែលផ្ញើដូចមានរាយមុខចុះក្នុងសៀវភៅនោះមែនហើយ។

មាត្រា ៤២.

ក្នុងរឿងក្តីរដ្ឋប្បវេណី ត្រូវទុកស្នាក្តីដូចជាអ្នកថណាយកូនក្តី គឺស្នាក្តីត្រូវធ្វើការជួសកូនក្តី នឹងតំណាងកូនក្តីក្នុងកិច្ចការគ្រប់ចំពូក អំពីរឿងក្តីនឹងនៅពេលដែលតុលាការជំនុំជំរះ។

បើកូនក្តីខានមិនបានចូលមក ក៏មិនជាការនាំឱ្យវិបត្តិការណ៍ជំនុំជំរះ ដែលត្រូវទុកជាបាន ធ្វើចំពោះមុខកូនក្តី នឹងមិនជាការនាំឱ្យវិបត្តិសេចក្តីសំរេច បើតុលាការបានជំនុំជំរះនឹងសំរេច សេចក្តីចំពោះមុខស្នាក្តីហើយ ។

កូនក្តីនឹងស្នាពីត្រូវជាប់ជំពាក់គ្នាទៅវិញទៅមកអំពីការទទួលសារភាព,ការព្រមទទួល, ការព្រមពៀងតាមសេចក្តីដែលគេសុំ ឬបដិសេធសេចក្តីដែលគេសុំ ហើយនឹងអំពីការលើកលែង តវ៉ាគឺថាទាំងពីរនាក់នេះ បើអ្នកណាបានទទួលយ៉ាងណា ម្នាក់ទៀតត្រូវទទួលយ៉ាងនោះដូចគ្នា ។

ប៉ុន្តែស្នាក្តីមិនអាចចូលទៅជួសកូនក្តី នឹងមិនអាចតំណាងកូនក្តីបានទេ ដោយប្រការដូច តទៅនេះ ៖

១. កាលណាបើកូនក្តីបានទទួលបង្គាប់ឱ្យចូលផ្ទាល់ខ្លួនចំពោះតុលាការ។

២. កាលណាបើចៅក្រម ឬគូក្តីម្ខាងតំរូវឱ្យស្បថ។ បើស្នាក្តីអាចហ៊ានទទួលសារភាព, ហ៊ានសុំ, ហ៊ានបដិសេធ, ហ៊ានព្រមព្រៀង, ហ៊ានលើកលែងតវ៉ា ឬហ៊ានទទួលព្រម ដោយកូនក្តី ខ្លួនមិនបានសុខចិត្តព្រមផងទេ នោះស្នាក្តីត្រូវទទួលខុសត្រូវចំពោះកូនក្តីខ្លួន។ បើត្រូវដាក់ ទណ្ឌកម្មដោយល្មើសនឹងវិន័យ ឬល្មើសនឹងក្រមព្រមព្រហ្មទណ្ឌផងក៏បាន។

មាត្រា ៤៣.

ក្នុងរឿងក្តីអាជ្ញាគតិ ស្នាក្តីមិនអាចនឹងចូលទៅជួសកូនក្តីខ្លួន នឹងមិនអាចនឹងតំណាង កូនក្តីខ្លួនបានឡើយ។ នៅវេលាដែលកូនក្តីខ្លួនចូលទៅចំពោះមុខចៅក្រមដងណា។ ខ្លួនគ្រាន់តែ ចូលទៅជួយសង្គ្រោះកូនក្តីខ្លួនដងនោះ។

មាត្រា ៤៤.

ស្នាក្តីត្រូវបាននូវការសម្រួលដើម្បីនឹងឱ្យដឹងសេចក្តីស៊ើបសួរខាងតុលាការ នៅវេលាដែល គេធ្វើកិច្ចការទាំងឡាយចំពោះមុខកូនក្តីខ្លួន។

មាត្រា ៤៥.

ស្នាក្តីមិនមែនត្រូវចូលទៅជួបជុំខានពុំបាននោះទេ។ ស្នាក្តីអាចខានចូលទៅជួយសង្គ្រោះកូនក្តី នៅវេលាដែលធ្វើកិច្ចការស៊ើបសួរ ឬនៅវេលាជំនុំជំរះក៏បាន តែត្រូវទទួលខុសត្រូវលើខ្លួន។ គ្រាន់តែត្រូវសំរួលឱ្យស្នាក្តីបានចូលទៅជួយសង្គ្រោះកូនក្តី ឬចូលទៅជួបជុំនៅវេលាដែលធ្វើកិច្ចការស៊ើបសួរ ក៏ជាការគ្រប់គ្រាន់ហើយ។

មាត្រា ៤៦.

ភ័ស្តុតាងដែលបញ្ជាក់ឱ្យឃើញថាបានសំរួលឱ្យស្នាក្តីចូលទៅជួយសង្គ្រោះកូនក្តី ឬចូលទៅជួបជុំនៅវេលាដែលធ្វើកិច្ចការស៊ើបសួរខាងតុលាការអំពីរឿងកូនក្តីមែននោះ គឺដីកាមួយច្បាប់ដែលមន្ទីរក្រឡាបញ្ជីបានចេញទៅហៅឱ្យចូលទៅ។ កាលណាបើចៅក្រមបានឱ្យតំណឹងមាត់ទទេ ពីកាលបរិច្ឆេទនឹងពេលម៉ោងដែលត្រូវស៊ើបសួរឬជំនុំជម្រះតទៅទៀត ក្រោយដែលបានចាប់ស៊ើបសួរ ឬចាប់ជំនុំជំរះចំពោះមុខស្នាក្តីរួចហើយ នោះមិនចាំបាច់ចេញដីកាហៅទៀតទេ តែក្រឡាបញ្ជីត្រូវចុះសេចក្តីឱ្យដំណឹងនេះក្នុងកំណត់កត់ហេតុឬក្នុងសៀវភៅកត់សេចក្តីជំនុំជំរះតាមការផង។

តាមធម្មតា ដីកាហៅដូច្នេះត្រូវផ្ញើទៅស្នាក្តី ២៤ ម៉ោងជាមុន ប៉ុន្តែបើការនោះប្រញាប់ ចៅក្រមអាចហៅស្នាក្តីក្នុងរវាងមួយម៉ោងក៏បាន។

មាត្រា ៤៧.

ក្នុងកិច្ចការទាំងប៉ុន្មានដែលចៅក្រម ឬដែលអ្នកទទួលអំណាចពីចៅក្រមបានធ្វើត្រូវឱ្យចុះសេចក្តីសំគាល់ពិសេស អំពីស្នាក្តីបានចូលទៅជួបជុំ ឬខានពុំបានចូលទៅជួបជុំ។ បើស្នាក្តីបានចូលទៅជួបជុំ ត្រូវស្នាក្តីចុះហត្ថលេខាជាមួយនឹងចៅក្រម ឬជាមួយនឹងអ្នកទទួលអំណាចពីចៅក្រម ហើយនឹងជាមួយនឹងក្រឡាបញ្ជី។ បើស្នាក្តីខានពុំបានចូលទៅជួបជុំទេ ត្រូវក្រឡាបញ្ជីកត់ត្រាពីមានដីកាហៅឱ្យចូលទៅ ឬពីបានឱ្យដំណឹងមាត់ទទេឱ្យចូលទៅនោះផង។

មាត្រា ៤៨.

ត្រូវឱ្យដំណឹងទៅស្នាក្តីដែលទទួលពំនឹងគេអំពីកិច្ចការដូចតទៅនេះ ៖

១. សាលក្រមសាលាជាន់ទាប នឹងសាលក្រមសាលាជាន់ខ្ពស់ដែលបានកាត់សេចក្តីក្រៅពីមុខស្នាក្តី។

២. ដីកាទាំងឡាយដែលសុភាចារបុរសបានចេញនៅវេលាស៊ើបសួរក្តី នៅវេលាស៊ើបសួរជាស្រេចហើយក្តី ដូចជាដីកាដែលចេញឱ្យឃុំខ្លួន មនុស្សជាប់ចោទ នឹងឱ្យមនុស្សជាប់ចោទនៅ

ក្រៅឃុំជាបណ្ដោះអាសន្នជាដើម ព្រមទាំងដីកាបញ្ឈប់ការស៊ើបសួររឿងអាជ្ញាគតិ នឹងបញ្ឈប់ការអង្កេតរឿងក្ដីរដ្ឋប្បវេណីមុនការចោទប្រកាន់ ឬមុនជំនុំជំរះ។

៣. ពេលជំនុំជំរះក្ដីឯណាដែលបានជូនទៅតុលាការដើម្បីជំនុំជំរះ ដោយបានប្រមូលការណ៍ស្រេចហើយ។

៤. សាលក្រមចោទប្រកាន់ដែលបានចេញ។

ការឱ្យតំណឹងកើតឡើងដោយមានដីកាមួយដែលធ្វើជា ២ច្បាប់ មានចុះថ្ងៃខែឆ្នាំ នឹងហត្ថលេខាក្រឡាបញ្ជីសាលាដែលទទួលជំនុំជំរះក្ដីនោះ។ ដីកានេះដែលចាងហ្វាងសាលាឬ ចៅក្រមបានចុះហត្ថលេខាបានឃើញជាមួយផង ត្រូវប្រគល់ឱ្យតាមសៀវភៅបញ្ជូន។ កាលបើបានទទួលដីកានេះហើយ ត្រូវកត់ត្រាថាបានទទួលឬបោះត្រាសំរាប់មន្ទីរស្មាក្ដីលើដីកានេះហើយត្រូវបង្វិលមួយច្បាប់ទៅមន្ទីរក្រឡាបញ្ជីវិញភ្លាម ដើម្បីយកទៅបញ្ចូលក្នុងសំណុំរឿងក្ដី នឹងចុះក្នុងបញ្ជីរាយលិខិតក្នុងសំណុំរឿងក្ដីតទៅ។

មាត្រា ៤៩.

អំពីរឿងក្ដីគ្រប់រឿង, ស្មាក្ដីអាចចូលទៅមន្ទីរក្រឡាបញ្ជីមើលសំណុំរឿងក្ដីដែលខ្លួនទទួលពំនឹងជួយគេនោះបាន។ ស្មាក្ដីអាចចំឡងកំណត់ពាក្យទាំងឡាយក្នុងសំណុំរឿងក្ដី ដែលគូក្ដីបាននាំមកជូនព្រមទាំងលិខិតស៊ើបសួរក៏បាន។

មាត្រា ៥០.

ការបង្ហាញសំណុំរឿងក្ដី ត្រូវធ្វើក្នុងទីសាលានៅពេលម៉ោងបើកប៉ុយរ៉ូធ្វើការ។

មាត្រា ៥១.

ស្មាក្ដីអាចឱ្យមនុស្សណាម្នាក់ដែលនៅធ្វើការជានិច្ចក្នុងមន្ទីរធ្វើការរបស់ខ្លួន ចូលទៅចំឡងលិខិតក្នុងសំណុំរឿងក្ដីក៏បាន តែការនេះត្រូវខ្លួនទទួលខុសត្រូវលើខ្លួនពេញទាំងមូល ឯស្មៀននោះត្រូវឱ្យមានកាន់នូវសំបុត្រអនុញ្ញាតដែលខ្លួនបានចុះហត្ថលេខា សំបុត្រអនុញ្ញាតនេះត្រូវបញ្ជាក់ពីសំណុំរឿងក្ដីដែលត្រូវឱ្យចំឡងផង។

កាលបើគ្មានសំបុត្រអនុញ្ញាតដូច្នេះទេ នឹងបង្ហាញសំណុំរឿងណាមួយពុំបានឡើយ។ ក្រឡាបញ្ជីឬសមុហបញ្ជីណាដែលល្មើសនឹងបញ្ញត្តិនេះអាចយកខ្លួនឱ្យជំនុំជំរះដាក់ទណ្ឌកម្មជារាជការបាន ហើយបើត្រូវមានទោសជម្មតាផងក៏អាចធ្វើទោសនេះថែមទៀតបាន។

មាត្រា ៤២.

ស្មាក្តីជួបនិយាយការនឹងកូនក្តីខ្លួនបានដោយសេរី។ ប៉ុន្តែក្នុងរឿងអាជ្ញាគតិ កាលណាបើកូនក្តីនោះជាប់ឃុំ ការប្រស្រ័យនេះត្រូវឱ្យចៅក្រមចេញដីកាអនុញ្ញាតផង។ លុះបានឃើញដីកាអនុញ្ញាតនេះហើយ ចាងហ្វាងគុកត្រូវចាត់ឱ្យហៅមនុស្សជាប់ឃុំមកជួបនឹងស្មាក្តីនៅក្នុងបន្ទប់ពិសេសមួយដែលធ្វើសំរាប់ឱ្យជួបដូច្នេះ។ ត្រូវហាមផ្តាច់មិនឱ្យជួបគ្នាដោយសម្ងាត់ ដោយលួចលាក់។

មាត្រា ៤៣.

ស្មាក្តីនឹងកូនក្តីខ្លួនអាចធ្វើសំបុត្រទៅមករកគ្នាបានដោយសេរី។

មាត្រា ៤៤.

ស្មាក្តីនឹងថ្លែងការណ៍មាត់ទទេក្តី ដោយលិខិតក្តីបានដោយសេរី ដើម្បីនឹងជូនសេចក្តីតវ៉ា, សេចក្តីសុំ, សេចក្តីពន្យល់នឹងសេចក្តីដោះសារបស់ខ្លួន។

មាត្រា ៤៥.

ស្មាក្តីត្រូវតែធ្វើពាក្យមួយច្បាប់ថ្លែងការណ៍ដែលខ្លួនអាងជូនអមបណ្តឹងឧទ្ធរណ៍ នឹងបណ្តឹងសាទុក្ខជាដរាប។

ដូចគ្នានឹងខាងលើនេះ ស្មាក្តីត្រូវតែធ្វើជូនក្រុមចោទពាក្យមួយច្បាប់ថ្លែងការណ៍ដោះសាការពារឱ្យកូនក្តីខ្លួន។

លិខិតដែលស្មាក្តីធ្វើជូនទាំងប៉ុន្មានត្រូវចុះថ្ងៃខែឆ្នាំ នឹងចុះហត្ថលេខាហើយត្រូវបោះត្រាសំរាប់មន្ទីរខ្លួនផង។ ក្រឡាបញ្ជីបើបានទទួលលិខិតនេះហើយ ត្រូវចេញបង្កាន់ដៃទទួល ហើយត្រូវចុះហត្ថលេខាបានឃើញនឹងបោះត្រាខ្លួនលើលិខិតនេះ រួចត្រូវបញ្ចូលលិខិតនេះក្នុងសំណុំរឿងនឹងកត់ក្នុងបញ្ជីរាយលិខិតតទៅ។

មាត្រា ៤៦.

នៅវេលាកំពុងស៊ើបសួរ កាលណាបើស្មាក្តីសុំឱ្យចាត់ការអ្វីមួយដែលមានប្រយោជន៍ដើម្បីសំដែងនូវសេចក្តីពិត ឬដែលមានប្រយោជន៍ដល់កូនក្តីខ្លួន នោះត្រូវព្រមតាមសុំជាប្រញាប់បំផុតតាមគួរនឹងការ បើចៅក្រមដែលទទួលពិនិត្យរឿងក្តីនោះ យល់ថាសំណូមនោះត្រឹមត្រូវមែន បើពុំ

នោះសោតចៅក្រមត្រូវចេញដីកាចុះហេតុជាសំអាងក្រោយ ដែលមានពាក្យសុំដោយលាយល័ក្ខណ៍អក្សរនាំមកដាក់សាលា។

ដីកាចៅក្រមនេះត្រូវក្រឡាបញ្ជីឱ្យតំណឹងភ្លាមទៅស្នាក្តីៗ អាចឧទ្ធរណ៍ពីដីកានេះទៅក្រុមចោទបានក្នុងរវាងបីថ្ងៃ គិតតាំងពីថ្ងៃដែលឱ្យតំណឹង។

មាត្រា ៥៧.

ស្នាក្តីអាចនិយាយបាន លុះតែចៅក្រមបើកឱ្យនិយាយ។

ទោះយ៉ាងណាក្តីស្នាក្តីមិនត្រូវនិយាយកាត់ការស៊ើបសួរ ឬការជំនុំជំរះឡើយ។

នៅវេលាកំពុងជំនុំជំរះ កំពុងស៊ើបសួរ ស្នាក្តីនិយាយផ្ទាល់ឆ្ពោះចៅក្រម ឬឆ្ពោះកូនក្តីខ្លួន។ តែហាមផ្តាច់មិនឱ្យស្នាក្តីនិយាយផ្ទាល់ឆ្ពោះគូក្តីម្ខាង,សាក្សី,ដើមបណ្តឹង ឬមនុស្សត្រូវចោទ ដែលពុំបានពឹងខ្លួននោះឡើយ។

មាត្រា ៥៨.

កាលណាបើយល់ថាជាការគួរ នោះចៅក្រមអាចបើកឱ្យស្នាក្តីនិយាយបាន។ ឯស្នាក្តីក៏អាចសុំនិយាយបានបើនៅវេលាកំពុងស៊ើបសួរ ឬនៅវេលាជំនុំជំរះខ្លួនយល់ថាមានប្រយោជន៍នឹងបំភ្លឺខសេចក្តីត្រង់ណាមួយ ឬបញ្ហាណាមួយដែលនៅងងឹត ដូចជានៅវេលាក្រោយសួរយកចំឡើយ ក្រោយដណ្តឹងសួរសាក្សីមួយនាក់,ឬក្រោយសួរឱ្យឆ្លើយតទល់គ្នាជាដើម។

មាត្រា ៥៩.

នៅវេលាដែលសុំបំភ្លឺសេចក្តីដូច្នេះ ហាមមិនឱ្យស្នាក្តីនិយាយដល់អង្គសេចក្តីទេ។ បើមិនបដិបត្តិតាមសេចក្តីបញ្ញត្តិនេះទេ ត្រូវដកសេចក្តីអនុញ្ញាតឱ្យនិយាយវិញ។

មាត្រា ៦០.

លុះសាលាដំបូង,សាលាឧទ្ធរណ៍ ឬសាលាវិនិច្ឆ័យបានពិភាក្សាហើយ ចាងហ្វាងសាលាត្រូវបើកឱ្យស្នាក្តីនិយាយ ទើបស្នាក្តីអានសេចក្តីយល់ឃើញរបស់ខ្លួនដែលបានសរសេរ។ ស្នាក្តីអាចជូនយោបល់ខ្លួន តែមាត់ទទេបំពេញថែមទៀតក៏បាន។ តអំពីនោះមកទៀត សេចក្តីយល់ឃើញនេះ ត្រូវជូនភ្លាមដល់ដៃក្រឡាបញ្ជីទីជំនុំ,ក្រឡាបញ្ជីនេះត្រូវចុះហត្ថលេខាបានឃើញ នឹង

បោះត្រារបស់ខ្លួន លើសេចក្តីយល់ឃើញ ហើយបញ្ចូលសេចក្តីយល់ឃើញនេះទៅក្នុងសំណុំរឿងក្តី នឹងចុះក្នុងបញ្ជីរាយលិខិត។

កិច្ចការទាំងប៉ុន្មានដែលបានធ្វើមកដូច្នេះ ត្រូវកត់ត្រាក្នុងសៀវភៅជំនុំជំរះ។

បើគ្មានជូនសេចក្តីយល់ឃើញ ដោយលិខិតទេ ត្រូវស្មាក្តីទទួលខុសត្រូវចំពោះកូនក្តីខ្លួន។

ប៉ុន្តែនៅចំពោះមុខសាលាឧក្រិដ្ឋ ស្មាក្តីដែលគេបានពឹងឱ្យជួយការពារមនុស្សត្រូវចោទ អាចនិយាយជូនយោបល់តែមាត់ទទេបាន។

មាត្រា ៦១.

ក្នុងរឿងក្តីរដ្ឋប្បវេណី,ត្រូវអានសេចក្តីយល់ឃើញខាងដើមចោទមុនអានសេចក្តីយល់ឃើញរបស់ចុងចំឡើយ។

ក្នុងរឿងក្តីអាជ្ញា ត្រូវអានសេចក្តីយល់ឃើញរបស់ដើមបណ្តឹងបទរដ្ឋប្បវេណីមុនអានសេចក្តីយល់ឃើញខាងមនុស្សត្រូវចោទ។

កាលណាបើមានដើមចោទច្រើននាក់ មានចុងចំឡើយច្រើននាក់, មានដើមបណ្តឹងបទរដ្ឋប្បវេណីច្រើននាក់ ឬមានមនុស្សត្រូវចោទច្រើននាក់, ត្រូវចាងហ្វាងសាលាបង្គាប់នូវលំដាប់ដែលស្មាក្តីត្រូវនិយាយ តែកុំឱ្យទាស់ខុសនឹងបទបញ្ញត្តិដូចមានខាងលើនេះ គឺត្រូវទុកអំណាចឱ្យចុងចំឡើយឆ្លើយតបតនឹងដើមចោទ ហើយនឹងត្រូវឱ្យមនុស្សត្រូវចោទបានអំណាចនិយាយនៅវេលាទីបំផុតជាដរាប។

មាត្រា ៦២.

ចៅក្រមមិនត្រូវកាត់សេចក្តីមុនបើកឱ្យស្មាក្តីអាននឹងជូនសេចក្តីយល់ឃើញរបស់ខ្លួននោះឡើយ។

សាលាឧក្រិដ្ឋត្រូវកាត់សេចក្តី ក្រោយបន្ទាប់វេលាដែលស្មាក្តីអ្នកទទួលពំនឹងពីមនុស្សត្រូវចោទជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម បានថ្លែងសេចក្តីយល់ឃើញរបស់ខ្លួន។

សាលាឯទៀតអាចកាត់សេចក្តីក្រោយបន្ទាប់វេលា ដែលស្មាក្តីបានថ្លែងសេចក្តីយល់ឃើញ ឬក៏លើកការកាត់សេចក្តីទៅពេលជំនុំជំរះជាន់មុខ។

មាត្រា ៦៣.

ក្នុងរឿងក្តីបទរដ្ឋប្បវេណីនឹងបទមជ្ឈិម នៅវេលាក្រោយដែលបញ្ចប់ការពិភាក្សាហើយ, ស្នាក្តីអាចសុំឱ្យលើករឿងក្តីនោះទៅដាក់ជំនុំជំរះដាន់មុខទៀតបាន ដើម្បីនឹងជូនសេចក្តីយល់ឃើញជាថ្មីទៀត។ បើបានលើកដូច្នេះហើយនឹងអនុញ្ញាតឱ្យលើកតទៅទៀតពុំបានឡើយ។ បើនៅវេលាជំនុំជំរះដាន់មុខបន្ទាប់នោះ ពុំបានជូនសេចក្តីយល់ឃើញទេ ត្រូវកត់ត្រាក្នុងសៀវភៅកត់សេចក្តីជំនុំជំរះ អំពីខ្វះសេចក្តីយល់ឃើញនេះ រួចត្រូវកាត់សេចក្តីរំលងសេចក្តីយល់ឃើញនេះតទៅ។

មាត្រា ៦៤.

ប៉ុន្តែនឹងអនុញ្ញាតឱ្យលើកជំនុំទៅថ្ងៃមុខកំណត់ ៨ ថ្ងៃក៏បាន តាមពាក្យសុំពីស្នាក្តីដែលចុងចំឡើយ ឬមនុស្សត្រូវចោទជាបទមជ្ឈិមពឹង ដើម្បីនឹងបានតបតនឹងសេចក្តីយល់ឃើញរបស់ដើមចោទ ឬដើមបណ្តឹងបទរដ្ឋប្បវេណីក្នុងរឿងក្តីមជ្ឈិម។

មាត្រា ៦៥.

ក្នុងរឿងក្តីមួយរឿងៗ ដែលស្នាក្តីទទួលពំនឹងគេស្នាក្តីនោះអាចធ្វើពាក្យមួយច្បាប់សុំឱ្យចុះរឿងក្តី នោះក្នុងបញ្ជីក្តីដែលត្រូវដាក់ជំនុំជំរះ ឬសុំឱ្យដាក់ក្តីនោះជំនុំជំរះក៏បាន ថ្វីបើពុំទាន់នាំមកដាក់មន្ទីរក្រឡាបញ្ជីប្រាក់ប្រដាប់ក្តី ដែលកូនក្តីខ្លួនត្រូវទទួលបន្ទុក។

ពាក្យសុំនេះ ដែលក្រឡាបញ្ជីត្រូវចុះហត្ថលេខាបានឃើញត្រូវបញ្ចូលក្នុងសំណុំរឿងក្តីនឹងចុះក្នុងបញ្ជីរាយលិខិត។

ត្រូវស្នាក្តីទទួលខុសត្រូវលើខ្លួនជួសកូនក្តីខ្លួននឹងជួសក្រឡាបញ្ជី អំពីបង់នឹងទារប្រាក់-ប្រដាប់ក្តីដែលនៅពុំទាន់ដាក់។

មាត្រា ៦៦.

ស្នាក្តីណាដែលយល់ឃើញថាមានគេជំទាស់ជំទែងដោយរំលោភលើការប្រើសិទ្ធិជួយការពារ អាចធ្វើពាក្យសាទុក្ខប្តឹងចាងហ្វាងសាលាដែលទទួលពិនិត្យរឿងក្តីនោះបាន។ បើពុំបានការតាមបណ្តឹងខ្លួនទេ ស្នាក្តីអាចចំឡងពាក្យសាទុក្ខនោះជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សំរេចសេចក្តី

ដោយបានឃើញសេចក្តីជំនុំនៃសាលាវិនិច្ឆ័យ រួមក្រុមដែលបានប្រជុំពិភាក្សាក្នុងបន្ទប់។ បើត្រូវការ នោះចាងហ្វាងសាលាវិនិច្ឆ័យនឹងចាត់ចៅក្រមម្នាក់ក្នុងសាលានេះឱ្យធ្វើអង្កេតជាមុនក៏បាន។

នឹងតវ៉ាពីសេចក្តីសំរេចនៃរដ្ឋមន្ត្រីពុំបានទេ។ សេចក្តីសំរេចនេះត្រូវឱ្យដំណឹងទៅស្មាក្តីនឹង ចៅក្រមសាមីខ្លួនឱ្យបានដឹង។

មាត្រា ៦៧.

ស្មាក្តីអាចជួយសង្គ្រោះទទេឥតយករង្វាន់ ឬដោយទាររង្វាន់ក៏បាន។

មាត្រា ៦៨.

ស្មាក្តីត្រូវជួយសង្គ្រោះទទេឥតយករង្វាន់ កាលណាបើខ្លួនត្រូវទទួលចាត់ជារាជការ ដើម្បី ជួយការពារចំពោះមុខសាលាឧក្រិដ្ឋ អស់ទាំងមនុស្សត្រូវចោទជាបទឧក្រិដ្ឋដែលពុំបានពឹងស្មាក្តី ណាទេ។

មាត្រា ៦៩.

ការចាត់ជារាជការនោះត្រូវចាងហ្វាងសម័យប្រជុំសាលាឧក្រិដ្ឋចាត់ចែងដោយដីកា។ដីកា នេះត្រូវក្រឡាបញ្ជីសាលាឧក្រិដ្ឋឱ្យដំណឹងទៅស្មាក្តីយ៉ាងតិចដប់ថ្ងៃមុនបើកវេលាជំនុំ។

តាំងពីថ្ងៃដែលឱ្យដំណឹង ស្មាក្តីអាចទៅមើលសំណុំរឿងក្តីនៅមន្ទីរក្រឡាបញ្ជីសាលាឧក្រិដ្ឋ នឹងទៅជួបនឹងកូនក្តីឯទីគុក ដោយមានអនុញ្ញាតពីចាងហ្វាងសាលានេះបាន។

មាត្រា ៧០.

មានតែស្មាក្តីដែលនៅឯទីដែលមានសាលាឧក្រិដ្ឋ ទើបអាចត្រូវចាត់ជារាជការបាន។ ដោយសុចរិតនោះត្រូវចាត់ម្តងម្នាក់។ ស្មាក្តីដែលត្រូវចាត់នឹងព្រមព្រៀងជាមួយនឹងស្មាក្តីឯទៀត ឱ្យទទួលការជួសខ្លួនបានតាមចិត្ត តែត្រូវឱ្យប្តឹងចាងហ្វាងសម័យប្រជុំសាលាឧក្រិដ្ឋផង។

ចាងហ្វាងសាលាឧក្រិដ្ឋត្រូវទាស់អំពីការស្មាក្តីសុំផ្លាស់ផ្តូគ្នា បើឃើញមានទាស់គ្នានូវ ប្រយោជន៍របស់គូក្តី ដែលស្មាក្តីតែមួយនាក់ជដែលជួយការពារ។

មាត្រា ៧១.

ប្រាក់រង្វាន់ស្មាក្តីអាចបង្គាប់ឱ្យបង់ជាមុនទាំងអស់ក្តីមួយភាគក្តី។ ប្រាក់រង្វាន់ដែលបាន ព្រមព្រៀងគ្នាត្រូវបង់ទាំងអស់តាំងពីថ្ងៃដែលរឿងក្តីបានកាត់សេចក្តីជាស្រេចឥតបញ្ជូនទៅសាលា ណាទៀត។

មាត្រា ៧២.

ប្រាក់រង្វាន់ស្មាក្តីត្រូវកូនក្តីបង់ខ្លួនឯងជាដរាប ទោះរឿងក្តីនោះ សាលាបានសេចក្តីដូចម្តេចក៏ដោយ ទោះគូក្តីម្ខាង សាលាបានកាត់សេចក្តីឱ្យបង់ប្រាក់ប្រដាប់ក្តីក៏ដោយ។

កូនក្តីច្រើននាក់ដែលបានពឹងស្មាក្តីតែមួយនាក់ត្រូវរួមគ្នា បង់ប្រាក់រង្វាន់ស្មាក្តីដែលបានព្រមព្រៀងគ្នាមកនោះ។

មាត្រា ៧៣.

ហាមមិនឱ្យស្មាក្តីប្តឹងតុលាការទារប្រាក់រង្វាន់ខ្លួនឡើយ។

មាត្រា ៧៤.

ប្រាក់រង្វាន់ស្មាក្តីត្រូវសំរេចចំនួនតាមស្មាក្តីនឹងកូនក្តីខ្លួនបានព្រមព្រៀងគ្នា។ ប្រាក់ទាំងប៉ុន្មានដែលស្មាក្តីបានទទួលពីកូនក្តីខ្លួន ត្រូវឱ្យមានចេញបង្កាន់ដៃទទួល ក្នុងបង្កាន់ដៃនេះត្រូវចុះឈ្មោះកូនក្តីនឹងចុះរឿងក្តី។

បង្កាន់ដៃនេះត្រូវចុះលេខ, ចុះថ្ងៃខែនឹងឆ្នាំ, ចុះហត្ថលេខាស្មាក្តី ត្រូវហែកពីគល់សៀវភៅបង្កាន់ដៃមួយក្បាល ដែលចាងហ្វាងសាលាវិនិច្ឆ័យបានចុះលេខរៀង,ចុះហត្ថលេខាសង្ខេបគ្រប់សន្លឹក នឹងចុះហត្ថលេខាលើសន្លឹកទី១ នឹងសន្លឹកចុងបំផុត ឬដែលចាងហ្វាងសាលានេះបានប្រគល់អំណាចឱ្យចៅក្រមណាធ្វើកិច្ចនេះ។

មាត្រា ៧៥.

ក្នុងប្រាក់រង្វាន់នេះត្រូវចំណាយក្នុងការការពារកូនក្តីគ្រប់ចំពូក។

មាត្រា ៧៦.

ហាមមិនឱ្យស្មាក្តីចុះសន្យានឹងកូនក្តីខ្លួនដោយព្រមព្រៀងគ្នាយកប្រាក់ដោយបង្ខំ ឬចុះសន្យាដោយលក្ខណៈមិនប្រាកដគឺ ដូចជាព្រមព្រៀងគ្នាថា បើកូនក្តីឈ្នះសេចក្តីស្មាក្តីត្រូវបានផលប្រយោជន៍ចំពោះខ្លួន ឬមិនចំពោះខ្លួនទៅលើក្តីនោះ។

កាលណាបើស្មាក្តីត្រូវទទួលចាត់ជារាជការ នោះមិនត្រូវទទួលយកប្រាក់រង្វាន់ទេ លុះតែខ្លួនប្រែត្រឡប់ទៅជាស្មាក្តីដែលកូនក្តីបានជ្រើសទើបទទួលប្រាក់រង្វាន់បាន។

ស្មាក្តីមិនត្រូវសុំខ្លួនធ្វើជាពំនឹងគេទេ គឺហាមផ្តាច់មិនឱ្យស្មាក្តីសរសេរសំបុត្រទៅមនុស្សត្រូវចោទជាបទមជ្ឈិម ឬជាបទឧក្រិដ្ឋ ដើម្បីសុំខ្លួនជួយការពារមនុស្សត្រូវចោទទាំងនោះជាដើម។

ស្មាក្តីមិនត្រូវឃោសនា ឬផ្សាយសេចក្តីប្រយោជន៍ឱ្យបានកូនក្តីចូលមកពឹងមន្ទីរធ្វើការខ្លួនឡើយ។ មួយទៀតហាមមិនឱ្យស្មាក្តីប្រើមនុស្សដោយប្រការណាក្តី ឱ្យដើររក ឬដើរប្រមូលកូនក្តីមកឱ្យខ្លួនដោយឱ្យប្រាក់ឈ្នួលឬប្រាក់រង្វាន់ក្តី ឥតឱ្យប្រាក់ឈ្នួល ឬប្រាក់រង្វាន់ក្តី។

ស្មាក្តីនឹងទទួល ឬប្រកែកមិនទទួលជួយក្តីណាមួយបានដោយសេរីក្រែងតែត្រូវទទួលចាត់ជារាជការ ឱ្យជួយទើបប្រកែកពុំបាន។

មាត្រា ៧៧.

ស្មាក្តីដែលគេបានរកទៅឃើញថា បានប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិដូចមានខាងលើនេះត្រូវមានទោសដូចសំដែងនូវមាត្រា ៣១១ ក្រមព្រហ្មទណ្ឌ ទុកដូចជាបានប្រព្រឹត្តខុសជាបទប្រើអំណោចយកប្រយោជន៍។

មាត្រា ៧៨.

បើបានទទួលពំនឹងកូនក្តីនៅពេលដែលកើតក្តីពីតំបូង តែបើក្តីនោះត្រូវសើរើទៅថ្ងៃមុខដោយមានគេប្តឹងទាស់ ឬបើក្តីនោះត្រូវរើជំនុំជំរះ ដោយគេបានតវ៉ាទៅសាលាជាន់ខ្ពស់ៗ បង្គាប់ឱ្យរើជំនុំជំរះ ស្មាក្តីត្រូវជួយការពារកូនក្តីខ្លួនដដែល ឥតឱ្យបន្ថែមប្រាក់រង្វាន់ឡើយ។

បើកាលណាក្រុមចោទ បានសម្រេចបង្គាប់ឱ្យបញ្ជូនរឿងក្តីណាមួយទៅឱ្យសាលាមជ្ឈិមជំនុំជំរះវិញ ដោយបានកែប្រែសេចក្តីចោទ នោះក៏ស្មាក្តីត្រូវប្រព្រឹត្តដូចខាងលើនេះដែរ។

មាត្រា ៧៩.

ស្មាក្តីដែលទទួលពំនឹងជួយក្តីគេ (ទោះក្តីបទរដ្ឋប្បវេណីក្តី បទអាជ្ញាក្តី) ត្រូវបង់ជាប្រយោជន៍ក្រឡាបញ្ជីសាលាដែលទទួលពិនិត្យរឿងក្តីនោះ ប្រាក់អាករពីររៀលក្នុងកិច្ចនីមួយៗ ដែលក្រឡាបញ្ជីត្រូវធ្វើបញ្ជូនទៅស្មាក្តីផ្ទាល់ខ្លួន តាមបញ្ញត្តិតាមច្បាប់នេះ (គឺសំបុត្រឱ្យតំណឹងពីពឹងស្មាក្តី, ដីកាកោះ, ដីកាឱ្យតំណឹង, ឬដីកាឯទៀតៗ) ។ ប្រាក់អាករនេះត្រូវបង់នៅវេលាដែលស្មាក្តី បានទទួលសំបុត្រ-ដីកាទាំងនោះ។

## កថាភាគ២
## ពីការណីយកិច្ចរបស់ស្មាក្តី

មាត្រា ៨០.

ស្មាក្តីត្រូវនៅក្រោមអំណាចរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងក្រោមការត្រួតត្រានៃចាងហ្វាងនឹងព្រះរាជបំរើសាលាវិនិច្ឆ័យ។

សំណុំសាវតារខ្លួនស្មាក្តី ត្រូវតំកល់នឹងរក្សាទុកនៅមន្ទីរក្រឡាបញ្ជីសាលាវិន័ច្ឆ័យ។

មាត្រា ៨១.

ស្មាក្តីត្រូវប្រព្រឹត្តត្រឹមត្រូវស្មោះត្រង់នឹងសុចរិតជាទីបំផុត ដើម្បីតំកើងកិត្តិយសរបស់ពួកក្រុមខ្លួន។

មាត្រា ៨២.

នៅវេលាជំនុំជំរះក្តី សំលៀកបំពាក់ស្មាក្តីដូចមានសំរេចក្នុងព្រះរាជប្រកាសលេខ ១០២ ចុះថ្ងៃ៣១ ឧសភា ១៩៣៩ ស្រាប់។

មាត្រា ៨៣.

កាលណាប្រើត្រូវដផែក ស្មាក្តីត្រូវឈរ ហើយត្រូវក្រោកឈរនៅវេលាដែលតុលាការស្រដីកាត់សេចក្តី ទោះក្នុងសាលាណាក្តី។ ស្មាក្តីអាចនៅពាក់មួកបាន តែបើកាលណាអានសេចក្តីយល់ឃើញ ឬអានលិខិតក្តី នោះស្មាក្តីត្រូវដោះមួកអាន។

មាត្រា ៨៤.

ស្មាក្តីត្រូវនិយាយទៅកាន់តុលាការសាលាតំបូងឬសាលាជាន់ខ្ពស់ ដោយពាក្យគប្បីមិនត្រូវពោលពាក្យជេរប្រមាទ នឹងជាពាក្យមាក់ងាយដល់ឯកជនឡើយ ទោះអ្នកនោះ ជាអ្នកក្តី ឬអ្នកក្រៅក្តី ដែលខ្លួនជួយក៏ដោយ។

ក្នុងសេចក្តីសរសេររបស់ស្មាក្តី ក៏ត្រូវហាមដូចគ្នាដែរ។

មាត្រា ៨៥.

ស្មាក្តី ត្រូវលាក់បិទបាំងការមុខក្រសួងខ្លួន កុំបីបរិហារការនេះឱ្យកូនក្តីខ្លួន នឹងគូក្តីម្ខាងដឹងឡើយ។

មាត្រា ៨៦.

សេចក្ដីលាក់បិទបាំងការមុខក្រសួងអាចលើកបាន លុះតែមានសេចក្ដីសំរេចពិសេសដែលបានចេញក្នុងរឿងក្ដីឧក្រិដ្ឋ ឬមជ្ឈិម។ បើដូច្នេះ ស្នាក្ដីត្រូវឆ្លើយក្នុងសម្បថឱ្យការពីរឿងដែលខ្លួនបានដឹងក្នុងខណៈកំពុងធ្វើការមុខក្រសួងខ្លួន។ ចំឡើយនេះត្រូវយកក្នុងបន្ទប់ដែលបិទទ្វារបង្អួចជិត។

មាត្រា ៨៧.

ស្នាក្ដីមិនអាចទិញ ដោយដេញថ្លៃនូវវត្ថុទាំងអស់ ឬខ្លះដែលលក់ក្នុងក្រឡាក្រមសាលាយកជាប្រយោជន៍ខ្លួនបានឡើយ ទោះទិញចំពោះខ្លួនឯងក្ដី មិនចំពោះខ្លួនឯងក្ដី។

មួយទៀត ស្នាក្ដីមិនអាចទិញចំពោះខ្លួនឯង ឬមិនចំពោះខ្លួនឯងបានឡើយ នូវសិទ្ធិទទួលមរដក ឬសិទ្ធិដែលនៅក្នុងវិវាទ។

## កថាភាគ ៣
## អំពីទណ្ឌកម្ម

មាត្រា ៨៨.

ស្នាក្ដី ត្រូវមុខក្រសួងសាលាឧទ្ធរណ៍ជំនុំជំរះកាត់សេចក្ដីអំពីបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងឱកាសធ្វើកិច្ចការមុខក្រសួងខ្លួនក្ដី ក្រៅពីឱកាសធ្វើកិច្ចការនេះក្ដី។

ត្រូវព្រះរាជបំរើនៃសាលានេះ ជាអ្នកដាក់ខ្លួនស្នាក្ដីឱ្យជំនុះជំរះក្រោយដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានព្រមព្រៀងផង។

មាត្រា ៨៩.

អាចសម្រេចសេចក្ដីដូចតទៅនេះ បានទៅលើស្នាក្ដីដែលល្មើសនឹងការប្រព្រឹត្តកោតខ្លាចតុលាការដោយវាចា ដោយអាការដៃជើង ឬដោយលិខិតៈ

១. ក្រើនឱ្យចូលរបៀប

២. ដកសេចក្ដីអនុញ្ញាតឱ្យនិយាយ

៣. បង្គាប់ឱ្យប្រែសំដី

៤. បណ្ដេញចេញ

មាត្រា ៩០.

អស់ទាំងទណ្ឌកម្មដូចតទៅនេះ៖

១. បន្ទោសប្រដៅ

២. បញ្ឈប់

៣. លុបឈ្មោះចោល

មាត្រា ៩១.

សេចក្តីក្រើនឱ្យចូលរបៀប, ដកសេចក្តីអនុញ្ញាតឱ្យនិយាយបង្គាប់ឱ្យប្រែសំដី នឹងបណ្តេញចេញ ត្រូវចាងហ្វាង ឬចៅក្រមសំរេចគឺចាងហ្វាង ឬចៅក្រម ដែលជាអ្នករក្សាការពារសេចក្តីស្ងប់ក្នុងទីជំនុំជំរះ ឬក្នុងបន្ទប់សាលា នៅវេលាដែលពិនិត្យឃើញថាមានប្រព្រឹត្តខុសក្នុងទីទាំងនោះ។

បើស្មាក្តីរឹងទទឹងមិនព្រមទទួលតាម ទើបត្រូវតែងសេចក្តីកត់ហេតុពីបានក្រើនឱ្យចូលរបៀប ដកសេចក្តីអនុញ្ញាតឱ្យនិយាយនឹងបង្គាប់ឱ្យប្រែសំដី។

មាត្រា ៩២.

កាលណាបើបានសំរេចបណ្តេញចេញត្រូវតែងសេចក្តីកត់ហេតុភ្លាម។

មាត្រា ៩៣.

អស់ទាំងសេចក្តីកត់ហេតុត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រញាប់ ដើម្បីនឹងធ្វើទណ្ឌកម្មបើត្រូវការធ្វើ។

មាត្រា ៩៤.

ស្មាក្តីណាដែលគេបានសំរេចបណ្តេញចេញនោះ ត្រូវនៅគ្រប់គ្រងមន្ទីរធ្វើការរបស់ខ្លួនតទៅ តែបើនឹងចូលខ្លួនទៅទីជំនុំជំរះក្តី ហើយនឹងចូលទៅមន្ទីរចៅក្រមតទៅទៀតបាន លុះណាតែមានសេចក្តីសំរេចលើខ្លួនពីរដ្ឋមន្ត្រីមករួចហើយ។

មាត្រា ៩៥.

សេចក្តីបន្ទោសប្រដៅត្រូវធ្វើដោយសេចក្តីសំរេចពីរដ្ឋមន្ត្រី តាមសេចក្តីដែលសាលាវិនិច្ឆ័យរួមក្រុមបានពិភាក្សាជូនយោបល់ក្រោយ ដែលបានបើកឱ្យស្មាក្តីជូនពាក្យដោះសារនឹងមធ្យោបាយ

ការពាររបស់ខ្លួនចំពោះសាលានេះ។ សេចក្តីសំរេចនេះ ត្រូវធ្វើជាតំណឹងទៅឱ្យស្មាក្តី នឹងទៅចាងហ្វាងសាលាដែលបានពិនិត្យការណ៍នេះ។

សេចក្តីសំរេចនេះ ត្រូវចំឡងមួយច្បាប់ទុកក្នុងសំណុំសារតារខ្លួនស្មាក្តី។

មាត្រា ៩៦.

ទណ្ឌកម្មបញ្ឈប់ ត្រូវសំរេចដូចលក្ខណប្បញ្ញត្តិធ្វើទណ្ឌកម្មបន្ទោសប្រដៅ។

សេចក្តីបញ្ឈប់នេះ ត្រូវសំរេចកំណត់មិនឱ្យតិចជាងបីខែ នឹងមិនឱ្យលើសពីមួយឆ្នាំ។

ទណ្ឌកម្មនេះ ត្រូវគិតតាំងពីថ្ងៃដែលមន្ទីរក្រឡាបញ្ជីសាលាវិនិច្ឆ័យបានឱ្យតំណឹងទៅស្មាក្តីតាមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំ។

ក្នុងរវាងកំណត់ទណ្ឌកម្មនេះ ស្មាក្តីមិនអាចនឹងធ្វើការមុខក្រសួងខ្លួនបានឡើយ គឺត្រូវហាមឃាត់មិនឱ្យទទួលពំនឹងជួយក្តីថ្មី ឬមិនឱ្យជួយក្តីឡើងសាលាឧទ្ធរណ៍ ឬឡើងសាលាវិនិច្ឆ័យ ហើយមិនអាចនឹងត្រូវចាត់ជារាជការ ជាដើម។

មាត្រា ៩៧.

ទណ្ឌកម្មលុបឈ្មោះចោល ត្រូវសំរេចដូចលក្ខណប្បញ្ញត្តិធ្វើទណ្ឌកម្ម បន្ទោសប្រដៅ នឹងទណ្ឌកម្មបញ្ឈប់។

ទណ្ឌកម្មលុបឈ្មោះចោល នាំឱ្យដកងារស្មាក្តីជាស្រេចតទៅ។ ស្មាក្តីមិនអាចនឹងធ្វើការមុខក្រសួងស្មាក្តីបានឡើយ គិតតាំងពីថ្ងៃដែលមន្ទីរក្រឡាបញ្ជីសាលាវិនិច្ឆ័យ បានឱ្យតំណឹងទៅខ្លួនតាមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំ។

មាត្រា ៩៨.

ស្មាក្តីទាំងឡាយ ដែលត្រូវទណ្ឌកម្មបញ្ឈប់ ឬលុបឈ្មោះចោល នោះក្នុងកំណត់ដប់ថ្ងៃគិតតពីថ្ងៃដែលបានទទួលតំណឹងពីដាក់ទណ្ឌកម្មទាំងនេះ ត្រូវនាំសំណុំរឿងក្តីដែលគេបានពឹងខ្លួនឱ្យជួយទៅតំកល់នៅមន្ទីរក្រឡាបញ្ជីសាលា ដែលត្រូវជំនុំជំរះក្តីទាំងនោះ។

ត្រូវចាងហ្វាងសាលាវិនិច្ឆ័យ ធ្វើដីកាបង្គាប់ឱ្យចែករឿងក្តីទាំងនោះទៅមន្ទីរធ្វើការស្មាក្តីឯទៀត។ អំពីប្រាក់រង្វាន់ស្មាក្តី បើគ្មានសេចក្តីព្រមព្រៀងគ្នាដូចម្តេចទេ ត្រូវចាងហ្វាងនេះ សំរេចចែក។

មាត្រា ៩៩.

ទណ្ឌកម្មលុបឈ្មោះចោលក្តី បញ្ឈប់ក្តី ត្រូវឱ្យតំណឹងដល់សាលាជំនុំជំរះក្តីទាំងឡាយ ដោយសារាចរពីរដ្ឋមន្ត្រី។

ចាងហ្វាងសាលាទាំងនេះត្រូវដាក់កំហិតកុំឱ្យក្រឡាបញ្ជីទទួល នឹងចុះបញ្ជីក្តីទាំងប៉ុន្មាន ដែលស្មាក្តីត្រូវទណ្ឌកម្មទាំងនោះទទួលពំនឹងជួយ។

មួយទៀតចាងហ្វាងសាលាទាំងនេះ ត្រូវត្រួតត្រាមើលឱ្យលុបពីតារ៉ាងស្មាក្តី នាមស្មាក្តី ដែលត្រូវទណ្ឌកម្មលុបឈ្មោះចោល។

មាត្រា ១០០.

ទោសឧក្រិដ្ឋ ឬមជ្ឈិមដែលបានកាត់ បណ្តាលឱ្យត្រូវទណ្ឌកម្មលុបឈ្មោះចោលឯងៗ។ តែបើគ្រាន់តែមានទោសពិន័យដែលត្រូវបានបង្អង់មិនទាន់ឱ្យសំរេច នោះរដ្ឋមន្ត្រីអាចសំរេចដាក់ទណ្ឌកម្មបញ្ឈប់ ជាជំនួសទណ្ឌកម្មលុបឈ្មោះចោលបាន ដោយបានឃើញយោបល់ដែលសាលាវិនិច្ឆ័យបានពិភាក្សាជូនមក។

មាត្រា ១០១.

ការដាក់ខ្លួនស្មាក្តីឱ្យតុលាការជំនុំជំរះ អំពីបទឧក្រិដ្ឋ ឬបទមជ្ឈិមបណ្តាលឱ្យបញ្ឈប់ឯងៗ។

មាត្រា ១០២.

ការប្រព្រឹត្តឱ្យសៅហ្មងដល់កិត្តិយស នឹងដល់សេចក្តីសុចរិត ដែលមិនចូលជាបទល្មើស នឹងក្រមព្រហ្មទណ្ឌ អាចបណ្តាលឱ្យសំរេចទណ្ឌកម្មបន្ទោសប្រដៅ បញ្ឈប់ ឬលុបឈ្មោះចោលបាន។

មួយទៀត ទណ្ឌកម្មទាំងនេះ អាចត្រូវបណ្តាលឱ្យសំរេចធ្វើបានដែរ ដោយមានជាប់ជំរះក្នុងតុលាការ ពីរឿងជំពាក់ប្រាក់គេនឹងដោយត្រូវរិបអូស ឬត្រូវបង្ខំខ្លួន ក្នុងឱកាសដែលគេបានប្តឹងពីស្មាក្តីដល់សាលាមុខក្រសួង។

មាត្រា ១០៣.

អស់ទាំងប្រាក់ ដែលបានកាត់សេចក្តីឱ្យស្មាក្តីសងគេ អាចកាត់យកលើប្រាក់ធានារបស់ស្មាក្តីបាន ដោយមានដីកាបង្គាប់ពីចាងហ្វាងសាលាវិនិច្ឆ័យ។

ប្រាក់ធានានេះ ក៏ធានាសងប្រាក់អាករដែលស្មាក្តីអាចចំពាក់ក្រឡាបញ្ជី។

មាត្រា ១០៤.

ព្រះរាជក្រមលេខ ៣០២ ន.ស. ចុះថ្ងៃ៨ ខែមិនា គ.ស.១៩៤៧ ដែលស្ដីអំពីស្មាក្ដីបារាំង ត្រូវឱ្យនៅអនុវត្តន៍បានជាដរាប តែត្រូវកែប្រែដូចមានក្នុងព្រះរាជក្រមនេះ។

មាត្រា ១០៥.

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងមានប្រកាសសំរេចចំនួនមន្ទីរធ្វើការស្មាក្ដី ក្នុងព្រះរាជអាណាចក្រ ទៅថ្ងៃមុខ។

មាត្រា ១០៦.

សេចក្ដីបញ្ញត្តិមុនៗ ទាំងប៉ុន្មានដែលផ្ទុយនឹងសេចក្ដីបញ្ញត្តិព្រះរាជក្រមនេះ ត្រូវទុកជាមោឃៈ។

# បទបញ្ជាផ្ទៃក្នុង
# នៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ១៩៩៥

## កំណត់សំគាល់

ច្បាប់ដែលអត្ថបទនេះរំលឹកឡើងនោះ គឺច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ន.ស ០៨-៩៥-០៦ ចុះថ្ងៃទី២២/៨/៩៥។

# ជំពូកទី១

# វិធាន វិជ្ជាជីវៈមេធាវី

## ប្រការ ១. វិធាន វិជ្ជាជីវៈមេធាវី

មេធាវីដែលត្រូវបានចុះឈ្មោះ ក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រតិបត្តិ និងគោរពគ្រប់វិធានវិជ្ជាជីវៈដែលកំណត់ដោយ «ក្រមសីលធម៌នៃមេធាវីដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា»។

# ជំពូកទី២

# មហាសន្និបាត គណៈមេធាវី

## ប្រការ ២. ការរៀបចំ មហាសន្និបាតគណៈមេធាវី

មហាសន្និបាត ប្រមូលផ្តុំមេធាវីទាំងអស់ដែលត្រូវបានចុះឈ្មោះ ក្នុងបញ្ជីគណៈមេធាវី និងចុះឈ្មោះក្នុងបញ្ជីមេធាវីកម្មសិក្សា។

មហាសន្និបាតនេះ មានគោលដៅ ជូនពត៌មាន ឬពិគ្រោះយោបល់។ មហាសន្និបាត អាចលើកសំណូមពរ ឬ លើកញត្តិ ដែលក្រុមប្រឹក្សាគណៈមេធាវី ត្រូវសំរេចក្នុងចិរៈវេលា ៣ ខែ។

មានតែមេធាវីដែលមានសិទ្ធិបោះឆ្នោត ទើបអាចចូលរួមក្នុងការពិភាក្សារបស់មហាសន្និបាត។

ក្រៅពីការកោះប្រជុំសំរាប់ធ្វើការបោះឆ្នោត ការកោះប្រជុំមហាសន្និបាតត្រូវធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង តាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ។

លើកលែងតែមានកិច្ចការប្រញាប់ របៀបវារៈនេះត្រូវឱ្យសហភាតាបានដឹងមួយខែមុនយ៉ាងតិច តាមគ្រប់មធ្យោបាយសមស្រប។

មេធាវីមួយរូបៗ អាចសុំចុះបញ្ហារបស់ខ្លួនក្នុងរបៀបវារៈបាន ដោយធ្វើពាក្យសុំផ្ញើទៅក្រុមប្រឹក្សាគណៈមេធាវី ១៥ ថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំ តាមរយៈនៃលិខិតអនុសិដ្ឋ ដែលមានចុះថាបានទទួល ឬ តាមលិខិត ដាក់ជូនអគ្គលេខាធិការដ្ឋាន ដោយមានបង្កាន់ដៃទទួល។

មហាសន្និបាត ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានគណៈមេធាវី។

បើប្រសិនជាត្រូវធ្វើការបោះឆ្នោត ត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងករណីជ្រើសរើសប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី។

ការបោះឆ្នោត តាមព្រឹតិបត្តិសំងាត់ អាចសំរេចដោយប្រធានគណៈមេធាវី ឬ ដោយសំណើរបស់សមាជិក ដែលមានចំនួន ១/៤ នៃសមាជិកវត្តមាន។

## ប្រការ ៣ . ការរៀបចំការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសសមាជិក ក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើឡើង ៣ ឆ្នាំម្តង។ ការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវី ត្រូវធ្វើឡើង ២ ឆ្នាំម្តង។

ការបោះឆ្នោតប្រព្រឹត្តទៅនៅថ្ងៃទី ១៦ តុលា នៃឆ្នាំដែលត្រូវបោះឆ្នោត ក្នុងសម័យប្រជុំជាសាធារណៈ។

មេធាវីអ្នកបោះឆ្នោត ត្រូវកោះអញ្ជើញ មួយខែ មុនថ្ងៃបោះឆ្នោត តាមគ្រប់មធ្យោបាយសមស្រប (លិខិតមានលក្ខណៈជាសារាចរ ផ្សាយតាមវិទ្យុ ទូរទស្សន៍ សារពត៌មាន និងប្រកាសបិទផ្សាយនៅមន្ទីរគណៈមេធាវី )។

បេក្ខភាព ត្រូវធ្វើឡើងជាលាយលក្ខ័អក្សរ ដាក់ជូនទៅប្រធានគណៈមេធាវី យ៉ាងតិច ១ ខែ មុនការបោះឆ្នោត បើមិនដូច្នោះ និងមិនត្រូវបានទទួលឡើយ។ ឈ្មោះនៃបេក្ខជនទាំងអស់ ត្រូវផ្សព្វផ្សាយតាមគ្រប់វិធី សមស្របហើយត្រូវបិទនៅការិយាល័យបោះឆ្នោត។

ការបោះឆ្នោត និងអាចប្រព្រឹត្តទៅ លុះត្រាវត្តមានសមាជិកនៃគណៈមេធាវី មានចំនួនលើសពីពាក់កណ្តាល។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់មេធាវីដែលមានវ័យចំណាស់ជាងគេ។

ប្រធានគណៈមេធាវី ឬ តំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬ នៅពេលរាប់សន្លឹកឆ្នោត។

មេធាវី នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត ត្រូវបង្ហាញប័ណ្ណវិជ្ជាជីវៈដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

ការបោះឆ្នោត តាមរយៈការប្រគល់សិទ្ធិ អាចទទួលយកបាន។ មេធាវីម្នាក់ៗ អាចទទួល ការប្រគល់សិទ្ធិបានតែមួយប៉ុណ្ណោះ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាស សលាត ឬ មោឃៈ ត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកភាគច្រើនឡើយ ។

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោត ហើយលទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខ័អក្សរ ទៅលោកអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍។ ក្រុមប្រឹក្សាគណៈមេធាវី ត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់។

## ជំពូកទី ៣

## ក្រុមប្រឹក្សា គណៈមេធាវី

### ប្រការ ៤. ការប្រជុំនិងការពិភាក្សា នៃក្រុមប្រឹក្សាគណៈមេធាវី

ក្រុមប្រឹក្សាគណៈមេធាវី រួមប្រជុំតាមការផ្តើមគំនិតរបស់ប្រធានគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ។

ការប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី គឺជាការប្រជុំមិនសាធារណៈ លើកលែងតែក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិពាក់ព័ន្ធផ្ទាល់ និងនីតិវិធីដាក់វិន័យ។

ក្រុមប្រឹក្សាគណៈមេធាវី និងអាចបើកប្រជុំបាន ប្រសិនបើមានវត្តមានសមាជិកជាងពាក់កណ្តាល។ ការសំរេចរបស់ក្រុមប្រឹក្សា ផ្អែកលើសំឡេងបញ្ចេញមតិភាគច្រើន។ ប្រធានគណៈមេធាវី ត្រូវបោះឆ្នោត ជាមួយសមាជិកក្រុមប្រឹក្សាគណៈមេធាវី តែសំឡេងរបស់ប្រធាន ពុំមានឧត្តមានុភាពឡើយ។

កំណត់ហេតុប្រជុំ ត្រូវធ្វើឡើងដោយលេខាធិការរបស់ក្រុមប្រឹក្សា។ កំណត់ហេតុនេះ និងទុកជាស្ថាពរបាន លុះត្រាមានការយល់ព្រមពីក្រុមប្រឹក្សា។

សមាជិកគ្រប់រូប នៃគណៈមេធាវីអាចសុំមើល និងដឹងបាននូវកំណត់ហេតុប្រជុំនោះនៅលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សា។ សមាជិកម្នាក់ៗ អាចសុំយកទៅថតចម្លងបាន លើកលែងតែមានការជំទាស់ពីប្រធានគណៈមេធាវី។

### ប្រការ ៤. ការចាត់តាំង ដោយក្រុមប្រឹក្សាគណៈមេធាវី

គ្រប់ការប្រជុំដំបូង របស់គណៈមេធាវីជាប់ឆ្នោតថ្មី គណៈមេធាវីនេះ ត្រូវចាត់តាំងអគ្គលេខាធិការម្នាក់ និងអគ្គលេខាធិការរងម្នាក់ អគ្គហិរញ្ញិកម្នាក់ និងអគ្គហិរញ្ញិករងម្នាក់។ អ្នកទាំងនេះ ទទួលសិទ្ធិអំណាចពីប្រធានគណៈមេធាវី ក្នុងការចុះហត្ថលេខា ចំពោះមុខធនាគារបាន។

## ជំពូកទី ៤

## ជំនួយសង្គ្រោះ តាមផ្លូវតុលាការ

### ប្រការ ៦. ការចាត់តាំងមេធាវីស្ម័គ្រចិត្ត ដោយប្រធានគណៈមេធាវី

ស្របតាមមាត្រា២៩ នៃច្បាប់បេឡាពិសេសមួយបានត្រូវបើកឡើង និងត្រៀមបំរុងសំរាប់ជួយសង្គ្រោះតាមផ្លូវតុលាការដល់ជនក្រីក្រ។

ជនដែលត្រូវបានទទួលនូវជំនួយសង្គ្រោះ តាមផ្លូវតុលាការ ត្រូវធ្វើពាក្យសុំជំនួយ ជូនទៅប្រធានគណៈមេធាវី ( គំរូលេខ១ ) ដោយមានចុះទិដ្ឋាការពីលើពាក្យនោះ អំពីភាពខ្វះខាតធនធានរបស់ជននេះពីសំណាក់ប្រធានតុលាការ ឬក្រឡាបញ្ជីនាយក ជាមុន។

ក្នុងកំឡុងពេល១៥ថ្ងៃយ៉ាងយូរបំផុត ប្រធានគណៈមេធាវី ត្រូវចាត់តាំងសហភាតារបស់ខ្លួនម្នាក់ ដែលត្រូវបំពេញ ដោយស្ម័គ្រចិត្ត នូវបទអន្តរាគម ក្នុងក្របខ័ណ្ឌនៃជំនួយសង្គ្រោះតាមផ្លូវតុលាការ។

មេធាវីស្ម័គ្រចិត្ត ត្រូវបង្ហាញខ្លួនចំពោះមុខប្រធានគណៈមេធាវី។

ក្រុមប្រឹក្សាគណៈមេធាវី ត្រូវកំណត់ឱ្យបានច្បាស់ អំពីចំនួនមេធាវីចាំបាច់ សំរាប់ធានានូវការប្រព្រឹត្តទៅឱ្យបានល្អ នៃជំនួយសង្គ្រោះតាមតាមផ្លូវតុលាការនេះ។

### ប្រការ ៧. អំពីប្រាក់បំណាច់ផ្ដាច់ឱ្យមេធាវីស្ម័គ្រចិត្ត

មេធាវីស្ម័គ្រចិត្ត ដែលមកធ្វើការក្នុងរឿងជំនួយសង្គ្រោះតាមផ្លូវតុលាការ នឹងត្រូវបានទទួលប្រាក់បំណាច់ផ្ដាច់ប្រចាំខែ (គិតចូលទាំងសោហ៊ុយផ្សេងៗទាំងឡាយផង) តាមចំនួនដែលនិងត្រូវកំណត់រៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាគណៈមេធាវី។

មេធាវីចាត់តាំង ត្រូវទទួលបន្ទុកលើសំណុំរឿង ដែលខ្លួនគេត្រូវចាត់តាំងឱ្យបំពេញ។

ចំនួនទឹកប្រាក់នៃប្រាក់បំណាច់ផ្ដាច់នេះ មិនបានគិតទៅតាមចំនួនសំណុំរឿងដែលត្រូវធ្វើឡើយ។

ដើម្បីបើកប្រាក់បំណាច់ដែលខ្លួនត្រូវបាន មេធាវីសាមីត្រូវប្រគល់របាយការណ៍ការងារនៅរៀងរាល់ថ្ងៃទី១៥ នៃខែនីមួយៗ (គំរូលេខ២) ដែលបញ្ជាក់អំពីស្ថានភាពជឿនលឿន នៃសំណុំរឿងដែលបានដាក់ចុះឱ្យបំពេញ។

ប្រសិនបើមេធាវីស្ម័គ្រចិត្ត ពុំបានបំពេញកិច្ចការចាំបាច់ តាមដំណើរនីតិវិធីដែលត្រូវប្រព្រឹត្តទៅទេ ប្រធានគណៈមេធាវីអាចនឹងដកឈ្មោះចេញពីបញ្ជីមេធាវីស្ម័គ្រចិត្ត ហើយអាចនឹងចោទប្រកាន់ខាងបទវិន័យដល់មេធាវីនោះផង។

ក្នុងករណីនេះមេធាវី ត្រូវសងប្រាក់ដែលខ្លួនបានបើកហើយ ដោយមិនត្រឹមត្រូវនោះមកវិញ។

## ជំពូកទី ៤

## មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការចូលបំពេញវិជ្ជាជីវៈ

### ប្រការ ៨. មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី

ទម្រាំនឹងមានអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ការបណ្ដុះបណ្ដាលមេធាវីត្រូវប្រព្រឹត្តទៅតាមបទបញ្ញានៃមាត្រា ៨០,៨១ និង ៨២ នៃច្បាប់ ប៉ុន្តែកម្មវិធីនិងបែបបទនៃវគ្គបណ្ដុះបណ្ដាល ព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡងដើម្បីត្រួតពិនិត្យលទ្ធផលនៃការបណ្ដុះបណ្ដាល ត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវីមិនមែនដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទៀតឡើយ។

ក្រុមប្រឹក្សាគណៈមេធាវី កំណត់ជាមុននូវចំនួនអតិបរមាមេធាវី ដែលត្រូវជ្រើសរើសក្នុងមួយវគ្គៗ។

### ប្រការ ៩. គណៈមេប្រយោគ

ប្រធានគណៈមេធាវី បង្កើតគណៈមេប្រយោគមួយ ដែលមានខ្លួនឯង ឬ តំណាងរបស់ខ្លួនជា ប្រធាន និងសមាជិក ៣ នាក់ គឺ៖

- មេធាវីម្នាក់ ដែលចាត់តាំងឡើងដោយប្រធានគណៈមេធាវី
- គ្រូបង្ហាត់ច្បាប់ម្នាក់ ចាត់តាំងឡើងដោយព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ភ្នំពេញ។

- ចៅក្រមមួយរូប ចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ គណៈមេប្រយោគ អាចអញ្ជើញមេប្រយោគជំនាញ ដើម្បីកែវិញ្ញាសារសរសេរបាន។

## ជំពូកទី ៦
## ការរៀបចំកម្មសិក្សា

### ប្រការ ១០. ការរៀបចំកម្មសិក្សា

កម្មសិក្សា មានថិរៈវេលា ១ ឆ្នាំ ហើយអាចពន្យាពេលបាន ១ឆ្នាំទៀត តាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

កម្មសិក្សាត្រូវគ្រោបទាំងសកម្មភាពបណ្តុះណ្តាលបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី ដែលអាចផ្ទេរឱ្យទៅ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផង និងការសហការពិតប្រាកដ ក្នុងការិយាល័យមេធាវីណាមួយផង។

កម្មសិក្សា អាចធ្វើផ្នែកខ្លះនៅក្នុងការិយាល័យបរទេសណាមួយក៏បាន។

### ប្រការ ១១. គ្រូកម្មសិក្សា និងកម្មសិក្សាការី

គ្រូកម្មសិក្សា និងកម្មសិក្សាការី ចុះហត្ថលេខាលើកិច្ចសន្យាសហការ (គំរូលេខ៣) ដែលត្រូវដាក់ជូនទៅក្រុមប្រឹក្សាគណៈមេធាវី ស្របតាមមាត្រា ៥២ នៃច្បាប់។

គ្រូកម្មសិក្សា មានកាតព្វកិច្ចចូលរួមដោយសកម្ម ចំពោះការអប់រំវិជ្ជាជីវៈ និងអប់រំក្រមសីលធម៌ ដល់កម្មសិក្សាការី។

បែបបទនៃកម្មសិក្សាកំណត់បានដោយសេរី រវាងគ្រូកម្មសិក្សា និងកម្មសិក្សាការី។

ក្រុមប្រឹក្សាគណៈមេធាវី អាចដកការយល់ព្រមកម្មសិក្សា ពីគ្រូកម្មសិក្សាបាន ប្រសិនបើការចាំបាច់នៃការបណ្តុះបណ្តាល មិនត្រូវបានបំពេញដោយប្រក្រតី។

### ប្រការ ១២. ការព្យួរ និងការបញ្ចប់កម្មសិក្សា

ការព្យួរកម្មសិក្សា ត្រូវសំរេចអនុញ្ញាតពីប្រធានគណៈមេធាវី។

ក្នុងករណី ដែលការព្យួរកម្មសិក្សាត្រូវបានពន្យារជាថ្មី, ប្រធានគណៈមេធាវី អាចកោះអញ្ជើញមេធាវីទៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី ដើម្បីលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា។

ការលុបឈ្មោះចេញ ក៏អាចសំរេចបានដែរ លើមេធាវីដែលមិនគោរពកិច្ចសន្យាកម្មសិក្សា ហើយដែលមិនអាចបញ្ជាក់បានត្រឹមត្រូវ នូវកិច្ចសហការពិតប្រាកដ។

# ជំពូកទី៧
# ការគ្រប់គ្រងមូលនិធិ និងប្រាក់ដំកល់ទុក

## ប្រការ ១៣. បេឡាទូទាត់របស់គណៈមេធាវី

សមស្របតាមមាត្រា ៧០ និង ៧១ នៃច្បាប់, មូលនិធិបានមកពីការដំកល់ទុកធានា បានមកពីប្រាក់ធានាសំរាប់សង គូភាគីឈ្នះក្តី ឬ បានមកពីប្រាក់តំកល់ទុកត្រូវមេធាវីបង់ចូលទៅគណនីយពិសេស ដែលបើកឡើងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលមានឈ្មោះថា «បេឡាទូទាត់គណៈមេធាវី»។

## ប្រការ ១៤. ការប្រព្រឹត្តទៅនៃបេឡា

មេធាវីត្រូវតំកល់មូលនិធិដែលបានទទួលដូចខាងលើ (ជាមូលប្បទានប័ត្រ, ការបង្វែរប្រាក់ ឬជាក្រដាសប្រាក់ ) នៅក្នុងបេឡាទូទាត់គណៈមេធាវី។

ក្រៅពីឈ្មោះផ្ទាល់របស់ខ្លួនចេញ មេធាវីត្រូវដាក់ឈ្មោះអតិថិជន និងរឿងក្តីដែលពាក់ព័ន្ធ (គំរូលេខ ៤)។

បង្កាន់ដៃមួយដែលមានពត៌មានដូចគ្នានេះ ត្រូវចេញឱ្យមេធាវីនោះ ដោយប្រធានគណៈមេធាវី (គំរូលេខ ៥)។

តាមការសុំជាលាយលក្ខ័អក្សរ (គំរូលេខ ៦) របស់មេធាវី, បេឡាត្រូវបើកមូលនិធិដែលបានរក្សាទុកក្នុងក្របខ័ណ្ឌនៃរឿងក្តី ឱ្យទៅជនជាអត្ថគាហក។

សំរង់បញ្ជីទឹកប្រាក់នៃមូលនិធិដែលនៅសល់ក្នុងរឿងក្តី ត្រូវប្រគល់ទៅឱ្យមេធាវី។

សមតុល្យនៃប្រាក់ក្នុងរឿងក្តីនីមួយៗ មិនត្រូវអាចជាសមតុល្យឥណាយឹកទេ។

## ប្រការ ១៥. ការកាត់យកប្រាក់កំរៃមេធាវី

មេធាវីនិងអាចកាត់យកមុនបាន នូវប្រាក់កំរៃពីមូលនិធិដំកល់ទុកដោយអតិថិជន តែក្នុងលក្ខខ័ណ្ឌ ដែលមានការអនុញ្ញាតិជាលាយលក្ខ័អក្សរពី អតិថិជននោះ ដោយបញ្ជាក់ច្បាស់អំពីឈ្មោះនៃរឿងក្តីនិងចំនួនទឹកប្រាក់ដែលត្រូវកាត់យកមុន។

សេចក្តីអនុញ្ញតិនេះ មេធាវីត្រូវបញ្ជូនដោយខានមិនបាន ទៅបេឡាទូទាត់របស់គណៈមេធាវី នៅពេលដែលធ្វើពាក្យសុំបើកកាត់ប្រាក់ពីមូលនិធិ។

### ប្រការ ១៦ . ការត្រួតពិនិត្យរបស់ប្រធានគណៈមេធាវី

ប្រធានគណៈមេធាវី អាចសុំឱ្យមេធាវីបញ្ជាក់ហេតុផលទាំងឡាយ ដែលទាក់ទងនឹងប្រភពដើម និង អត្តគហាក នៃមូលនិធិដំកល់ទុក។

ប្រធានគណៈមេធាវី អាចចោទប្រកាន់មេធាវីពីបទវិន័យ បើសិនជាពុំមានអ្វីសំអាងហេតុផលឱ្យបានត្រឹមត្រូវ។

## ជំពូកទី៨
## គណនេយ្យកិច្ចគណនេយ្យ និងការត្រួតពិនិត្យ

### ប្រការ ១៧. គណនេយ្យកិច្ចគណនេយ្យ

មេធាវីត្រូវកាន់គណនេយ្យនៃកិច្ចប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន ដោយញែកឱ្យបានច្បាស់រវាងកិច្ចប្រតិបត្តិទាក់ទងនិងការគ្រប់គ្រងការិយាល័យរបស់ខ្លួន និងកិច្ចប្រតិបត្តិធ្វើឡើងសំរាប់ផលប្រយោជន៍អតិថិជន។

គណនេយ្យនៃកិច្ចប្រតិបត្តិដែលពាក់ព័ន្ធនិងការគ្រប់គ្រងការិយាល័យមេធាវី ត្រូវធ្វើឡើងឱ្យសមស្របនិងវិធានច្បាប់ ឬ បើគ្មានវិធាននេះ ក៏ត្រូវធ្វើតាមបែបបទ ចំណូល/ចំណាយដែរ។

កិច្ចប្រតិបត្តិដែលទាក់ទងនិងការបង់ប្រាក់ប្រដាប់ក្តី ប្រាក់ពន្ធអាករ និងប្រាក់ចេញជួសឱ្យមុន ដែលធ្វើឡើងក្នុងផលប្រយោជន៍អតិថិជន ត្រូវកត់ចូលក្នុងគណនេយ្យមួយដោយឡែក។

### ប្រការ ១៨. ការត្រួតពិនិត្យ និងការពិនិត្យបញ្ជាក់

ប្រធានគណៈមេធាវី ចាត់ចែងឱ្យត្រួតពិនិត្យការប្រើប្រាស់មូលនិធិប្រាក់តំកល់ទុក និងឱ្យពិនិត្យផ្ទៀងផ្ទាត់លើឯកសារគណនេយ្យនានា តាមរយៈមេធាវីទាំងឡាយដែលខ្លួនចាត់តាំងអមជាយថាហេតុ ដោយជនមានសមត្ថភាព ឬ ដោយអ្នកជំនាញការងារគណនេយ្យ។

មេធាវីដែលត្រូវត្រួតពិនិត្យ ត្រូវចង្អុលឈ្មោះ ដោយប្រធានគណៈមេធាវី។

មេធាវី ត្រូវបង្ហាញគណនេយ្យរបស់ខ្លួន ដល់ជនដែលត្រូវបានចាត់តាំងដោយប្រធានគណៈមេធាវី។

ការត្រួតពិនិត្យ ត្រូវធ្វើឡើងក្នុងការិយាល័យមេធាវីដែលត្រូវត្រួតពិនិត្យ ។

អ្នកត្រួតពិនិត្យ អាចឱ្យមេធាវីដែលត្រូវត្រួតពិនិត្យប្រគល់ ឯកសារគណនេយ្យនានា សំណុំរឿង ហើយប្រសិនបើមានការត្រូវការ សុំឱ្យប្រគល់ឯកសារនៃគណនីផ្ទាល់ខ្លួនរបស់មេធាវី និងសុំឱ្យធ្វើការពន្យល់សព្វសារពើផង ។

ការត្រួតពិនិត្យនីមួយៗ តម្រូវឱ្យមានរបាយការណ៍លំអិត ដែលត្រូវជូនទៅប្រធានគណៈមេធាវី ។

*******

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អនុម័ត នៅថ្ងៃទី១៥ វិច្ឆិកា ១៩៩៥ នាសម័យប្រជុំក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី ១៥ វិច្ឆិកា ១៩៩៥ ក្រោមអធិបតីភាព លោកបណ្ឌិត **សាយ បូរី** ប្រធានគណៈមេធាវី ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ វិច្ឆិកា ១៩៩៥

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**សាយ បូរី**

# គំរូលេខ១១

# ពាក្យសុំជំនួយសង្គ្រោះ តាមផ្លូវតុលាការ

---

អ្នកសុំ : ថ្ងៃខែនៃពាក្យសុំ :

នាមត្រកូល :

បកតិនាម :

អាស័យដ្ឋាន :

---

ទិដ្ឋាការ នៃប្រធានតុលាការ :

លោក.................................. ប្រធានតុលាការ បានពិនិត្យឃើញថាមានភាពខ្វះខាតធនធាន របស់ឈ្មោះ....................នេះមែន។

ហត្ថលេខាប្រធានតុលាការ និងត្រា ថ្ងៃ....................

---

ទិដ្ឋាការ នៃក្រឡាបញ្ជីនាយក

លោក.................................. ក្រឡាបញ្ជីនាយក បានពិនិត្យឃើញថាមានភាពខ្វះខាតធនធាន របស់ឈ្មោះ....................នេះមែន។

ហត្ថលេខាក្រឡាបញ្ជីនាយក និងត្រា ថ្ងៃ....................

---

ការចាត់តាំងមេធាវី

លោកប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចាត់តាំងលោកមេធាវី ..........................
ដើម្បីជួយការពារក្តីលោក ..........................................................................................
ក្នុងនិតិវិធី ( បញ្ជាក់អំពីប្រភេទនិតិវិធី ) ..........................................................................
តទល់ នឹង លោក ..........................................................................................................

ទិដ្ឋាការ គណៈមេធាវី ថ្ងៃខែ ចាត់តាំង

ធ្វើជា ៣ ច្បាប់ (១ច្បាប់សំរាប់ដើមចោទ, ១ច្បាប់សំរាប់មេធាវី, ១ច្បាប់សំរាប់គណៈមេធាវី )

# គំរូលេខ១២
# របាយការណ៍ នៃការជួយសង្គ្រោះតាមផ្លូវតុលាការ

ធ្វើដោយលោកមេធាវី.................................................................................................

ថ្ងៃ.....................................................................................................................

| ឈ្មោះ អតិថិជន | ឈ្មោះ រឿងក្តី | នីតិវិធី | ភាពជឿនលឿន សំណុំរឿង |
|---|---|---|---|
| ឧ.ម៉ៅ សុក | ម៉ៅ សុក/សម សៅ | ការបណ្តេញចេញពីការងារដោយរំលោភ | -បានជួបប្រាស្រ័យ ២ដង/ម្តង១ម៉ោង<br>-បានចេញដីកាកោះរួចហើយ |
| | | | |

ហត្ថលេខាមេធាវី

# គំរូលេខ១៣
# កិច្ចសន្យាសហការ

រវាង ៖

លោកមេធាវី ............................................ មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ទីលំនៅ នៅផ្ទះលេខ ........................................................................... ភាគីម្ខាង

**និង**

លោកមេធាវី .......................................... មេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ទីលំនៅ នៅផ្ទះលេខ ...................................................................... ភាគីម្ខាងទៀត

បានកំណត់ និងព្រមព្រៀងគ្នា ដូចខាងក្រោម៖

ប្រការ១

លោក មេធាវី..............................និងលោក មេធាវី..........................បានយល់ព្រមជាមួយគ្នា ធ្វើកិច្ចសន្យាសហការគិតពីថ្ងៃទី.................................................តទៅ

ប្រការ២

លោកមេធាវី....................និងប្រគល់ទៅលោកមេធាវី..........................................នូវការរៀបចំសំណុំរឿង សេវាគ្រប់បែបសំរាប់សវនាការ សេចក្តីសន្និដ្ឋានដោះសារ និងការអនុវត្តន៍គ្រប់ការងារ ដែលសមស្របនិងវិជ្ជាជីវៈ។

លោកមេធាវី.........................មានលទ្ធភាពបរិបូរណ៍ ក្នុងការបំពេញកិច្ចការនៃវិជ្ជាជីវៈមេធាវីដើម្បី ទាញយកប្រយោជន៍ផ្ទាល់ខ្លួន និងពង្រីកអតិថិជនផ្ទាល់ខ្លួន ។

ប្រការ៣

លោកមេធាវី.........................ប្រគល់ជូនទៅលោកមេធាវី....................................ប្រើប្រាស់ទីកន្លែង, បណ្ណាល័យ សំភារៈ និងលេខាធិការដ្ឋាន ដែលមានការចាំបាច់សំរាប់កិច្ចសហការផង។

ប្រការ៤

លោកមេធាវី.......................... ត្រូវអនុវត្តន៍ឱ្យបានហ្មត់ចត់នូវការងារដែលប្រគល់ឱ្យធ្វើឱ្យបានសំរេចដូចជាការងាររបស់ខ្លួនផ្ទាល់។

ប៉ុន្តែលោកមេធាវី..................អាចសុំមិនទទួលនូវបេសកកម្ម ដែលខ្លួនយល់ថាផ្ទុយពីសម្បជញ្ញៈរបស់ខ្លួន។ លោកមេធាវី......................................... ត្រូវរៀសវៃធ្វើពាក្យសុំមិនទទួលធ្វើនេះឱ្យបានទាន់ក្នុងឋិរៈវេលា ដែលអាចឱ្យរកមេធាវីផ្សេងដទៃមកជំនួសបាន ដោយមិនបណ្តាលឱ្យមានការខូចខាតដល់ការិយាល័យមេធាវី ដែលប្រគល់ការងារឱ្យធ្វើផង ឬ ដល់អតិថិជនផង។

មេធាវីត្រូវរៀបចំសកម្មភាពរបស់ខ្លួន ទៅតាមផ្ទៃរឿងដែលការិយាល័យបានប្រគល់ឱ្យផង ដែលអតិថិជនផ្ទាល់របស់ខ្លួន បានប្រគល់ឱ្យផង និងទៅតាមសកម្មភាព កម្មសិក្សាផង។

**ប្រការ៥**

មេធាវី..............................ផ្ទេរឱ្យមេធាវី...........................វិញ ជាបដិភាគនៃសហការនូវប្រាក់កំរៃ ក្រោមលក្ខខ័ណ្ឌដូចតទៅនេះ៖

មេធាវីក្រោយនេះ ជាអ្នកទទួលខុសត្រូវខ្លួនឯង ក្នុងការបង់ប្រាក់បន្ទុកសង្គម និងពន្ធដារដែលទាក់ទិននិងសកម្មភាពការងារនោះ។

សោយហ៊ុយធ្វើដំណើរ បានចាយក្នុងក្របខ័ណ្ឌសហការ និងត្រូវទូទាត់ជាច់ដោយឡែកតាមបែបបទដូចតទៅ៖

**ប្រការ៦**

មេធាវី...................................ត្រូវជូនដំណឹងទៅមេធាវី...................................អំពីអវត្តមានរបស់ខ្លួន។ កាលបរិច្ឆេទ ក្នុងករណីអវត្តមានដែលអាចព្រាងទុកមុនបាន និងត្រូវកំណត់តាមការព្រមព្រៀងទៅវិញទៅមកឱ្យបានឆាប់ដើម្បីចៀសវាងការរំខានភាគីទាំងសងខាង។

**ប្រការ៧**

កិច្ចសន្យាសហការនេះ ពុំមានកំណត់ពេលវេលាឡើយ។

គូភាគី អាចបញ្ចប់កិច្ចសន្យាបានក្រោមការគោរពការជូនដំណឹង៣ខែមុន។ ប៉ុន្តែក្នុងរយៈកាល ២ ខែ ដំបូង គូភាគីអាចបញ្ចប់កិច្ចសន្យាបាន ដោយមិនបាច់គិតរយៈ ជូនដំណឹងជាមុនឡើយ ។

មេធាវី...................... អាចតាំងទីលំនៅ នៅការិយាល័យ របស់មេធាវី.......................

បានរហូតដល់ពេលខ្លួនបានជូនដំណឹងទៅគណៈមេធាវី អំពីលក្ខខ័ណ្ឌសកម្មភាពថ្មីរបស់ខ្លួន ហើយការជូនដំណឹងអំពីលក្ខខ័ណ្ឌសកម្មភាពថ្មីនេះ ត្រូវធ្វើឡើងមិនឱ្យលើសពី ៣ ខែឡើយ។

ប៉ុន្តែក្រោយរយៈពេលនេះ សំបុត្រឆ្លងឆ្លើយទាំងឡាយរបស់មេធាវីនេះ ត្រូវបញ្ជូនឱ្យជាធម្មតា។

**ប្រការ៨ (កម្មសិក្សា)**

មេធាវី................ សន្យាជាបដិភាគក្នុងក្របខ័ណ្ឌសហការជាមួយមេធាវី ...........ថានឹងធានាអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មេធាវី ................ ដោយមានការឱ្យចូលរួមពេញលេញក្នុងសកម្មភាពការិយាល័យ និងឱ្យជួបជាមួយអតិថិជនរបស់ខ្លួនជាដើម។

សកម្មភាពដែលត្រូវធ្វើជា កាតព្វកិច្ចនៃកម្មសិក្សា គឺមានលក្ខណៈជាអាទិភាព។

**ប្រការ៩**

គ្រប់ការលំបាកដែលលេចឡើង ក្នុងពេលអនុវត្ត ឬ មិនបានអនុវត្ត ឬ ក្នុងពេលផ្តាច់កិច្ចសន្យានេះ ត្រូវដាក់ជូន១ច្បាប់ទៅប្រធានគណៈមេធាវី ដើម្បីឱ្យជួយសម្រុះសម្រួល។

ធ្វើនៅ

ជាបីច្បាប់ដើម ថ្ងៃទី.

ត្រូវជូន១ច្បាប់ទៅអគ្គលេខាធិការដ្ឋានគណៈមេធាវី ថ្ងៃទី..................................

# គំរូលេខ ៤

លោកមេធាវី.................................... បានដាក់ប្រាក់ដំកល់ទុក នៅថ្ងៃទី................................
ចំនួន .....................................................................................................................
ក្នុងគណនី នៃបេឡាទូទាត់របស់គណៈមេធាវី
សំរាប់រឿងក្តី ........................................................................................................

ភ្នំពេញ.ថ្ងៃទី..............................

**មេធាវី**

(ហត្ថលេខា)

# គំរូលេខ១៩

## <u>បង្កាន់ដៃ គណៈមេធាវី</u>

ប្រធានគណៈមេធាវី បញ្ជាក់ថាបានទទួល នៅថ្ងៃទី..................................................

ប្រាក់ដំកល់ទុក ចំនួន...............................................................................................

ជា ក្រដាសប្រាក់ - មូលប្បទានប័ត្រ (១)

ពីលោក មេធាវី.........................................................................................................

សំរាប់រឿងក្តី.............................................................................................................

ភ្នំពេញ,ថ្ងៃទី..........................

ប្រធានគណៈមេធាវី

( ហត្ថលេខា )

(១) លប់ចោលពាក្យឥតប្រយោជន៍

# គំរូលេខ១៦
# ពាក្យសុំឱ្យបើកប្រាក់

លោក មេធាវី..................................... សុំឱ្យគណៈមេធាវីបើកប្រាក់ឱ្យលោក .........................

ចំនួន ..........................................................................................................................

សំរាប់រឿងក្តី ...............................................................................................................

ភ្នំពេញ ថ្ងៃទី.......................

មេធាវី

(ហត្ថលេខា)

# ក្រមសីលធម៌មេធាវី
# នៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ១៩៩៥

## កំណត់សំគាល់

ច្បាប់ដែលអត្ថបទនេះរំលឹកឡើងនោះ គឺច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ន.ស ០៨-៩៥.០៦ ចុះថ្ងៃទី២២/៨/៩៥។

## ជំពូកទី១
## ទីលំនៅវិជ្ជាជីវៈ កន្លែងពិគ្រោះច្បាប់

### មាត្រា ១. ទីលំនៅវិជ្ជាជីវៈ - ការិយាល័យសាខា

មេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ទីលំនៅវិជ្ជាជីវៈដើមនៅក្នុងប្រទេសកម្ពុជា។

ស្របតាមមាត្រា២១ នៃច្បាប់ មេធាវីអាចតាំងការិយាល័យសាខាច្រើនបាន ពោលគឺអាគារដោយឡែកពីទីលំនៅវិជ្ជាជីវៈដើម ដែលមេធាវីអាចទទួលអតិថិជន។

ការតាំងទីប្រកបវិជ្ជាជីវៈ ត្រូវរ៉ាប់រងឱ្យបាននូវការគោរពគោលការណ៍នៃសេចក្តីថ្លៃថ្នូរ និងភាពឯករាជ ព្រមទាំងធានាឱ្យបាននូវអាថ៌កំបាំងវិជ្ជាជីវៈ។

ក្រុមប្រឹក្សាគណៈមេធាវី អាចទៅត្រួតពិនិត្យបានគ្រប់ពេលវេលា នូវភាពសមស្របនិងវិធានវិជ្ជាជីវៈ។

### មាត្រា ២. ការិយាល័យសាខា នៃមេធាវីខ្មែរ

មេធាវីខ្មែរ ដែលចង់បើកការិយាល័យសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតិ ជាមុន ពីក្រុមប្រឹក្សាគណៈមេធាវី ដោយជូនសេចក្តីបញ្ជាក់អំពីទីកន្លែង និងបែបបទសកម្មភាព ដែលបំរុង និងធ្វើ ក្នុងការិយាល័យសាខានោះ។

មេធាវីខ្មែរ ដែលមានបំណងបើកការិយាល័យសាខានៅបរទេស ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈមេធាវីបរទេសដែលជាអ្នកទទួលឱ្យបើកនោះ។

មេធាវី ត្រូវជូនដំណឹង ទៅក្រុមប្រឹក្សាគណៈមេធាវី អំពីការបិទការិយាល័យសាខារបស់ខ្លួន។

### មាត្រា ៣. ការិយាល័យសាខានៃមេធាវីដែលចុះឈ្មោះនៅបរទេស

ការបើកការិយាល័យសាខា នៅប្រទេសកម្ពុជា ដោយមេធាវីបរទេសដែលបានបំពេញលក្ខខ័ណ្ឌ នៃមាត្រា៦ នៃច្បាប់ ត្រូវសុំអនុញ្ញាតិពីក្រុមប្រឹក្សាគណៈមេធាវី។

មេធាវីបរទេសនោះ ត្រូវបង់ភាគទានដែលកំណត់រាល់ឆ្នាំដោយក្រុមប្រឹក្សាគណៈមេធាវី ដោយសារការបើកការិយាល័យសាខានេះ។

មេធាវីបរទេសត្រូវជូនដំណឹង ទៅក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អំពីការលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី ការដាក់ទណ្ឌកម្មខាងវិន័យដែល គណៈមេធាវីដើមរបស់ខ្លួន បានធ្វើចំពោះខ្លួន។

បញ្ជីការិយាល័យសាខា ត្រូវភ្ជាប់និងបញ្ជីរាយឈ្មោះរបស់គណៈមេធាវី។

## មាត្រា ៤. កន្លែងទទួលអតិថិជន

មេធាវី ត្រូវទទួលអតិថិជននៅទីលំនៅវិជ្ជាជីវៈដើម ឬ ក្នុងការិយាល័យសាខា។

មេធាវី អាចទៅកាន់ផ្ទះអតិថិជនរបស់ខ្លួន (ផ្ទះនៅ ឬនៅទីកន្លែងឯកជនណាផ្សេង)

មេធាវីមិនអាចទទួលពិគ្រោះច្បាប់ នៅទីកន្លែងសាធារណៈបានឡើយ លើកលែងតែនៅសាលាខេត្ត ក្រុង និងឃុំ ដែលមានបន្ទប់សំរាប់ការពិគ្រោះច្បាប់នេះ។

## មាត្រា ៥. សេវាពិគ្រោះច្បាប់ក្រៅការិយាល័យ

នៅគ្រប់សេវាពិគ្រោះច្បាប់ ធ្វើឡើងក្រៅការិយាល័យដើម ឬក្រៅការិយាល័យសាខារបស់មេធាវី ត្រូវមានការអនុញ្ញាតិជាមុនពីក្រុមប្រឹក្សាគណៈមេធាវី។

# ជំពូកទី២

# វិជ្ជាជីវៈ និងវិន័យផ្សេង ៗ

## មាត្រា ៦. គោលការណ៍គ្រឹះ

នៅគ្រប់កាលៈទេសៈ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈ នៃមនុស្សធម៌ និងនៃភាពគួរសមថ្លៃថ្នូរ។

មេធាវី មិនត្រូវចូលរួមនិងសកម្មភាព ដែលមានលក្ខណៈផ្ទុយពីច្បាប់និងបទបញ្ជា ផ្ទុយនិងវិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនដែលតម្រូវឱ្យធ្វើ។

## មាត្រា ៧. អាថ៌កំបាំងវិជ្ជាជីវៈ

មេធាវីត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដាច់ខាត នូវអាថ៌កំបាំងវិជ្ជាជីវៈ។ អាថ៌កំបាំងនេះ មិនត្រូវអាចឱ្យ ជនណាស្រង់យកបានឡើយ ទោះបីថាជាអតិថិជនក៏ដោយ។

មេធាវី ត្រូវកំណត់ឱ្យបានច្បាស់តាមសម្បជញ្ញៈរបស់ខ្លួន នូវកត្តាចាំបាច់សំរាប់ធ្វើការការពារ។ ពុំមានកាតព្វកិច្ចលាក់អាថ៌កំបាំងទេ ល្គឹកណាមេធាវីត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់អតិថិជនរបស់ខ្លួន ប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកំរិតនៃការចាំបាច់នៃការការពាររបស់ខ្លួនតែប៉ុណ្ណោះ។

## មាត្រា ៨. បញ្ហាលើការតាក់តែងលិខិតដោយមេធាវី

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមតែម្នាក់ឯង អាចធ្វើសកម្មភាព ឬ ការពារលើការអនុវត្តន៍ លិខិតនោះបាន នៅពេលដែលការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួនត្រូវចោទប្រកាន់ឡើងលើកលែងតែទៅ ប្រឆាំងនឹងភាគីណាមួយដែលនៅក្នុងលិខិតស្នាមនោះ។

មេធាវីដែលបានចូលរួម ក្នុងការតាក់តែងលិខិតស្នាម ក្នុងឋានៈជាទីប្រឹក្សារបស់ភាគីម្ខាង អាចធ្វើសកម្មភាព ឬ ការពារលើការអនុវត្តន៍លិខិតនោះតទល់នឹងភាគីម្ខាងទៀតបាន។

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាម ឬ ដែលជាអ្នកចូលរួមតាក់តែង មិនអាចបំពេញកិច្ចការ ឬ ការពារលើសុពលភាព ឬ លើការបកស្រាយលិខិតស្នាមដែលខ្លួនបានសរសេរនោះទេ កាលបើការអន្តរាគមន៍របស់ខ្លួន នាំខ្លួនឱ្យទៅជាសាក្សី ឬ ឱ្យប៉ះពាល់ដល់អាថ៌កំបាំងវិជ្ជាជីវៈ។ មេធាវីនេះក៏មិនអាចធ្វើអន្តរាគមន៍ទៅកើតដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួន ត្រូវចោទប្រកាន់ឡើង។

## មាត្រា ៩. លិខិតតាក់តែងឡើងជាមួយគ្នា

មេធាវីម្នាក់ៗ ត្រូវប្រមូលផ្តុំនូវឯកសារពត៌មានផ្ទាល់របស់អតិថិជននៃខ្លួន។ មេធាវីម្នាក់ៗ ត្រូវផ្ទៀងពិនិត្យភាពត្រឹមត្រូវ ឬភាពសច្ចៈនៃអត្តសញ្ញាណរបស់បុគ្គលនៃនិទ្ទេសនានា និងឯកសារនានាដែលខ្លួនបាននាំយកមក និងហត្ថលេខាដែលខ្លួនបានឱ្យចុះ។

លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ មេធាវីដែលរ៉ាប់រងការរៀបចំលិខិតស្នាមត្រូវចាប់កិច្ចការភ្លាម និងចាប់ធ្វើទំរង់ការចាំបាច់នានា សំរាប់សុពលភាព និងប្រសិទ្ធិភាព។ បន្ទាប់មក មេធាវីនេះត្រូវ ជូនទៅសហភាតារបស់ខ្លួន នូវលិខិតស្នាមគ្រប់ច្បាប់ដែលត្រូវបញ្ជូនត្រឡប់ទៅឱ្យអតិថិជនរបស់សហភាតានោះ។

មេធាវីម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះមុខសហភាតារបស់ខ្លួន អំពីការខ្វះខ្នែង អំពីបែបបទដែលខ្លួនជាអ្នកទទួលបន្ទុកត្រូវធ្វើក្នុងផលប្រយោជន៍រួម ប៉ុន្តែក្នុងលក្ខ័ណដែលខ្លួនត្រូវបានទទួលមូលនិធិចាំបាច់រួចហើយសិន។

## មាត្រា ១០. ប័ណ្ណវិជ្ជាជីវៈ

មេធាវី បញ្ជាក់ភាពត្រឹមត្រូវនៃមុខងាររបស់ខ្លួន តាមប័ណ្ណដែលចេញឱ្យ ដោយគណៈមេធាវី។ ប័ណ្ណនេះ ត្រូវប្រគល់ឱ្យគណៈមេធាវីវិញ ក្នុងករណីដែលមេធាវីនោះបានលាឈប់ ឬត្រូវលុបឈ្មោះចេញ ឬត្រូវហាមឃាត់បំពេញវិជ្ជាជីវៈមួយរយៈកាល ឬត្រូវព្យួរឈ្មោះជាបណ្ដោះអាសន្ន។

## មាត្រា ១១. ពាក់អាវផាយ

នៅចំពោះមុខចៅក្រម និងយុត្តាធិការគ្រប់ប្រភេទ មេធាវីត្រូវពាក់អាវផាយ លើកលែងតែមានប្រពៃណីផ្ទុយពីនេះ។ មេធាវីពាក់អាវផាយដែរ នៅពេលបុណ្យ និងនៅពេលសំដែងសកម្មភាពនៃគណៈមេធាវី។

# ជំពូកទី៣
# ការផ្សព្វផ្សាយ និងការទំនាក់ទំនងវិជ្ជាជីវៈ

## មាត្រា ១២. ការទំនាក់ទំនងវិជ្ជាជីវៈ

គណៈមេធាវី រ៉ាប់រងការផ្សព្វផ្សាយវិជ្ជាជីវៈ និងការទំនាក់ទំនងនៃមន្ទីគណៈមេធាវី។

## មាត្រា ១៣. ការដើរទាក់ទងភ្ញៀវ និងការសុំឱ្យគេមករកខ្លួនត្រូវហាមឃាត់

មេធាវីត្រូវ ហាមឃាត់មិនឱ្យធ្វើការទាក់ទាញភ្ញៀវ ឬ សុំឱ្យគេមករកខ្លួនឡើយ។

## មាត្រា ១៤. ក្រដាសសរសេរលិខិត - ប័ណ្ណវិជ្ជាជីវៈ

ក្រដាសសរសេរលិខិតត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូល បកតិនាមមេធាវី ឬ នាមករណ៍ នៃក្រុមហ៊ុនមេធាវី។
- និទ្ទេស «មេធាវី» ឬ «មេធាវីនៃគណៈនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា»។
- ទីលំនៅវិជ្ជាជីវៈ ហើយបើមាន ចុះអាស័យដ្ឋាននៃការិយាល័យសាខា ដែលបានបើកដោយត្រឹមត្រូវតាមច្បាប់។ ទាំងអស់នេះ ធ្វើឡើងដោយកុំឱ្យមានការភ័ន្តច្រឡំ នឹងលំនៅឋានរស់នៅផ្ទាល់ខ្លួន។
- និយាមការប្រៃសណីយ៍, ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដ៏ទៃទៀត។

- ឋានន្តរសាកលវិទ្យាល័យ ឬ សញ្ញាប័ត្រសាលាជាន់ខ្ពស់ ឬ បុព្វសិទ្ធិផ្ទាល់ខ្លួន តែត្រូវបញ្ជាក់បង្ហាញថាមានមែនត្រឹមត្រូវ ជូនទៅគណៈមេធាវី។
- បញ្ជីមេធាវីជាសមាជិកការិយាល័យ, ជាសមាគមិក ឬ ជាមេធាវីសហការី។

ការប្រើរូបសញ្ញា ( Logo) ត្រូវបានអធ្យាស្រ័យឱ្យប្រើ។

មេធាវីទាំងឡាយ ដែលបំពេញការងារនៅការិយាល័យប្រមូលផ្តុំ ដោយពុំបានធ្វើជាសមាគមក្រោមរូបភាពណាមួយ អាចត្រូវអនុញ្ញាតឱ្យប្រើក្រដាសសរសេរលិខិតរួមបាន ក្រោមលក្ខខ័ណ្ឌដែលមិនបង្កើតឱ្យមានការភ័ន្តច្រឡំជាមួយរចនាសម្ព័ន្ធការងារ។

## មាត្រា ១៥ . អន្តរាគមន៍តាមប្រព័ន្ធផ្សាយពត៌មានជាសាធារណៈ នៃមេធាវី

គ្រប់អន្តរាគមន៍សាធារណៈ ឬ តាមប្រពន្ធ័ផ្សាយពត៌មានជាសាធារណៈរបស់មេធាវីក្នុងឋានៈខ្លួនជាមេធាវី និងអាចអនុញ្ញាតឱ្យធ្វើបាន តែក្នុងក្របខ័ណ្ឌនៃការគោរពដោយម៉ឺងម៉ាត់នូវកាតព្វកិច្ចនៃវិជ្ជាជីវៈ។ អន្តរាគមន៍បែបនេះ ទាមទារឱ្យមានការប្រុងប្រយ័ត្នជាទីបំផុត។

ប្រធានគណៈមេធាវី ត្រូវតែបានទទួលដំណឹងនិងទទួលពិគ្រោះយោបល់ជាមុនក្នុងរឿងនេះ លើកលែងតែពុំមានលទ្ធភាព ។

# ជំពូកទី៤
# ទំនាក់ទំនងជាមួយអតិថិជន

## មាត្រា ១៦. ការទទួល ការបដិសេធ ការបោះបង់ចោលបេសកកម្ម

មេធាវី មានសេរីភាពទទួល ឬមិនទទួលជួយកូនក្តី លើកលែងតែត្រូវចាត់តាំង ដោយប្រធានគណៈមេធាវី ។

ប្រសិនបើយល់ព្រមទទួលជួយ មេធាវីត្រូវបំពេញបេសកកម្មរបស់ខ្លួនរហូតដល់ទីបំផុត លើកលែងតែត្រូវដោះបន្ទុកវិញដោយអតិថិជន។

ដោយសារបុព្វហេតុដែលចេញពីសម្បជញ្ញៈរបស់ខ្លួន មេធាវីអាចសំរេចបញ្ឈប់បេសកកម្មរបស់ខ្លួន តែត្រូវជូនដំណឹងទៅអតិថិជនក្នុងពេលវេលាមួយ ដែលផ្តល់លទ្ធភាពឱ្យអតិថិជននេះអាចបង្ការផលប្រយោជន៍របស់ខ្លួនបាន។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន មេធាវី ក្នុងការគោរពសេរីភាពរបស់អតិថិជន ត្រូវស្ថិតនៅជាម្ចាស់នៃមធ្យោបាយការពារ។

មេធាវីត្រូវប្រកែកមិនព្រមទទួលជួយ កិច្ចប្រតិបត្តិការទាំងឡាយណា ឬអំពើទាំងឡាយណាដែលផ្ទុយពីវិធានវិជ្ជាជីវៈ និងផ្ទុយពីការតម្រូវនៃសម្បជញ្ញៈរបស់ខ្លួន។

មេធាវីត្រូវដឹងឱ្យច្បាស់ថា កិច្ចប្រតិបត្តិការនោះ ស្ថិតនៅក្នុងក្របខ័ណ្ឌជានាប់ទាក់ទងពីក្រុមហ៊ុនដែលជានាប់ទាក់ទងចំពោះខ្លួន។

## មាត្រា ១៧. លិខិតប្រគល់សិទ្ធិ

ក្នុងគ្រប់រឿងអ្វីក៏ដោយ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិពីអតិថិជនរបស់ខ្លួន។

## មាត្រា ១៨. ទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន

ការទាក់ទងជាមួយអតិថិជន ត្រូវធ្វើដោយចំពោះ និងផ្ទាល់ខ្លួន។ មេធាវី មិនអាចទទួលរឿងក្តីមួយតាមរយៈតតិយជនបានឡើយ បើប្រសិនជាខ្លួនគ្មានសេរីភាពនឹងចូលទាក់ទងផ្ទាល់ខ្លួនជាមួយអតិថិជនដែលមានរឿងនោះបាន។

វិធាននេះ អាចនឹងមិនត្រូវប្រតិបត្តិតាមបាន លុះត្រាណាមេធាវី ដើរតួជាអ្នកឆ្លើយឆ្លងរបស់មេធាវីម្នាក់ទៀត។

## មាត្រា ១៩. អតិថិជនច្រើនគ្នា

នៅពេលដែលមេធាវីត្រូវអតិថិជនច្រើនគ្នាពឹងពាក់ ក្នុងរឿងក្តីតែមួយ ឬ ក្នុងការប្រតិបត្តិការតែមួយដូចគ្នា មេធាវីមិនត្រូវកាន់ជើងផ្តល់ប្រយោជន៍ឱ្យតែអតិថិជនណាមួយឡើយ។ អ្វីៗត្រូវតែជូនដំណឹងទៅភាគីទាំងអស់គ្រប់គ្នា។ មេធាវីមិនអាចប្តល់យោបល់ ឬជួយ ឬតំណាង ឬការពារភាគីច្រើនគ្នា បើប្រសិនជាមានកើតឡើងរវាងភាគីទាំងនោះ នូវទំនាស់ផលប្រយោជន៍គ្នាណាមួយ។ បើសិនជារឿងនេះកើតឡើងមែន ក្នុងពេលដែលមេធាវី ឬ ធ្លាប់ជាទីប្រឹក្សារបស់ភាគី ច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារ ប្រយោជន៍ភាគីណាមួយបាន លុះត្រាតែត្រូវជំរាបទៅភាគីឯទៀតៗឱ្យបានដឹងសិន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពគួរសមថ្លៃថ្នូរ និងអាថ៌កំបាំងវិជ្ជាជីវៈផង។

## មាត្រា ២០. អតិថិជន

ក្នុងរឿងតុលាការ មេធាវីដែលបានផ្តល់យោបល់ ឬបានជួយ ឬ បានតំណាងភាគីណាមួយ មិនអាចទៅធ្វើអន្តរាគមន៍ជួយខាងគូប្រឆាំង ក្នុងរឿងក្តីដដែល ឬក្នុងរឿងដែលពាក់ព័ន្ធនិងរឿងក្តីដដែលបានឡើយ។

ក្នុងគ្រប់រឿងទាំងអស់ មេធាវីនឹងអាចធ្វើអន្តរាគមន៍ប្រឆាំងនឹងកូនក្តីដែលខ្លួនធ្លាប់បានជួយពីលើកមុន បានតែក្នុងលក្ខណៈតឹងរឹងនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ និងភាពគួរសមថ្លៃថ្នូរប៉ុណ្ណោះ។

បទបញ្ញត្តិនេះ ត្រូវអនុវត្តន៍ ទៅលើគ្រប់មេធាវីទាំងអស់ដែលធ្វើការនៅក្នុងរចនាសម្ពន្ធតែមួយរួមគ្នា ហើយនឹងទៅលើសហការី ឬ និយោជិតទាំងអស់។

មេធាវី ទាំងឡាយដែលជាសមាជិកនៃក្រុមប្រមូលផ្តុំមធ្យោបាយ អាចនឹងប្តល់យោបល់ ឬជួយ ឬតំណាងភាគីនានាដែលមានផលប្រយោជន៍ប្រឆាំងគ្នាបាន លុះត្រាតែមានការយល់ព្រមពីអតិថិជនរៀងៗខ្លួន និងក្នុងលក្ខណៈនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ។

## មាត្រា ២១. អតិថិជនជាប់ឃុំ

មេធាវី ត្រូវប្រុងប្រយ័ត្នឱ្យបានហ្មត់ចត់ កុំយកទៅឱ្យអតិថិជនរបស់ខ្លួន នូវមធ្យោបាយអ្វីទាំងអស់ ដែលសំរាប់ឱ្យរត់រួច ពីដំណើរការធម្មតារបស់តុលាការ ឬ ដែលសំរាប់បំភាន់ការសើុបសួរជាដំបូង។

មេធាវី ត្រូវហាមមិនឱ្យប្រគល់ទៅឱ្យអតិថិជនរបស់ខ្លួន ឬ ផ្ញើរពីក្រៅទៅឱ្យនូវវត្ថុ ឬឯកសារ ឬ សំបុត្រ ឬ សារតាមសំដីទាំងឡាយ លើកលែងតែមានសេចក្តីអនុញ្ញាតិ ពីចៅក្រមសើុបសួរ (ក្នុងករណីជាប់ឃុំឃាំងបណ្តោះអាសន្ន) ឬពីអាជ្ញាធរពន្ធនាគារ (បើសិនជាអតិថិជន ត្រូវជាប់ទោសគុកជាស្ថាពរ រួចហើយ)។

## មាត្រា ២២. កំរៃមេធាវី

គេអាចធ្វើកិច្ចព្រមព្រៀងគ្នាមុនបញ្ជាក់អំពីចំនួនទឹកប្រាក់សរុបផ្តាច់តែម្តង ឬ អំពីរបៀបកំណត់ប្រាក់កំរៃមេធាវី។

បើមានការមិនចុះសម្រុងគ្នា ប្រធានគណៈមេធាវី អាចត្រូវភាគីសុំឱ្យជួយសម្រុះសម្រួលគ្នាបាន។

## មាត្រា ២៣. ការបញ្ចប់បេសកកម្ម

មេធាវីប្រគល់ឱ្យទៅអតិថិជន តាមការសុំរបស់គេ នូវបញ្ជីស្រង់ប្រាក់ដែលមេធាវីបានចេញជំនួសចំណាយផ្សេងៗ និងប្រាក់កំរៃមេធាវី។

បើបេសកកម្មជាការតាក់តែងលិខិតស្នាមវិញ មេធាវីត្រូវប្រគល់ឱ្យភាគីហត្ថលេខីនិមួយៗ នូវលិខិតដើម ហើយនិងឯកសារទាំងអស់ដែលបញ្ជាក់អំពីការបានបំពេញបែបបទគ្រប់សព្វតាមច្បាប់និងបទបញ្ជារ។ ទាំងអស់នេះ ត្រូវប្រគល់ ដោយមានលិខិតទទួលពីអតិថិជនផង។

មេធាវីត្រូវប្រគល់ត្រឡប់វិលទៅឱ្យអតិថិជនវិញភ្លាម នូវឯកសារទាំងអស់ដែលខ្លួនបានទទួលទុក ដោយគ្មានសិទ្ធិកាក់ទុកអ្វីទាំងអស់។ ការប្រគល់នេះ ត្រូវមានលិខិតទទួលត្រឹមត្រូវពីអតិថិជន។

## ជំពូកទី៥
## ទំនាក់ទំនងជាមួយចៅក្រម

### មាត្រា ២៤. ទំនាក់ទំនងជាមួយចៅក្រម

មេធាវីដែលត្រូវឡើងសាលាជាលើកដំបូង ត្រូវទៅបង្ហាញខ្លួនដល់ចៅក្រម។

មេធាវីត្រូវសំដែងជូនចៅក្រម ក្នុងភាពឯករាជ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងារ។

មេធាវី ត្រូវគោរពតាមវិធាននៃនិតិវិធី ហើយនឹងទម្លាប់នៃតុលាការ។ មេធាវីមិនត្រូវជាដាច់ខាតប្រើវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់មុខគ្នា។ មេធាវី មានសិទ្ធិសំដែងឡើងនូវអ្វីៗ ដែលខ្លួនយល់ថាមានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។

ក្នុងករណីមានកើតហេតុជាមួយចៅក្រម មេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី។

វិបត្តិទាំងឡាយ ដែលកើតឡើងរវាងសហភាគា ក្រៅតែអំពីការអនុវត្តន៍ នៃវិធាននីតិវិធីតុលាការ ត្រូវឡើងទៅរកការសម្រុះសម្រួល នៃប្រធានគណៈមេធាវី។

## ជំពូកទី៦
## ទំនាក់ទំនងជាមួយ សហភាគា និងសមាជិកនៃវិជ្ជាជីវៈប្រហែលគ្នា

### មាត្រា ២៥. វិធានទូទៅ និងវិធានផ្សេងៗ

គ្រប់ការទំនាក់ទំនង រវាងមេធាវីគ្នាឯង ត្រូវប្រព្រឹត្តឡើងក្នុងស្មារតីនៃសហភាគរភាពសមរម្យ និងគួរសមជានិច្ច។

ក្នុងការគោរពផលប្រយោជន៍របស់អតិថិជនខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនឹងនាំឱ្យខូចខាតដល់សហភាគានៃខ្លួនឡើយ។

មេធាវីត្រូវជូនដំណឹងជាមុនដល់បដិវាទករ អំពីការសុំផ្អាកពេល ព្រមទាំងការចាប់ផ្ដើមនីតិវិធីថ្មីណាមួយ លើកលែងតែមានការចាំបាច់ផ្ទុយទៅវិញ ក្នុងគោលប្រយោជន៍របស់អតិថិជន។ មេធាវីត្រូវប្រាប់បដិវាទករឱ្យដឹងអំពីឧប្រាស្រ័យ ដែលខ្លួនបានធ្វើ។

មេធាវីត្រូវជៀសវាង កុំឱ្យមានការយឺតយ៉ាវក្នុងការប្ដល់ប្រវេសន៍ និងការទំនាក់ទំនងនានាឱ្យសោះ ហើយត្រូវប្រគល់ច្បាប់ដើមទាំងអស់ នៃឯកសារដែលខ្លួនបានទទួល ដោយគ្មានបង្អែបង្អង់ឡើយ។ ទោះជាក្នុងករណីណាក៏ដោយ មេធាវីមិនត្រូវប្រគល់ឯកសារអស់ទាំងនេះ ទៅអតិថិជនខ្លួនឡើយ។

ការប្រជុំ និងការណាត់ជួបគ្នា ត្រូវកំណត់ដោយកិច្ចព្រមព្រៀងជាមួយគ្នាឱ្យសមស្របនឹងអធ្យាស្រ័យរៀងៗខ្លួន។ ជាធម្មតា ការប្រជុំនិងការណាត់ជួបគ្នានេះ ត្រូវមកកន្លែងការិយាល័យរបស់មេធាវី ដែលមានអតីតភាពច្រើនជាងគេ។

រំដាប់ថ្នាក់ហៅចូលសវនាការ ត្រូវចាត់ឡើងស្មើភាពគ្នាទាំងអស់ រវាងសហភាតាលើកលែងតែប្រធានគណៈមេធាវី ដែលត្រូវតែហៅមុនគេ។

ទំនាស់សព្វយ៉ាងរវាងសហភាតា ត្រូវដោះស្រាយដោយប្រធានគណៈមេធាវី។

## មាត្រា ២៦. ការប្ដឹងគ្នាទៅតុលាការ

ប្រធានគណៈមេធាវី ត្រូវតែបានទទួលដំណឹងជាមុន មុននឹងមេធាវីណាចាប់ប្ដឹងតាមផ្លូវតុលាការពីមេធាវីណាមួយទៀត ឬពីចៅក្រម ឬពីសមាជិកណាមួយទៀត នៃរាល់វិជ្ជាជីវៈគតិយុត្ត ឬតុលាការណាដែលមានច្បាប់គ្រប់គ្រង។

## មាត្រា ២៧. សំបុត្រឆ្លើយរវាងសហភាតា

ការឆ្លងឆ្លើយតាមលិខិត ឬតាមសំដីរវាងមេធាវីនិងមេធាវី ធម្មតាត្រូវជាការសម្ងាត់។

ការឆ្លងឆ្លើយនេះមិនអាចក្នុងប្រការណាក៏ដោយ រឹបអូស ឬបង្ហាញក្នុងតុលាការបានឡើយ និងមិនអាចទុកជាកម្មវត្ថុ នៃការលើកភាពសម្ងាត់ចេញបានឡើយដែរ។

មិនមែនជាការសម្ងាត់ ៖

- សំបុត្រដែលជំនួសលិខិតនីតិវិធី។
- សំបុត្រដែលមានដាក់ថា «ផ្លូវការ» ហើយដែលបញ្ជូនសេចក្ដីស្នើណាមួយ ឬឯកសារមិនសម្ងាត់នានាមក។

- ការប្តូរសំបុត្រគ្នាទៅវិញទៅមក ដែលមានដាក់ថា «ផ្លូវការ» ដើម្បីបង្ហាញបញ្ជាក់កិច្ចព្រមព្រៀងណាមួយ ឬ ការចុះហត្ថលេខា នៃកិច្ចព្រមព្រៀងណាមួយ រវាងមេធាវី និងមេធាវី ក្នុងកំរិតលក្ខ័ណនៃអាណត្តិរបស់ខ្លួន។

សំបុត្រនិងឯកសារទាំងនេះ មិនត្រូវមានយោងទៅលើការប្តូរសំបុត្រគ្នាទៅវិញទៅមក ឬក៏ការប្រាស្រ័យគ្នាពីលើកមុន ដែលមានលក្ខណៈជាសម្ងាត់នោះឡើយ។

ក្នុងករណីដែលមានការបំពាន លើវិធានទាំងឡាយដូចបានចែងហើយពីខាងលើមកនោះ ប្រធានគណៈមេធាវី ដែលជាអ្នកធានាឱ្យបាននូវគោលការណ៍សំខាន់ៗនៃវិជ្ជាជីវៈមេធាវី ត្រូវប៉ប់រងឱ្យបាននូវការគោរពគោលការណ៍ទាំងនោះ តាមផ្លូវក្រុមសីលធម៌។

ក្នុងការទំនាក់ទំនងជាមួយមេធាវីបរទេសណាមួយ មេធាវី មុននឹងប្តូរពត៌មានសម្ងាត់គ្នាទៅវិញទៅមក ត្រូវដឹងឱ្យច្បាស់អំពីវិជ្ជមាននៃវិធានក្នុងការរក្សាភាពសម្ងាត់នៃការឆ្លងឆ្លើយ នៅក្នុងប្រទេសដែលមានសហភាតាបរទេសប្រកបមុខការ។ នៅក្នុងករណីអវិជ្ជមានវិញ មេធាវីត្រូវសួរអតិថិជនរបស់ខ្លួនថា តើគេយល់ព្រមហ៊ានប្រថុយឱ្យបាត់ភាពសម្ងាត់ នៃការឆ្លងឆ្លើយប្តូរពត៌មាននោះឬទេ ។

## មាត្រា ២៨. ការប្តូរមេធាវី

មេធាវីដែលទទួលសំណើរពីអតិថិជនណាមួយ ឬសំណុំរឿងណាមួយ ត្រូវតែពិនិត្យផ្ទៀងផ្ទាត់ឱ្យឃើញថា គ្មានសហភាតាណាមួយបានទទួលយករួចហើយពីមុនខ្លួន។

មេធាវី ដែលទទួលបន្តពីសហភាតាណាម្នាក់ ឬទទួលធ្វើអន្តរាគមន៍អមក្បែរគ្នា មុននឹងធ្វើការខ្វាស់ខ្វែង ត្រូវសរសេរប្រាប់សហភាតានោះឱ្យបានដឹងមុន ហើយសួរអំពីប្រាក់សោហ៊ុយ និងប្រាក់កំរៃដែលគេត្រូវបាន។ មេធាវីនោះ ត្រូវខំទារឱ្យបានសងដល់សហភាតា។

មេធាវី ដែលត្រូវគេឱ្យឈប់ធ្វើរឿងក្តីនោះ ត្រូវឆ្លើយតបយ៉ាងរហ័ស និងបញ្ជូនមកនូវអ្វីៗទាំងអស់របស់សំណុំរឿង ដែលខ្លួនគ្មានសិទ្ធិអ្វីនឹងឃាំងទុកតទៅទៀតឡើយ។

មេធាវីដែលបន្ត នឹងអាចទទួលយករឿងក្តីនោះឱ្យបានពេញដៃបាន តែក្រោយមានកំរៃឱ្យសហភាតា លើកលែងតែមានការយល់ព្រមពីសហភាតា ឬ មានការអនុញ្ញាតិពីប្រធានគណៈមេធាវី។

បើមានការឈ្លោះប្រកែកគ្នាពីរឿងកំរៃ ត្រូវប្ដឹងទៅប្រធានគណៈមេធាវី ហើយប្រធានគណៈមេធាវី អាចសុំយកប្រាក់កំរៃនោះតំកល់ទុកសិន។

មេធាវីដែលបន្ត ត្រូវជូនដំណឹងអំពីអន្តរាគមន៍របស់ខ្លួន ទៅទីប្រឹក្សានៃភាគីម្ខាងទៀត ឬជាយថាហេតុទៅយុត្តាធិការដែលទទួលបណ្ដឹង។

បើមេធាវីដែលគេមកពឹងពាក់ មិនទាន់ចង់ឆ្លើយព្រមទទួលរឿងក្ដីភ្លាម មេធាវីនោះត្រូវសរសេរទៅប្រាប់សហភាតា ដោយសុំឱ្យផ្ញើសំណុំរឿងមកពិនិត្យ។ មេធាវីនោះត្រូវតែឆ្លើយប្រាប់អំពីជំហរបស់គាត់ក្នុងកម្លុង១ខែ។ ផុតពីនេះ ត្រូវចាត់ទុកថាគាត់មិនបានយល់ព្រមទទួលឡើយ។

រហូតមកដល់ពេលមានប្រវេសន៍នៃការយល់ព្រមទទួលរបស់មេធាវីក្រោយ មេធាវីមុននៅតែពុំទាន់ផុតភារៈកិច្ចនៅឡើយ។ មេធាវីក្រោយមិនត្រូវទាន់ធ្វើការខ្នះខ្នែងអ្វីទេ ក្រៅអំពីពិនិត្យសំណុំរឿង និងការទទួល ឬទៅជួបអតិថិជនប៉ុណ្ណោះ។

ការបំពេញកិច្ចការអ្វីមួយជាផ្លូវវិជ្ជាជីវៈ មានន័យថាសុខចិត្តព្រមទទួលធ្វើ។

រាល់ការខ្វះមិនគោរពវិធានទាំងអស់នេះ អាចតម្រូវ តាមសេចក្ដីសំរេចរបស់ប្រធានគណៈមេធាវីឱ្យមេធាវីក្រោយ ចេញសងកំរៃទៅមេធាវីមុន។

## មាត្រា ២៩. មេធាវីដែលជជួលបេសកកម្ម

មេធាវីដែលទទួលធ្វើជា អ្នកឆ្លងឆ្លើយរបស់សហភាតាណាមួយ ត្រូវទទួលខុសត្រូវចំពោះសហភាតា និងចំពោះអតិថិជន អំពីការធ្វើឱ្យបានសំរេចផលល្អនៃបេសកកម្មរបស់ខ្លួន បើសិនជាខ្លួនបាន ទទួលឯកសារជាចាំបាច់ទាំងអស់នៃសំណុំរឿង។

មេធាវីនោះ អាចជួបផ្ទាល់ជាមួយអតិថិជនបាន លុះត្រាតែមានការយល់ព្រមអំពីមេធាវីដើមសំណុំរឿង ឬ លើកលែងតែមានការចាំបាច់។

មេធាវីបេសកជនធ្វើពាក្យសុំប្រាក់បំរុង និងប្រាក់កំរៃ តាមរយៈសហភាតារបស់ខ្លួន ដែលត្រូវសំរេចយល់ព្រមផង។

មេធាវីដែលប្រគល់បេសកកម្មឱ្យសហភាតាណាមួយ ត្រូវទទួលខុសត្រូវចំពោះសហភាតានេះ នូវការចេញសោហ៊ុយ បរិលាភ និងកំរៃនានាក្នុងលក្ខ័ណដែលមានសំអាងពិតប្រាកដ។

## មាត្រា ៣០. ភាគីដែលគ្មានមេធាវីជួយ

មុននឹងទៅដល់ការប្ដឹងប្ដល់គ្នា មេធាវី ដោយមានការសុខចិត្តពីអតិថិជនរបស់ខ្លួនផង អាចនឹងទាក់ទងជាមួយភាគីបដិបក្ស ដើម្បីរកការដោះស្រាយដោយសម្រុះសម្រួលគ្នា។

ក្នុងឱកាសនោះ មេធាវីមិនត្រូវនិយាយអ្វីឱ្យហួសពេក ឬមិនស្មោះត្រង់ដែលផ្ទុយអំពីភាពគួរសម និងភាពថ្លៃថ្នូរ។ ជាដាច់ខាត មេធាវីត្រូវសូមអញ្ជើញភាគីនោះឱ្យមកតាមរយៈទីប្រឹក្សារបស់គេ។ ទោះជាក្នុងករណីណាក៏ដោយ មេធាវីមិនអាចជួបភាគីបដិបក្ស ដោយគ្មានវត្តមានទីប្រឹក្សារបស់គេ។ បើប្រសិនជាភាគីបដិបក្ស មិនត្រូវការមានទីប្រឹក្សាជួយខ្លួនគេទេ មេធាវីអាចទទួលភាគីនោះ ជាមួយនឹងអតិថិជនផ្ទាល់របស់ខ្លួនបាន ឬក៏តែម្នាក់ឯង ដោយមានការសុខចិត្តពីអតិថិជននេះផង។

មុននឹងជជែកគ្នា មេធាវីត្រូវរំលឹកទៅភាគីបដិបក្ស អំពីសិទ្ធិរបស់គេដែលត្រូវមានទីប្រឹក្សាជួយ។

## មាត្រា ៣១. ភាគីដែលមានមេធាវីជួយ

មេធាវី នឹងអាចចូលទំនាក់ទំនងជាមួយនឹងមនុស្សដែលខ្លួនដឹងថាមានមេធាវីជួយហើយនោះ បានតែនៅចំពោះមុខមេធាវីនេះ ឬដោយមានការយល់ព្រមពីមេធាវីនេះ។

ក្រៅពីមានការព្រមព្រៀងគ្នាជាមុន រាល់ការជួបប្រជុំ ត្រូវធ្វើនៅចំពោះមុខភាគីសាមីទាំងអស់ និងមេធាវីរបស់គេ។

## មាត្រា ៣២. ការទៅចូលក្នុងប្រជុំ ឬក្នុងសន្និបាត

មេធាវីដែលបំរុងនឹងទៅចូលក្នុងប្រជុំ រឿងវិវាទ ឬមិនវិវាទ ត្រូវឱ្យដំណឹងមុនទៅអ្នកចូលរួមដ៏ទៃទៀត ដោយផ្ទាល់ខ្លួនតែម្តង ឬតាមរយៈអតិថិជនរបស់ខ្លួន។

## មាត្រា ៣៣. តតិយជន និងសាក្សី

ក្នុងក្របខ័ណ្ឌសាលាជំរះក្តីណាមួយ និងក្នុងករណីនិងលក្ខ័ណដែលមានចែងទុកក្នុងវិធាននីតិវិធី មេធាវីអាចចូលទំនាក់ទំនងជាមួយនឹងតតិយជន ដើម្បីសុំឱ្យប្តល់ដោយស្រុះស្រួលគ្នា នូវឯកសារដែលគេមានទុកនឹងខ្លួន។ បើសុំមិនបាន មេធាវីអាចសុំឱ្យចៅក្រមទាមទារ។

មេធាវី ត្រូវហាមឃាត់មិនឱ្យជួបសាក្សីណាមួយជាយថាហេតុ ហើយនិងមិនឱ្យប្រើឥទ្ធិពលតាមវិធីណាមួយក៏ដោយ លើសក្ខីកម្មរបស់គេ។

# ជំពូកទី៧
# ទំនាក់ទំនងជាមួយគណៈមេធាវី

## មាត្រា ៣៤. លក្ខណៈទូទៅ

មេធាវី ជាសមាជិកនៃគណៈមេធាវី។

គណៈមេធាវី មានសេវាជូនមេធាវី ជួយជ្រុំជ្រែងមេធាវី និងការពារមេធាវី។

គណៈមេធាវី តំណាងមេធាវី គ្រប់គ្រងកិច្ចការរួមនៃមន្ទីគណៈមេធាវី ជាពិសេស ការការពារក្តី និងការចូលទៅតុលាការ ។

ដោយអាកប្បកិរិយារបស់ខ្លួន មេធាវីម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះកេរ្តិ៍ឈ្មោះរបស់ គណៈមេធាវី ចំពោះឫទ្ធិអំណាចរបស់ប្រធានគណៈមេធាវី និងអំពីប្រសិទ្ធិផលនៃក្រុមប្រឹក្សា គណៈមេធាវី។

## មាត្រា ៣៥. បេសកកម្មប្រគល់ឱ្យ ដោយគណៈមេធាវី

មេធាវី ត្រូវទទួលរ៉ាប់រង ដោយវ៉ាសវៃ និងហ្មត់ចត់ នូវបេសកកម្មនិងសេវារួម ដែលបាន ប្រគល់ឱ្យដោយគណៈមេធាវី។

## មាត្រា ៣៦. ការលើកកិច្ចត្រូវឆ្លើយទៅប្រធានគណៈមេធាវី

មេធាវី ត្រូវឆ្លើយទៅនឹងការសុំទាំងឡាយ ឬអធិបញ្ញាទាំងឡាយនៃប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ដោយគ្មានបង្អែរបង្អង់។

## មាត្រា ៣៧. មេធាវីដែលត្រូវគេប្តឹង

មេធាវីដែលត្រូវគេប្តឹងអំពីកំហុស ឬអំពីបទព្រហ្មទណ្ឌ ដែលទាក់ទិននឹងការប្រកបវិជ្ជាជីវៈ ឬ ដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ត្រូវឱ្យដំណឹងភ្លាមទៅប្រធានគណៈមេធាវី។

## មាត្រា ៣៨. ការបង់ភាគទាន

ការបង់ភាគទានទៅគណៈមេធាវី ត្រូវទារឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំ។ ភាគទាន ត្រូវតែបង់ឱ្យទាន់ពេលវេលាដែលបានកំណត់។

* * * *

ក្រមសីលធម៌នេះ ត្រូវបានក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុម័ត នៅថ្ងៃទី១៥ វិច្ឆិកា ១៩៩៥ នាសម័យប្រជុំក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី១៥ វិច្ឆិកា ១៩៩៥ ក្រោមអធិបតីភាពលោកបណ្ឌិត ***សាយ បូរី*** ប្រធានគណៈមេធាវី ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ វិច្ឆិកា ១៩៩៥

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

បណ្ឌិត សាយ បូរី

# ប្រការមួយចំនួន
# នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០១៦
# ដែលត្រូវបានកែសម្រួល

## ប្រការ១៣. ដំណើរការនៃការបោះឆ្នោត

ការបោះឆ្នោតនឹងអាចប្រព្រឹត្តទៅបានលុះត្រាតែវត្តមានមេធាវីពេញសិទ្ធិចំនួនលើសពីពាក់កណ្ដាល។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលត្រូវបានសម្រេចជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមួយត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមានតួនាទីរៀបចំដំណើរការបោះឆ្នោតប្រធាន និងបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

សមាជិកគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី ក្នុងចំណោមមេធាវីពេញសិទ្ធិ និងមេធាវីកម្មសិក្សា ដែលស្ម័គ្រចិត្តដាក់ពាក្យសុំចូលរួមជួយបំពេញកិច្ចការនេះ។

គណៈកម្មការបោះឆ្នោតជាគណៈកម្មការចំពោះកិច្ច ដែលត្រូវចប់ភារកិច្ច និងរំលាយដោយស្វ័យប្រវត្តិក្រោយពីការរាប់សន្លឹកឆ្នោតនិងប្រកាសលទ្ធផលនៃការបោះឆ្នោតចប់សព្វគ្រប់។

ប្រធានគណៈមេធាវី ឬតំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត មេធាវីមានសិទ្ធិបោះឆ្នោតត្រូវពាក់អាវរ៉ូបមេធាវី និងបង្ហាញបណ្ណសម្គាល់មេធាវី ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

ការបោះឆ្នោតលើកទី ១ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) (រាប់ទាំងសំឡេងផ្ទេរសិទ្ធិ) នៃមេធាវីពេញសិទ្ធិទាំងអស់។ ការបោះឆ្នោតលើកទី ១ នេះ ការប្រគល់សិទ្ធិ អាចទទួលយកបាន។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

ការបោះឆ្នោតលើកទី ២ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើននៃមេធាវីពេញសិទ្ធិដែលមានវត្តមានក្នុងពេលបោះឆ្នោត។ ក្នុងករណីនេះ សម្លេងផ្ទេរសិទ្ធិ និងមេធាវីដែលបានផ្ទេរសិទ្ធិឱ្យគេបោះឆ្នោតនៅការបោះឆ្នោតលើកទី ១ មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតទេ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាសសលាត ឬមោឃៈត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកសម្លេងភាគច្រើនឡើយ។

## ប្រការ១៤. ការរាប់សន្លឹកឆ្នោត

បន្ទាប់ពីការបោះឆ្នោតចប់ភ្លាម គណៈកម្មការបោះឆ្នោតត្រូវរៀបចំការរាប់សន្លឹកឆ្នោត។ ការរាប់សន្លឹកឆ្នោត ត្រូវរាប់តាមការិយាល័យនីមួយៗនៃការបោះឆ្នោតនៅចំពោះមុខសមាជិក-សមាជិកាគណៈមេធាវី ដែលចូលរួមនៅក្នុងមហាសន្និបាត។

បែបបទ និងវិធីនៃការរាប់សន្លឹកឆ្នោត ត្រូវសម្រេចកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី។

## ប្រការ១៥. លទ្ធផលនៃការបោះឆ្នោត

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោតភ្លាម។ លទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់។

ដើម្បីបំពេញបន្ថែមលើបទបញ្ញាផ្ទៃក្នុងនេះ រាល់ពេលបោះឆ្នោតម្តងៗ ក្រុមប្រឹក្សាគណៈមេធាវីអាចកំណត់នូវបទបញ្ញានិងនីតិវិធីនៃការបោះឆ្នោតមួយដោយឡែកបន្ថែមទៀត។

## ប្រការ១៦. ការកោះប្រជុំ និងរបៀបវារៈ

ក្រុមប្រឹក្សាគណៈមេធាវីរួមប្រជុំតាមការផ្តួចផ្តើមគំនិតរបស់ប្រធានគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ។ សមាជិកក្រុមប្រឹក្សាគណៈមេធាវីចំនួន ១/៣ (មួយភាគបី) អាចស្នើសុំមកប្រធានគណៈមេធាវីដើម្បីពិនិត្យ និងសម្រេចកោះប្រជុំ។

លើកលែងតែមានកិច្ចការប្រញាប់ ប្រធានគណៈមេធាវីត្រូវកោះអញ្ជើញសមាជិកក្រុមប្រឹក្សាគណៈមេធាវីឱ្យបានយ៉ាងតិច ០៣ (បី) ថ្ងៃមុនថ្ងៃកំណត់ប្រជុំ ដោយភ្ជាប់ជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ តាមគ្រប់មធ្យោបាយសមស្រប។

## ប្រការ១៧. ការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី

កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវីត្រូវដឹកនាំដោយប្រធានគណៈមេធាវី។ ប្រធានគណៈមេធាវីត្រូវចូលរួមពិភាក្សា និងបោះឆ្នោតសម្រេចជាមួយសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ សម្លេងរបស់ប្រធានគណៈមេធាវី ពុំមានឧត្តមានុភាពឡើយ។

## ប្រការ២០. វិន័យការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី

សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវចូលរួមកិច្ចប្រជុំឱ្យបានទៀងទាត់និងទាន់ពេលវេលា។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវជូនដំណឹងអំពីអវត្តមានរបស់ខ្លួនមកប្រធានគណៈមេធាវី ក្នុងរយៈពេលសមស្រប តាមគ្រប់មធ្យោបាយសមស្រប។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីដែលមានធុរៈអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនសមាជិកណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនក្នុងការបោះឆ្នោតសម្រេចលើបញ្ហានានានៅក្នុងកិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាគណៈមេធាវីម្នាក់អាចទទួលការផ្ទេរសិទ្ធិបានតែមួយប៉ុណ្ណោះ។

## ប្រការ២៨. ការរៀបចំកម្មសិក្សា

កម្មសិក្សាមានថិរវេលា១(មួយ)ឆ្នាំហើយអាចពន្យារពេលបាន១(មួយ)ឆ្នាំទៀត តាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

កម្មសិក្សាត្រូវរួមបញ្ចូលទាំងសកម្មភាពបណ្តុះបណ្តាលបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវីនិងការសហការពិតប្រាកដក្នុងការិយាល័យរបស់មេធាវីណាមួយផង។

កម្មសិក្សាការី អាចធ្វើផ្នែកខ្លះនៅក្នុងការិយាល័យមេធាវីនៅឯបរទេសនៃប្រទេសណាមួយក៏បាន។

## ប្រការ ៣២. ការព្យួរ និងការលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា

ការព្យួរកម្មសិក្សាត្រូវសម្រេចអនុញ្ញាតពីប្រធានគណៈមេធាវី។

ក្នុងករណីដែលការព្យួរកម្មសិក្សាត្រូវបានពន្យារជាថ្មី ប្រធានគណៈមេធាវី អាចកោះអញ្ជើញមេធាវីទៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី ដើម្បីលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា។

ការលុបឈ្មោះចេញ ក៏អាចសម្រេចបានដែរ ចំពោះមេធាវីដែលមិនគោរពកិច្ចសន្យាកម្មសិក្សា ហើយដែលមិនអាចបញ្ជាក់បានត្រឹមត្រូវនូវកិច្ចសន្យាសហការពិតប្រាកដ។

## ប្រការ ៣៧. ការបញ្ចប់កម្មសិក្សា

នៅពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការីត្រូវធ្វើរបាយការណ៍ពីកម្មសិក្សារបស់ខ្លួន ដោយមានមូលវិចារពីគ្រូកម្មសិក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេចចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ។

កម្មសិក្សាការីត្រូវដាក់របាយការណ៍បញ្ចប់កម្មសិក្សាមកគណៈមេធាវី ក្នុងរយៈពេល៣ (បី)ខែ គិតចាប់ពីថ្ងៃបញ្ចប់រយៈពេលកម្មសិក្សា។ ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចដាក់ទណ្ឌកម្មវិន័យ។

ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចឱ្យធ្វើកម្មសិក្សាបន្តទៀត តែមិនឱ្យលើសពី១(មួយ) ឆ្នាំឡើយ ចំពោះកម្មសិក្សាការីណា ដែលមិនមានសមត្ថភាពគ្រប់គ្រាន់។ ការសម្រេចមិនចុះឈ្មោះក្នុងបញ្ជីមេធាវីពេញសិទ្ធិ ចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល។

## ប្រការ ៣៨. ការតព្វកិច្ចគណនេយ្យ

មេធាវីត្រូវកាន់គណនេយ្យនៃកិច្ចប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន ដោយញែកឱ្យបានច្បាស់រវាងកិច្ចប្រតិបត្តិទាក់ទងនឹងការគ្រប់គ្រងការិយាល័យរបស់ខ្លួន និងកិច្ចប្រតិបត្តិធ្វើឡើងសម្រាប់ផលប្រយោជន៍អតិថិជន។

គណនេយ្យនៃកិច្ចប្រតិបត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការិយាល័យមេធាវី ត្រូវធ្វើឡើងឱ្យសមស្របនឹងវិធានច្បាប់ ឬបើគ្មានវិធាននោះទេ ក៏ត្រូវធ្វើតាមបែបបទចំណូល/ចំណាយដែរ។

កិច្ចប្រតិបត្តិការដែលទាក់ទងនឹងការបង់ប្រាក់ប្រដាប់ក្តី ប្រាក់ពន្ធអាករ និងប្រាក់ចេញជួសឱ្យមុន ដែលធ្វើឡើងក្នុងផលប្រយោជន៍អតិថិជន ត្រូវកត់ចូលក្នុងគណនេយ្យមួយដោយឡែក។

# សេចក្តីសម្រេចលេខ
# ៣៩៣/សសកម/២០
# ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០
# ស្តីពីការកែសម្រួលប្រការ១៣
# នៃបទបញ្ញាផ្ទៃក្នុងនៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៣៩៣/សសគម/២០

ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលប្រការ១៣ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី *សួន វិសាល* ជាប្រធានគណៈមេធាវីអាណត្តិទី ១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៩

-យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០

## សម្រេច

**ប្រការមួយ.** ប្រការ ១៣ នៃបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចខាងក្រោម៖

**ប្រការ១៣ថ្មី. ដំណើរការនៃការបោះឆ្នោត**

ការបោះឆ្នោតនឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែវត្តមានមេធាវីពេញសិទ្ធិចំនួនលើសពីពាក់កណ្តាល។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលត្រូវបានសម្រេចជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមួយត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមានតួនាទីរៀបចំដំណើរការបោះឆ្នោតប្រធាន និងបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

សមាជិកគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី ក្នុងចំណោមមេធាវីពេញសិទ្ធិ មេធាវីកម្មសិក្សា សិស្សមេធាវី និងបុគ្គលិកគណៈមេធាវី ដែលស្ម័គ្រចិត្តដាក់ពាក្យសុំចូលរួមជួយបំពេញកិច្ចការនេះ។

គណៈកម្មការបោះឆ្នោតជាគណៈកម្មការចំពោះកិច្ច ដែលត្រូវចប់ភារកិច្ច និងរំលាយដោយស្វ័យប្រវត្តិក្រោយពីការរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោតចប់សព្វគ្រប់។

ប្រធានគណៈមេធាវី ឬតំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត មេធាវីដែលមានសិទ្ធិបោះឆ្នោតត្រូវពាក់អាវវិជ្ជាជីវៈមេធាវី ឬអាវសម្រាប់ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី និងបង្ហាញបណ្ណសម្គាល់មេធាវី ឬលិខិតបញ្ជាក់ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

ការបោះឆ្នោតលើកទី ១ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) (រាប់ទាំងសំឡេងផ្ទេរសិទ្ធិ) នៃមេធាវីពេញសិទ្ធិទាំងអស់។ ការបោះឆ្នោតលើកទី ១ នេះ ការ

ប្រគល់សិទ្ធិ អាចទទួលយកបាន។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

ការបោះឆ្នោតលើកទី ២ ប្រព្រឹត្តទៅដោយយកតាមសំឡេងភាគច្រើននៃមេធាវីពេញសិទ្ធិដែលវត្តមានក្នុងពេលបោះឆ្នោត។ ក្នុងករណីនេះ សម្លេងផ្ទេរសិទ្ធិ និងមេធាវីដែលបានផ្ទេរសិទ្ធិឱ្យគេបោះឆ្នោតនៅការបោះឆ្នោតលើកទី ១ មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតទេ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាសសលាត ឬមោឃៈត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកសម្លេងភាគច្រើនឡើយ។

**ប្រការពីរ.** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.** សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខារបស់ប្រធានគណៈមេធាវី។

ប្រធាន

**ចម្លងជូន៖**
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
-ក្រុមប្រឹក្សាគណៈមេធាវី
«ដើម្បីជ្រាប»
-ឯកសារ-កាលប្បវត្តិ

# ក្រុមការងាររៀបចំចងក្រង
# «កម្រងវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា»

| | | |
|---|---|---|
| ១. ឯកឧត្តម | លី ច័ន្ទតុលា | ប្រធានគណៈមេធាវី |
| ២. ឯកឧត្តម | លីវ សុវណ្ណា | អគ្គលេខាធិការគណៈមេធាវី |
| ៣. លោកមេធាវី | សួង សុផល | សមាជិកក្រុមប្រឹក្សាគណៈមេធាវី |
| ៤. លោកស្រីមេធាវី | ទេព ប៊ូផល | ប្រធាននាយកដ្ឋានស្រាវជ្រាវបោះពុម្ពនិងផ្សព្វផ្សាយ |
| ៥. លោកមេធាវី | ឡៀង វុទ្ធា | អនុប្រធាននាយកដ្ឋានស្រាវជ្រាវបោះពុម្ពនិងផ្សព្វផ្សាយ |
| ៦. កញ្ញាមេធាវី | ឈុំ មុនីសុជាតា | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ |
| ៧. លោក | លី ពន្លឺ | ប្រធានការិ.ព្រឹត្តិបត្រនិងបោះពុម្ពនៃនាយកដ្ឋាន ស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ |
| ៨. លោក | ហ្លួត គីមឡាក់ | បុគ្គលិកនាយកដ្ឋានស្រាវជ្រាវបោះពុម្ពនិងផ្សព្វផ្សាយ |
| ៩. កញ្ញា | ញ៉ លឹមហ័ង | បុគ្គលិកនាយកដ្ឋានស្រាវជ្រាវបោះពុម្ពនិងផ្សព្វផ្សាយ |

នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ
បោះពុម្ពលើកទី១ (ឆ្នាំ២០២៣)

រក្សាសិទ្ធិ © ខែកញ្ញា ឆ្នាំ២០២៣
គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា